01588290

លេខ៖ D360

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

| | |
|---|---|
| ចំពោះមុខ ៖ | **សហចៅក្រមស៊ើបអង្កេត** |
| កាលបរិច្ឆេទ ៖ | **ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨** |
| ភាសា ៖ | **អង់គ្លេស [ភាសាដើម]** |
| ចំណាត់ថ្នាក់ឯកសារ ៖ | **សាធារណៈ** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 26-Oct-2018, 13:13
CMS/CFO: Ly Bunloung

## ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីនៃ
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

## មាតិកា

១. ប្រវត្តិនីតិវិធី....................7

២. ផលប៉ះពាល់ដោយសារសេចក្តីពិចារណារបស់ អ.ប.ផ លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០៤/១ .................... 15

២.១. ការពន្យារពេលហួសហេតុ .................... 16

២.២. គោលជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា .................... 25

២.៣. ការពិចារណាលើភ័ស្តុតាង .................... 26

២.៤. សេចក្តីសន្និដ្ឋាន .................... 38

៣. ការជំទាស់នីតិវិធីជាទូទៅពីមេធាវីការពារក្តី.................... 38

៣.១. ដីកាសន្និដ្ឋានលើកទី ៣ មានកំហុសឆ្គង ហើយកិច្ចស៊ើបសួរទាំងមូលត្រូវទុកជាមោឃៈ .................... 40

៣.២. ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ មានកំហុសឆ្គង។ ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នាមិនត្រូវបានអនុញ្ញាតទេ .................... 43

៣.៣. ស.ច.ស មិនអាចការពារភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីបានឡើយ បន្ទាប់ពីចេញដីកាដំណោះស្រាយ.................... 43

៣.៤. ស.ព.អ កំពុងស្វះស្វែងឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះអង្គហេតុដែល មិនបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ .................... 45

៣.៥. ស.ច.ស មិនគួរធ្វើតាមការបកស្រាយរបស់ អ.ជ.ត.ក អំពីយុត្តាធិការបុគ្គលឡើយ .................... 45

៤. ច្បាប់ជាធរមាន .................... 45

៤.១. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក.................... 45

៤.២. ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក .................... 49

៤.២.១. ឧក្រិដ្ឋកម្មជាតិ (ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦).................... 49

៤.២.២. ឧក្រិដ្ឋកម្មអន្តរជាតិ .................... 52

៤.៣. ទម្រង់នៃការទទួលខុសត្រូវ.................... 87

៤.៣.១. ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ .................... 87

៤.៣.២. ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ (ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦).................... 100

៥. ការពិចារណាអំពីភ័ស្តុតាង .................... 101

៥.១. ចម្លើយដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ច.ស .................... 101

៥.២. ភស្តុតាងពាក្យចចាមអារ៉ាម និងការពឹងផ្អែកលើភស្តុតាងដែលមិនមានការបញ្ជាក់ ................ 105
៥.៣. ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ................................................ 107
៥.៤. របាយការណ៍រៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ........................................ 109
៥.៥. ចំនួនជនរងគ្រោះ ........................................................................ 111
៥.៦. បញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស ................................................ 115
៥.៧. លិខិតធានា ............................................................................ 115
៦. ការវិភាគអង្គហេតុ និងការរកឃើញ.......................................................... 116
៦.១. រចនាសម្ព័ន្ធរដ្ឋបាល ...................................................................... 116
៦.១.១. ថ្នាក់ជាតិ ............................................................................ 116
៦.១.២. ភូមិភាគកណ្ដាល........................................................................ 121
៦.១.៣. តំបន់ ៤១............................................................................ 125
៦.១.៤. ស្រុកនៅតំបន់ ៤១...................................................................... 128
៦.១.៥. អំណាចតាមផ្លូវច្បាប់របស់ភូមិភាគ និងតំបន់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ............... 130
៦.២. ការរកឃើញខាងអង្គហេតុ និងសហឧក្រិដ្ឋកម្មរួម ................................................ 143
៦.២.១. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន........................................... 143
៦.២.២. ការកសាង “សមាសភាពមិនល្អ” និងការសម្លាប់ “ខ្មាំង” ទាំងក្នុង និងក្រៅជួរ ប.ក.ក ....... 155
៦.២.២.១. គោលនយោបាយ ប.ក.ក ក្នុងការបោសសម្អាតខ្មាំង បង្កើតមន្ទីរសន្តិសុខ និង ទីតាំងសម្លាប់មនុស្ស ............................................................... 155
៦.២.២.២. ការអនុវត្តគោលនយោបាយបោសសម្អាតនៅភូមិភាគកណ្ដាល ក្រោយការ មកដល់របស់កម្មាភិបាលភូមិភាគនិរតី................................................. 164
៦.២.៣. ការកំណត់គោលដៅលើក្រុមជាក់លាក់ រួមមានកម្មាភិបាល ប.ក.ក នៅភូមិភាគកណ្ដាល អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ “ប្រជាជន ១៧ មេសា” ប្រជាជនមកពីភូមិភាគបូព៌ា ជនជាតិចាម និងគ្រួសារ......................................................................... 169
៦.២.៣.១. សេចក្ដីណែនាំឱ្យបញ្ឈប់ការបោសសម្អាត.................................................. 172
៦.២.៤. ការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍.................................................... 175
៦.៣. ការរកឃើញខាងអង្គហេតុ និងតួនាទីរបស់ អោ អាន ............................................ 193
៦.៣.១. តួនាទីរបស់ អោ អាន មុនខែ មេសា ឆ្នាំ ១៩៧៥ និងក្រោយថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩. 193
៦.៣.១.១. ប្រវត្តិផ្ទាល់ខ្លួន........................................................................ 193

01588293



៦.៣.១.២. សកម្មភាពនយោបាយ ........................................ 195
៦.៣.២. តួនាទី និងសិទ្ធិអំណាចរបស់ អោ អាន នៅភូមិភាគនិរតី ........................................ 197
៦.៣.៣. តួនាទី និងសិទ្ធិអំណាចរបស់ អោ អាន នៅភូមិភាគកណ្ដាល ........................................ 199
៦.៣.៣.១. ការផ្ទេរ អោ អាន ទៅភូមិភាគកណ្ដាល ........................................ 199
៦.៣.៣.២. លេខាតំបន់ ៤១........................................ 203
៦.៣.៣.៣. អនុលេខាភូមិភាគកណ្ដាល និងសមាជិកគណៈភូមិភាគ ........................................ 206
៦.៣.៣.៤. ការទទួលខុសត្រូវ សិទ្ធិអំណាច និងប្រភពនៃការដឹងរបស់ អោ អាន នៅភូមិភាគកណ្ដាល ........................................ 213
៦.៣.៤. ការប្រព្រឹត្តិរបស់ អោ អាន នៅភូមិភាគកណ្ដាល និងការចូលរួមចំណែកក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម........................................ 221
៦.៣.៤.១. ការបង្កើត និងប្រតិបត្តិការការដ្ឋាន និងសហករណ៍ ........................................ 221
៦.៣.៤.២. ការកសាងសមាសភាពមិនល្អ និងការសម្លាប់ "ខ្មាំង"........................................ 242
៦.៣.៤.៣. ការកំណត់គោលដៅលើក្រុមជាក់លាក់ ........................................ 252
៦.៣.៤.៤. ការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍ ........................................ 274
៦.៤. ការរកឃើញខាងអង្គហេតុលើឧក្រិដ្ឋកម្ម........................................ 280
៦.៤.១. ការដ្ឋាន មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស........................................ 280
៦.៤.១.១. ការដ្ឋានពលកម្មដោយបង្ខំសាងសង់ទំនប់អន្លង់ជ្រៃ ........................................ 280
៦.៤.១.២. ទីតាំងសម្លាប់មនុស្សគោកព្រីង........................................ 310
៦.៤.១.៣. មន្ទីរសន្តិសុខមិត្តសុប ........................................ 339
៦.៤.១.៤ ទួលបេង និងមន្ទីរសន្តិសុខវត្តអង្គញ្ញី ........................................ 363
៦.៤.១.៥ មន្ទីរសន្តិសុខវត្តអូរត្រកួន ........................................ 399
៦.៤.១.៦ មន្ទីរសន្តិសុខវត្តបាធាយ ........................................ 438
៦.៤.១.៧ ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស ........................................ 471
៦.៤.១.៨ មន្ទីរសន្តិសុខវត្តតាមាក់........................................ 486
៦.៤.២. បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើប្រជាជនចាមនៅកំពង់ចាម ........................................ 513
៦.៤.២.១. សេចក្ដីផ្ដើម ........................................ 513
៦.៤.២.២ គោលនយោបាយរបស់ ប.ក.ក. ចំពោះប្រជាជនចាម ........................................ 518
៦.៤.២.៣. ការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួនប្រជាជនចាមនៅក្នុងភូមិភាគកណ្ដាល ........ 546

៦.៤.២.៤. តួនាទីរបស់ អោ អាន នៅក្នុងប្រតិបត្តិការបំបាត់ជនជាតិចាម .......... 570

៦.៤.២.៥. ការសម្លាប់ជនជាតិចាមនៅតំបន់ ៤១ .......... 575

៦.៤.២.៦. ការសម្លាប់ជនជាតិចាមនៅតំបន់ ៤២ .......... 591

៦.៤.២.៧. ការសម្លាប់ជនជាតិចាមនៅតំបន់ ៤៣ .......... 605

៦.៤.៣. ការរៀបការដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ .......... 607

៧. សំអាងហេតុអង្គច្បាប់អំពីយុត្តាធិការបុគ្គល .......... 630

៧.១. តួនាទីរបស់ អោ អាន នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ .......... 631

៧.២. លក្ខណៈ និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានកើតឡើង .......... 633

៧.៣. សេចក្តីសន្និដ្ឋាន .......... 634

៨. ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីបទឧក្រិដ្ឋ .......... 635

៨.១. ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ .......... 635

៨.២. ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីបទឧក្រិដ្ឋនៅក្នុងតំបន់៤១ .......... 637

៨.២.១. ការដ្ឋានពលកម្មដោយបង្ខំ ទំនប់អន្លង់ជ្រៃ .......... 637

៨.២.២. ទីកន្លែងសម្លាប់មនុស្សគោកព្រីង .......... 639

៨.២.៣. មន្ទីរសន្តិសុខមិត្តសុប .......... 640

៨.២.៤. មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញ្ជី .......... 643

៨.២.៥. មន្ទីរសន្តិសុខវត្តអូរត្រកួន .......... 647

៨.២.៦. មន្ទីរសន្តិសុខវត្តបាធាយ .......... 651

៨.២.៧. ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស .......... 655

៨.២.៨. មន្ទីរសន្តិសុខវត្តតាមាក់ .......... 656

៨.៣. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាម .......... 659

៨.៤. ការសំអាងអង្គច្បាប់ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ .......... 662

៩. ការសំអាងផ្នែកអង្គច្បាប់ពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវ .......... 663

៩.១. ឧក្រិដ្ឋកម្មអន្តរជាតិ .......... 663

៩.១.១. ការប្រព្រឹត្តក្នុងឋានៈជាជនដៃដល់ផ្ទាល់ .......... 663

៩.១.២. ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម .......... 663

៩.១.៣. ការរៀបចំផែនការ .......... 668

៩.១.៤. ការបញ្ជា .......... 671

៩.១.៥. ការញុះញង់ ..... 673
៩.១.៦. ការទទួលខុសត្រូវរបស់ថ្នាក់លើ ..... 675
៩.២. ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ ..... 678
៩.២.១. ការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្ម ..... 678
៩.២.២. ការរៀបចំផែនការ និងការបញ្ជា ..... 678
១០. ការបង្ខិតបង្ខំ ..... 678
១១. សេចក្តីសម្រេចលើការឃុំខ្លួន មុនសវនាការ ..... 679
១២. ដីកាបញ្ចប់ការស៊ើបសួរយោងវិធាន *៦៦ស្ទួន* ..... 680
១៣. ដីកាលើកលែងចោទចំពោះការចោទប្រកាន់មួយចំនួន ..... 680
១៤. ដីកាចោទប្រកាន់ ..... 681

**ឧបសម្ព័ន្ធ ១៖ កាលប្បវត្តិនៃគម្រោងបញ្ចប់ផែនការ**
**ឧបសម្ព័ន្ធ ២៖ សារណា និងសំណើដែលបានដាក់ដោយសហចៅក្រមស៊ើបអង្កេត**
**ឧបសម្ព័ន្ធ ៣៖ សាក្សីនៃការរៀបការដោយបង្ខំតាមខេត្ត**
**ឧបសម្ព័ន្ធ ៤៖ ជនរងគ្រោះចាម**

01588296



## អក្សរកាត់

| ពាក្យ | អក្សរកាត់ |
|---|---|
| កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ | កិច្ចព្រមព្រៀង អ.វ.ត.ក |
| ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | ច្បាប់ អ.វ.ត.ក |
| ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា | ក្រមព្រហ្មទណ្ឌ |
| អង្គជំនុំជម្រះតុលាការកំពូល | អ.ជ.ត.ក |
| អង្គបុរេជំនុំជម្រះ | អ.ប.ជ |
| ការិយាល័យសហចៅក្រមស៊ើបអង្កេត | ក.ស.ច.ស |
| សហចៅក្រមស៊ើបអង្កេត | ស.ច.ស |
| សហចៅក្រមស៊ើបអង្កេតអន្តរជាតិ | ស.ច.ស អន្តរជាតិ |
| ការិយាល័យសហព្រះរាជអាជ្ញា | ក.ស.ព |
| សហព្រះរាជអាជ្ញាអន្តរជាតិ | ស.ព.អ |
| សហព្រះរាជអាជ្ញាជាតិ | ស.ព.ជ |
| បក្សកុម្មុយនីស្តកម្ពុជា | ប.ក.ក |
| តុលាការព្រហ្មទណ្ឌអន្តរជាតិ | តុលាការ ICC |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី | តុលាការ ICTY |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា | តុលាការ ICTR |
| តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន | តុលាការ SCSL |
| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | អ.វ.ត.ក |

| | |
|---|---|
| អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប | អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម |

## ១. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ និងថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៨។

២. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានចេញ*ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ("ដីកាសន្និដ្ឋាន") ដែលក្នុងដីកានេះ ស.ព.អ បានធ្វើការចោទប្រកាន់ផ្សេងៗ ដូចជា **អោ អាន** ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិមួយចំនួន ដែលបានប្រព្រឹត្តស្ថិត នៅក្រោមយុត្តាធិការពេលវេលា និងដែនដីរបស់ អ.វ.ត.ក[1]។ ដោយសារមានករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ទើប ស.ព.អ ស្តីទីបញ្ជូនដីកាសន្និដ្ឋានទៅ ស.ច.ស នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩[2]។

៣. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥ និងថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបន្ថែម ដោយស្នើសុំ ស.ច.ស ទទួលពិនិត្យការចោទប្រកាន់ថ្មីៗមកលើ **អោន អាន** យោងតាមវិធានផ្ទៃក្នុង ៥៥(៣)[3]។

---

[1] ឯកសារ **D1** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។

[2] ឯកសារ **D1/1** *សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣* ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩។

[3] ឯកសារ **D65** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១។ ឯកសារ **D191** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ* ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៤។ ឯកសារ **D237/1** *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឯកសារ D237* ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៥។ ឯកសារ **D254/1** *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមាក់* ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥។ ឯកសារ **D272/1** *ចម្លើយតបទៅនឹង*

៤. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ អតីត ស.ចៅ.ស.អន្តរជាតិ Harmon បានដាក់ **អោ អាន** ឱ្យស្ថិតក្រោមការពិនិត្យពីបទរំលោភលើមាត្រា ៥០១ និង៥០៦ (មនុស្សឃាតគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4]។ នៅពេលនោះ **អោ អាន** បានបញ្ជាក់ថា គាត់នឹងមិនឆ្លើយសំណួរពី ស.ចៅ.ស អន្តរជាតិឡើយ[5]។ នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ យើង Michael Bohlander បានដាក់ **អោ អាន** ឱ្យស្ថិតក្រោមការពិនិត្យពីបទល្មើសបន្ថែមទៀត រួមមាន ការរំលោភលើមាត្រា ៥០១ និង៥០៦ (មនុស្សឃាត) នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ការរំលោភលើអនុសញ្ញាស្ដីពីការបង្ការ និងផ្ដន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ និងបទល្មើសបន្ថែមទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[6]។ កំណត់ហេតុទាំងស្រុងអំពីបទចោទមាននៅក្នុង*កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀតរបស់ អោ អាន* ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦[7]។ **អោ អាន** បានលះបង់សិទ្ធិមិនចូលរួមការបង្ហាញខ្លួនម្ដងទៀត ហើយសហមេធាវីរបស់គាត់បានសម្រេចមិនធ្វើសេចក្ដីសន្និដ្ឋាន ឬសេចក្ដីអង្កេត តាងនាមឱ្យគាត់នៅពេលនោះទេ[8]។

៥. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ យើង Michael Bohlander បានចេញដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុដែលបានចោទប្រកាន់ដូចខាងក្រោម យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ("ដីកាសម្រេចយោងតាមវិធាន ៦៦*ស្ទួន*")[9]។

ក. ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់៤២ និង៤៣៖

i. មន្ទីរសន្តិសុខទួលតាផ្គុង[10]

---

*ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធ នឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥។

[4] ឯកសារ **D242** *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន* ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥។

[5] ឯកសារ **D242** *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន* ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ទំព័រ ៩។

[6] ឯកសារ **D303** *កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦។

[7] ឯកសារ **D303** *កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ទំព័រ ៤-១៤។

[8] ឯកសារ **D303** *កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ទំព័រ ២។

[9] ឯកសារ **D337** *ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៦។

ii. មន្ទីរសន្តិសុខវត្តកណ្តាល[11]

iii. មន្ទីរសន្តិសុខចម្ការស្វាយចន្ទី[12]

iv. មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក[13]

v. មន្ទីរសន្តិសុខវត្តស្រង៉ែ[14]

ខ) ការចាប់ខ្លួន និងការសម្លាប់ជនជាតិចាមនៅភូមិភាគបូព៌ា[15]

គ) ការធ្វើទារុណកម្មនៅទួលបេង/វត្តអង្គញ្ញដី[16]

ឃ) ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញនៅវត្តភ្នំប្រុស[17]។

(អង្គហេតុទាំងនេះ ហៅកាត់រួមថា "អង្គហេតុដែលបានដកចេញ")។

---

[10] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥០-៥១។

[11] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥២។

[12] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៣៩។

[13] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៣។

[14] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៤៩។

[15] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៤៥-៤៦។

[16] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៣០-៣៣។ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ* ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១១។ ឯកសារ D237/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឯកសារ D237* ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ កថាខណ្ឌ ១-២។

[17] ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៣០-៣១។

៦. អង្គហេតុដែលបានដកចេញ គឺជាមូលដ្ឋាននៃបទចោទមួយចំនួនលើ **អោ អាន** ពោលគឺ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការធ្វើមនុស្សឃាតគិតទុកជាមុនដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខចម្ការស្វាយចន្ទី[18] មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក[19] និងមន្ទីរសន្តិសុខវត្តស្រងែ[20]។

៧. សំអាងហេតុសម្រាប់កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ មានបង្ហាញនៅក្នុង*សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* និង*សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន(២)*[21]។ កិច្ចស៊ើបសួរលើអង្គហេតុដែលបានដកចេញ ត្រូវតែដាក់ឱ្យផុតរលត់ជាផ្លូវការយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*(៥) ហើយយើង Michael Bohlander នឹងចេញដីកាបង្គាប់បែបនោះ។

៨. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ស.ច.ស ទាំងពីរ បានជូនដំណឹងភាគីទាំងអស់អំពីការបិទកិច្ចស៊ើបសួរលើ **អោ អាន** យោងតាមវិធានផ្ទៃក្នុង ៦៦(១) ហើយបានជូនដំណឹងភាគីទាំងអស់ថា ភាគីអាចស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមក្នុងរយៈពេល ១៥ ថ្ងៃ[22] ព្រមទាំងបានបង្គាប់ឱ្យបំបែកសំណុំរឿង **អោ អាន** ចេញពីសំណុំរឿង ០០៤[23]។ នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦ យើង Michael Bohlander បានពន្យារពេលឱ្យភាគីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម រហូតដល់ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧[24]។

៩. យោងតាមសេចក្តីណែនាំនេះ ភាគីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរមួយចំនួន។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ក្រោយពី ចៅក្រម Michael Bohlander បានចេញដីកាសម្រេច

---

[18] ឯកសារ **D303** *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ទំព័រ ១១។

[19] ឯកសារ **D303** *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ទំព័រ ១៥។

[20] ឯកសារ **D303** *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ទំព័រ ១១។

[21] ឯកសារ **D307/3** *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦។ ឯកសារ **D307/4** *សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន(២)* ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦។

[22] ឯកសារ **D334** *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

[23] ឯកសារ **D334/1** *ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

[24] ឯកសារ **D340/1** *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំពន្យាររយៈពេលកំណត់ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមក្រោយពីមានការជូនដំណឹងអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។

នានាលើសំណើសុំបំពេញកិច្ចស៊ើបសួរទាំងនោះរួចមក ស.ច.ស បានចេញ*សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង **អោ អាន*** ហើយបានជូនដំណឹងភាគីទាំងអស់ថា ច្បាប់មិនតម្រូវឱ្យផ្ដល់ពេលវេលាថែមទៀត ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតទេ[25]។

១០. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ ស.ច.ស បានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា ដើម្បីឱ្យចេញដីកាសន្និដ្ឋានស្ថាពរ[26]។

---

[25] ឯកសារ D334/2 *សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧។ អ.ប.ជ មិនបានទទួលពិនិត្យបញ្ហានេះជាផ្លូវការទេនៅពេលនោះ ប៉ុន្តែចាប់តាំងពីពេលនោះមក នៅក្នុងសាលដីកាមួយនៅក្នុងសំណុំរឿង ០០៤ អ.ប.ជ បានបញ្ជាក់នៅក្នុងសេចក្ដីពន្យល់ថា ស្របតាមការបកស្រាយអំពីវិធានផ្ទៃក្នុង ៦៦(១) ស.ច.ស គួរតែបានផ្ដល់ជូនភាគីនូវរយៈពេល ១៥ ថ្ងៃទៀតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ ដើម្បីឱ្យពិនិត្យភស្តុតាងថ្មីណាដែលប្រមូលបាន (*សូមមើល* សំណុំរឿង ០០៤- ឯកសារ D361/4/1/10 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់* ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ២៣-២៧)។ នៅពេលនោះ យើងមិនយល់ឃើញថាចាំបាច់ត្រូវផ្ដល់ជូនភាគីសំណុំរឿង ០០៤ ឬសំណុំរឿង០០៤/២ នូវរយៈពេល ១៥ ថ្ងៃទៀតដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរ យោងតាមមតិយោបល់របស់ អ.ប.ជ ទេ ពីព្រោះថា យើងយល់ឃើញថា គ្មានភាគីណាមួយទំនងជាទទួលរងផលប៉ះពាល់ដោយសារតែយើងមិនបានផ្ដល់ជូនពេល ១៥ ថ្ងៃទៀតទេ ហើយច្បាស់ណាស់ ក៏មិនប៉ះពាល់ដល់ថ្នាក់ជាករណីពិសេសដែលតម្រូវឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់យើងដែរ។ ជាងនេះទៀត ក៏ដោយសារថា ទោះបីជាភាគីអាចចូលពិនិត្យមើលសំណុំរឿង ០០៤ ហេតុនេះបានដឹងអំពីមតិយោបល់របស់ អ.ប.ជ ក៏ដោយ ក៏គ្មានភាគីណាមួយនៅក្នុងសំណុំរឿង ០០៤/២ បានប្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ ឬក៏លើកឡើងថាជាបញ្ហាដែរចំពោះការមិនផ្ដល់ពេល ១៥ ថ្ងៃទៀតនោះ ហើយក៏គ្មានភាគីណាស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរទេ ចាប់តាំងពី អ.ប.ជ បានផ្ដល់មតិយោបល់បែបនោះមក។ នេះគឺជាការជូនដំណឹងដោយប្រយោលអំពីការលះបង់សិទ្ធិទទួលបានរយៈពេល ១៥ ថ្ងៃទៀត ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៦(១) មានន័យ ថា មតិយោបល់របស់ អ.ប.ជ អំពីអង្គច្បាប់នេះត្រូវទុកជាមោឃៈ។ នៅក្នុងបរិបទនេះ មានភាពពាក់ព័ន្ធត្រង់ថា នៅក្នុងសំណុំរឿង ០០៤ អ.ប.ជ មិនបានយល់ឃើញថាជាការសមស្របត្រូវបង្គាប់ឱ្យ ស.ច.ស ផ្ដល់ពេលវេលា ១៥ ថ្ងៃទៀតទេ ពីព្រោះថា តាមទ្រឹស្ដី អ.ប.ជ អាចធ្វើដូច្នេះបាន ដោយសារថា បណ្ដឹងឧទ្ធរណ៍ក្នុងករណីនេះគឺពាក់ព័ន្ធនឹងពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ (ទោះបីជាថា ការមិនផ្ដល់ពេល ១៥ ថ្ងៃទៀត អាចជាកំហុសនីតិវិធីធ្ងន់ធ្ងរ តាមសំអាងហេតុផ្ទាល់ខ្លួនរបស់ អ.ប.ជ ដែលមិនពាក់ព័ន្ធលម្អិតជាមួយនឹងមតិយោបល់ផ្ទុយមានសំអាងហេតុរបស់ ស.ច.ស ក៏ដោយ) ហើយ អ.ប.ជ ក៏មិនបានយល់ឃើញថា បញ្ហានេះគឺជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីពន្យារពេលរៀបចំតាមសំណើរបស់មេធាវីការពារក្ដីសំណុំរឿង ០០៤ ដែរ។

១១. នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧ ដោយសារបញ្ហាភស្តុភារទាក់ទងនឹងពេលវេលាសម្រាប់បកប្រែដីកាសន្និដ្ឋានស្ថាពរទាំងស្រុងទៅជាភាសាខ្មែរ ទើប ស.ច.ស អនុញ្ញាតឱ្យ ស.ព.អ ដាក់ដីកាសន្និដ្ឋានស្ថាពរជាភាសាអង់គ្លេស និងជាភាសាខ្មែរ នៅត្រឹមថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ដោយឯកសារយោងនៅជាភាសាអង់គ្លេសសិន សម្រាប់ដីកាសន្និដ្ឋានស្ថាពរជាភាសាអង់គ្លេស និងភាសាខ្មែរ បន្ទាប់មក ត្រូវដាក់សំណៅបកប្រែទាំងស្រុងជាភាសាខ្មែរ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន[27]។

១២. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើថា ការចោទប្រកាន់ទាំងអស់លើ **អោ អាន** គួរត្រូវលើកលែង ដោយផ្អែកលើមូលដ្ឋានថា **អោ អាន** មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ[28]។

១៣. នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ស.ព.អ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើថា **អោ អាន** គួរត្រូវចោទបញ្ជូនទៅជំនុំជម្រះចំពោះបទចោទ ដែលបានបង្ហាញនៅក្នុងដីកា សន្និដ្ឋានទាំងអស់[29]។

១៤. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស បានជូនដំណឹងភាគីទាំងអស់ថា ស.ច.ស យល់ឃើញថា ស.ច.ស អាចចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា យោងតាមករណីខ្វែងយោបល់គ្នារវាង ស.ច.ស តាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ហើយក៏បាន

---

[26] ឯកសារ D351 *ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤)នៃវិធានផ្ទៃក្នុង* ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០១៧។

[27] ឯកសារ D351/3 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំកែប្រែបរិច្ឆេទដាក់ដីកាសន្និដ្ឋានស្ថាពរ* ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧។

[28] ឯកសារ D351/4 *ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។

[29] ឯកសារ D351/5 *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៧។

ជូនដំណឹងភាគីទាំងអស់អំពីកិច្ចដំណើរការនីតិវិធី ដែលអាចកើតមានសម្រាប់បណ្ដឹងឧទ្ធរណ៍ យោងតាមវិធានផ្ទៃក្នុង ៧៧(១៣)[30]។

១៥. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៧ មេធាវីការពារក្ដី **អោ អាន** បានដាក់ចម្លើយតប ដោយស្នើថា បទចោទលើ **អោ អាន** គួរត្រូវលើកលែង ដោយផ្អែកលើមូលដ្ឋានថា ដីកាសន្និដ្ឋាន និងការបំពេញកិច្ចទាំងអស់ដែលបានអនុវត្តនាពេលបន្ទាប់មក មិនមានសុពលភាពទេ ស.ចៅ.ស មិនអាចការពារសុចរិតភាព និងភាពយុត្តិធម៌នៃកិច្ចស៊ើបសួរបានឡើយ អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ **អោ អាន** ទេ ហើយ មិនមានភស្តុតាងគ្រប់គ្រាន់ដែលត្រូវចោទ **អោ អាន** បញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលបានដាក់ជាបទចោទទេ[31]។

១៦. នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៨ ស.ចៅ.ស បានចុះកំណត់ហេតុករណីខ្វែងយោបល់គ្នាទាក់ទងនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា។

## ២. ផលប៉ះពាល់ដោយសារសេចក្ដីពិចារណារបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០៤/១

១៧. ការរៀបចំដីកាដំណោះស្រាយនេះបានឈានដល់ដំណាក់កាលចុងក្រោយ ជិតបញ្ចប់ទៅហើយ នៅពេលដែល អ.ប.ជ ចេញសេចក្ដីពិចារណារបស់ខ្លួននៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៨ លើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០៤/១ ("សេចក្ដីពិចារណា")[32]។ អ.ប.ជ បានបង្ហាញការយល់ឃើញមួយចំនួនដែលមានការពាក់ព័ន្ធជាពិសេសនៅក្នុងករណីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អ.ជ.ប និង/ឬ ចៅក្រមអន្តរជាតិនៅ អ.ប.ជ មានសេចក្ដីព្រួយបារម្ភអំពីបញ្ហាចំនួនបីសំខាន់ៗ ដែល

---

[30] ឯកសារ D355/1 *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញ ឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់* ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ១៣-១៦។ មិនមានការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចនេះទេ ហើយក៏មិនមានសំណើសុំឱ្យពិចារណាឡើងវិញដែរ។

[31] ឯកសារ D351/6 *ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦* ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧។

[32] **សំណុំរឿង០០៤/១ ឯកសារ** D308/3/1/20 *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (អ.ប.ជ)* ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨។

01588305



អាចមានផលប៉ះពាល់មកលើសំណុំរឿងដែលនៅសេសសល់ គឺការពន្យារពេលហួសហេតុ គោលជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា និងវិធីសាស្ត្ររបស់ ស.ច.ស ក្នុងការវាយតម្លៃភស្តុតាង។ បញ្ហាទាំងនេះនឹងត្រូវដោះស្រាយម្តងមួយៗនៅខាងក្រោមនេះ។

## ២.១. ការពន្យារពេលហួសហេតុ

១៨. នៅក្នុងការចោទប្រកាន់ជាទូទៅពេក ដែលមានការបញ្ជាក់តែប្អូនកថាខណ្ឌតែប៉ុណ្ណោះ[33] អ.ប.ជ ទាំងមូល បានចោទថា ស.ច.ស បានរំលោភលើមាត្រា ៣៥ *ថ្មី* នៃច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង២១(៤) ពោលគឺជាវិធានដែលកំណត់ថា កិច្ចដំណើរការនីតិវិធីត្រូវបិទបញ្ចប់ "ក្នុងរយៈពេលមួយសមស្រប"។ តាមពិត មូលដ្ឋាននៃការចោទប្រកាន់ធ្ងន់ធ្ងរនេះគឺសំដៅលើគម្លាតរយៈពេលរវាងពេលបិទបញ្ចប់កិច្ចស៊ើបសួរ ជាមួយនឹងពេលចេញ*ដីកាដំណោះស្រាយ (សំអាងហេតុ)* ដែលមានរយៈពេល ១៨ ខែ។ អ.ប.ជ យល់ថា គម្លាតរយៈពេលនេះពុំមានសមាមាត្រទេ[34] ដោយសារ"*ភាពស្មុគស្មាញមានកម្រិតនៃសំណុំរឿង*" ហើយបើប្រៀបធៀបជាមួយនឹងពេលវេលា ដែលបានចំណាយក្នុងការរៀបចំដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០១ និង ០០២[35]។

១៩. នៅក្នុងបរិបទនេះ កត្តាផ្សេងទៀតក៏ជាប់ពាក់ព័ន្ធផងដែរ គឺថា អ.ប.ជ ទាំងមូល ជាថ្មីម្តងទៀត បានយល់ឃើញថា ដីកាដោះស្រាយផ្នែកសេចក្តីសម្រេចបានចេញរួចហើយនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ហើយ ស.ច.ស បានបំពេញសមត្ថកិច្ចរបស់ខ្លួនរួចភ្លាមហើយនៅពេលដែលបានចុះហត្ថលេខាលើដីកាដំណោះស្រាយផ្នែកសេចក្តីសម្រេច[36] ប៉ុន្តែ អ.ប.ជ ខ្លួនឯងបានចំណាយពេលជិតមួយឆ្នាំ ដើម្បីចេញសេចក្តីពិចារណារបស់ខ្លួន ក្រោយពេលរង់ចាំដីកាដំណោះស្រាយ(សំអាងហេតុ)បានដាក់។ បន្ថែមពីនេះទៀត ចៅក្រមអន្តរជាតិនៅ អ.ប.ជ យល់ឃើញថា **អ៊ឹម ចែម** ត្រូវស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ហើយគួរត្រូវដាក់ស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋថែមទៀត ហើយត្រូវចោទបញ្ជូនទៅជំនុំជម្រះ។ ចៅក្រម

[33] សេចក្តីពិចារណា កថាខណ្ឌ ២៨-៣១។

[34] សេចក្តីពិចារណា កថាខណ្ឌ ៣១។

[35] សេចក្តីពិចារណា កថាខណ្ឌ ៣០។

[36] សេចក្តីពិចារណា កថាខណ្ឌ ៣៣។

01588306



អន្តរជាតិនៅ អ.ប.ជ ក៏បានបង្ហាញពីការទទួចឱ្យតុលាការធម្មតារបស់ប្រទេសកម្ពុជា ទទួល ចាត់ការលើរឿងក្តីដែល ស.ច.ស បានលើកលែងការចោទប្រកាន់រួចហើយ តាមការយល់ឃើញរបស់ ស.ច.ស[37]។ យ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិនៅ អ.ប.ជ មិនបានផ្តល់មតិយោបល់ថាតើ "*ការពន្យារពេលហួសហេតុ*" ដែលបង្កឡើងដោយ ស.ច.ស អាចមានផលប៉ះពាល់ដែរឬអត់ ឬក៏មានផលប៉ះពាល់យ៉ាងណា មកលើការចោទប្រកាន់ណាមួយនាពេលអនាគតនៅចំពោះមុខតុលាការជាតិ ជាអ្វីដែលប្រាកដជាយកមកអនុវត្តផងដែរ នៅក្នុងបរិបទ អ.វ.ត.ក ក្នុងករណីមានដីកាបញ្ជូនទៅជំនុំជម្រះនាពេលអនាគត ហើយ ស.ច.ស នឹងឱ្យតម្លៃលើសេចក្តីណែនាំលម្អិត តាមរយៈមតិយោបល់បែបនោះ។

២០. កត្តាទាំងនេះរួមបញ្ចូលគ្នា ធ្វើឱ្យ ស.ច.ស មានការលំបាកយ៉ាងខ្លាំងក្នុងការទាញយកគំរូបទពិសោធច្បាស់លាស់ សម្រាប់អនាគតនៃសំណុំរឿង ដែលនៅសេសសល់ និងការចាត់ការលើសំណុំរឿងដែលនៅសេសសល់នៅក្នុងបរិបទ ដែលមានការចោទប្រកាន់ថាមាន "*ការពន្យារពេលហួសហេតុ*"។ ដោយសារថា អ.ប.ជ បានបង្ហាញការយល់ឃើញខាងលើ ដោយពុំមានការជូនដំណឹងជាមុន ហើយអាចធ្វើរបៀបនេះម្តងទៀតនៅក្នុងសំណុំរឿងណាមួយនៅក្នុងចំណោមសំណុំរឿង ដែលនៅសេសសល់នោះ ទើបជាការប្រុងប្រយ័ត្នត្រូវបង្ហាញពីបញ្ហាដែល ស.ច.ស ប្រឈមមុខ និងផលប៉ះពាល់យ៉ាងណា ដែលបញ្ហានោះអាចមានមកលើសំណុំរឿង ដែលនៅសេសសល់ តាមការយល់ឃើញរបស់ ស.ច.ស។

*គោលបំណង និងលក្ខណៈមិនច្បាស់លាស់នៃការយល់ឃើញអំពីការពន្យារពេលហួសហេតុ*

២១. ទីមួយ អ.ប.ជ បានធ្វើការអះអាងបែបនេះតាមការផ្តួចផ្តើមគំនិតផ្ទាល់ខ្លួន និងដោយគ្មានការរំពឹងទុកជាមុនទាល់តែសោះ។ គ្មានភាគីណាមួយបានលើកឡើងពីបញ្ហានេះជូន អ.ប.ជ នៅក្នុងសារណារបស់ខ្លួននៅពេលប្តឹងឧទ្ធរណ៍ ឬក្នុងពេលណាមួយនៅក្នុងរយៈពេលទាំងស្រុងដែល អ.ប.ជ បានយកជាមូលដ្ឋានសម្រាប់ការរិះគន់របស់ខ្លួនឡើយ ហើយ អ.ប.ជ មិនបានជូនដំណឹងជាមុនដល់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ថា អ.ប.ជ អាចលើកឡើង និងដោះស្រាយបញ្ហានេះទេ។ នៅក្នុងសេចក្តីសម្រេចពីមុនៗរបស់ អ.ប.ជ ស.ច.ស មិន

[37] សេចក្តីពិចារណា កថាខណ្ឌ ៣៣៩-៣៤០។

ដែលទទួលបានការជូនដំណឹងថា បញ្ហាការពន្យារពេលហួសហេតុអាចកើតឡើងឡើយ ទោះបីជាគ្មានអ្វីរារាំង អ.ប.ជ មិនឱ្យបង្ហាញពីសេចក្ដីព្រួយបារម្ភរបស់ខ្លួន ដែលហាក់ដូចជាធ្ងន់ធ្ងន់ណាស់ ហើយក៏ជាបង្ហាញសេចក្ដីព្រួយបារម្ភតាមការផ្ដួចផ្ដើមគំនិតផ្ទាល់ខ្លួននៅក្នុងសេចក្ដីអង្កេតនៅក្នុងសេចក្ដីសម្រេចមួយទៀតក្នុងចំណោមសេចក្ដីសម្រេចពីមុនៗរបស់ អ.ជ.ប ក៏ដោយ។

២២. ទីពីរ មិនច្បាស់ថាតើមានផលប៉ះពាល់លក្ខណៈបែបណាមកលើភាគីណាមួយឡើយ ហើយមានដំណោះស្រាយបែបណា នៅពេលដែលរកឃើញថាមានការពន្យារពេលហួសហេតុនោះ៖ **អ៊ឹម ចែម** ក៏ដូចជា **អោ អាន** ដែរមិនដែលបានជាប់ឃុំខ្លួនទេ ហើយផលប៉ះពាល់ដែលអាចមានដោយសារឈ្មោះ **អ៊ឹម ចែម** ត្រូវបានដឹងជាសាធារណៈថាជាជនម្នាក់ស្ថិតនៅក្រោមការស៊ើបអង្កេតរបស់ ស.ច.ស នោះ មិនមែនជាផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារពេលវេលាដែលបានចំណាយដើម្បីបិទបញ្ចប់សំណុំរឿងឡើយ។ សំណុំរឿងរបស់ **អ៊ឹម ចែម** ត្រូវបានលើកលែងការចោទប្រកាន់ជាឯកច្ឆ័ន្ទ ហើយភាគីទាំងអស់ រួមទាំងសាធារណជនត្រូវបានជូនដំណឹងតាមរយៈដំណោះស្រាយ(សេចក្ដីសម្រេច) មុនពេលដាក់សំអាងហេតុលើកលែងការចោទប្រកាន់។ ទោះបីជាថា ដំណោះស្រាយចំពោះបញ្ហាពន្យារពេលហួសហេតុ ដែល អ.ប.ជ បានគិតនោះគឺមានលក្ខណៈជាការបកស្រាយក៏ដោយ ក៏ អ.ប.ជ គួរតែបានបង្ហាញពីលក្ខណៈនៃផលប៉ះពាល់ ដែលត្រូវដោះស្រាយដែរ។ ហេតុនេះ នៅតែមិនច្បាស់ថាតើនរណាជាអ្នកទទួលប្រយោជន៍ ពីការរកឃើញអំពីការពន្យារពេលហួសហេតុនេះ ហើយគំរូបទពិសោធអ្វី ដែល ស.ច.ស គួរតែរៀនសូត្រតាមសម្រាប់សំណុំរឿង **អោ អាន** និងសំណុំរឿងសេសសល់ផ្សេងទៀត[38]។

២៣. ទីបី អ.ប.ជ មិនបានបង្ហាញឱ្យលម្អិតអំពីលក្ខណៈវិនិច្ឆ័យ ដែលខ្លួនបានវាយតម្លៃលទ្ធផលការងាររបស់ ស.ច.ស ឡើយ ក្រៅពីលើកឡើងថា តាមការយល់ឃើញជាទូទៅផ្ទាល់ខ្លួន

---

[38]ប៉ុន្តែ ក្នុងករណីនេះ តាមពិត អ.ប.ជ បានបង្ហាញពីអ្វីដែលស្ទើរតែឱ្យឃើញថាជាការលើកឡើងពាក់ព័ន្ធនឹងការអនុវត្តការងារជាទូទៅរបស់ ស.ច.ស ក្នុងកិច្ចការនីតិវិធីស៊ើបសួរ។ សូមអធ្យាស្រ័យ ហើយនឹងមានការពន្យល់នៅខាងក្រោមផងដែរ នេះមិនមែនជាមុខងាររបស់ អ.ប.ជ ទេ ហើយប្រសិនបើនេះពិតជាចេតនារបស់ អ.ប.ជ មែន នោះ អ.ប.ជ បានបំពេញកិច្ចហួសដែនអំណាចរបស់ខ្លួនហើយ។

របស់ អ.ប.ជ ភាពស្មុគស្មាញសំណុំរឿងនេះមិនតម្រូវឱ្យមានពេលវេលាយូរបែបនេះឡើយ។ ចាំបាច់ត្រូវតែបញ្ជាក់ថា អ.ប.ជ មិនមានការយល់ឃើញដាច់ដោយឡែកអ្វីសោះអំពីបញ្ហាដែល ក.ស.ច.ស បានប្រឈមមុខ ហើយ អ.ប.ជ ក៏មិនដែលបានស្នើសុំការពន្យល់ពី ស.ច.ស នៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីបណ្ដឹងឧទ្ធរណ៍ពីមុនដែរ។ ចាប់តាំងពីឆ្នាំ ២០១៤ មក ស.ច.ស បានផ្ដល់ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំ និងយ៉ាងលម្អិតសម្រាប់របាយការណ៍បញ្ចប់ការងារប្រចាំត្រីមាសរបស់ អ.វ.ត.ក ដោយបានពន្យល់ពីមូលហេតុដែលសំណុំរឿងនានាអាចត្រូវពន្យារពេល ប៉ុន្តែ អ.ប.ជ មិនបានលើកឡើងពីចំណុចនេះទាល់តែសោះ ហេតុនេះ អ.ប.ជ បានប្រកាសដោយប្រយោលថា ព័ត៌មានបច្ចុប្បន្នរបស់ ស.ច.ស មិនពាក់ព័ន្ធនឹងការយល់ឃើញរបស់ អ.ប.ជ ឡើយ។ ការអនុវត្តដ៏ល្អនៅតុលាការ តម្រូវថា ការចោទប្រកាន់អំពីការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និង/ឬការមិនបានចាត់នីតិវិធីឱ្យរឿងក្ដីដំណើរការទៅមុខឱ្យបានត្រឹមត្រូវនោះ ជានិច្ចកាល ត្រូវតែមានព័ត៌មានច្បាស់លាស់ និងយកចិត្តទុកដាក់អំពីចំណុចបញ្ហាពាក់ព័ន្ធនឹងមូលហេតុ នៃការពន្យារពេល និងអ្វីដែលតុលាការជាន់ទាបនោះគួរតែអាចធ្វើបាន ដើម្បីកុំឱ្យមានការពន្យារពេល។ សេចក្ដីពិចារណារបស់ អ.ប.ជ មិនបានបំពេញតាមបទដ្ឋាននេះឡើយ ហេតុនេះ ធ្វើឱ្យ ស.ច.ស មិនមានតម្រុយថាតើត្រូវវាយតម្លៃយ៉ាងណាអំពីការពន្យារពេលណាមួយ ដែលអាចកើតឡើងរួចហើយនាពេលកន្លងមកនៅក្នុងសំណុំរឿងដែលមិនទាន់បិទបញ្ចប់ និងត្រូវវាយតម្លៃយ៉ាងណាអំពីផលលំបាក ដែលអាចកើតមានសម្រាប់សំណុំរឿងដែលមិនទាន់បិទបញ្ចប់។ ករណីនេះកាន់តែមានបញ្ហាថែមទៀត ពីព្រោះថា ដោយពិចារណាលើពេលវេលាដែលត្រូវការសម្រាប់បណ្ដឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង ០០៤/១ គឺទំនងខ្លាំងដែលអាចថា ដីកាដំណោះស្រាយ ដែលនៅសល់ទាំងអស់នឹងបានចេញ មុនពេលដែល អ.ប.ជ អាចផ្ដល់សេចក្ដីណែនាំលម្អិតថែមទៀតនៅក្នុងសំណុំរឿង ០០៤/២ ដែលមានលក្ខណៈស្មុគស្មាញជាង។

២៤. ទីបួន មិនមានភាពច្បាស់លាស់ថែមទៀតអំពីដែនកំណត់នៃការយល់ឃើញអំពីការពន្យារពេលហួសហេតុ ដោយសារការសម្រេចជារួមរបស់ អ.ប.ជ ដែលថា ដីកាដំណោះស្រាយមួយមិនអាចបំបែកទៅជាផ្នែកសេចក្ដីសម្រេច និងផ្នែកសំអាងហេតុឱ្យដាច់ដោយឡែកពីគ្នាបានឡើយ ហើយ ស.ច.ស បានបំពេញសមត្ថកិច្ចរបស់ខ្លួនរួចហើយនៅពេលដែល ស.ច.ស បានចុះ

ហត្ថលេខាលើដីកាដំណោះស្រាយផ្នែកសេចក្តីសម្រេច កាលពីខែកុម្ភៈ ឆ្នាំ ២០១៧។ យោងតាមហេតុផលផ្ទាល់ខ្លួនរបស់ អ.ប.ជ ដីកាដំណោះស្រាយ(សេចក្តីសម្រេច)អាចត្រូវទុកជាមោឃៈរួចទៅហើយដោយសារខ្វះសំអាងហេតុ ហើយដីកាដំណោះស្រាយ(សំអាងហេតុ)ច្បាស់ជាទុកជាមោឃៈ ដោយសារខ្វះយុត្តាធិការ។ ហេតុនេះ មិនមានសេចក្តីសម្រេចដែលមានសុពលភាព ឬសំអាងហេតុដែលមានសុពលភាពឡើយ។ ដោយសារថា តាមការយល់ឃើញរបស់ អ.ប.ជ ការបំបែកដីកាដំណោះស្រាយទៅជាផ្នែកៗបែបនេះគឺជាកំហុសនីតិវិធីធ្ងន់ធ្ងររបស់ ស.ច.ស ទើប អ.ប.ជ ទាំងមូល គួរតែបានច្រានចោលដីកាដំណោះស្រាយ(សេចក្តីសម្រេច)រួចទៅហើយ ដោយមិនគិតពីបញ្ហាចោទអំពីអង្គសេចក្តីនៃយុត្តាធិការ បុគ្គលឡើយ ហើយបញ្ជូនសំណុំរឿងត្រឡប់មក ស.ច.ស វិញ ដោយណែនាំកុំឱ្យបំបែកដីកាដំណោះស្រាយទៅជាផ្នែកៗ ដែលក្នុងករណីបែបនេះ អាចបញ្ចូលមតិយោបល់អំពីសេចក្តីព្រួយបារម្ភពាក់ព័ន្ធនឹងការពន្យារពេលហួសហេតុ។ ការធ្វើរបៀបនេះគឺស្របតាមវិធានជាទូទៅដែលថា បញ្ហាចោទអំពីនីតិវិធីត្រូវតែដោះស្រាយ មុនពេលសំណុំរឿងណាមួយត្រូវពិនិត្យ លើអង្គសេចក្តី[39]។ ជាងនេះទៀត នៅពេលនោះ វាមិនចម្លែកទេដែលត្រូវទទួលយកការយល់ឃើញដែលថា សេណារីយ៉ូនេះអាចកើតឡើងម្តងទៀតនៅក្នុងសំណុំរឿងមួយទៀត មុនពេលបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង ០០៤/១ ត្រូវបានសម្រេច។ ប៉ុន្តែ អ.ប.ជ បានបង្គាប់ឱ្យ ស.ព.អ រង់ចាំសិន កុំអាលដាក់បណ្តឹងឧទ្ធរណ៍ រហូតដល់ដីកាដំណោះស្រាយ(សំអាងហេតុ) បាន ដាក់សិន ហើយ អ.ប.ជ បានចំណាយពេលជិតមួយឆ្នាំ គឺរហូតដល់ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ទើបចេញសេចក្តីពិចារណារបស់ខ្លួន ទោះបីជាថា វិសាលភាពនៃបណ្តឹងឧទ្ធរណ៍នេះមិនស្មុគស្មាញ ជាងការងារកសាងសំណុំរឿងដើម្បីចេញដីកាដំណោះស្រាយ និងរៀបចំដីកាដំណោះស្រាយក៏ដោយ។

២៥. ទីប្រាំ អ.ប.ជ មិនបានពន្យល់ថាតើការយល់ឃើញអំពីការពន្យារពេលហួសហេតុ នាំឱ្យមានផលលំបាកអ្វីខ្លះ ហើយចៅក្រមអន្តរជាតិនៅ អ.ប.ជ ក៏មិនបានដោះស្រាយបញ្ហាដែរ នៅពេលដែលបង្ហាញចេតនារបស់ខ្លួនថា ឥឡូវនេះ តុលាការធម្មតារបស់ប្រទេសកម្ពុជា គួរតែ

[39] ចំណុចនេះមានភាពពាក់ព័ន្ធ ឧទាហរណ៍ នៅក្នុងបរិបទដែលចៀសវាងកុំឱ្យមានផលប៉ះពាល់ដោយសារបញ្ហាដែលបានសម្រេចលើអង្គសេចក្តីរួចហើយប្រសិនបើតាមនីតិវិធី តុលាការមិនអាចធ្វើសេចក្តីសម្រេចលើអង្គសេចក្តីបានឡើយ។

01588310



ចោទប្រកាន់ អ៊ីម ចែម ទោះបីជាជាក់ស្តែងអាចមានផលប៉ះពាល់ តាមបរិបទនៃវិធានច្បាប់ក៏ដោយ។ អ.ប.ជ ក៏មិនបានបញ្ជាក់ពីការយល់ឃើញរបស់ខ្លួនយ៉ាងច្បាស់លាស់ដែរ ដោយសារការយល់ឃើញរបស់ខ្លួនខ្វះអំណាចឱ្យតុលាការជាតិជាប់កាតព្វកិច្ច (សូមមើលខាងក្រោមពាក់ព័ន្ធនឹងបញ្ហាគោលជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា)។ បញ្ហានេះមិនសូវពាក់ព័ន្ធទេ ក្នុងករណីលើកលែងការចោទប្រកាន់ ប៉ុន្តែ វាមានសារៈសំខាន់ខ្លាំង ប្រសិនបើដីកាដំណោះស្រាយសម្រេចបញ្ជូនទៅជំនុំជម្រះ៖ តើការពន្យារពេលហួសហេតុ មានកម្រិតខុសគ្នាដែរឬទេ ហើយតើការព្យោរពេលហួសហេតុមានផលប៉ះពាល់ខុសគ្នាមកលើលទ្ធផលនៃសំណុំរឿងណាមួយដែរឬទេ? តើមានដែនកំណត់ដែលកំណត់ត្រឹមណាថា ការស៊ើបសួរសំណុំរឿងណាមួយបានចំណាយពេលយូរហួសហេតុ រហូតដល់រំលោភបំពានលើបទដ្ឋានជំនុំជម្រះក្តី ដោយយុត្តិធម៌ ដល់ចំណុចដែលដំណោះស្រាយសមហេតុផលតែមួយគត់គឺត្រូវផ្អាកកិច្ចដំណើរការនីតិវិធី ឬលើកលែងការចោទប្រកាន់? មានករណីយុត្តិសាស្ត្រគ្រប់គ្រាន់នៅក្នុងយុត្តាធិការជាច្រើនអំពីបញ្ហានេះ ហើយគួរតែអាចមានការរំពឹងទុកសមហេតុផលថា អ.ប.ជ បានផ្តល់ជូន ស.ច.ស នូវសេចក្តីណែនាំសមស្របនៅពេលដែល អ.ប.ជ លើកឡើងពីបញ្ហាទូទៅដែលមានវិសាលភាពបែបនេះ នៅក្នុងដំណាក់កាលចុងក្រោយបែបនេះ និងលើកឡើងតាមការផ្តួចផ្តើមគំនិតខ្លួនឯង។

*មូលដ្ឋានមិនច្បាស់លាស់ចំពោះការយល់ឃើញរបស់ អ.ប.ជ*

២៦. គួរឱ្យចាប់អារម្មណ៍គឺថា អ.ប.ជ ទាំងមូល ប្រើប្រាស់ពាក្យថា អ.ប.ប ជា“***ស្ថាប័នដែលត្រួតពិនិត្យនៅដំណាក់កាលស៊ើបអង្កេត***”[40] (គូសបញ្ជាក់បន្ថែម) ដើម្បីធ្វើជាយុត្តិកម្មសម្រាប់ការយល់ឃើញរបស់ខ្លួនអំពីការពន្យារពេលហួសហេតុ។ ពាក្យនេះមិនមានប្រើប្រាស់នៅក្នុងលិខិតុបករណ៍ណាមួយអំពីច្បាប់នៅចំពោះ អ.វ.ត.ក ឡើយ។ ហេតុនេះ វាមិនច្បាស់ថាតើ អ.ប.ជ មានបំណងអ្វី ដែលប្រើប្រាស់ពាក្យនេះ ហើយសំដៅលើអ្វីនោះទេ។

[40] សេចក្តីពិចារណា កថាខណ្ឌ ២៨។

២៧. ច្បាប់ជាធរមាននៅចំពោះ អ.វ.ត.ក កំណត់យ៉ាងច្បាស់អំពីតួនាទី និងមុខងាររបស់ អ.ប.ជ នៅក្នុងដំណាក់កាលបុរេជំនុំជម្រះ។ ច្បាប់នេះមិនមានបទប្បញ្ញត្តិណាមួយដែលផ្ដល់ជូន អ.ប.ជ នូវអំណាចធ្វើការត្រួតពិនិត្យជាទូទៅលើការអនុវត្តការងាររបស់ ស.ច.ស ឡើយ។

២៨. ជាពិសេស វិធានផ្ទៃក្នុង ត្រូវបានសម្រេចជាបន្តបន្ទាប់ថាមានឋានៈជាច្បាប់ពិសេសសម្រាប់គ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ហើយការងាកទៅប្រើប្រាស់ច្បាប់ជាទូទៅរបស់កម្ពុជា អាចអនុញ្ញាតបានតែក្នុងករណីដែលមានការបង្ហាញថា អ្នករៀបចំវិធានផ្ទៃក្នុងមាន*ចន្លោះប្រហោងដោយអចេតនា*តែប៉ុណ្ណោះ។ ដោយពិនិត្យឃើញថា ការត្រួតពិនិត្យការអនុវត្តការងារ និង/ឬការគ្រប់គ្រងវិន័យរបស់ ស.ច.ស គឺជាបញ្ហាធ្ងន់ធ្ងរនៅក្នុងបរិបទនៃឯករាជ្យភាពរបស់តុលាការ ទើបមិនអាចនឹកឃើញទាល់តែសោះថា បញ្ហានេះគួរបានមើលរំលងឡើយ។

២៩. ការសង្កត់ធ្ងន់ឡើងវិញលើគោលការណ៍នេះមានភាពពាក់ព័ន្ធ ពីព្រោះថា នាពេលកន្លងមក និងនៅក្នុងសំណុំរឿងនេះ អ.ប.ជ បានអះអាងថា ខ្លួនបំពេញមុខងាររបស់សភាស៊ើបសួរនៅសាលាឧទ្ធរណ៍របស់កម្ពុជា។ ប៉ុន្តែ នៅគ្រប់ករណីទាំងអស់ដែលមានការលើកឡើងរបៀបនេះ គឺពាក់ព័ន្ធតែអំណាចនៅក្នុងការស៊ើបសួរអង្គសេចក្ដីតែប៉ុណ្ណោះ គឺថាតើ អ.ប.ជ អាចបំពេញកិច្ចស៊ើបសួរផ្ទាល់ខ្លួនបានដែរឬអត់ ឬអាចជំនួសដីកាសម្រេចណាមួយរបស់ ស.ច.ស នូវសាលដីការបស់ខ្លួនដែរឬអត់ ។ល។ ទោះបីជាថា អ.ប.ជ មិនបានលើកឡើងដូច្នេះឲ្យបានច្បាស់លាស់បែបនេះក៏ដោយ ក៏មានការបង្ហាញតិចតួចដែរថា ឥឡូវនេះ អ.ប.ជ អាចសន្មតថាខ្លួនមានមុខងារ និងអំណាចជាប្រធានសភាស៊ើបសួរ ដែលមានចែងនៅមាត្រា ២៨៣ និងមាត្រាបន្តបន្ទាប់ទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២00៧ របស់កម្ពុជា និងជាពិសេសមាត្រា ២៨៣៖

មាត្រា ២៨៣

អំណាចរបស់ប្រធានសភាស៊ើបសួរ

01588312



ប្រធានសភាស៊ើបសួរ ក៏បរងលើការប្រព្រឹត្តទៅដ៏ល្អនៃមន្ទីរស៊ើបសួរនៃចៅក្រមស៊ើបសួរ។ ប្រធានសភាស៊ើបសួរផ្ទៀងផ្ទាត់មើលជាអាទិ៍ លក្ខខណ្ឌនៃការអនុវត្តបទប្បញ្ញត្តិស្តីពីការឃុំខ្លួនបណ្ដោះអាសន្ន ដីកាតុលាការផ្សេងៗ ដីកាចាត់ឱ្យស៊ើបសួរជំនួស និងមោឃភាព។

*ប្រធានសភាស៊ើបសួរ ក៏បរងកុំឱ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវ ដោយមិនសមហេតុផល។*

*ប្រធានសភាស៊ើបសួរអាចចុះទៅធ្វើអធិការកិច្ចនៅក្នុងមន្ទីរស៊ើបសួរ*"។ (គូសបញ្ជាក់បន្ថែម)

៣០. បើទោះបីជាបទប្បញ្ញត្តិនេះអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ក៏ដោយ ក៏អំណាចបែបនេះស្ថិតនៅលើ*ប្រធាន* អ.ប.ជ ដែរ មិនមែនស្ថិតនៅលើ អ.ប.ជ ទាំងមូលឡើយ ហើយអំណាចបែបនេះស្ថិតនៅក្នុងសមត្ថកិច្ច*រដ្ឋបាល*សុទ្ធសាធ មិនមែនជាការបំពេញតួនាទីរបស់តុលាការនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការឡើយ។ ហើយបើដូច្នេះមែន តួនាទីនេះក៏ត្រូវបំពេញជាមុនជាប្រចាំ មិនមែននៅដំណាក់កាលចេញសាលដីកាស្ថាពរឡើយ នៅពេលដែលតួនាទីត្រួតពិនិត្យនេះលែងមានប្រយោជន៍អ្វីល្អហើយ។ ចុងក្រោយបំផុត ប្រសិនបើ អ.ប.ជ ទាំងមូលមានមុខងារបែបនេះ នៅដំណាក់ចុងក្រោយនៃកិច្ចដំណើរការនីតិវិធីរបស់ ក.ស.ច.ស នឹងបង្កឱ្យមានបញ្ហាផ្នែកច្បាប់សម្រាប់ អ.វ.ត.ក។

*ផលលំបាកដោយសារការយល់ឃើញរបស់ អ.ប.ជ អំពីការពន្យារពេលហួសហេតុសម្រាប់ដីកាដំណោះស្រាយនាពេលអនាគត*

៣១. កង្វះភាពច្បាស់លាស់នៃការយល់ឃើញរបស់ អ.ប.ជ អំពីការពន្យារពេលហួសហេតុ គឺមិនបានជួយដល់ ស.ច.ស នោះទេ កុំថាឡើយដល់ទៅភាគី ហើយមូលដ្ឋាន និងគោលបំណងនៃការយល់ឃើញតាមការផ្តួចផ្តើមគំនិតផ្ទាល់ខ្លួនបែបនេះ ដោយជាក់ស្តែងមិនមានសេចក្តីលម្អិតនោះ អាចជាបញ្ហាទោទ។ ចំណែកឯខ្លឹមសារពីសេចក្តីពិចារណារបស់ អ.ប.ជ ចង្អុលបង្ហាញយ៉ាងច្បាស់ថា អ.ប.ជ នឹងធ្វើរបៀបនេះម្តងទៀត ហើយមិនជូនដំណឹងជាមុនទេ ប្រសិនបើ អ.ប.ជ យល់ឃើញថា សំណុំរឿងតម្រូវឱ្យធ្វើដូច្នេះ។

---

[៤]"គូសបញ្ជាក់បន្ថែម។

៣២. ហេតុនេះ ស.ច.ស ត្រូវតែបញ្ជាក់ថា នៅក្នុងសំណុំរឿងណាមួយនាពេលអនាគត អ.ប.ជ អាចលើកឡើងពីបញ្ហានេះឱ្យបានច្បាស់ជាងនេះ តាមលក្ខខណ្ឌតម្រូវសម្រាប់ការអនុវត្តដ៏ល្អរបស់តុលាការ ហើយប្រជាជនកម្ពុជាជាទូទៅទទួលបានការជូនដំណឹងគ្រប់គ្រាន់អំពីការវិវត្តនៃសំណុំរឿង និងមូលហេតុដែលនាំឱ្យពន្យារពេលសំណុំរឿងណាមួយ។

៣៣. ហេតុនេះ ដីកាដំណោះស្រាយនីមួយៗ ដែលចុះហត្ថលេខាដោយ ស.ច.ស.អន្តរជាតិ ដោយចាប់ផ្តើមពីដីកាដំណោះស្រាយនេះ នឹងមានឧបសម្ព័ន្ធចំនួនពីរជាបទដ្ឋាន៖ ឧបសម្ព័ន្ធទីមួយមានសេចក្តីលម្អិតតាមកាលបរិច្ឆេទអំពីការចូលរួមចំណែកផ្តល់ព័ត៌មានរបស់ ស.ច.ស ដល់បច្ចុប្បន្នភាពផែនការបញ្ចប់ការងារប្រចាំត្រីមាស របស់ អ.វ.ត.ក។ ឧបសម្ព័ន្ធទីពីរ មានបញ្ជីលម្អិតតាមកាលបរិច្ឆេទអំពីញត្តិ និងសំណើសុំបំពេញកិច្ចស៊ើបសួរទាំងអស់ ដែលបានដាក់ជូន ស.ច.ស ពេលវេលាដែល ស.ច.ស បានចំណាយដើម្បីដោះស្រាយញត្តិ និងសំណើទាំងនោះ ព្រមទាំងបណ្តឹងឧទ្ធរណ៍ទាំងអស់ ដែលបានដាក់ជំទាស់នឹងដីកាសម្រេចរបស់ ស.ច.ស និង/ឬពាក្យសុំមោឃភាពដែលបានបញ្ជូនទៅ អ.ប.ជ និងពេលវេលារហូតដល់ពេលមានសាលដីកា។ នៅក្នុងបរិបទនេះ ត្រូវតែមានការយកចិត្តទុកដាក់ជាពិសេសពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ ដរាបណា ក.ស.ច.ស បានបំពេញកិច្ចស៊ើបសួរលើសំណើបែបនោះ ដែលជាទូទៅគឺការចុះបេសកកម្មស៊ើបសួរច្រើនដង និងការចេញដីកាកោះ។ ចំណុចនេះពន្យល់ពីរយៈពេលដែលជួនកាលស៊ីពេលយូរ រហូតដល់ពេលមានសេចក្តីសម្រេចចុងក្រោយលើសំណើនីមួយៗ។ ភាគច្រើននៃម៉ោងការងាររបស់បុគ្គលិក ក.ស.ច.ស ក៏បានចំណាយលើសំណើយ៉ាងច្រើនសុំដាក់បង្ហាញឯកសារពី ស.ព.អ ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ដែលបានធ្វើការត្រួតពិនិត្យយ៉ាងលម្អិត លើកំណត់ហេតុស្តាប់ចម្លើយពាក់ព័ន្ធទាំងអស់ដើម្បីរកព័ត៌មានសម្ងាត់ និងចេញដីកាសម្រេចលើវិធានការការពារដែលចាំបាច់។ ការងារនេះបានកាត់បន្ថយសមត្ថភាពការងារដែលមាន ដើម្បីដំណើរការកិច្ចស៊ើបសួរជាក់ស្តែងឱ្យវិវត្តទៅមុខ។

## ២.២. គោលជំហររបស់ អ.ខ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

៣៤. អ.ប.ជ ជំទាស់នឹងការយល់ឃើញរបស់ ស.ច.ស ដែលថា អ.វ.ត.ក មានយុត្តាធិការផ្តាច់មុខលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យខ្មែរក្រហម[42]។ អ.ប.ជ បានសម្រេចថា ស.ច.ស បានដើរលើសពីអាណត្តិការងាររបស់ខ្លួន តាមរយៈការសម្រេចយល់ឃើញបែបនេះ ពីព្រោះថា ទាំង ស.ច.ស ទាំង អ.ប.ជ មិនមានយុត្តាធិការលើបញ្ហានេះឡើយ[43]។ ប៉ុន្តែ អ.ប.ជ បន្តបង្ហាញមតិយោបល់របស់ខ្លួនយ៉ាងច្រើនក្នុងនាមជា"*អង្គជំនុំជម្រះត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍*" ហើយយល់ឃើញថា"*ចាំបាច់ត្រូវតែពិចារណាទៅលើបញ្ហាដែលបានលើកឡើង ដែលជាបញ្ហាសំខាន់ទូទៅមួយសម្រាប់យុត្តិសាស្ត្រ និងកេរដំណែលរបស់ អ.វ.ត.ក*"[44]។ ចុងក្រោយបង្អស់ នៅក្នុងផ្នែកសេចក្តីសម្រេចនៃការយល់ឃើញជារួមរបស់ខ្លួន អ.ប.ជ បានបញ្ចូលមតិយោបល់ផ្ទាល់ខ្លួនដែលថា តុលាការធម្មតារបស់កម្ពុជា មានយុត្តាធិការលើឧក្រិដ្ឋកម្មដែលមិនអាចធ្វើការជំនុំជម្រះបានចំពោះមុខ អ.វ.ត.ក[45] ជាអ្វីដែល អ.ប.ជ មិន

[42] សេចក្តីពិចារណា កថាខណ្ឌ ៦៤ និងកថាខណ្ឌបន្តបន្ទាប់។

[43] សេចក្តីពិចារណា កថាខណ្ឌ ៧២។

[44] សេចក្តីពិចារណា កថាខណ្ឌ ៧៣។ មតិយោបល់ច្បាស់លាស់ទីមួយគឺថា ប្រសិនបើ ស.ច.ស បានដើរលើសពីអាណត្តិការងាររបស់ខ្លួនដោយធ្វើការសម្រេចបែបនេះ នោះ អ.ប.ជ ក៏បានដើរលើសដូចគ្នាដែរ ថែមទាំងដើរលើសឆ្ងាយទៀតផង ដោយសារ អ.ប.ជ បានបញ្ចូលការយល់ឃើញរបស់ខ្លួននៅក្នុងផ្នែកសេចក្តីសម្រេច ទោះបីជាទទួលស្គាល់ថា អ.ប.ជ មិនមានយុត្តាធិការក៏ដោយ។ ជាងនេះទៀត ការយល់ឃើញនេះគ្រាន់តែជាការយល់ឃើញមិនឱ្យជាប់កាតព្វកិច្ចផ្លូវច្បាប់ទេ ពីព្រោះថាវាមិនមែនជាផ្នែកមួយនៃសំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់តុលាការឡើយ។ ការយល់ឃើញនេះមិនឱ្យ ស.ច.ស ជាប់កាតព្វកិច្ចត្រូវអនុវត្តតាមឡើយ។ មិនមានប្រយោជន៍ឡើយដែលលើកឡើងថា បញ្ហា"សំខាន់ជាទូទៅ" និង "កេរដំណែល"គឺជាយុត្តិកម្មសម្រាប់ដោះស្រាយបញ្ហាដែល អ.ប.ជ ខ្លួនឯងមិនមានយុត្តាធិការឲ្យ តុលាការជាតិជាប់កាតព្វកិច្ចត្រូវអនុវត្ត ពីព្រោះថា តាមហេតុផលផ្ទាល់ខ្លួនរបស់ អ.ប.ជ អ.វ.ត.ក មិនអាចកំណត់អំពីបញ្ហាសំខាន់ជាទូទៅនេះបានទេ ហើយក៏មិនអាចកំណត់អំពីកេរដំណែល ដែលតុលាការជាតិ នឹងត្រូវអនុវត្តតាមដែរ។ តុលាការជាតិនឹងកំណត់ថាតើករណីនោះពិតជាកេរដំណែលដែល អ.វ.ត.ក បានបន្សល់ទុកដែរឬអត់។ គោលបំណងរបស់ ស.ច.ស ក្នុងការដោះស្រាយបញ្ហានេះទទួលបានការចាប់អារម្មណ៍យ៉ាងត្រឹមត្រូវពីបណ្ឌិត ប៊ិត ស៊ាងលីម សហមេធាវីជាតិតំណាង អ៊ឹម ចែម នៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.វ.ត.ក នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០១៧។ សូមមើល ឯកសារ D308/3/1/19/2.1 ប្រតិចារឹកសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ [អ៊ឹម ចែម] ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ទំព័រ ១១-១៣។

[45] សេចក្តីពិចារណា កថាខណ្ឌ ២៧។

អាចធ្វើបានឡើយ បើយោងតាមការយល់ឃើញផ្ទាល់ខ្លួនរបស់ អ.ប.ជ ដែលថា ខ្លួនមិនមានយុត្តាធិការ។ ជាគោលការណ៍ បញ្ហានេះនៅមានភាពពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយដែលនៅសល់ទាំងអស់។ ប៉ុន្តែ គ្រប់គ្នាគួរតែបានច្បាស់ហើយថា ប្រសិនបើ*បម៉ិសេស*ថា អ.វ.ត.ក មិនមានយុត្តាធិការផ្តាច់មុខទេ នោះ*កាន់តែងាយស្រួល*សម្រាប់ ស.ច.ស ធ្វើការច្រានចោលយុត្តាធិការបុគ្គល ដោយសារមូលហេតុយ៉ាងច្បាស់ថា នៅមានយុត្តាធិការលើឧក្រិដ្ឋកម្មទាំងនោះ ហើយមិនមានគម្លាតនិទណ្ឌភាពទេ។ យ៉ាងណាក៏ដោយ អ.ប.ជ មិនអាចឱ្យតុលាការជាតិជាប់កាតព្វកិច្ចលើអង្គច្បាប់បានឡើយ ប៉ុន្តែ ការយល់ឃើញមិនតម្រូវជាប់កាតព្វកិច្ចផ្លូវច្បាប់របស់ អ.ប.ជ ដូចជា ការយល់ឃើញបែបនេះ ពិតជាបង្កើតឱ្យមានអំណាចគួរឱ្យជឿជាក់បានសម្រាប់ ស.ច.ស ហេតុនេះ ការយល់ឃើញរបស់ អ.ប.ជ ត្រូវបានកត់សម្គាល់សម្រាប់ដីកាដំណោះស្រាយដែលនៅសល់ទាំងអស់។

## **២.៣. ការពិចារណាលើភ័ស្តុតាង**

៣៥. អ.ប.ជ និង/ឬ ចៅក្រមអន្តរជាតិបានរិះគន់ ស.ច.ស នៅក្នុងបរិបទនៃការពិចារណារបស់ ស.ច.ស លើភ័ស្តុតាងនៅក្នុងសំណុំរឿង។ ការរិះគន់នេះអាចមានផលប៉ះពាល់មកលើដីកាដំណោះស្រាយដែលនៅសល់ទាំងអស់ ហើយចាំបាច់ត្រូវធ្វើការវិភាគ។ ការវិភាគនេះ នាំឱ្យមានសេចក្តីសន្និដ្ឋានថា អ.ប.ជ និង/ឬ ចៅក្រមអន្តរជាតិ បានបកស្រាយខុស ចំពោះចំណុចខ្លះ ហេតុនេះយល់ច្រឡំអំពីវិធីសាស្រ្តរបស់ ស.ច.ស។ ចំពោះចំណុចផ្សេងទៀត ការយល់ឃើញរបស់ អ.ប.ជ និង/ឬចៅក្រមអន្តរជាតិ មិនបានឆ្លុះបញ្ចាំងឱ្យបានត្រឹមត្រូវអំពីការពិចារណាលើភ័ស្តុតាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡើយ។ កំហុសឆ្គងទាំងនេះមានលក្ខណៈដែល ស.ច.ស មិនអាចទទួលយកការយល់ឃើញរបស់ អ.ប.ជ ដោយគ្មានការជំទាស់ឡើយ ប៉ុន្តែ ជាការសមស្របសូម អ.ប.ជ ពិចារណាឡើងវិញ លើមតិយោបល់របស់ខ្លួននៅក្នុងបណ្តឹងឧទ្ធរណ៍ដែលនឹងត្រូវដាក់ជំទាស់នឹងដីកាដំណោះស្រាយនេះ។

៣៦. អ.ប.ជ បានធ្វើការរិះគន់ដូចខាងក្រោម៖

*ក. អ.ប.ជ ទាំងមូល*

i. ស.ច.ស មិនគួរបានបបញ្ចូលជំពូកស្តីពីការពិចារណាលើភ័ស្តុតាងទេ ពីព្រោះថា "*ការពិចារណាបែបនេះ...មិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយបើតាមទស្សនៈរបស់អង្គបុរេជំនុំជម្រះ ការពិចារណាបែបនេះប្រហែលជាមិនចាំបាច់ និងគ្មានប្រយោជន៍ឡើយ។ ភារកិច្ចតែមួយរបស់សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង គឺចេញដីកាលើកលែងការចោទប្រកាន់ ប្រសិនបើក្នុងចំណោមអង្គហេតុផ្សេងៗទៀត "ពុំមានភ័ស្តុតាងគ្រប់គ្រាន់ បញ្ជាក់ពីបទចោទ*"។ អ.ប.ជ ក៏បញ្ជាក់ពីការពិតដែលថា ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០១ និង ០០២ មិនមានជំពូកបែបនេះឡើយ[46]។

ii. "*ការប្រមូលភ័ស្តុតាងនៅចំពោះមុខ អ.វ.ត.ក ត្រូវបានកំណត់ដោយគោលការណ៍សេរីភាពនៃភ័ស្តុតាង ដែលជាលក្ខណៈពិសេសនៃ**ប្រព័ន្ធច្បាប់ស៊ីវិល**។ និយាយម្យ៉ាងទៀត ភ័ស្តុតាងទាំងអស់គឺអាចទទួលយកបានដូចមានចែងក្នុងវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ បន្ថែមពីលើនេះទៀត ភ័ស្តុតាងទាំងអស់ជាទូទៅគឺមានតម្លៃជាភ័ស្តុតាងស្មើគ្នា។ មាត្រា ២៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានឆ្លុះបញ្ចាំងពីគោលការណ៍នេះ ដោយកំណត់ថា "សហចៅក្រមស៊ើបអង្កេតអាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មានដែលទទួលបានពីស្ថាប័ននានា"។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា **លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ** ភ័ស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភ័ស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន"។ មាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង បានចែងដូចគ្នាថា បទល្មើសអាចត្រូវបានបង្ហាញ ភ័ស្តុតាងតាមគ្រប់ទម្រង់នៃភ័ស្តុតាង*

[46] សេចក្តីពិចារណា កថាខណ្ឌ ៤១។

*ហើយចៅក្រមត្រូវសម្រេច ផ្អែកលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន"* [47]។ (គូសបញ្ជាក់បន្ថែម)

iii. *"បន្ថែមពីលើនេះទៀត អង្គបុរេជំនុំជម្រះសូមរំឭកថា សហចៅក្រមស៊ើបអង្កេតធ្វើការវាយតម្លៃដោយសេរីទៅលើតម្លៃជាភស្តុតាងនៃភស្តុតាង ដែលប្រមូលបានក្នុងពេលធ្វើការស៊ើបអង្កេត ហើយច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក មិនបានបញ្ញត្តិអំពីវិធាននានាពាក់ព័ន្ធនឹងការវាយតម្លៃទៅ លើភាពគ្រប់គ្រាន់នៃភស្តុតាងសម្រាប់ការចោទប្រកាន់នោះឡើយ។ តាមពិតទៅ គឺមិនមានមូលដ្ឋានសម្រាប់ការញែកចេញពីគ្នានូវចម្លើយនានា ដោយផ្អែកទៅលើប្រភពនៃចម្លើយនោះឡើយ។ ភស្តុតាងទាំងអស់សុទ្ធតែអាចទទួលយកបាន ហើយជាទូទៅទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន តាមផ្លូវច្បាប់ដូចៗគ្នា ប្រសិនបើភស្តុតាងទាំងនោះត្រូវបានប្រមូលមកដោយស្របច្បាប់"* [48]។ (គូសបញ្ជាក់បន្ថែម)

iv. *"ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ យល់ឃើញថា* ***នៅក្នុងប្រព័ន្ធដែលសួរដេញដោលដែលផ្អែកលើភស្តុតាងជាលាយលក្ខណ៍អក្សរ*** *គឺជាកំហុសអង្គច្បាប់ ដែលធ្វើការអះអាងជាទូទៅអំពីតម្លៃជាភស្តុតាងនៃប្រភេទភស្តុតាងជាក់លាក់មួយចំនួន ដែលនាំឱ្យមានការបង្កើតនូវឋានុក្រមនៃភស្តុតាង ផ្អែកលើលក្ខណៈនៃភស្តុតាង ដោយមិនផ្អែកលើខ្លឹមសារនៃភស្តុតាង ហើយជាលទ្ធផល ផ្តល់នូវទម្ងន់តិចជាងចំពោះភស្តុតាងដែលប្រមូលបានដោយស្ថាប័នដទៃ ដោយសារតែមូលហេតុផ្លូវការប៉ុណ្ណោះ។ លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់ គួរតែជាឥទ្ធិពលដែលខ្លឹមសារនៃភស្តុតាងនោះអាចមានទៅលើជំនឿស្មោះត្រង់ពិតប្រាកដ របស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហាថាតើមានភស្តុតាងគ្រប់គ្រាន់ឬអត់សម្រាប់ការចោទប្រកាន់នោះ"* [49]។ (គូសបញ្ជាក់បន្ថែម)

---

[47] សេចក្តីពិចារណា កថាខណ្ឌ ៤៤។

[48] សេចក្តីពិចារណា កថាខណ្ឌ ៥១។

[49] សេចក្តីពិចារណា កថាខណ្ឌ ៥២។

v. "អង្គបុរេជំនុំជម្រះយល់ឃើញថា ជាបញ្ហាធ្ងន់ធ្ងរក្នុងការច្រានចោលជាមុនជាទូទៅនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនឱ្យទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន ហើយត្រូវទទួលបាន"តម្លៃជាភស្តុតាងទាបប៉ុណ្ណោះ" ដោយផ្អែកទៅលើកាលៈទេសៈនៃការកត់ត្រាពាក្យសុំតាំងខ្លួននោះ។ **អ.វ.ត.ក គឺជាតុលាការដំបូងគេ ដែលធ្វើការជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិជារួម ដែល ផ្តល់នូវឱកាសឱ្យជនរងគ្រោះបានចូលរួមដោយផ្ទាល់ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី**។ [...] ហេតុដូច្នេះ ប្រសិនបើសហចៅក្រមស៊ើបអង្កេត បដិសេធជាបឋមនូវសច្ចធារណ៍នៃភាពអាចជឿជាក់បានសម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយផ្តល់នូវតម្លៃជាភស្តុតាងទាបជាងភស្តុតាងដទៃទៀត ដែលប្រមូលបានដោយការិយាល័យសហចៅក្រមស៊ើបអង្កេតពេលនោះ សហចៅក្រមស៊ើបអង្កេតអាចខ្លួនឯងផ្ទាល់ ឬ តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស នឹងជាប់កាតព្វកិច្ចត្រូវស្តាប់ចម្លើយអ្នកដាក់ពាក្យសុំទាំងអស់ក្នុងនាមជាសាក្សី ដោយពិចារណាថា ពួកគាត់មាននូវព័ត៌មាន ដែលនាំទៅដល់ការស្វែងរកការពិត។ [...] និយាយម្យ៉ាងទៀត ការកំណត់ ឋានានុក្រមមិនត្រឹមត្រូវទៅលើភស្តុតាងដែលកំណត់ឡើងដោយសហចៅក្រម ស៊ើបអង្កេត ដោយបានបដិសេធនូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន និងផ្តល់នូវតម្លៃជាភស្តុតាងទាបជាទូទៅទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចជាការបង្ហាញនូវកំហុសឆ្គងធ្ងន់ធ្ងរក្នុងការបំពេញកិច្ចស៊ើបសួរ អនុលោម តាមវិធាន ៥៥(៥)នៃវិធានផ្ទៃក្នុង។ **បន្ថែមពីលើនេះទៀត ការកំណត់ឋានានុក្រមនេះនឹងមានផលវិបាកដល់ការកម្រិតទៅលើប្រសិទ្ធភាពនៃសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងតុលាការ យោងតាមអត្ថន័យនៃមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធាន ២១ នៃវិធានផ្ទៃក្នុង និងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ បើទោះបីជា អ.វ.ត.ក ស្ថិតក្នុង**

01588319



*ចំណោមតុលាការដែលមានលក្ខណៈជាតុលាការអន្តរជាតិដំបូងៗដែលបានផ្តល់ដល់ជនរងគ្រោះ នូវតួនាទីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីក្តី*[50]។

vi. ទាក់ទងនឹងចម្លើយរបស់ អ៊ឹម ចែម ដែលបានផ្តល់ទៅឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា អ.ប.ជ ដំបូងទទួលស្គាល់ថា ស.ច.ស.អន្តរជាតិ បានព្យាយាមតែមិនបានជោគជ័យដើម្បីឱ្យ អ៊ឹម ចែម មកបង្ហាញខ្លួនលើកដំបូង[51] ប៉ុន្តែ បន្ទាប់មក អ.ប.ជ អះអាងថា "ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ចម្លើយរបស់ជនសង្ស័យ ដែលបានផ្តល់ទៅឱ្យស្ថាប័នដទៃទៀត មិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការស្វែងរកការពិត ដោយសារតែប្រភពនៃចម្លើយនោះ សហចៅក្រមស៊ើបអង្កេត ចាំបាច់គួរតែអញ្ជើញជនសង្ស័យមកផ្តល់ចម្លើយឱ្យការិយាល័យរបស់ខ្លួន បន្ទាប់ពីសហមេធាវីរបស់ជនសង្ស័យ ទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង។ អង្គបុរេជំនុំជម្រះ មិនឃើញមានការចង្អុលបញ្ជាក់ណាមួយថា មានករណីបែបនេះឡើយ"[52]។ ដោយសារថា **អោ អាន** ក៏បានផ្តល់ចម្លើយឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ផងដែរ ហើយត្រូវបានយោងលើម្តងម្កាលនោះ ទើបបញ្ហានេះក៏ជាប់ពាក់ព័ន្ធផងដែរ នៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ។

vii. ជាងនេះទៀត អ.ប.ជ បានរិះគន់ ស.ច.ស ចំពោះការយោងលើការពិចារណាលើភ័ស្តុតាងពីដំណាក់កាលជំនុំជម្រះក្តី និងបណ្តឹងសាទុក្ខ ហើយបានផ្តល់មតិយោបល់ថា ការពិចារណាបែបនេះមិនអាចអនុវត្តបានឡើយ ពីព្រោះថា បទដ្ឋានភ័ស្តុតាង នៅដំណាក់កាលជំនុំជម្រះក្តីគឺខ្ពស់ជាង នៅដំណាក់កាលស៊ើបសួរ[53]។ អ.ប.ជ បានធ្វើសេចក្តីសន្និដ្ឋាន ដោយបញ្ជាក់ថា "*បទចោទគ្រប់គ្រាន់*"ត្រូវបំពេញតាមលក្ខខណ្ឌជាអប្បបរមានៃវិធានផ្ទៃក្នុង ៥៥(៤) គឺត្រូវ"*មានតម្រុយ*

[50] សេចក្តីពិចារណា កថាខណ្ឌ ៥៤-៥៦។

[51] សេចក្តីពិចារណា កថាខណ្ឌ ៥។

[52] សេចក្តីពិចារណា កថាខណ្ឌ ៥៩។

[53] សេចក្តីពិចារណា កថាខណ្ឌ ៦០-៦២។

*ច្បាស់លាស់ និងស៊ីចង្វាក់* បញ្ជាក់ថា បុគ្គលណាម្នាក់អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដូច្នេះហើយ ត្រូវសហចៅក្រមស៊ើបអង្កេតបញ្ជូនទៅជំនុំជម្រះ"[54]។

ខ) ចៅក្រមអន្តរជាតិ

i. ដោយយោងលើករណីយុត្តិសាស្ត្រពីតុលាការ ICTY, ICTR និង ICC ចៅក្រមអន្តរជាតិ បានកត់សម្គាល់ថា ស.ច.ស "*បានខិតខំកំណត់ចំនួនជនរងគ្រោះឱ្យបានត្រឹមត្រូវ និងច្បាស់លាស់សម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលមិនត្រូវបានចោទប្រកាន់*"។ ចៅក្រមអន្តរជាតិ យល់ឃើញថា "*លក្ខខណ្ឌតម្រូវនេះគ្មានយុត្តិកម្មឡើយ ជាពិសេសពាក់ព័ន្ធនឹងស្តង់ដារភស្តុតាង ដែលអាចអនុវត្តបាននៅដំណាក់កាលមុនពេលជំនុំជម្រះ។ ចៅក្រមអន្តរជាតិរំឭកឡើងវិញថា "វាអាចមិនសមហេតុផលទាល់តែសោះ ក្នុងការផ្តោតតែលើភាពជាក់លាក់កម្រិតខ្ពស់ក្នុងករណីឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងមិនចាំបាច់ដឹងច្បាស់ពីចំនួនជនរងគ្រោះជាក់លាក់នោះទេ។ ភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះជាក់លាក់ មិនបានទាត់ចោលសេចក្តីសន្និដ្ឋានថា ឧក្រិដ្ឋកម្មនានាត្រូវបានប្រព្រឹត្តនៅទីកន្លែង និងពេលវេលាជាក់លាក់ឡើយ*"[55]។

៣៧. គ្មានការរិះគន់ណាមួយក្នុងចំណោមការរិះគន់ទាំងនេះគួរឱ្យជឿជាក់នោះទេ ហេតុនេះហើយ មិនតម្រូវឱ្យមានការកែប្រែវិធីសាស្ត្រចំពោះដីកាដំណោះស្រាយដែលនៅសល់ឡើយ។

ក. *អ.ប.ជ ទាំងមូល*

i. ការណ៍ដែលថា អ្វីមួយមិនមានចែងនៅក្នុងលក្ខន្តិកៈ ឬវិធាននោះ មិនមានន័យថា អ្វីមួយនោះត្រូវបានហាមឃាត់ ឬមិនចាំបាច់ ឬគ្មានប្រយោជន៍ឡើយ។ គោលបំណងរបស់ ស.ច.ស គឺចង់ផ្តល់តម្លាភាពពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់ខ្លួននៅពេលដែលវាយតម្លៃភស្តុតាងនៅក្នុងសំណុំរឿង។ វិធីសាស្ត្រដែលគាំទ្រដោយ អ.ប.ជ មិនទទួលបានតម្លាភាពកម្រិតដូចគ្នាឡើយ។ ជាងនេះទៀត គោល

---

[54] សេចក្តីពិចារណា កថាខណ្ឌ ៦២។

[55] សេចក្តីពិចារណា កថាខណ្ឌ ២១៤។

01588321



បំណងនៃជំពូកស្ដីពីការពិចារណាលើភស្តុតាង បើគិតតាមគណិតវិទ្យា គឺដើម្បីទាញយកកត្តារួមចេញ ដូចក្នុងសមីការ ab+ac= a(b+c) ជាវិធីសាស្ត្រដែលបានអនុវត្តចំពោះការវាយតម្លៃភស្តុតាងទាំងអស់ នៅទីតាំងឧក្រិដ្ឋកម្មនីមួយៗ ។ល។ ស.ច.ស មិនមានបំណងបង្កើតទ្រឹស្ដីឋានានុក្រមភស្តុតាង នៅក្នុងបរិបទដែលភាគច្រើនលើសលុបមានវិធានផ្លូវការស្ដីពីភស្តុតាង ហើយឋានានុក្រមតឹងរ៉ឹងបែបនេះក៏មិនបានអនុវត្តដែរនៅពេលដែលវាយតម្លៃភស្តុតាងនាពេលកន្លងមក[56]។

ii. ស.ច.ស ទាំងពីរ មកពីប្រព័ន្ធច្បាប់ស៊ីវិល គឺមកពីប្រទេសអាល្លឺម៉ង់ និងកម្ពុជា។ ប៉ុន្តែ ការប្រៀបធៀបតែប្រព័ន្ធច្បាប់ទាំងពីរនេះបង្ហាញឱ្យឃើញរួចហើយថា មិនមាន "ប្រព័ន្ធច្បាប់ស៊ីវិល" តែមួយនោះទេ។ ហេតុនេះ អ.ប.ជ បានដកស្រង់ខ្លឹមសារដែលមិនមានប្រយោជន៍[57]។

iii. ការយល់ឃើញដែលបានបង្ហាញជាទូទៅថា ភស្តុតាងទាំងអស់ទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានដូចគ្នា ឲ្យតែភស្តុតាងទាំងនោះ ប្រមូលបានដោយស្របច្បាប់ គឺជាការយល់ឃើញមិនត្រឹមត្រូវ។ ឧទាហរណ៍ ពីរ អាចគ្រប់គ្រាន់ហើយដើម្បីបញ្ជាក់ពីភាពមិនត្រឹមត្រូវនេះ៖ ជាច្រើនឆ្នាំកន្លងមក ចម្លើយសារភាពយ៉ាងច្រើននៅមន្ទីរសន្តិសុខ ស ២១ ត្រូវបានប្រមូលដោយស្របច្បាប់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឬដោយមន្ទីរសន្តិសុខ ស ២១ ប៉ុន្តែ ផ្ទុយមកវិញ ដោយសារថា ចម្លើយសារភាពទាំងនេះបានធ្វើឡើង ដោយពាក់ព័ន្ធ

---

[56] ស.ច.ស ជាតិ គឺជា ស.ច.ស ដដែលតាំងពីដើម ដែលបានចុះហត្ថលេខាលើដីកាដំណោះស្រាយសំណុំរឿង ០០១ និង ០០២ ផងដែរ។ ការពិតនេះប្រហែលជាអាចឲ្យ អ.ប.ជ បានពិចារណាលើលក្ខណៈនៃទឡ្ហីករណ៍នោះ។

[57] តាមពិត ការដកស្រង់ដែល អ.ប.ជ បានប្រើប្រាស់ ហាក់ដូចជាបង្ហាញថា "ប្រព័ន្ធច្បាប់ស៊ីវិល"គឺស្មើគ្នានឹងប្រព័ន្ធច្បាប់បារាំង ទោះតិច ឬច្រើន។ អំពីគ្រោះថ្នាក់នៃការដកស្រង់ខ្លឹមសារ នៅក្នុងការស្រាវជ្រាវប្រៀបធៀប នាពេលថ្មីៗនេះ សូមមើល Albin Eser *ច្បាប់ព្រហ្មទណ្ឌប្រៀបធៀប* (CH Beck/Hart/NOMOS, Munich/Oxford/Baden-Baden, 2017) ត្រង់ទំព័រ ១៤១ [ភាសាអង់គ្លេស]។ Eser ណែនាំថា សំខាន់"កុំចង់បានការរំពឹងទុកដែលមិនអាចសម្រេចបាន មិនត្រូវធ្វើសេចក្ដីសន្និដ្ឋានលឿនពេក និងឲ្យមានតែមួយភាគីឡើយចំពោះគោលដៅហរដែលបានសង្ឃឹមទុក ហើយបើតាមទ្រឹស្ដីក៏មិនត្រូវពិចារណាសើៗ និងគ្មានជំនាញឡើយ [...]"។

ជាមួយនឹងការធ្វើទារុណកម្ម ទើបចម្លើយសារភាពទាំងនេះមិនទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានទាល់តែសោះ។ ឧទាហរណ៍ ប្រសិនបើ យកតាមការយល់ឃើញរបស់ អ.ប.ជ ទាំងស្រុង នោះក៏មានន័យផងដែរថា លិខិតអនាមិកមួយដែលគ្រាន់តែមានពាក្យថា "អោ អាន ជាអ្នកធ្វើលិខិតនេះ!" ហើយបានប្រគល់ជូនអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ក្នុងអំឡុងពេលចុះបេសកកម្ម និងបានដាក់ចូលក្នុងសំណុំរឿង ជាផ្នែកមួយនៃរបាយការណ៍បំពេញកិច្ចស៊ើបសួររបស់អ្នកស៊ើបអង្កេតនោះ ក៏ទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បាន ដូចគ្នានឹងកំណត់ហេតុស្តាប់ចម្លើយចំនួន ២០០ ទំព័រដែលធ្វើឡើងដោយ ស.ច.ស ខ្លួនឯងផងដែរ។ ចុងក្រោយ គោលការណ៍សេរីភាពក្នុងការវាយតម្លៃភស្តុតាងផ្តល់ឆន្ទានុសិទ្ធិជូនចៅក្រម ប៉ុន្តែ មិនមែនជាអាជ្ញាបណ្ណឲ្យធ្វើតាមទំនើងចិត្តឡើយ គឺថា ចៅក្រមត្រូវតែផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួន ហើយសំអាងហេតុទាំងនោះត្រូវតែពាក់ព័ន្ធនឹងដែនកំណត់ទូទៅមួយចំនួនដែលច្បាប់ និងតុលាការទទួលយក។

iv. នីតិវិធីនៅចំពោះមុខ អ.វ.ត.ក អាចជាប្រព័ន្ធដដែកសួរដេញដោល យ៉ាងហោចណាស់នៅដំណាក់កាលស៊ើបសួរ ប៉ុន្តែ ការហៅ នីតិវិធីនេះថា *"ផ្អែកលើភស្តុតាងជាលាយលក្ខណ៍អក្សរ"* ហើយព្យាយាមទាញសេចក្តីសន្និដ្ឋានអំពីលក្ខណាវិនិច្ឆ័យភស្តុតាងពីនោះ គឺក្បត់ឆន្ទៈខ្លួនឯងដែលចូលចិត្តចង់បានអ្វីដែលអាចមើលឃើញ។ តាមពិត ភស្តុតាងនៅក្នុងសំណុំរឿងគឺមានទម្រង់ជាលាយលក្ខណ៍អក្សរ ប៉ុន្តែ មិនមែនជាខ្លឹមសារភស្តុតាងទេ ប្រសិនបើភស្តុតាងនោះមិនមែនជាភស្តុតាងឯកសារពិតប្រាកដ។ ខ្លឹមសារភស្តុតាង និងប្រភពបញ្ជាក់ពីភស្តុតាងនោះជាលាយលក្ខណ៍អក្សរនៅក្នុងសំណុំរឿង គឺជាអ្វីដែលផ្តល់ជាមូលដ្ឋានដើម្បីវាយតម្លៃភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាន។ ជាងនេះទៀត ទោះបីជា ស.ច.ស មិនបានសរសេរជំពូកស្តីពីការពិចារណាលើភស្តុតាង ជាគោលការណ៍ទ្រឹស្តីអំពីភស្តុតាងយ៉ាងណាក៏ដោយ ក៏ជាការពិតច្បាស់ពេកទៅហើយដែលថា *មាន*ឋានានុក្រមភស្តុតាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល។

អ.ប.ជ ខ្លួនឯងក៏ទទួលស្គាល់ច្រើនដែរ នៅពេលដែល អ.ប.ជ បញ្ចូលឃ្លាបន្ថែមន័យថា(*លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ*)។ ឃ្លាបន្ថែមន័យនេះគ្មានអ្វីក្រៅពីទទួលស្គាល់ថាមានលក្ខខណ្ឌហាមនុក្រមនៅក្នុងច្បាប់ឡើយ[58]។

v. ទឡ្ហីករណ៍ពាក់ព័ន្ធនឹងបញ្ហាតួនាទីដំបូងគេរបស់ អ.វ.ត.ក ទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះគឺជាការបំភាន់៖ សេចក្ដីសម្រេចលើគោលការណ៍ដែលអនុញ្ញាតឱ្យជនរងគ្រោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធី មិនជាប់ពាក់ព័ន្ធអ្វីឡើយថា តើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ នៅក្នុងពាក្យសុំរបស់ខ្លួន អាចគួរឱ្យជឿជាក់បាន និងអាចទុកចិត្តបានយ៉ាងណា។ នេះមិនមានន័យថាជាការសន្មតជាទូទៅថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់អាចជឿជាក់បាន ដោយសារថា ពាក្យសុំទាំងនោះចេញមកពីជនរង

---

[58]ករណីនេះយកមកអនុវត្តស្ទើរតែនៅក្នុងច្បាប់បារាំងក៏ដោយ ដូចមានឧទាហរណ៍មួយបង្ហាញជូនខាងក្រោមនេះ៖ កំណត់ហេតុមានតម្លៃជាភស្តុតាងផ្សេងៗគ្នា អាស្រ័យលើរបៀប/នរណាជារៀបចំកំណត់ហេតុនោះ៖ កំណត់ហេតុមានតម្លៃជាភស្តុតាងតែក្នុងករណីដែលកំណត់ហេតុមានទម្រង់ដែលជាប្រចាំ ហើយអ្នកធ្វើកំណត់ហេតុ ដោយបំពេញកិច្ច អនុវត្តភារកិច្ចរបស់ខ្លួន រាយការណ៍អំពីប្រធានបទដែលជាសមត្ថកិច្ចរបស់ខ្លួនអំពីអ្វីដែលគាត់បានឃើញ បានឮ ឬបានឃើញដោយផ្ទាល់ (មាត្រា ៤២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ លើកលែងករណីដែលច្បាប់ចែងផ្ទុយពីនេះ កំណត់ហេតុពាក់ព័ន្ធនឹងបទល្មើស គ្រាន់តែជាប្រភពនៃព័ត៌មានតែប៉ុណ្ណោះ (មាត្រា ៤៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារសាធារណៈទទួលបន្ទុកមុខងារមួយចំនួនរបស់នគរបាលយុត្តិធម៌ ទទួលបានតាមរយៈបទប្បញ្ញត្តិច្បាប់ណាមួយនូវអំណាចដើម្បីបញ្ជាក់ពីបទល្មើស តាមរយៈកំណត់ហេតុ ឬរបាយការណ៍នោះ ភស្តុតាងដែលផ្ទុយអាចបង្ហាញជូនបានតែក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬតាមរយៈសាក្សីតែប៉ុណ្ណោះ (មាត្រា ៤៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលមួយទៀត តុលាការកំពូលកូរ៉េ(ខាងត្បូង) គោរពតាមវិធានល្អបំផុតអំពីភស្តុតាង៖ "*តុលាការកំពូលកូរ៉េ ចាត់ទុកសក្ខីកម្មផ្ទាល់មាត់ ជាភស្តុតាងដើម ហើយសក្ខីកម្មលាយលក្ខណ៍អក្សរជាភស្តុតាងជំនួសភស្តុតាងដើម ហើយជឿថា សក្ខីកម្មផ្ទាល់មាត់គួរតែជាមូលដ្ឋានសម្រាប់ការជំនុំជម្រះក្ដី។ សំណៅចតម្លងទទួលបានសិទ្ធិជាភស្តុតាងដូចគ្នានឹងសំណៅដើម តែក្នុងករណីដែលបានបំពេញតាមលក្ខខណ្ឌច្បាស់លាស់តែប៉ុណ្ណោះ។ នេះអាចចាត់ទុកថាជាសេចក្ដីសម្រេចរបស់តុលាការកំពូលកូរ៉េក្នុងការអនុវត្តវិធានល្អបំផុតអំពីភស្តុតាង*"។ សូមមើល Sang Won Lee វិធានល្អបំផុតអំពីភស្តុតាងក្នុងយុគសម័យឌីជីថល ដែលមាននៅក្នុងសៀវភៅចំណងជើង បញ្ហាបច្ចុប្បន្ននៅក្នុងច្បាប់កូរ៉េ កែសម្រួលដោយ Laurent Mayali/John Yoo. The Robbins Collection. Berkeley ឆ្នាំ ២០១៤ ទំព័រ ១៨៨ គេហទំព័រ www.law.berkeley.edu/robbins។ ច្បាប់កម្ពុជាមិនខុសពីនេះដែរ សូមមើលមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០១៧ ដែលមានចែងផងដែរអំពីសេចក្ដីណែនាំមួយចំនួនអំពីការប្រើប្រាស់ភស្តុតាង។

គ្រោះនោះទេ។ តាមពិត នៅពេលខ្លះ នៅ ក.ស.ច.ស មានសេចក្តីព្រួយបារម្ភអំពីគំរូស្រដៀងគ្នាកើតចេញពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលដាក់មកពីប្រភពណាមួយ ដោយក្នុងនោះប្រភពដែលដាក់ពាក្យសុំមិនបានពិនិត្យខ្លឹមសារ និងភាពពាក់ព័ន្ធនៃពាក្យសុំនីមួយៗឱ្យបានត្រឹមត្រូវទេ។ ទោះបីជាថា ស.ច.ស មានអន្លានុសិទ្ធិទូលំទូលាយអំពីរបៀប បំពេញកិច្ចស៊ើបសួរក៏ដោយ ក៏តាមពិត មានការស្តាប់ចម្លើយតែអ្នកដាក់ពាក្យសុំណា ដែលពាក្យសុំអាចឱ្យមានការវិនិច្ឆ័យបានគ្រប់គ្រាន់ថា អាចមានប្រយោជន៍ជាភ័ស្តុតាងសម្រាប់ការស៊ើបសួរតែប៉ុណ្ណោះ។ ការតម្រូវឱ្យ ស.ច.ស ស្តាប់ចម្លើយមនុស្ស គ្រប់គ្នា ឬទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ គឺ ផ្ទុយ ស្រឡះពីភាពជាក់ស្តែងនៃការអនុវត្តកិច្ចស៊ើបសួរ ហើយ ជាការព្រួយបារម្ភយ៉ាងខ្លាំងនៅក្នុងបរិបទដែលមានការរិះគន់ជាទូទៅមកលើ ស.ច.ស ចំពោះការពន្យារពេលហួសហេតុ។

vi. អ.ប.ជ មានមតិយោបល់ផ្ទុយជាមួយខ្លួនឯង គឺ អ.ប.ជ ទទួលស្គាល់ថា ចៅក្រម Harmon បានព្យាយាមតែមិនបានជោគជ័យដើម្បីឱ្យ **អ៊ឹម ចែម** មកបង្ហាញខ្លួនលើកដំបូង ប៉ុន្តែ បន្ទាប់មក អ.ប.ជ លើកឡើងថា អ.ប.ជ រកមិនឃើញថា មានសញ្ញាណាមួយបង្ហាញថា មានការព្យាយាមដើម្បីស្តាប់ចម្លើយ **អ៊ឹម ចែម** ទេ។ ក្រៅ ពីចំណុចនេះ ទឡ្ហីករណ៍នេះក៏មិនអាចមានការពាក់ព័ន្ធនៅក្នុងសំណុំរឿងដែលនៅ សល់ដែរ៖ **អោ អាន** និងជនត្រូវចោទទាំងអស់ផ្សេងទៀតបានបង្ហាញខ្លួននៅ ចំពោះមុខ ស.ច.ស អន្តរជាតិ ហើយដោយមានវត្តមានរបស់មេធាវីការពារក្តីស្ទើតែបានប្រកាសថា ខ្លួននឹងមិនបញ្ចេញមតិយោបល់ណាមួយឡើយ។ ការសម្រេចនេះត្រូវតែគោរពដោយ ស.ច.ស ហើយម្យ៉ាងទៀត បើទោះបីជាព្យាយាមថែមទៀតដើម្បីស្តាប់ចម្លើយជនត្រូវចោទទាំងនេះក៏ដោយ ក៏មិនមានប្រយោជន៍ដែរទោះក្នុងករណីណាក៏ដោយ។

vii. ចុងក្រោយ ការរិះគន់អំពីការប្រើប្រាស់ករណីយុត្តិសាស្ត្រអំពីការវាយតម្លៃភ័ស្តុតាង ពីដំណាក់កាលជំនុំជម្រះក្តី និងបណ្តឹងសាទុក្ខ គឺជាការរិះគន់មិនសំខាន់

01588325



ពីព្រោះថា អ.ប.ជ ដាក់បញ្ចូលគ្នារវាង *បទដ្ឋានភស្តុតាង* ដែលពិតជាមានលក្ខណៈខុសគ្នានៅដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ជាមួយនឹងគោលការណ៍ចែងអំពី *ការវាយតម្លៃភស្តុតាង* ដែលមានលក្ខណៈដូចគ្នានៅគ្រប់ដំណាក់កាលទាំងអស់នៃ កិច្ចដំណើរការនីតិវិធី។ ប៉ុន្តែ ការលើកឡើងរបស់ អ.ប.ជ ដែលថា "*បទចោទ គ្រប់គ្រាន់*" ត្រូវបំពេញតាមលក្ខខណ្ឌជាអប្បបរមាគឺត្រូវ "*មានតម្រុយច្បាស់លាស់ និងស៊ីចង្វាក់*" នោះ ធ្វើឲ្យមានមន្ទិលថាតើឥឡូវនេះ អ.ប.ជ ចាត់ទុកថា បទដ្ឋានភស្តុតាង ដើម្បីដាក់ជនសង្ស័យឲ្យស្ថិតក្រោមការពិនិត្យ ក៏ជាភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជូន ជនត្រូវចោទទៅជំនុំជម្រះដែរ ឬអត់។

ខ. ចៅក្រមអន្តរជាតិ

i. ទីមួយ ចៅក្រមអន្តរជាតិ មានការយល់ច្រឡំអំពីអ្វីដែល ស.ច.ស បានធ្វើ៖ ស.ច.ស មិនមានបំណងបង្កើតឲ្យមានចំនួន *ត្រឹមត្រូវ ឬច្បាស់លាស់* ទេ ប៉ុន្តែចង់បានចំនួនប៉ាន់ស្មានអប្បបរមាដ៏ប្រយ័ត្នប្រយែង ហើយវិធីសាស្ត្រដូចគ្នាត្រូវបានអនុវត្តនៅក្នុងដីកាដំណោះស្រាយនេះ។ ស.ច.ស បានដឹងយ៉ាងច្បាស់ថា ចំនួនច្បាស់លាស់មិនអាចទទួលបានឡើយនៅក្នុងកិច្ចដំណើរការនីតិវិធីប្រភេទនេះ ប៉ុន្តែ នេះមិនអាចរារាំងចៅក្រមមិនឲ្យព្យាយាមឲ្យបានច្បាស់លាស់តាម ដែលអាចធ្វើទៅបានទៅតាមកាលៈទេសៈឡើយ ហើយម្យ៉ាងទៀត គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនសង្ស័យ ក៏អនុវត្តផងដែរ នៅក្នុងបរិបទដែលបញ្ជាក់ពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ជាធាតុផ្សំនៃយុត្តាធិការបុគ្គល[59]។

ii. ទីពីរ ករណីយុត្តិសាស្ត្រដែលចៅក្រមអន្តរជាតិបានដកស្រង់ដើម្បីគាំទ្រការយល់ឃើញរបស់ខ្លួនដែលថា នៅក្នុងនីតិវិធីបញ្ជាក់ពីបទចោទ ដោយអង្គបុរេជំនុំជម្រះ

---

[59] ការយល់ឃើញនេះត្រូវបានបង្ហាញដោយ ស.ច.ស.អន្តរជាតិនៅក្នុង*ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៤ របស់ អោ អាន* ឯកសារ D244/1 ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ កថាខណ្ឌ ២៤-២៦។ ដីកាសម្រេចនេះមិនមានការប្តឹងឧទ្ធរណ៍ទេ។ អ.ប.ជ មិនមានមតិយោបល់តាមការផ្តួចផ្តើមគំនិតខ្លួនឯងលើចំណុចនេះទេរហូតមកដល់កាលបរិច្ឆេទនេះនៅក្នុងសំណុំរឿងដែលនៅសេសសល់។

របស់តុលាការ ICC និងក្រោយមក នៅក្នុងដំណាក់កាលជំនុំជម្រះក្តី មិនមានលក្ខខណ្ឌតម្រូវឱ្យព្យាយាមឱ្យបានច្បាស់លាស់ក្នុងករណីឧក្រិដ្ឋកម្មរួមនោះទេ គឺជាករណីយុត្តិសាស្ត្រដែលនៅមានមន្ទិលយ៉ាងខ្លាំងរួចទៅហើយ ហើយភាគច្រើនទំនងជាត្រូវទុកជាមោឃៈសម្រាប់គោលបំណង និងចេតនាគ្រប់យ៉ាង ក្រោយពីអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICC បានចេញសាលដីកាសំឡេងភាគច្រើន ៣ៈ ២ នៅក្នុងរឿងក្តី Bemba កាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨[60]។ មុននោះអង្គជំនុំជម្រះសាលាដំបូង ដែលគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូលសំឡេងភាគតិច[61] បានធ្វើការជំទាស់ស្រដៀងគ្នានេះទៅអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងតម្រូវការបញ្ជាក់ពីហេតុការណ៍នីមួយៗ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលសំឡេងភាគច្រើន បានសម្រេចថា ការជំទាស់នេះមិនសមស្រប ឡើយ[62]។ អង្គជំនុំជម្រះតុលាការកំពូលសំឡេងភាគច្រើន ក៏បានបញ្ជាក់ច្បាស់លាស់ផងដែរអំពីបញ្ហាភាពអាចជឿជាក់បាននៃភស្តុតាង និងតម្លៃជាភស្តុតាង ហេតុនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលសំឡេងភាគច្រើន ជួយពង្រឹងទឡ្ហីករណ៍ដែលបានលើកឡើងខាងលើជំទាស់នឹងការរិះគន់របស់ អ.ប.ជ ទាំងមូល[63]។

iii. ចៅក្រម Eboe-Osuji បានធ្វើការសង្ខេបយ៉ាងល្អអំពីបញ្ហានេះដូចខាងក្រោម៖

---

[60] *រឿងក្តី ព្រះរាជអាជ្ញាតទល់នឹង Jean-Pierre Bemba Gombo* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC (សំណុំរឿងលេខ ICC-01/05-01/08A) ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ ("សាលដីការឿងក្តី Bemba AC") ដោយមានមតិយោបល់រួមគ្នារបស់ចៅក្រម Van den Wyngaert និងចៅក្រម Morrison ("Wyngaert/Morrison") សំណុំរឿងលេខ ICC-01/05-01/08-3636-ឧបសម្ព័ន្ធ ២ និងមតិយោបល់ដាច់ដោយឡែករបស់ចៅក្រម ("Eboe-Osuji") សំណុំរឿងលេខ ICC-01/05-01/08-3636-ឧបសម្ព័ន្ធ ៣ ដែលចៅក្រមទាំងបីរូបនេះសុទ្ធតែស្ថិតនៅក្នុងចំណោមចៅក្រមសំឡេងភាគច្រើន។

[61] មតិយោបល់ជំទាស់របស់ចៅក្រម Monageng និងចៅក្រម Hofmanski សំណុំរឿងលេខ ICC-01/05-01/08-3636-ឧបសម្ព័ន្ធ ១.ពណ៌ក្រហម។ ជាពិសេស សូមមើលមតិយោបល់របស់ចៅក្រមនៅកថាខណ្ឌ ៣៣-៣៩។

[62] ឧទាហរណ៍ សាលដីការឿងក្តី Bemba AC កថាខណ្ឌ ១០៣-១០៤, ១១០, ១៨៣-១៨៤, ១៩២។

[63] Wyngaert/Morrison កថាខណ្ឌ ៨-៩, ២៣-២៥, ៧៤ និង ៧៩។

01588327



> "ការរកឃើញអំពីពិរុទ្ធ [...] មិនមែនកើតចេញពីការឱ្យតម្លៃបំប៉ោងទៅលើភស្តុតាងដែលមានបានតាមរបៀបជំនាញឡើយ ហើយក៏មិនមែនកើតចេញពីការវិភាគភស្តុតាងដែលបង្ហាញឱ្យឃើញថា មានការបង្វែរទិសដៅដោយចេតនាដោយគិតពីដីកាបញ្ជូនទៅជំនុំជម្រះ។ ក្នុងនោះ ការពិចារណាអាចចាប់ផ្តើមមើលឃើញពីអ្វីដែលមិនមាន"[64]។

## ២.៤. សេចក្តីសន្និដ្ឋាន

៣៨. ការវិភាគខាងលើបង្ហាញឱ្យឃើញថា សេចក្តីពិចារណារបស់ អ.ប.ជ ទោះបីជាសេចក្តីពិចារណារបស់ អ.ប.ជ ទាំងមូល ឬដោយខ្វះការយកចិត្តទុកដាក់ក៏ដោយ គឺមិនបានជួយដល់ការងាររបស់ ស.ច.ស ហើយក៏មិនផ្តល់ជាការណែនាំដ៏មានប្រយោជន៍ក្នុងការចេញដីកាដំណោះស្រាយដែលនៅសល់ឡើយ។

## ៣. ការជំទាស់នីតិវិធីជាទូទៅពីមេធាវីការពារក្តី

៣៩. មេធាវីការពារក្តី លើកឡើងពីការជំទាស់ជាទូទៅមួយចំនួនពាក់ព័ន្ធនឹងនីតិវិធីស៊ើបសួរ។ ការជំទាស់ទាំងនេះមានដូចខាងក្រោម៖

ក. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ("ដីកាសន្និដ្ឋានលើកទី ៣") មានកំហុសឆ្គង ពីព្រោះថា ស.ព.អ បានចាប់ផ្តើមបំពេញកិច្ចស៊ើបសួរបឋម ដោយឯកតោភាគី ដោយមិនមានការពិគ្រោះយោបល់ជាមុនជាមួយ ស.ព.ជ[65] ហើយដីកានេះមិនមានហត្ថលេខារបស់ ស.ព.ជទេ[66]។ មេធាវីការពារក្តីអះអាងថា កំហុសទាំងនេះជាក់ស្តែងធ្វើឱ្យកិច្ចស៊ើបសួរទាំងមូលត្រូវទុកជាមោឃៈ[67]។

ខ. ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ត្រូវទុកជាមោឃៈ ពីព្រោះថា វាមិនមានការចុះហត្ថលេខា ឬការធ្វើកំណត់ហេតុលើករណីខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.ជ ហេតុនេះ ស.ព.អ មិនអាចដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន

---

[64] Eboe-Osuji កថាខណ្ឌ ១០។

[65] ចម្លើយតប កថាខណ្ឌ ២៥-២៧។

[66] ចម្លើយតប កថាខណ្ឌ ២៨-២៩។

[67] ចម្លើយតប កថាខណ្ឌ ៣១។

បានឡើយ[68]។ ជាពិសេស មេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍ថា ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នាមិនត្រូវបានអនុញ្ញាតទេតាមច្បាប់ជាធរមាន[69]។

គ. ស.ច.ស មិនអាចការពារភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី បន្ទាប់ពីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះបានឡើយ ហេតុនេះចាំបាច់ត្រូវផ្អាកកិច្ចដំណើរការនីតិវិធី[70]។ ក្រៅពីបញ្ហាថវិកាដែលបានលើកឡើងនៅក្នុងដីកាសម្រេចរបស់ ស.ច.ស លើផលប៉ះពាល់ដោយសារស្ថានភាពថវិកាចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧[71] នោះ ការប្រកាសជាសាធារណៈ និងជាងដែលៗរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីកង្វះឆន្ទៈគាំទ្រការជំនុំជម្រះក្តីណាមួយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ នឹងនាំឱ្យមានស្ថានភាពមួយដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចធ្វើឱ្យ អោ អាន មានសេចក្តីព្រួយបារម្ភ ដោយមិនមានការរំពឹងថា នឹងមានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឆាប់រហ័សទេ ប្រសិនបើមិនមានការធានាកិច្ចសហការពីរាជរដ្ឋាភិបាលកម្ពុជាមុនពេលចេញដីកាដំណោះស្រាយ[72]។ មានការលើកឡើងថា ស.ច.ស មិនអាចការពារសិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌បានឡើយ បន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[73]។

ឃ. ស.ព.អ កំពុងស្វះស្វែងពង្រីកវិសាលភាពនៃដីកាដំណោះស្រាយ ដោយស្នើសុំឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអង្គហេតុដែល **អោ អាន** មិនត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ[74]។ មេធាវីការពារក្តីមិនជំទាស់នឹងសំណើរបស់ ស.ព.អ ដែល

---

[68] ចម្លើយតប កថាខណ្ឌ ៣៣-៣៤។

[69] ចម្លើយតប កថាខណ្ឌ ៣៥-៣៦។

[70] ចម្លើយតប កថាខណ្ឌ ៤១-៤៥។

[71] *សូមមើល* **សំណុំរឿង ០០៤/២- ឯកសារ D349/6** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំសរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧។

[72] ចម្លើយតប កថាខណ្ឌ ៤៤។

[73] ចម្លើយតប កថាខណ្ឌ ៤៥។

[74] ចម្លើយតប កថាខណ្ឌ ៤៧-៤៨។

សុំលើកលែងបទចោទនៃឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដោយផ្អែកលើមូលដ្ឋានថា ឧក្រិដ្ឋកម្មបែបនេះលែងមានអាជ្ញាយុកាលហើយ[75]។

ង. អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ **អោ អាន** ទេ[76]។ ស.ច.ស មិនគួរធ្វើតាមសាលដីការបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០១ អំពីការបកស្រាយពាក្យថា "*មេដឹកនាំជាន់ខ្ពស់*"និងជនទាំងឡាយដែល"*ទទួលខុសត្រូវខ្ពស់បំផុត*"[77]។ ជាពិសេសពាក្យទាំងនេះគួរត្រូវបកស្រាយថាជាលក្ខណៈវិនិច្ឆ័យយុត្តាធិការពេញលេញ[78]។

៤០. ការជំទាស់ជាទូទៅទាំងនេះគួរត្រូវដោះស្រាយជាមុនសិន។

**៣.១. ដីកាសន្និដ្ឋានលើកទី ៣ មានកំហុសឆ្គង ហើយកិច្ចស៊ើបសួរទាំងមូលត្រូវទុកជាមោឃៈ**

៤១. ទឡ្ហីករណ៍នេះបាត់ភាពជាក់ស្តែងអំពីនីតិវិធីដែលសំណុំរឿង ០០៤ ទាំងមូល ក៏ដូចជាសំណុំរឿង ០០៤/២ ផងដែរ បានវិវត្តចាប់តាំងពីពេលដាក់ដីកាសន្និដ្ឋានលើកទី ៣ ជាពិសេសចាប់តាំងពីមាននីតិវិធី បណ្តឹងករណីខ្វែងយោបល់គ្នាពីដំបូងរវាង ស.ព.អ ជាមួយនឹង ស.ព.ជ នៅចំពោះមុខ អ.ប.ជ[79] ហើយ អ.ប.ជ មិនមានសំឡេងភាគច្រើនសម្រេចលើការយល់ឃើញណាមួយឡើយ ហេតុនេះអនុញ្ញាតឱ្យដីកាសន្និដ្ឋានលើកទី ៣ បន្តនីតិវិធីទៅមុខ[80]។ ទោះបីជាយ៉ាងណាក៏ដោយ ការចោទប្រកាន់ថាមិនមានដីកាសន្និដ្ឋានដែលបានដាក់ត្រឹមត្រូវទេ នៅតែជាបញ្ហាមួយ ដែលចៅក្រមទាំងអស់ត្រូវតែដោះស្រាយជាភារកិច្ចរបស់ខ្លួន និងនៅដំណាក់កាលណាក៏ដោយនៃកិច្ចដំណើរការនីតិវិធី។

---

[75] ចម្លើយតប កថាខណ្ឌ ៥១។

[76] ចម្លើយតប កថាខណ្ឌ ៥៣-៥៥។

[77] ចម្លើយតប កថាខណ្ឌ ៥៣, ៧៧-៧៩។

[78] ចម្លើយតប កថាខណ្ឌ ៥៦, ៦២-៦៩។

[79] ដីកាសន្និដ្ឋានស្ពាពរបស់ ស.ព.ជ កថាខណ្ឌ ២-១២។

[80] **សំណុំរឿង ០០៤- ឯកសារ** D121/4/1/4 *ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើសុំពិនិត្យមើល ឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត* ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១២។

៤២. នៅក្នុងបរិបទនេះ គួរកត់សម្គាល់ថា ម្យ៉ាង ស.ច.ស ទាំងពីរ បានអនុវត្តនីតិវិធីចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ លើអង្គសេចក្ដីនៃបញ្ហាចោទអំពីយុត្តាធិការបុគ្គល។ ស.ច.ស ទាំងពីរ មិនបានផ្ដល់សំអាងហេតុថា ចាំបាច់ត្រូវលើកលែងការចោទប្រកាន់ ដោយសារថា មានកំហុសនីតិវិធីធ្ងន់ធ្ងរនៅក្នុងដីកាសន្និដ្ឋានលើកទី ៣ ដែលនាំឱ្យមោឃភាពកិច្ចស៊ើបសួរទាំងមូលទេ។ ម្យ៉ាងវិញទៀត អ.ប.ជ រាប់បញ្ចូលទាំងចៅក្រមជាតិ ដែលមេធាវីការពារក្ដី ហាក់ដូចជាលើកឡើងថាជាសំឡេងនៃការបកស្រាយយថាភាពនោះ[81] បានដោះស្រាយដូចគ្នាលើបណ្ដឹងឧទ្ធរណ៍ និងពាក្យសុំរបស់ភាគីនានា ដោយផ្អែកលើមូលដ្ឋាននៃកង្វះយុត្តាធិការបុគ្គលជាទូទៅ(លើកឡើងដោយចៅក្រមជាតិ) ឬក៏លើអង្គសេចក្ដីនៃបណ្ដឹង។ ជាពិសេស គួរកត់សម្គាល់ថា នាពេលថ្មីៗនេះ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤ និង ០០៤/២ រកបានសំឡេងភាគច្រើនតាមលក្ខខណ្ឌតម្រូវដើម្បីសម្រេចលើភាពអាចទទួលយក និង/ឬអង្គសេចក្ដីនៃពាក្យសុំមោឃភាពចំនួនពីរ និងបណ្ដឹងឧទ្ធរណ៍ចំនួនពីររបស់មេធាវីការពារក្ដី យឹម ទិត្យ និង **អោ អាន**[82]។ ករណីនេះបានកើតឡើង ទោះបីជាថា នៅក្នុងសេចក្ដីសម្រេចពីមុនៗនៅក្នុងសំណុំរឿង ០០៤ សំណុំរឿង ០០៤/១ សំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ ចៅក្រមជាតិជាធម្មតាបានសម្រេចថា មិនមានយុត្តាធិការបុគ្គលទេ ហេតុនេះ កិច្ចស៊ើបសួរទាំងអស់គួរទុកជាមោឃៈ[83] ឬក៏តាមសំអាងហេតុដូចគ្នានេះ មិនចាំបាច់បំពេញកិច្ចស៊ើបសួរ

---

[81] ចម្លើយតប កថាខណ្ឌ ៥៤។

[82] **សំណុំរឿង ០០៤-D360/1/1/6** *សេចក្ដីសម្រេចលើពាក្យសុំរបស់ យឹម ទិត្យ សុំធ្វើមោឃភាពការដាក់សក្ខីកម្មផ្ទាល់មាត់ពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤* ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧។ **សំណុំរឿង ០០៤- ឯកសារ D351/1/4** *សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាព ឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ Paolo Stocchi* ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧។ **សំណុំរឿង ០០៤- ឯកសារ D347/2/1/4** *សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំដាក់សម្ភារៈទៅក្នុងសំណុំរឿង ០០៤* ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧។ **សំណុំរឿង ០០៤/២- ឯកសារ D350/1//1/4** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើពាក្យសុំរបស់ អោ អាន សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល* ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧។

[83] *សូមមើល ឧទាហរណ៍* **សំណុំរឿង ០០៤- ឯកសារ D257/1/8** *សេចក្ដីពិចារណាលើសំណើរបស់ អោ អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រមហួត វុទ្ធី កថាខណ្ឌ ១៤។ **សំណុំរឿង ០០៤/១- ឯកសារ D298/2/1/3** *សេចក្ដីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំធ្វើមោឃភាពប្រតិចារិក និងកំណត់ហេតុ*

បន្ថែមទៀតទេ[84]។ ការចោទប្រកាន់អំពីកំហុងឆ្គងនៅក្នុងដីកាសន្និដ្ឋានលើកទី ៣ មិនដែលត្រូវបានលើកឡើងថាជាសំអាងហេតុសម្រាប់ធ្វើមោឃភាព ឬក៏មិនចាំបាច់បំពេញកិច្ចស៊ើបសួរថែមទៀតទេ។ ហេតុនេះ ស្តែងឱ្យឃើញថា ក្រៅពី ស.ច.ស អ.ប.ជ ក៏មិនទទួលយកទឡ្ហីករណ៍របស់មេធាវីការពារក្តីដែរ។ តាមពិត សូម្បីតែ ស.ព.ជ ទោះបីជាបានលើកឡើងយ៉ាងលម្អិត នៅក្នុងដីកាសន្និដ្ឋានស្តាពររបស់គាត់អំពីនីតិវិធីខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងដីកាសន្និដ្ឋានលើកទី ៣ យ៉ាងណាក៏ដោយ ក៏ ស.ព.ជ មិនបានលើកឡើងពីទឡ្ហីករណ៍នេះដែរ[85] ប៉ុន្តែ ស.ព.ជ ពឹងផ្អែកតែលើបញ្ហាយុត្តាធិការបុគ្គលតែប៉ុណ្ណោះ។

---

*នៃការស្តាប់ចម្លើយសាក្សី* ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ធុល និងចៅក្រម ហ្វូត វុទ្ធី ទាក់ទងនឹងអង្គសេចក្តីនៃពាក្យសុំ កថាខណ្ឌ ៣៩។ **សំណុំរឿង ០០៤- ឯកសារ** D345/1/6 *សេចក្តីពិចារណាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្អួត* ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧ យោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ធុល និងចៅក្រមហ្វូត វុទ្ធី ទាក់ទងនឹងអង្គសេចក្តីនៃពាក្យសុំ កថាខណ្ឌ ១៦។ **សំណុំរឿង ០០៣- ឯកសារ** D165/2/26 *[កោសលុប] សាលដីការបស់អង្គបុរេជំនុំជម្រះ ១)លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២)លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ធុល និងចៅក្រម ហ្វូត វុទ្ធី ពាក់ព័ន្ធនឹងសំណើទាំងប្រាំបួនរបស់ មាស មុត សុំមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ ៩៦។

[84] *សូមមើល ឧទាហរណ៍* **សំណុំរឿង ០០៤/២- ឯកសារ** D343/4 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីរប់របស់ អោ អាន* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៧ មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ធុល និងចៅក្រមហ្វូត វុទ្ធី កថាខណ្ឌ ១៧-១៨។ **សំណុំរឿង ០០៤/២- ឯកសារ** D277/1/1/4 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី៧ របស់ អោ អាន* ថ្ងៃទី៣ ខែ មេសា ឆ្នាំ ២០១៧ មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ធុល និងចៅក្រមហ្វូត វុទ្ធី កថាខណ្ឌ ១៨-១៩។

[85] ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ កថាខណ្ឌ ២-១២។

01588332



## ៣.២. ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ មានកំហុសឆ្គងខុស ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នា មិនត្រូវបានអនុញ្ញាតទេ

៤៣. ទឡ្ហីករណ៍ពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពរផ្ទុយគ្នា គឺមិនមានមូលដ្ឋានទេ ដូចដែល ស.ច.ស បានសម្រេចរួចហើយ[86]។ ទឡ្ហីករណ៍នានារបស់មេធាវីការពារក្តី នៅក្នុងចម្លើយតប មិនតម្រូវឲ្យពិចារណាឡើងវិញលើការសម្រេចបែបនោះឡើយ។

## ៣.៣. ស.ច.ស មិនអាចការពារភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីបានឡើយ បន្ទាប់ពីចេញដីកាដំណោះស្រាយ

៤៤. ចំពោះស្ថានភាពថវិកា ស.ច.ស បានបញ្ជាក់រួចហើយអំពីការយល់ឃើញរបស់ខ្លួននៅក្នុងដីកាសម្រេចចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧ ហើយនៅតែពិនិត្យបញ្ហានេះយ៉ាងសកម្ម[87]។ នៅក្នុងអង្គប្រជុំជាមួយនឹង ស.ច.ស នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៨ ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ បានធ្វើការធានាឡើងវិញ និងបន្តការសន្យាដាច់ខាតថានឹងផ្តល់ថវិកាឲ្យបានគ្រប់គ្រាន់ដល់តុលាការ។ ស.ច.ស ក៏បានបញ្ជាក់ថា នៅពេលដែលដីកាដំណោះស្រាយបានចេញរួចហើយ ជាគោលការណ៍ ស.ច.ស លែងមានភារកិច្ចហើយ[88] ហើយ ចៅក្រមនៅ អ.ប.ជ, អ.ជ.ស.ដ និង អ.ជ.ត.ក ជាអ្នកការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ[89]។

---

[86] **សំណុំរឿង 00៤/២- ឯកសារ D353/1** *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ* ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។

[87] **សំណុំរឿង 00៤/២- ឯកសារ D349/6** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង 00៣ សំណុំរឿង 00៤ និងសំណុំរឿង 00៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧។

[88] **សំណុំរឿង 00៤/២-D349/6** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង 00៣ សំណុំរឿង 00៤ និងសំណុំរឿង 00៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧ កថាខណ្ឌ ១៨។

[89] **សំណុំរឿង 00៤/២-D349/6** *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង 00៣ សំណុំរឿង 00៤ និងសំណុំរឿង 00៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ* ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ១៨។

៤៥. អាណត្តិការងាររបស់ ស.ច.ស នៅមានរហូតដល់ពេលបញ្ចប់កិច្ចស៊ើបសួរ យោងតាមមាត្រា ២៧ ថ្មីនៃច្បាប់ អ.វ.ត.ក។ មាត្រា ៥(៧) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ចែងអំពីការបញ្ចប់ "ការជំនុំជម្រះ" ប៉ុន្តែអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា យល់ឃើញថា ពាក្យពេចន៍នៅមាត្រា ២៧ថ្មី នៃច្បាប់ អ.វ.ត.ក ឆ្លុះបញ្ចាំងបានល្អជាងអំពីចេតនារបស់ភាគីកិច្ចព្រមព្រៀង ហើយក្នុងករណីមានបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ អាណត្តិការងាររបស់ ស.ច.ស ត្រូវបញ្ចប់នៅពេលដែល អ.ប.ជ ចេញសាលដីកាចុងក្រោយលើបណ្តឹងឧទ្ធរណ៍បែបនោះ[៧០]។ ស.ច.ស យល់ស្របតាមការបកស្រាយបែបនេះ។ ហេតុនេះ ស.ច.ស អាចគ្រប់គ្រងឧបសគ្គណាដែលកើតឡើង នៅក្នុងសំណុំរឿងនៅចំពោះមុខខ្លួន មុនពេលមានការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ គឺមុនពេលដែល ស.ច.ស បាត់បង់យុត្តាធិការលើរឿងក្តីជាក់លាក់ណាមួយ ប៉ុន្តែ ស.ច.ស ឈប់មានអាណត្តិការងារទាំងស្រុងហើយ នៅពេលដែល អ.ប.ជ ចេញសាលដីកាចុងក្រោយលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ។ ហេតុនេះ កិច្ចការពារសិទ្ធិរបស់ភាគី និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី គឺស្ថិតនៅក្នុងដៃរបស់ អ.ប.ជ និងអង្គជំនុំជម្រះផ្សេងទៀតទាំងស្រុង តាមករណីដែលអាចមាន។ ស.ច.ស មិនអាចជ្រៀតជ្រែកទៀតបានទេ ហើយនេះគឺដោយសារតែតម្រូវការនីតិវិធីរបស់ច្បាប់ អ.វ.ត.ក តែប៉ុណ្ណោះ។ តាមសំអាងហេតុដូចគ្នានេះដែរ មិនមានករណីអយុត្តិធម៌ *ជាបឋម* ណាមួយដែលធ្លាប់កើតឡើង ដោយសារតែ ស.ច.ស ពែងចូលរួមនោះទេ។

៤៦. ទឡ្ហីករណ៍របស់មេធាវីការពារក្តីអំពីការជ្រៀតជ្រែកនយោបាយ ពីរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ដោយផ្អែកលើសេចក្តីថ្លែងការណ៍ពីតំណាងនានារបស់រដ្ឋាភិបាល និងការចោទប្រកាន់អំពីកង្វះភាពច្បាស់លាស់អំពីការជំនុំជម្រះក្តី មិននិយាយដល់ការជំនុំជម្រះក្តីដោយយុត្តិធម៌ និងដោយឆាប់រហ័សផង ត្រូវឆ្លើយតបក្នុងរបៀបដូចគ្នានេះ។

---

[៧០] *លិខិតពីជំនួយការអគ្គលេខាធិការ Mathias ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ផ្ញើជូន ស.ច.ស.អន្តរជាតិ*។ លិខិតនេះនៅក្នុងសំណុំ ឯកសាររបស់ ស.ច.ស ប៉ុន្តែ នឹងមិនដាក់បង្ហាញឡើយ ដោយសារថា ខ្លឹមសារពិតប្រាកដហួសពីអ្វីដែលបានបញ្ជាក់ខាងលើ ហេតុនេះជា ឯកសារសម្ងាត់ចំពោះស្ថានភាពការងាររបស់ ស.ច.ស.អន្តរជាតិ។

01588334



### ៣.៤. ស.ព.អ កំពុងស្វះស្វែងឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះអង្គហេតុដែលមិនបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ

៤៧. ស.ច.ស បានបញ្ជាក់យ៉ាងច្បាស់ថា ករណីនេះមិនអាចអនុញ្ញាតបានឡើយ[៩១]។ ប៉ុន្តែ មិនមានសំអាងហេតុលើកលែងបទចោទនៃឧក្រិដ្ឋកម្មជាតិដែល ស.ព.អ បានស្នើសុំ ហើយមេធាវីការពារក្តី បានទទួលយកនោះទេ[៩២]។ បទចោទទាំងនេះនៅរក្សាទុកដដែល។

### ៣.៥. ស.ច.ស មិនគួរធ្វើតាមការបកស្រាយរបស់ អ.វ.ត.ក អំពីយុត្តាធិការបុគ្គលឡើយ

៤៨. បញ្ហានេះត្រូវបានពិភាក្សាយ៉ាងច្រើនរួចហើយ នៅក្នុងដីកាដំណោះស្រាយ(សំអាងហេតុ)នៅក្នុងសំណុំរឿង អ៊ឹម ចែម[៩៣]។ ការបកស្រាយអំពីពាក្យ "*មេដឹកនាំជាន់ខ្ពស់*" និង "*ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត*" ធ្លាប់បានតវ៉ារួចហើយនៅ អ.វ.ត.ក[៩៤] ហើយមិនមានសំអាងហេតុត្រូវដើរខុសពីការយល់ឃើញរួមគ្នារបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០៤/១ ឡើយ។

## ៤. ច្បាប់ជាធរមាន

### ៤.១. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក

៤៩. តាមមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")

---

[៩១] **សំណុំរឿង ០០៤/១- ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ២៤៥។

[៩២] *សូមមើល* ច្បាប់ជាធរមាន ចំណងជើង "ឧក្រិដ្ឋកម្មជាតិ" (ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦)" សម្រាប់ការពិភាក្សាថែមទៀតអំពីទង្វើករណ៍របស់ភាគីដើម្បីលើកលែងបទចោទនៃឧក្រិដ្ឋកម្មជាតិ។

[៩៣] **សំណុំរឿង ០០៤/១- ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ផ្នែក ២.១ យុត្តាធិការបុគ្គលនៅ អ.វ.ត.ក។

[៩៤] *សូមមើល* **សំណុំរឿង ០០១- ឯកសារ F28** *សាលដីកា* ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៥៨-៧៩។

01588335



> "គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ០៦ មករា ១៩៧៩"។

៥០. មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ អ.វ.ត.ក") ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង អ.វ.ត.ក[95] ចែងថា៖

> "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"។

៥១. មាត្រា ២ នៃច្បាប់ អ.វ.ត.ក រំឭកឡើងវិញថា អ.វ.ត.ក ត្រូវបង្កើតឡើងដើម្បីជំនុំជម្រះ *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...] ដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩"*។

៥២. អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានបកស្រាយពាក្យថា *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"* សំដៅលើជនពីរប្រភេទ គឺ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួល

---

[95] មាត្រា ២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក។

ខុសត្រូវខ្ពស់បំផុត និងជនដែលមិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ប៉ុន្តែក៏ជាជនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។ ជនទាំងពីរប្រភេទនេះ ត្រូវតែជាមន្ត្រីខ្មែរក្រហម និងស្ថិតនៅក្នុងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតដើម្បីឱ្យ អ.វ.ត.ក អនុវត្តយុត្តាធិការបុគ្គលឱ្យបានត្រឹមត្រូវ ហេតុនេះ លក្ខណវិនិច្ឆ័យទាំងនេះមានលក្ខណៈត្រួតលើគ្នា មិនមែនដាច់ដោយឡែកពីគ្នាទេ[96]។

៥៣. អ.ជ.ត.ក បានប្រកាសដោយខ្លួនឯងស្តីពីលក្ខណៈយុត្តាធិការនៃមាត្រា ១ នៃច្បាប់ **អ.វ.ត.ក**។ ទាក់ទិននឹងចំណុចនេះ អ.ជ.ត.ក បានសន្និដ្ឋានថា បញ្ហាថាតើជនជាប់ចោទជាកម្មាភិបាលខ្មែរក្រហម ឬអត់នោះ គឺ *"ពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុប្រវត្តិសាស្ត្រ ដែលមានលក្ខណៈងាយយល់ និងច្បាស់លាស់ ហើយផ្តល់ឥន្ទានុសិទ្ធិតិចតួច ឬមិនបានផ្តល់ឥន្ទានុសិទ្ធិទាល់តែសោះដល់អង្គជំនុំជម្រះសាលាដំបូង"* ហេតុនេះជាបញ្ហាដែលអាចវិនិច្ឆ័យបាននៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[97]។

៥៤. ផ្ទុយទៅវិញ ទាក់ទិននឹងពាក្យថា "មេដឹកនាំជាន់ខ្ពស់" និងជនដែល"ទទួលខុសត្រូវខ្ពស់បំផុត" អ.ជ.ត.ក បានសន្និដ្ឋានថា ប្រភេទទាំងពីរនេះពុំមែនជាលក្ខណវិនិច្ឆ័យផ្នែកយុត្តាធិការ*តាមន័យចង្អៀត (stricto sensu)* ទេ វាគ្រាន់តែបង្ហាញពីគោលការណ៍ចោទប្រកាន់របស់ ក.ស.ព និងគោលការណ៍ស៊ើបអង្កេត ដោយឯករាជ្យរបស់ ក.ស.ច.ស ប៉ុណ្ណោះ។ អ.ជ.ត.ក បានសន្និដ្ឋានថា ជាគោលការណ៍ ប្រភេទទាំងពីរនេះមិនត្រូវបានកំហិតដោយវិធាននៃការបកស្រាយបែបតឹងរ៉ឹងទេ ហើយជាខ្លឹមសារ វាពុំអាចធ្វើការវិនិច្ឆ័យបានទេ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អ.ជ.ត.ក ប្រសិនពុំមានបង្ហាញអំពីការបំពានឥន្ទានុសិទ្ធិដោយពុំសុចរិត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ[98]។ ស.ច.ស បានបង្ហាញការយល់ឃើញរួមគ្នាផ្ទាល់ខ្លួនរួចហើយអំពីការបកស្រាយ និងលក្ខណៈនៃលក្ខខណ្ឌនេះនៅក្នុងដីកា

---

[96] **សំណុំរឿង ០០១- ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៥៧។

[97] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦១។

[98] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៧៩-៨១។

01588337



ដំណោះស្រាយ(សំអាងហេតុ)សំណុំរឿង 004/1[99]។ ការយល់ឃើញរួមគ្នាដូចគ្នានេះអនុវត្តនៅក្នុងសំណុំរឿងនេះដែរ។

*គោលការណ៍ច្បាប់ព្រហ្មទណ្ឌ៖ ប្រសិទ្ធភាពនៃគោលការណ៍"វិមតិសង្ស័យបានប្រយោជន៍ដល់ជនជាប់ចោទ" និងការបកស្រាយក្នុងន័យចង្អៀត*

៥៥. ក្នុងចំណោមកត្តានានាដែលត្រូវយកមកពិចារណាដើម្បីអនុវត្តឆន្ទានុសិទ្ធិ មានគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀតអំពីច្បាប់ព្រហ្មទណ្ឌ។ ចំពោះសំអាងហេតុលម្អិតអំពីចំណុចនេះ យើង Michael Bohlander យោងលើ *ដីកាដំណោះស្រាយ (សំអាងហេតុ)* សំណុំរឿង 004/1[100]។

*លក្ខណវិនិច្ឆ័យក្នុងការអនុវត្តឆន្ទានុសិទ្ធិ៖ ការធ្វើសេចក្តីសម្រេចនៅក្នុងវចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ*

៥៦. យើង Michael Bohlander កត់សម្គាល់ឃើញថា ដោយប្រើប្រាស់និយមន័យដែលបានកំណត់នៅក្នុងសាលដីការបស់ខ្លួនក្នុងសំណុំរឿង 001 អ.ជ.ត.ក ក៏បានសម្រេចដោយប្រយោលថា ពុំមានមូលដ្ឋានទេ ចំពោះការអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាអំពីការបង្កើត អ.វ.ត.ក នាំឱ្យមានការយល់ឃើញជារួម និងត្រូវជាប់កាតព្វកិច្ចថា មានតែបុគ្គល(មានឈ្មោះ)មួយចំនួនប៉ុណ្ណោះ ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការពោលគឺ ការជ្រើសយកបុគ្គលមួយចំនួនមកធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះកាលពីពេលមុន និងឥឡូវនេះគឺជាបញ្ហាឆន្ទានុសិទ្ធិសុទ្ធសាធរបស់ ក.ស.ព និង ក.ស.ច.ស ហើយផ្អែកទាំងស្រុងទៅលើអង្គសេចក្តីនៃរឿងក្តីនីមួយៗ។ ចំពោះសេចក្តីលម្អិត

---

[99] **សំណុំរឿងលេខ 004/1- ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី10 ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ 9-10។

[100] **សំណុំរឿងលេខ 004/1- ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី10 ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២៦-៣៦។

អំពីការអនុវត្តគន្ធានុសិទ្ធិនេះ យើង Michael Bohlander យោងលើ*ដីកាដំណោះស្រាយ (សំអាងហេតុ)* សំណុំរឿង ០០៤/១[101]។

## ៤.២. ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក

៥៧. ឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក មានរៀបរាប់នៅក្នុងមាត្រា ៣ ដល់ មាត្រា ៨ នៃច្បាប់ អ.វ.ត.ក។ ផ្នែកនេះនឹងសង្ខេបតែច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជាការចោទប្រកាន់ និងបទចោទលើ **អោ អាន** តែប៉ុណ្ណោះ ។

### ៤.២.១. ឧក្រិដ្ឋកម្មជាតិ (ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦)

៥៨. មាត្រា ៣ ថ្មីនៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការឱ្យ ស.ច.ស លើឧក្រិដ្ឋកម្មមនុស្សឃាត[102] ទារុណកម្ម[103] និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា[104] ជាការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលជាក្រមព្រហ្មទណ្ឌអាចយកមកអនុវត្តបាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[105]។

៥៩. នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ស.ព.អ បញ្ជាក់ថា គាត់មិនស្នើសុំឱ្យចេញដីកាចោទប្រកាន់ **អោ អាន** ចំពោះឧក្រិដ្ឋកម្មជាតិទេ ដោយផ្អែកលើមូលដ្ឋានថា ការប្រព្រឹត្តិរបស់ **អោ អាន** មានលក្ខណៈត្រួតគ្នាជាមួយឧក្រិដ្ឋកម្មអន្តរជាតិផង គឺអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយការលើកលែងបទចោទអំពីឧក្រិដ្ឋកម្មជាតិនឹងចៀសវាងមិនឱ្យមាននីតិវិធីបណ្តឹងដែលមិនចាំបាច់ ហេតុនេះនឹងពន្លឿនកិច្ចដំណើរការនីតិវិធីសំណុំរឿង

---

[101] **សំណុំរឿងលេខ ០០៤/១- ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ៣៧-៤១។

[102] មាត្រា ៥០១ មាត្រា ៥០៣ មាត្រា ៥០៤ មាត្រា ៥០៥ មាត្រា ៥០៦ មាត្រា ៥០៧ និងមាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[103] មាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[104] មាត្រា ២០៩ និងមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

[105] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩២។

វិញ[106]។ មេធាវីការពារក្តី គាំទ្រឱ្យលើកលែងបទចោទអំពីឧក្រិដ្ឋកម្មជាតិ ដោយផ្អែកលើមូលដ្ឋានថា មេធាវីការពារក្តីជឿថា ឧក្រិដ្ឋកម្មបែបនេះលែងមានអាជ្ញាយុកាលហើយ ដោយដកស្រង់មតិយោបល់ពីមុនរបស់ចៅក្រមជាតិ នៅអង្គជំនុំជម្រះសាលាដំបូង អំពីបញ្ហានេះ[107]។ យើង Michael Bohlander មិនយល់ឃើញថា ចាំបាច់ ឬក៏គួរតែលើកលែងបទចោទអំពីឧក្រិដ្ឋកម្មជាតិ ដោយផ្អែកលើមូលដ្ឋានបែបនោះឡើយ។ ទីមួយ ប្រសិនបើលើកលែងបទចោទបែបនោះមែន នោះពេលវេលាដែលអាចចំណេញបានគឺមានចំនួនតិចតួចបំផុត ដោយពិនិត្យឃើញថា អង្គហេតុ និងភស្តុតាងដែលត្រូវការដើម្បីបញ្ជាក់ពីឧក្រិដ្ឋកម្មអន្តរជាតិ ត្រួតដូចគ្នាយ៉ាងច្រើនបើទោះជាមិនបានទាំងស្រុងក៏ដោយ ជាមួយនឹងអង្គហេតុ និងភស្តុតាងដែលត្រូវការដើម្បីបញ្ជាក់ពីឧក្រិដ្ឋកម្មជាតិ។ ទីពីរ យើង Michael Bohlander សូមរំឭកឡើងវិញអំពីការយល់ឃើញពីមុនរបស់យើងដែលថា បញ្ហាអាជ្ញាយុកាលត្រូវបាន អ.ប.ជ ដោះស្រាយយ៉ាងច្បាស់ និងដោយឯកច្ឆន្ទរួចហើយ ហេតុនេះ ច្បាស់លាស់គឺថា ឧក្រិដ្ឋកម្មជាតិ ដែលជាបទចោទលើ **អោ អាន** មិនបានផុតរលត់អាជ្ញាយុកាលទេ[108]។

<u>*មនុស្សឃាត*</u>

---

[106] **សំណុំរឿងលេខ 00៤/២- ឯកសារ** D351/5 *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ៦៣៥។

[107] **សំណុំរឿងលេខ 00៤/២- ឯកសារ** D351/6 *ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦* ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៥១ ដោយដកស្រង់មតិយោបល់របស់ចៅក្រម Cartwright និងចៅក្រម Lavergne **នៅក្នុងសំណុំរឿងលេខ ១- ឯកសារ** E187 *សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៧-៣៥, ៣៩-៥៥។

[108] **សំណុំរឿងលេខ 00៤- ឯកសារ** D258/1 *ដីកាសម្រេចលើពាក្យសុំតាមវិធានផ្ទៃក្នុង ៧៦ របស់ អោ អាន សុំមោឃភាព បទចោទប្រកាន់អំពីមនុស្សឃាតដោយចេតនា និងកិច្ចស៊ើបសួរពាក់ព័ន្ធនានា* ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ១១-១២។

01588340



៦០. ឧក្រិដ្ឋកម្មមនុស្សឃាតក្នុងច្បាប់ជាតិមានពីរទម្រង់ យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺ (១) មនុស្សឃាតដោយគ្មានចេតនាសម្លាប់[109] និង (២) មនុស្សឃាតគិតទុកជាមុន[110]។

៦១. ឧក្រិដ្ឋកម្មមនុស្សឃាតក្នុងច្បាប់ជាតិទាមទារនូវធាតុផ្សំដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ចំពោះបទមនុស្សឃាតទាំងពីរទម្រង់ ចារីត្រូវជាអ្នកដែលបណ្តាលឱ្យបុគ្គលម្នាក់ទៀតស្លាប់[111]។

ខ. *ធាតុផ្សំអត្តនោម័ត៖*

i. ចំពោះមនុស្សឃាតដែលគ្មានចេតនាសម្លាប់ ចារីត្រូវតែបានធ្វើសកម្មភាព "*ចង់ឱ្យឈឺរូបកាយដល់បុគ្គលណាម្នាក់*" ប៉ុន្តែមិន "*ចង់ឱ្យបុគ្គលនោះស្លាប់ទេ*"[112]។

ii. ចំពោះមនុស្សឃាតគិតទុកជាមុន ចារីត្រូវតែបានធ្វើសកម្មភាព "*ដោយគិតទុកជាមុន*" និង "*មានចេតនាបណ្តាលឱ្យស្លាប់*"[113]។ ការគិតទុកជាមុនត្រូវបានកំណត់និយមន័យថាជា "*ការតាំងចិត្តជាស្រេចថានឹងប្រព្រឹត្តនូវអំពើណាមួយ មុនពេលដែលប្រព្រឹត្តនូវអំពើនោះ គឺថា ពេលសម្រេចចិត្ត និងពេលដែលប្រព្រឹត្តមានចន្លោះឃ្លាតពីគ្នាល្មមឱ្យចារីរៀបចំដំណើរការនោះបាន*"[114]។

---

[109] មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៤-៧៥។

[110] មាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៤ កថាខណ្ឌ ៧៦។

[111] **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៤។

[112] **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៥។

[113] **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៦។

[114] **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៨។

៦២. អ.ប.ជ បានសម្រេចថា មនុស្សឃាតដោយគ្មានចេតនាសម្លាប់ មានបញ្ចូលនៅក្នុងបទមនុស្សឃាតក្រោមច្បាប់អន្តរជាតិ[115] ចំណែកមនុស្សឃាតគិតទុកជាមុនមិនមានបញ្ចូលទេ។ មនុស្សឃាតគិតទុកជាមុនទាមទារធាតុផ្សំនៃការគិតទុកជាមុន និង*ធាតុផ្សំអត្តនោម័តិ*ខ្ពស់ជាងពោលគឺ ចេតនាសម្លាប់ មិនមែនត្រឹមតែមានចេតនាធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរលើរូបរាងកាយទេ [116]។

## ៤.២.២. ឧក្រិដ្ឋកម្មអន្តរជាតិ

៦៣. អនុសញ្ញាអន្តរជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ គឺជាប្រភពច្បាប់អន្តរជាតិជាធរមាន នៅក្នុងអំឡុងពេលពាក់ព័ន្ធ[117]។ ទោះបីជាយុត្តិសាស្ត្រនៃសាលាក្តីមិនអចិន្ត្រៃយ៍ ដែលត្រូវបានបង្កើតឡើងចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក ពុំចងកាតព្វកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក ក៏ដោយ[118] គឺអង្គជំនុំជម្រះនានានៅ អ.វ.ត.ក បានពឹងផ្អែកយ៉ាងខ្លាំងលើសេចក្តីសម្រេចរបស់សាលាក្តីទាំងនោះពាក់ព័ន្ធនឹងធាតុផ្សំនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ដោយ អ.ជ.ត.ក បានកត់សម្គាល់ថា អង្គជំនុំជម្រះនានាមានកាតព្វកិច្ចត្រូវសម្រេចថា សេចក្តីសម្រេចបែបនោះអាចអនុវត្តបាន នៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយជនត្រូវចោទ អាចដឹងជាមុនថាមានសេចក្តីសម្រេចបែបនោះ និងអាចចូលពិនិត្យមើលសេចក្តីសម្រេចបែបនោះបានចំពោះពេលវេលាពាក់ព័ន្ធនឹងបទចោទ[119]។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

---

[115] **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៨៣។

[116] **សំណុំរឿងលេខ ០០១- ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៨៤។

[117] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧ ដល់ កថាខណ្ឌ ១៨។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩២។

[118] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧ *ឯកសារ* មាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។

[119] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧។

៦៤. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការឱ្យ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាត្រានេះកំណត់និយមន័យថាជា "*អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយ*" ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

៦៥. លើកលែងតែអំពើរំលោភសេពសន្ថវៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនេះគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[120]។ ចំពោះការរំលោភលើផ្លូវភេទ អ.ជ.ត.ក បានសម្រេចថា វាពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពោលគឺជាអំឡុងពេលដែលមានចែងនៅក្នុងក្របខណ្ឌយុត្តាធិការរបស់ អ.វ.ត.ក[121]។ ទោះបីជាយ៉ាងនេះក្តី អ.វ.ត.ក មានយុត្តាធិការលើការរំលោភលើផ្លូវភេទ

---

[120] <u>មនុស្សឃាត</u>៖ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១១។ <u>ការសម្លាប់រង្គាល</u>៖ **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៥។ <u>ការដាក់ឱ្យទៅជាទាសករ</u>៖ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤២។ <u>ការដាក់ពន្ធនាគារ</u>៖ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៧។ <u>ទារុណកម្ម</u>៖ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដាឆ្នាំ២០១០ កថាខណ្ឌ ៣៥៣។ **សំណុំរឿងលេខ ០០១- ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥ ដល់ កថាខណ្ឌ ២០៥។ <u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ</u>៖ **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤២៦។ **សំណុំរឿងលេខ ០០១- ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២២៥។ <u>អំពើអមនុស្សធម៌ផ្សេងទៀត</u>៖ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣៥។

[121] **សំណុំរឿងលេខ ០០១- ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៨០ ដល់ កថាខណ្ឌ ១៨៣។

ជាអំពើទារុណកម្ម នៅពេលដែលធាតុផ្សំទាំងអស់ផ្សេងទៀតនៃអំពើទារុណកម្មត្រូវបានបំពេញ[122] និងជាអំពើអមនុស្សធម៌ផ្សេងៗទៀត[123]។

*ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៦៦. ***អត្ថិភាពនៃការវាយប្រហារ៖*** ការវាយប្រហារគឺជាការប្រព្រឹត្តិនូវអំពើហិង្សាច្រើន ដែលមិនមែនគិតត្រឹមតែការប្រើកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះទេ ហើយអាចរួមបញ្ចូលទាំងការធ្វើបាបប្រជាជនស៊ីវិលផងដែរ[124]។ ការវាយប្រហារទៅលើប្រជាជនស៊ីវិលមានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធ[125]។

៦៧. ***លក្ខណៈជាទូទៅ ឬជាប្រព័ន្ធនៃការវាយប្រហារ៖*** លក្ខខណ្ឌនៃ"លក្ខណៈជាទូទៅ" គឺសំដៅលើការវាយប្រហារដែលមានលក្ខណៈទ្រង់ទ្រាយធំ និងមានចំនួនជនរងគ្រោះច្រើន ហើយធាតុផ្សំនៃលក្ខណៈ"ជាប្រព័ន្ធ" គឺសំដៅលើអំពើហិង្សាដែលមានការរៀបចំ[126]។ ភ័ស្តុតាងដែលបង្ហាញអំពី"លក្ខណៈជាទូទៅ" ឬ"ជាប្រព័ន្ធ"នៃការវាយប្រហារ គឺគ្រប់គ្រាន់អាចបំពេញតាមលក្ខខណ្ឌធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[127]។

---

[122] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៧ ដល់ កថាខណ្ឌ ២០៨ កថាខណ្ឌ ២១៣។

[123] **សំណុំរឿងលេខ ០០២- ឯកសារ D427/2/12** *សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ* ដីកា ១១(០២)។ **សំណុំរឿងលេខ ០០២- ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៤៣៣។ *សូមមើលផងដែរ* រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu* សំណុំរឿងលេខ ICTR-96-4-T សាលក្រម ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៦៨៨។

[124] **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៨។ **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៩៨។

[125] **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៨។ **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៩៨។

[126] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៩។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០០។

[127] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៩។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០០។

៦៨. ***សំដៅលើប្រជាជនស៊ីវិល៖*** ការវាយប្រហារត្រូវតែមានគោលដៅជាចម្បងសំដៅលើប្រជាជនស៊ីវិល[128]។ មិនចាំបាច់ត្រូវបង្ហាញថា ទាល់តែប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រណាមួយបានទទួលរងការវាយប្រហារ ទើបត្រូវចាត់ទុកថា ការវាយប្រហារនោះសំដៅលើជនស៊ីវិលទេ។ គ្រប់គ្រាន់ហើយត្រឹមតែបង្ហាញថា បុគ្គលមួយចំនួននៅក្នុងក្រុមនោះគឺជាគោលដៅនៅក្នុងអំឡុងពេលវាយប្រហារ ឬក៏ជាគោលដៅក្នុងរបៀបមួយដែលបង្ហាញថា ការវាយប្រហារនោះតាមពិតសំដៅលើ"ប្រជាជន"ស៊ីវិល មិនមែនសំដៅលើបុគ្គលក្នុងចំនួនមួយមានកម្រិត និងដោយចៃដន្យទេ[129]។ ប្រជាជនដែលត្រូវទទួលរងការវាយប្រហារ ត្រូវតែមានចំនួនជនស៊ីវិលច្រើនលើសលុប[130]។ វត្តមានរបស់បុគ្គលមួយចំនួននៅក្នុងចំណោមប្រជាជនស៊ីវិល ហើយបុគ្គលទាំងនោះមិនមានលក្ខណៈគ្រប់គ្រាន់ជាជនស៊ីវិលទេ មិនប្រាកដជាដកហូតលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនោះទេ[131]។ ជាងនេះទៀត ដូចបានជូនដំណឹងទៅភាគីរួចហើយ យើង Michael Bohlander យល់ឃើញថា ការវាយប្រហាររបស់រដ្ឋ ឬអង្គការមកលើកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនឯង គឺជាការវាយប្រហារមកលើប្រជាជន

---

[128] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨២។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-96-23 & IT-96-23/1-A) សាលដីកា ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩១-៩២។

[129] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣០៣។

[130] **សំណុំរឿងលេខ ០០២- ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៣៨, ៧៤០។ **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Dragomir Milošević* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-29/1-A) សាលដីកា ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៥០-៥១។

[131] **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤០។ **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Stanislav Galić* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-98-29-A) សាលដីកា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៣៦-១៣៨។

01588345



ស៊ីវិល លើកលែងតែកងកម្លាំងប្រដាប់អាវុធដែលត្រូវបានវាយប្រហារនោះ មានសម្ព័ន្ធភាព ឬផ្តល់ការគាំទ្រពាក់ព័ន្ធទៅខាងកងទ័ពប្រឆាំងនៅក្នុងជម្លោះប្រដាប់អាវុធ[132]។

៦៩. ***ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា៖*** មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ចែងថា ការវាយប្រហារដូចបានកំណត់ខាងលើ ត្រូវតែធ្វើឡើង ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ប៉ុន្តែ មិនមែនចាំបាច់ទាល់តែមូលហេតុ រើសអើងឡើយ[133]។ នេះគឺជាលក្ខខណ្ឌយុត្តាធិការដែលអនុវត្តចំពោះការវាយប្រហារជាទូទៅ ហើយមិនអនុវត្តចំពោះបទល្មើសជាមូលដ្ឋានទេ[134]។ ដូច្នេះ មិនចាំបាច់បង្ហាញភ័ស្តុតាងអំពី ចេតនារើសអើងសម្រាប់គ្រប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ ចេតនារើសអើង គឺគ្រាន់តែ ជាលក្ខខណ្ឌតម្រូវមួយទាក់ទិននឹងបទឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ[135]។

៧០. ***ទំនាក់ទំនងរវាងអំពើរបស់ជនត្រូវចោទ និងការវាយប្រហារ៖*** អំពើរបស់ចារី ទោះជាអំពើនោះ ជាអំពើប្រភេទណា ឬមានលទ្ធផលយ៉ាងណាក៏ដោយ ជាសត្យានុម័តត្រូវតែជាផ្នែកមួយនៃការ វាយប្រហារលើប្រជាជនស៊ីវិល[136]។

---

[132] **សំណុំរឿងលេខ ០០៤/២- ឯកសារ** D347.1 *ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល"នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ* ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ ៦៩។

[133] **សំណុំរឿងលេខ ០០២- ឯកសារ F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤២, ៧៤៤-៧៤៥។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៨។

[134] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤៤-៧៤៥។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៨។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨។

[135] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៤៤។ **សំណុំរឿង លេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៨-១៨៩។ **សំណុំរឿងលេខ ០០១ - ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jean-Paul Akayesu* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ ICTR-96-4-A) សាលដីកា ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៤៦៥-៤៦៦។

[136] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* កថាខណ្ឌ ៧៥៣-៧៥៤។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩០។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី

01588346



៧១. ***ត្រូវដឹង*** ៖ ជនល្មើសត្រូវតែបានដឹងអំពីការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងបានដឹងថា អំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនោះ។ ជនល្មើសមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារដែលមានលក្ខណៈទូទៅនោះទេ[137]។

៧២. ***ពុំមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ*** ៖ នៅក្នុងដីកាសម្រេចជាសាធារណៈចេញនៅក្នុងសំណុំរឿង ០០៣ យើង Michael Bohlader បានសម្រេចថា អត្ថិភាពនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាមួយនឹងជម្លោះប្រដាប់អាវុធលែងជាធាតុផ្សំសំខាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទៀតហើយ[138]។ អ.ប.ជ អង្គជំនុំជម្រះសាលាដំបូង និង អ.ជ.ត.ក សុទ្ធតែបានធ្វើសេចក្ដីសម្រេចដូច្នេះដែរ[139]។

---

២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣១៨។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-96-23 & IT-96-23/1-A) សាលដីកា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩៩។

[137] **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩១។ **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣១៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-96-23 & IT-96-23/1-A) សាលដីកា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១០២-១០៣។

[138] **សំណុំរឿងលេខ ០០៣- ឯកសារ D87/2/1.7/1** *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦។

[139] *សូមមើល* **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* សំណុំរឿង ០០២/០១ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៧៧ និង**សំណុំរឿងលេខ ០០២- ឯកសារ** F36 *សាលដីកា* ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧២១, ៧៣២។ នៅឆ្នាំ ២០១១ អ.ប.ជ ពិតជាបានសម្រេចថា ទំនាក់ទំនងនេះគឺជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ *សូមមើល* **សំណុំរឿងលេខ ០០២- ឯកសារ** D427/3/15 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ ខៀវ សំផន និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៤៤ និង **សំណុំរឿងលេខ ០០២- ឯកសារ** D427/1/30 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៣១១។ ប៉ុន្តែ ក្រោយពីមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស. អន្តរជាតិ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ (**សំណុំរឿងលេខ ០០៣- ឯកសារ D87/2/1.7/1** *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦) ទើប អ.ប.ជ បានពិចារណាឡើងវិញលើជំហរពីមុនរបស់ខ្លួន ហើយបានសម្រេចថា

*ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក*

៧៣. ធាតុផ្សំនៃការ**ធ្វើមនុស្សឃាត** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្មដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ និងចូលរួមចំណែកយ៉ាងសំខាន់ធ្វើឱ្យជនរងគ្រោះស្លាប់[140]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ចេតនារបស់ចារីក្នុងការសម្លាប់ ឬបង្កឱ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ដោយមានហេតុផលដឹងថា អំពើសកម្ម ឬអកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស[141]។

៧៤. ធាតុផ្សំនៃការ**សម្លាប់រង្គាល** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម អំពើអកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ ដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[142]។ ការកំណត់ទៅលើការសម្លាប់រង្គាល មិនចាំបាច់ត្រូវបង្ហាញចំនួនជនរងគ្រោះក្នុងកម្រិតអប្បបរមាណាមួយនោះទេ[143]។ លក្ខខណ្ឌតម្រូវ "ទ្រង់ទ្រាយធំ"ត្រូវ

---

ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធមិនតម្រូវឱ្យមានទេ ហេតុនេះ អ.ប.ជ ស្របតាមអង្គជំនុំជម្រះផ្សេងទៀតនៅ អ.វ.ត.ក *សូមមើល* **សំណុំរឿងលេខ ០០៣- ឯកសារ** D87/2/1.7/1/1/7 *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧។

[140] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣១។

[141] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣៩១, ៤០៩, ៤១០។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៣។

[142] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៤។

[143] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៦។

វាយតម្លៃតាមករណីនីមួយៗ ដោយផ្អែកលើកត្តាពេលវេលា និងទីកន្លែងសម្លាប់ ការសម្រិតសម្រាំងជនរងគ្រោះ និងវិធីកំណត់គោលដៅជនរងគ្រោះ និងការសម្លាប់ដែលមានចេតនាសំដៅលើក្រុមរួមណាមួយ ជាជាងសំដៅតែលើជនរងគ្រោះម្នាក់ៗ[144]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការបំផ្លាញផ្នែកសំខាន់ណាមួយនៃក្រុមនោះ[145]។ អ.ជ.ត.ក បានសម្រេចថា គោលបំណងនៃការសម្លាប់រង្គាល គឺដើម្បីលុបបំបាត់បុគ្គលដែលជាផ្នែកនៃក្រុមមួយ ដូច្នេះហើយវាពុំស្របជាមួយនឹងសញ្ញាណនៃចេតនាប្រយោល (*dolul eventualis*) ទេ។ ប៉ុន្តែ បន្ទាប់មក អ.ជ.ត.ក បានបញ្ជាក់ថា មិនចាំបាច់ត្រូវដឹងថា *អំពើពិរុទ្ធនោះ*នឹងបណ្តាលឱ្យមនុស្សស្លាប់ទេ ប៉ុន្តែអ្វីដែលចាំបាច់នោះគឺ "*ការបង្ហាញថា ការសម្លាប់សមាជិកនៃក្រុមមួយគឺជាចេតនារបស់ចារី ដោយពុំគិតពីបញ្ហាថាតើចារីបានដឹងច្បាស់ថា ការសម្លាប់នេះនឹងកើតមានឡើងជាក់ស្តែង ដែរឬយ៉ាងណានោះឡើយ។ ការគ្រាន់តែដឹងថាអាចមានការស្លាប់កើតឡើង ពុំគ្រប់គ្រាន់ឡើយ*"[146]។

៧៥. ធាតុផ្សំនៃ**ការធ្វើឱ្យទៅជាទាសករ** គឺ៖

[144] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២៥, ៥២៧។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milan Lukić និង Sredoje Lukić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-98-32/1-A) ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៥៣៨។

[145] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០, ៥២២ ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krsti* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-98-33-T) ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥០៣។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៣៨។

[146] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២០។

01588349



ក. *ធាតុផ្សំសត្យានុម័ត៖* ការប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើមនុស្ស[147]។ ការធ្វើការងារដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្ត អាចជាការធ្វើឲ្យទៅជាទាសករ[148]។ ភ័ស្តុតាងបញ្ជាក់អំពីការធ្វើបាប គឺមិនចាំបាច់ត្រូវមានឡើយ ដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃបទល្មើសនៃការធ្វើឲ្យទៅជាទាសករ[149]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ជនរំលោភត្រូវតែបានប្រើប្រាស់ដោយចេតនានូវអំណាចមួយក្នុងនាមជាម្ចាស់កម្មសិទ្ធិលើបុគ្គលម្នាក់ទៀត[150]។

៧៦. ធាតុផ្សំនៃ**ការដាក់ក្នុងមន្ទីរឃុំឃាំង** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការដកហូតសេរីភាពរបស់បុគ្គលតាមទំនើងចិត្តដោយគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់ ឬផ្អែកលើបទប្បញ្ញត្តិច្បាប់ជាតិដែលរំលោភលើច្បាប់អន្តរជាតិ[151]។ មិនមែនរាល់ការរំលោភបំពានបន្តិចបន្តួចលើសិទ្ធិ

---

[147] **សំណុំរឿងលេខ 00១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២0១0 កថាខណ្ឌ ៣៤២។

[148] **សំណុំរឿងលេខ 00១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២0១0 កថាខណ្ឌ ៣៤៤។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Milorad Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-97-25T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២00២ កថាខណ្ឌ ៣៥៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-96-23-T & IT-96-23/1-T) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២00១ កថាខណ្ឌ ៥៤២-៥៤៣។

[149] **សំណុំរឿងលេខ 00១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២0១0 កថាខណ្ឌ ៣៤៤។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២00២ កថាខណ្ឌ ១២៣*ដកស្រង់រឿងក្តីសហរដ្ឋអាមេរិក តទល់នឹង Oswald Pohl និងអ្នកផ្សេងទៀត* សាលក្រម ថ្ងៃទី0៣ ខែវិច្ឆិកា ឆ្នាំ១៩៤៧ បោះពុម្ពឡើងវិញនៅក្នុង*ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ ១0 របស់ក្រុមប្រឹក្សាគ្រប់គ្រង* វ៉ុល ៥ (ឆ្នាំ១៩៩៧) ទំព័រ ៩៥៨ គ្រង់ទំព័រ ៩៧0។

[150] **សំណុំរឿងលេខ 00១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២0១0 កថាខណ្ឌ ៣៤៥។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២00២ កថាខណ្ឌ ១២២។

[151] **សំណុំរឿងលេខ 00១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២0១0 កថាខណ្ឌ ៣៤៧-៣៤៨។

សេរីភាព មានន័យថាជាការដាក់ក្នុងមន្ទីរឃុំឃាំងនោះទេ ហើយការដកហូតសិទ្ធិសេរីភាព ត្រូវតែមានភាពធ្ងន់ធ្ងរស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលមានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក[152]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ចារីមានចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល ឬចារីបានប្រព្រឹត្តដោយបានដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនមុខជាបង្កឱ្យមានការដកហូតតាមទំនើងចិត្ត នូវសេរីភាពរបស់បុគ្គល[153]។

៧៧. ធាតុផ្សំនៃ**ការធ្វើទារុណកម្ម** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើណាមួយដែលបណ្តាលឱ្យមានការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរផ្នែករាងកាយ ឬស្មារតី ដែលប្រព្រឹត្តឡើង ឬដោយញុះញង់ពីមន្ត្រីសាធារណៈ[154]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ចារីត្រូវមានចេតនាបង្កឱ្យមានការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរទៅលើជនរងគ្រោះ[155]។

គ. អំពើនោះត្រូវតែបានប្រព្រឹត្តឡើងក្នុងគោលបំណង ដូចជា ដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ[156]។

---

[152] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៤៩ ដកស្រង់រឿងក្តី *រឿងក្តីព្រះរាជអាជ្ញា Ntagerura និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-99-46-T) កថាខណ្ឌ ៧០២។ *សូមមើល ផ្ទុយពីនេះ រឿងក្តីព្រះរាជអាជ្ញា តទល់នឹង Milorad Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១១២។

[153] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥០។ *រឿងក្តីព្រះរាជអាជ្ញា តទល់នឹង Milorad Krnojelac* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IIT-97-25-T) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១១៥។

[154] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៥៥។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[155] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៩៥-១៩៦។

៧៨. អ.ជ.ត.ក បានសម្រេចថា **ការរំលោភលើផ្លូវភេទ** អាចបង្កើតបានជាការធ្វើទារុណកម្ម នៅពេលណាដែលធាតុផ្សំផ្សេងៗទៀតនៃអំពើទារុណកម្មត្រូវបានបំពេញ[157]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ដែលមានការយល់ស្របពី អ.ជ.ត.ក ផងដែរនោះ[158] បានកំណត់ចរិតលក្ខណៈនៃការរំលោភសេពសន្ថវៈ ដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការបញ្ចូលអង្គជាត ទោះបីជាមិនបានស៊ីជម្រៅក៏ដោយ ទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារី នៅពេលដែលការបញ្ចូលអង្គជាតនោះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ។ ការយល់ព្រមមានន័យថា ត្រូវតែស្ម័គ្រចិត្តចេញពីឆន្ទៈរបស់ជនរងគ្រោះ ដែលត្រូវធ្វើការវាយតម្លៃក្នុងបរិបទកាលៈទេសៈពាក់ព័ន្ធជុំវិញ[159]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ចារីត្រូវតែបានប្រព្រឹត្តដោយមានចេតនាបញ្ចូលអង្គជាត និងដឹងថា ការបញ្ចូលអង្គជាតកើតឡើង ដោយគ្មានការយល់ព្រមពីជនរងគ្រោះ[160]។

៧៩. ធាតុផ្សំនៃ**បទធ្វើឱ្យខូចរូបកាយ្មេញ** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្ម ដែលរើសអើងជាក់ស្តែង និងដកហូត ឬរំលោភសិទ្ធិជាសារវន្តដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់

---

[156] **សំណុំរឿងលេខ ០០១- ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៩៥-១៩៦។

[157] **សំណុំរឿងលេខ ០០១- ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៧-២០៨, ២១៣។

[158] **សំណុំរឿងលេខ ០០១- ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៨។

[159] **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេងទៀត សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-96-23 & IT-96-23/1-A) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១២៧។

[160] **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៥។

អន្តរជាតិ ឬសន្ធិសញ្ញា[161]។ ធាតុផ្សំនៃការរើសអើងនៅក្នុង*អំពើពិរុទ្ធ*ត្រូវបានបង្កើតឡើង នៅពេលដែលជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះជាសមាជិក នៅក្នុងក្រុមណាមួយដែលចារីបានកំណត់ជាអត្តនោម័តិ និងបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[162]។ ជនរងគ្រោះត្រូវតែស្តែងឱ្យបានឃើញច្បាស់លាស់គ្រប់គ្រាន់ថាគាត់ស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ ដែលផលវិបាកដោយសារការធ្វើទុក្ខបុកម្នេញត្រូវតែកើតមានទៅលើក្រុម នោះ[163]។ ទាក់ទិននឹងបញ្ហានេះ អ.ជ.ត.ក បានសម្រេចថា ពុំមានការរើសអើងទេ នៅពេលដែលនៅក្នុងអង្គហេតុ ចារីមានការភាន់ច្រឡំលើជនរងគ្រោះ ដោយបានមិនដឹងថាតើ ជនរងគ្រោះពិតជាស្ថិតនៅក្នុងក្រុមគោលដៅ ដែលត្រូវកំណត់ដោយអត្តនោម័ត ដែរឬយ៉ាងណា ឬនៅពេលដែលចារីកំណត់គោលដៅជនរងគ្រោះដោយមិនគិតថាតើ ជនរងគ្រោះស្ថិតនៅក្នុងលក្ខណវិនិច្ឆ័យនៃការរើសអើង ដែរឬយ៉ាងណា ឬក៏អាចនិយាយបានថា នៅពេលដែលចារីកំណត់គោលដៅ"ដោយមិនរើសមុខ"[164]។ ការធ្វើទុក្ខបុកម្នេញ

---

[161] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៧-៦៦៨។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៥៧, ២៦១-២៦២, ២៦៧, ២៧១-២៧៨។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៧-៤២៨។

[162] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៧, ៦៧៨-៦៧៩, ៦៨៣, ៦៩៥។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧២-២៧៣, ២៧៤, ២៧៦, ២៣៧។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៨។

[163] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៨។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧៤-២៧៧។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៨។

[164] **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧៧។ *សូមមើលផងដែរ* កថាខណ្ឌ ២៧២-២៧៦។

ដោយមូលហេតុនយោបាយ ពិចារណាទៅលើការយល់ឃើញរបស់ចារី នៅពេលធ្វើការកំណត់ក្រុមដែលជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ ដូច្នេះ មិនមានលក្ខខណ្ឌតម្រូវថា សមាជិកនៃក្រុមដែលគេកំណត់គោលដៅនោះ ត្រូវតែប្រកាន់ទស្សនៈនយោបាយរួម ឬទស្សនៈនយោបាយណាមួយនោះឡើយ[165] ។

ខ. ការធ្វើទុក្ខបុកម្នេញអាចប្រព្រឹត្តឡើងតាមរយៈបទល្មើសមួយ ឬច្រើនក្នុងចំណោមបទល្មើសជាមូលដ្ឋានដទៃទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ព្រមទាំងតាមរយៈអំពើដទៃទៀត ដែលមានស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរស្មើគ្នា រួមបញ្ចូលទាំងអំពើទាំងឡាយដែលមិនចាំបាច់ទាល់តែឧក្រិដ្ឋកម្មអន្តរជាតិទេ[166]។

គ. *ធាតុផ្សំអត្តនោម័តិ៖* ការប្រព្រឹត្តអំពើសកម្ម ឬអកម្មដោយមានចេតនារើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[167]។ ទោះបីជាក្នុងករណីដែល អំពើទាំងនេះ បង្កើតបានជាបទល្មើសនៅក្រោមច្បាប់អន្តរជាតិក៏ដោយ ក៏មិនចាំបាច់ត្រូវបង្ហាញនូវ*ចេតនាឧក្រិដ្ឋ*ដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទល្មើសទាំងនេះឡើយ៖ គ្រប់គ្រាន់ហើយត្រឹមបង្ហាញថា អំពើនេះត្រូវបានអនុវត្តឡើងដោយមានចេតនារើសអើង ដែលជាលក្ខខណ្ឌតម្រូវ[168]។

---

[165] **សំណុំរឿងលេខ ០០២- ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៨, ៦៧៧-៦៨០។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧២-២៧៣។

[166] **សំណុំរឿងលេខ ០០១- ឯកសារ** F28 *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Radoslav Brđanin សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (T-99-36-A) ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២៩៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tihomir Blaškić សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14-A) ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១៣៥។

[167] **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៧។ **សំណុំរឿងលេខ ០០១- ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៩,២៣៦,២៤០។

[168] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-05-88-A) ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ៧៣៨។

៨០. ធាតុផ្សំនៃ**អំពើអមនុស្សធម៌ផ្សេងៗទៀត** គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្មរបស់ចារី ដែលបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[169]។ អំពើសកម្ម ឬអកម្មរបស់ចារីត្រូវតែមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀត ដូចមានរៀបរាប់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែលត្រូវធ្វើការវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាលើកាលៈទេសៈនីមួយៗនៅក្នុងរឿងក្តី[170]។ មិនមានលក្ខខណ្ឌតម្រូវថា ការឈឺចាប់នោះត្រូវមានផលប៉ះពាល់រយៈពេលយូរអង្វែងនោះឡើយ ទោះបីជាចានេះអាចជាកត្តាពាក់ព័ន្ធដើម្បីវាយតម្លៃភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ[171]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរមកលើជនរងគ្រោះ ដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ ឬបានដឹងថា អំពើសកម្ម ឬអកម្មនោះទំនងជាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរមកលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ[172]។

---

[169] **សំណុំរឿងលេខ ០០២- ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៨០។

[170] **សំណុំរឿងលេខ ០០២- ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៦៧, ៥៨០។ **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៨។

[171] **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៩។ **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៩។

[172] **សំណុំរឿងលេខ ០០២- ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៨០។ **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៧។ **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៨, ៣៧១។

៨១. អំពើអមនុស្សធម៌ផ្សេងៗទៀត មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាប់តាំងពីឆ្នាំ ១៩៧៥ មក[173]។ អំពើដែលជាមូលដ្ឋាននៃ"អំពើឧក្រិដ្ឋកម្មអមនុស្សធម៌ផ្សេងៗទៀត" មិនចាំបាច់ទាល់តែជាអំពើឧក្រិដ្ឋតាមច្បាប់អន្តរជាតិនៅពេលដែលប្រព្រឹត្តនោះឡើយ[174]។ គ្រប់គ្រាន់ហើយត្រឹមថា អំពើនោះបំពេញតាមធាតុផ្សំអង្គច្បាប់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត[175] ដោយពិចារណាលើកាលៈទេសៈនៃសំណុំរឿងនោះ។ ហេតុនេះ មិនចាំបាច់បញ្ជាក់អំពីធាតុផ្សំនៃអំពើដែលបានចោទថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនោះទេ។ ការសម្រេចបែបនេះបានធ្វើរួចហើយនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)សំណុំរឿង 00៤/១[176] ដែលមានសេចក្តីលម្អិតអំពីប្រភេទអំពើដែលត្រូវបានរកឃើញថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត ប៉ុន្តែ នៅពេលដំណាលគ្នានោះដែរ អ.ជ.ត.ក យល់ឃើញថា ការសម្រេចបែបនោះមិនត្រឹមត្រូវទេ[177] ហើយ យើង Michael Bohlander មិនអនុវត្តតាមការសម្រេចបែបនោះនៅក្នុងដីកាដំណោះស្រាយនេះទេ ។

៨២. ប៉ុន្តែ អាចចាំបាច់ត្រូវកំណត់ប៉ារ៉ាម៉ែត្រនៃអំពើនោះដើម្បីកំណត់ថាតើ ជនត្រូវចោទអាចប្រមើលមើលដឹង និងអាចដឹងថា ខ្លួនអាចត្រូវស៊ើបអង្កេត និងចោទប្រកាន់ដោយសារអំពើបែបនោះដែរឬអត់[178]។ ត្រូវគោរពតាមគោលការណ៍គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែងប្រសិនបើអំពើនោះរំលោភលើសិទ្ធិជាមូលដ្ឋានណាមួយរបស់ជនរងគ្រោះ ហើយមានលក្ខណៈ

---

[173] **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៧៦។

[174] **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៨៤។

[175] **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៨៥។

[176] **សំណុំរឿងលេខ 00៤/១- ឯកសារ D308/3** *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ៧៦-៧៧។

[177] **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៨៥។

[178] **ឯកសារ D301/5** *ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និងបង្ខំឱ្យមានផ្ទៃពោះដោយបង្ខំ* ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥១, ៦៣។

និងស្ថានទម្ងន់ស្រដៀងគ្នានឹងបទល្មើសផ្សេងទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតម្រូវឱ្យធ្វើការវិភាគលើអំពើនោះតាមករណីនីមួយៗ[179]។

៨៣. ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវសច្ចភាពផ្លូវច្បាប់ ត្រូវធ្វើការប្រៀបធៀបរវាងលក្ខណៈ និងស្ថានទម្ងន់នៃប្រភេទអំពើខាងលើជាមួយនឹងលក្ខណៈ និងស្ថានទម្ងន់នៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានចែង យោងតាម*គោលការណ៍នៃការបញ្ចូលគ្នាតែមួយនូវអ្វីដែលមានភាពស្រដៀងគ្នា(ejusdem generis)*[180]។ ចំពោះលក្ខណៈនៃអំពើដែលអាចបង្កើតបានជាអំពើអមនុស្សធម៌ណាមួយ អាចយោងលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិដែលចែងអំពីជម្លោះប្រដាប់អាវុធរវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ រួមមាន ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឬការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើបទដ្ឋានសិទ្ធិមនុស្សជាសារវន្តដែលត្រូវការពារតាមច្បាប់អន្តរជាតិនៅពេលនោះ[181]។

៨៤. ករណីបាត់ខ្លួនដោយបង្ខំ[182] រំលោភលើផ្លូវភេទ[183] ការបំពារបំពានលើរាងកាយអ្នកទោស[184] ស្ថានភាពអមនុស្សធម៌នៃការឃុំខ្លួន[185] និងការរៀបការដោយបង្ខំ[186] ធ្លាប់ត្រូវបានសម្រេចថាមានលក្ខណៈ និងស្ថានទម្ងន់ដូចគ្នានឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានចែង។

---

[179] **ឯកសារ D301/5** *ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និងបង្ខំឱ្យមានផ្ទៃពោះដោយបង្ខំ* ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៤។

[180] ពាក្យ *ejusdem generis* មាននិយមន័យថាជា"ប្រភេទនៃគោលការណ៍ដែលបកស្រាយថា នៅពេលដែលពាក្យ ឬឃ្លាទូទៅណាមួយមានចែងបន្ទាប់ពីការរៀបរាប់អំពីប្រភេទអ្វីមួយ នោះ ពាក្យ ឬឃ្លាទូទៅនេះនឹងត្រូវបកស្រាយថារួមមានតែអ្វីដែលជាប្រភេទដូចគ្នាដូចបានរៀបរាប់នោះតែប៉ុណ្ណោះ(វចនានុក្រម Black's Law បោះពុម្ពលើកទី ៩)។

[181] **សំណុំរឿងលេខ ០០២- ឯកសារ D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៦៤។

[182] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៤៤-៤៤៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Zoran Kupreškić និងអ្នកផ្សេងទៀត សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-16-T) ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៦៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Alex Tamba Brima និង អ្នកផ្សេងទៀត សាលដីកា* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL (SCSL-04-16-A) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៨៤។

*អំពើប្រល័យពូជសាសន៍*

៨៥. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ដែលផ្តល់ឲ្យ អ.វ.ត.ក នូវយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺមានមូលដ្ឋានលើមាត្រា ២ និង ៣ នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍[187]

---

[183] **សំណុំរឿងលេខ 00២- ឯកសារ** D427/3/15 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៥៤។ **សំណុំរឿងលេខ 00២- ឯកសារ** D427 *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៤៣៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (ICTR-96-4-T) ចុះថ្ងៃទី 0២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦៨៨។

[184] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvocka សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-98-30/1-T) ថ្ងៃទី 0២ ខែវិច្ឆិកា ឆ្នាំ ២00១ កថាខណ្ឌ ២0៨ និង ២0៩។

[185] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krnojelac សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-97-25-T) ថ្ងៃទី ១៥ ខែ មីនាណា ឆ្នាំ ២00២ កថាខណ្ឌ ១៣៣។

[186] **សំណុំរឿងលេខ 00២- ឯកសារ** D427 *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣១៤។

[187] មាត្រា ៤ នៃច្បាប់ អ.វ.ត.ក មិនផ្តន្ទាទោសចំពោះការជំរុញដោយផ្ទាល់ និងជាសាធារណៈដើម្បីធ្វើការប្រល័យពូជសាសន៍ ឬការរួមគំនិតដើម្បីធ្វើការប្រល័យពូជសាសន៍ ដូចមានចែងនៅកថាខណ្ឌ ខ និង គ នៃអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ទេ ("អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍")។ និយមន័យអំពីអំពើប្រល័យពូជសាសន៍នៅក្នុងសំណៅជាភាសាអង់គ្លេសនៃមាត្រា ៤ នៃច្បាប់ អ.វ.ត.ក អាចត្រូវបកស្រាយថាជាការរៀបរាប់មិនទេះអស់អំពីអំពើប្រល័យពូជសាសន៍(ដោយសារមានពាក្យ *"such as*-ដូចជា") ហើយដកចេញនូវពាក្យ"*as such*-ដោយមានចេតនាបែបនោះ"ពីឃ្លាថាដើម្បីបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកមកលើក្រុមត្រូវការពារ។ករណីទាំងពីរនេះគឺផ្ទុយពីអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ និងយុត្តិសាស្ត្រដែលបានបង្កើតរួចហើយ។ ផ្ទុយមកវិញ សំណៅជាភាសាបារាំងនៃមាត្រា ៤ ឆ្លុះបញ្ចាំងពីបទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ដោយចែងថា៖ *"On entend par crime de génocide, qui est imprescriptible l'un quelconque des actes ci-après, commis dans l'intention de détruire, en tout ou en partie, un groupe national, ethnique, racial ou religieux, comme tel".* សំណៅជាភាសាខ្មែរកាន់តែជិតត្រូវគ្នាជាមួយនឹងខ្លឹមសារនៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ដោយបានកម្រិតអំពើប្រល័យពូជសាសន៍នៅត្រឹមតែអំពើដែលបានរៀបរាប់នៅក្នុងមាត្រា៤ តែប៉ុណ្ណោះ៖ "អំពើប្រល័យពូជសាសន៍ ដែលគ្មានអាជ្ញាយុកាលគឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោមហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា:" បកប្រែទៅជាភាសាអង់គ្លេស *"The acts of genocide, which have no statute of limitations, mean any of the following acts committed with the intent to destroy, in whole or in part, a national, ethnical, racial or religious group:"*។ ទាំង កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៩ ទាំងច្បាប់ អ.វ.ត.ក មាត្រា ៤ ក៏ចែងថា យុត្តាធិការរបស់អ.វ.ត.ក ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍

ដែលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិរវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[188]។ ស្របតាមគោលការណ៍ *មិនមែនជាបទល្មើស បើគ្មានច្បាប់ចែង(nullem crimen sine lege)* និងយុត្តិសាស្ត្រដែលបានបង្កើតរួចហើយនោះ និយមន័យអំពីអំពើប្រល័យពូជសាសន៍ ដែលប្រើប្រាស់នៅក្នុងដីកាដំណោះស្រាយនេះ គឺសំដៅលើការប្រព្រឹត្តិអំពើណាមួយក្នុងចំណោមអំពើដែលមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ប្រព្រឹត្តឡើងដោយមានចេតនាជាក់លាក់ដើម្បីបំផ្លាញទាំងស្រុង ឬមួយផ្នែកទៅលើក្រុមជាតិ ក្រុមជាតិពន្ធុ ក្រុមពូជសាសន៍ ឬក្រុមសាសនា ដែលជាក្រុមគោលដៅច្បាស់លាស់ដោយមានចេតនាបែបនោះ[189]។

---

ត្រូវកម្រិតនៅត្រឹមឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ *"ដូចដែលបានកំណត់"* នៅក្នុងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍។ ហេតុនេះ និយមន័យអំពីអំពើប្រល័យពូជសាសន៍ដែលប្រើប្រាស់នៅក្នុងដីកាដំណោះស្រាយនេះ គឺប្រកាន់យកតាមនិយមន័យនៅក្នុងសំណៅជាភាសាបារាំង និងភាសាខ្មែរនៃមាត្រា ៤ អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ និងយុត្តិសាស្ត្រដែលបានបង្កើតរួចហើយ *សូមមើល* **សំណុំរឿងលេខ ០០២- ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣១១។

[188]សេចក្តីមតិយោបល់អំពីអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ *មតិយោបល់ប្រឹក្សា* ICJ Rep15(ឆ្នាំ ១៩៥១)ទំព័រ ២៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៣៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤៩៥។ **សំណុំរឿងលេខ ០០២- ឯកសារ D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១០៨។ ប្រទេសកម្ពុជាបានចូលជាសមាជិកអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៥០ បន្ទាប់ពីទទួលបានស្វ័យភាពអធិបតេយ្យភាពយោងតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋបារាំងលើកទី ៤។ ការចូលជាសមាជិករបស់កម្ពុជា ត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ ហើយមិនមានកំណត់ហេតុអំពីការជំទាស់អង្គច្បាប់អំពីការចូលជាសមាជិកនេះទេ។ បន្ទាប់ពីទទួលបានការចូលជាសមាជិក និងការធ្វើសច្ចាប័នតាមចំនួនដែលត្រូវការរួចមក អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ បានចូលជាធរមាននៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៥១ *សូមមើល* **សំណុំរឿងលេខ ០០២- ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣១០។

[189] **សំណុំរឿងលេខ ០០២- ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣១២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៤៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤៩៨-៤៩៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić*

*ធាតុផ្សំទូទៅនៃអំពើប្រល័យពូជសាសន៍*

៨៦. មិនមានលក្ខខណ្ឌតម្រូវថា អំពើដែលបានចោទនោះត្រូវតែបានកើតឡើងនៅក្នុងបរិបទដែលបង្ហាញឲ្យឃើញច្បាស់អំពីលំនាំអំពើស្រដៀងគ្នាទេ[190]។ ស្រដៀងគ្នានេះដែរ អត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋ (ឬគោលនយោបាយ ឬផែនការផ្សេងទៀត)ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺមិនមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ[191] ហើយក៏មិនមានលក្ខខណ្ឌតម្រូវថា អំពើដែលបានចោទនោះត្រូវតែជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធមកលើប្រជាជនស៊ីវិលទេ[192]។ ប៉ុន្តែ កត្តាបែបនេះអាចជួយបញ្ជាក់ពីការរកឃើញចេតនាជាក់លាក់នៃការប្រព្រឹត្ត[193]។

*ក្រុមត្រូវការពារ*

---

សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៤២។

[190] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ២២៣-២២៥។

[191] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-05-88-A) ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ៤៣៩, ៤៣៦, ៤៤០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-3-A) ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៥២៥។

[192] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ២២៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-10-A) ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ៤៨។

[193] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ២២៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-10-A) ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ៤៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-3-A) ថ្ងៃទី ២៦ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៥២៥។

៨៧. អ.វ.ត.ក មានយុត្តាធិការលើអំពើប្រល័យពូជសាសន៍ដែលសំដៅលើក្រុមជាតិ ក្រុមជាតិពន្ធុ ក្រុមពូជសាសន៍ និងក្រុមសាសនា[194]។ មានតែក្រុមទាំងបួនដែលបានបញ្ជាក់យ៉ាងច្បាស់នេះទេដែលជាក្រុមត្រូវការពារ[195]។

៨៨. មិនមាននិយមន័យដែលត្រូវបានទទួលស្គាល់ជាទូទៅអំពីក្រុមត្រូវការពារទាំងបួនប្រភេទនេះទេ[196]។ យុត្តិសាស្ត្ររបស់សាលាក្តីមិនអចិន្ត្រៃយ៍ បញ្ជាក់អំពីការវិវត្តនៃលក្ខខណ្ឌចម្រុះតាមករណី

[194] ច្បាប់ អ.វ.ត.ក មាត្រា ៤។ អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ មាត្រា ២ និង ៣។

[195] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី 0២ ខែ សីហា ឆ្នាំ ២00១ កថាខណ្ឌ ៥៥៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨០៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema នឹង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី 0៧ ខែ មិថុនា ឆ្នាំ ២00១ កថាខណ្ឌ ៦០-៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២00៣កថាខណ្ឌ ៣១១។ ទោះបីជាថា *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី 0២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥១៦ អង្គជំនុះជម្រះសាសលាដំបូងនៅតុលាការ ICTR បានបញ្ជាក់ថា អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ត្រូវបានរៀបចំឡើងដើម្បីការពារក្រុមដែលមានស្ថិរភាព និងអចិន្ត្រៃយ៍*ណាមួយ* (គូសបញ្ជាក់បន្ថែម) ដោយធ្វើការបញ្ជាក់ឆ្លើយតបទៅនឹងបញ្ហាចោទថាតើអំពើប្រល័យពូជសាសន៍កម្រិត ឬមិនកម្រិតនៅត្រឹមអំពើដែលប្រព្រឹត្តមកលើក្រុមទាំងបួនដែលបានលើកឡើងយ៉ាងច្បាស់។ ត្រង់ចំណុចនេះ សេចក្តីសម្រេចដែលលក្ខណៈទូលំទូលាយជាងនេះគឺកម្រិតនៅត្រឹមថា ការអនុវត្តអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍គឺកំណត់នៅត្រឹមក្រុមដែលមានស្ថិរភាព និងអចិន្ត្រៃយ៍ ហេតុនេះមិនរាប់បញ្ចូល "ក្រុមចល័ត" ទេ ប៉ុន្តែ មិនបានធ្វើសេចក្តីសន្និដ្ឋានថា ហេតុនេះ ក្រុមដែលមានស្ថិរភាព និងអចិន្ត្រៃយ៍ គឺជាក្រុមដែលត្រូវការពារនោះទេ។ *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-10-T) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២000 កថាខណ្ឌ ១៦២។

[196] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូង

នីមួយៗដើម្បីកំណត់ថាតើ ជនរងគ្រោះ (ឬក្រុមគោលដៅ)ស្ថិតនៅក្នុងចំណោមក្រុមណាមួយក្នុងចំណោមក្រុមត្រូវការពារដែរឬអត់[197]។ ទីមួយ គួរយោងលើលក្ខណៈសត្យានុម័តនៃបរិបទនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលជាប់ពាក់ព័ន្ធ[198]។ ប៉ុន្តែ ដោយសារថា ក្រុមគោលដៅណាមួយអាចមិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់ទេ ហើយអាចត្រូវចារីធ្វើការកំណត់ចរិតលក្ខណៈក្នុងរបៀបផ្សេងខុសពីការយល់ឃើញដែលគេទទួលស្គាល់រួមគ្នាជាទូទៅអំពីក្រុមគោលដៅនោះ ឬក៏ខុសពីការយល់ឃើញរបស់មនុស្សទាំងឡាយនៅក្នុងសង្គម[199] ទើប

---

នៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៦៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ *៥៥៥-៥៥៦*។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-10-T) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧០ ទោះបីជាថា អង្គជំនុំជម្រះសាលាដំបូងទាំងឡាយ នៅតុលាការ ICTR ម្តងម្កាលបានព្យាយាមកំណត់និយមន័យអំពីក្រុមត្រូវការពារទាំងបួន *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥១២-៥១៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៨។

[197] ទោះបីជាថា *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-10-T) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩ កថាខណ្ឌ ៧០ មានការប្រកាន់យកលក្ខខណ្ឌដែលមើលទៅបង្ហាញឱ្យឃើញថាមានលក្ខណៈអត្តនោម័តទាំងស្រុងក៏ដោយ។

[198] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៦-៥៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៥៧។

[199] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៦៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-10-T) ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧០។

គួរតែពិចារណាផងដែរទៅលើការយល់ឃើញអត្តនោម័តរបស់ជនរងគ្រោះ និងចារី អំពីសមាជិកភាពរបស់ជនរងគ្រោះនៅក្នុងក្រុមគោលដៅនោះ[200]។

៨៩. ក្រុមគោលដៅ ត្រូវតែមានអត្តសញ្ញាណវិជ្ជមានពិសេសណាមួយ ហេតុនេះ មិនអាចត្រូវបានកំណត់និយមន័យដោយអវិជ្ជមានបានឡើយ[201]។ ប្រសិនបើមានក្រុមលើសពីមួយត្រូវបានដាក់ជាគោលដៅដែលត្រូវបំផ្លាញ នោះលក្ខខណ្ឌធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ត្រូវតែបានបំពេញចំពោះក្រុមនីមួយៗ[202]។

*ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ដែលមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក*

៩០. មាត្រា ៤ នៃ ច្បាប់ អ.វ.ត.ក ចែងអំពីអំពើប្រល័យពូជសាសន៍ ដែលធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តត្រូវតែធ្វើការបញ្ជាក់(បន្ថែមពីលើចេតនាជាក់លាក់ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍[203] ដូចមានបង្ហាញជូនខាងក្រោម)។ អំពើប្រល័យពូជសាសន៍ខាងក្រោមនេះគឺមានភាពពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៤/២៖ (១) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម (២) ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម និង (៣)ការធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក។

---

[200] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៧។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៦១។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៥៧។

[201] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤១។

[202] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤១។

[203] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤កថាខណ្ឌ ២០។

៩១. ធាតុផ្សំនៃការ**ធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម** គឺស្មើគ្នានឹងធាតុផ្សំនៃការធ្វើមនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[204]។ ការស្លាប់ជនរងគ្រោះអាចបញ្ជាក់បានតាមរយៈ

[204] *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១០, ៧៨៧-៧៨៨។ ក្នុងសាលក្រមនេះ នៅក្នុងការយល់ឃើញរបស់ខ្លួនដែលថា ធាតុផ្សំនៃការសម្លាប់សមាជិកក្រុមគឺស្មើនឹងធាតុផ្សំនៃការធ្វើមនុស្សឃាត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា ធាតុផ្សំនៃការធ្វើមនុស្សឃាត ដែលជាការរំលោភលើច្បាប់ ឬទំនៀមទម្លាប់សង្គ្រាម (តាមគ្រោម ៣ នៃលក្ខន្តិកៈ ICTY) និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាធាតុផ្សំដូចគ្នា។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤២។ ពាក្យថា "ការសម្លាប់"ត្រូវបានបកស្រាយថាជាការសម្លាប់ដោយចេតនា (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១០៣) មនុស្សឃាតដែលបានប្រព្រឹត្តឡើងដោយមានចេតនាបណ្តាលឲ្យស្លាប់ (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Seromba* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-2001-66-I) ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣១៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៥៥) និងការធ្វើមនុស្សឃាត (*សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១០, ៧៨៧-៧៨៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤២)។ នៅក្នុង*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ នៅផ្នែកកំណត់សម្គាល់ ២៩១៨ អង្គជំនុំជម្រះសាលាដំបូង បានឯកភាពយោងលើ*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៩ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Seromba* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-2001-66-I) ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣១៧ និង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៥៥ ដែលបង្ហាញពីធាតុផ្សំស្មើគ្នាទោះបីជារបៀបហៅខុសគ្នាក៏ដោយ។ ចំពោះធាតុផ្សំអត្តនោម័ត សំណៅជាភាសាអង់គ្លេសនៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ហាមឃាត់មិនឲ្យមាន"ការសម្លាប់" ដែលពាក្យនេះមានលក្ខណៈអព្យាក្រឹត្យចំពោះចេតនានៃការប្រព្រឹត្តិ ចំណែកឯ សំណៅជាភាសាបារាំងវិញ ហាមឃាត់មិនឱ្យមាន"*ការសម្លាប់ដោយចេតនា- meurtre*" ដែលមានន័យថាការធ្វើមនុស្សឃាតដោយចេតនា។ អង្គជំនុំជម្រះនៅតុលាការ ICTR បានប្រកាន់យកការបកស្រាយដែលល្អបំផុតសម្រាប់ជនជាប់ចោទ គឺ *"ការសម្លាប់ដោយចេតនា-meurtre"* ហេតុនេះត្រូវ

ភស្តុតាងតាមកាលៈទេសៈ ដរាបណាមានតែសេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ដែលអាចទាញចេញបានពីភស្តុតាងបែបនោះ គឺសេចក្តីសន្និដ្ឋានដែលថា ជនរងគ្រោះបានស្លាប់ហើយ[205] ហេតុនេះ តម្រូវឱ្យមានភស្តុតាងបញ្ជាក់ពីលទ្ធផល(ទោះបីជាតាមរយៈសេចក្តី

---

មានចេតនាសម្លាប់ ឬបណ្តាលឱ្យស្លាប់ ប៉ុន្តែពុំមានការគិតទុកជាមុនទេ (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥០០-៥០១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំ ជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣កថាខណ្ឌ ៣១៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-95-1-A) ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ១៥១)។ អង្គជំនុំជម្រះនៅ ICTY បានប្រកាន់យកគោលជំហរស្មើភាពគ្នា ដោយឱ្យ"ការសម្លាប់"ស្មើនឹង"ការធ្វើមនុស្សឃាត" ហើយតាមរយៈការសម្រេចបែបនេះ បានឯកភាពតាមវិធីសាស្ត្ររបស់តុលាការ ICTR (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-10-T) ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-02-60-T) ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៤២)។ ក្នុងករណីណាក៏ដោយ ក៏មានការសេចក្តីអង្កេតថា នៅក្នុងបរិបទនៃចេតនាប្រល័យពូជសាសន៍ "*ស្ទើរតែគ្មានភាពខុសគ្នា*"រវាងការសម្លាប់ ជាមួយនឹងការសម្លាប់ដោយចេតនាឡើយ (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-95-1-A) ថ្ងៃទី០១ ខែ មិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១៥១)។

[205] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌs ៧៨៩, ៨១០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៦,៥៤២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-30/1-A) ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ២៦០។

សន្និដ្ឋានក៏ដោយ)[206]។ មិនមានលក្ខខណ្ឌតម្រូវត្រូវធ្វើការវាយតម្លៃអំពីចំនួនមនុស្សដែលត្រូវបានសម្លាប់ដើម្បីបញ្ជាក់ពី *អំពើពិឃាត* ទេ[207]។

៩២. ធាតុផ្សំនៃការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុមត្រូវការពារ

ក. *ធាតុផ្សំសត្យានុម័ត៖*

i. អំពើសកម្ម ឬអំពើអកម្ម ដែលធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកណាម្នាក់ ឬច្រើននាក់នៅក្នុងក្រុមត្រូវការពារ ត្រូវធ្វើការវាយតម្លៃតាមករណីនីមួយៗអំពីកាលៈទេសៈនោះ[208]។ ភ័ស្តុតាងបញ្ជាក់ពីលទ្ធផលនៃអំពើនោះត្រូវតម្រូវឱ្យមាន[209]។ របួសធ្ងន់ធ្ងរមិនចាំបាច់ទាល់តែជារបួសអចិន្ត្រៃយ៍ ឬមិនអាចព្យាបាលបានទេ ប៉ុន្តែ ត្រូវតែលើសពីការបាត់បង់សមត្ថភាពរាងកាយ ឬសតិបញ្ញាតិចតួច ឬជាបណ្តោះអាសន្ន ហើយ

---

[206] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤២។

[207] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* វិធាន ៩៨ ស្ទួន សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-5/18-AR98bis.1) ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ២៣។

[208] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៣, ៥៤៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១០៨, ១១០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣២៣។

[209] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៣។

នាំឱ្យខូចខាតសមត្ថភាពធ្ងន់ធ្ងរ និងរយៈពេលវែងដើម្បីរស់ក្នុងជីវិតធម្មតា និងអាចប្រកបកិច្ចការបាន[210]។

ii. មិនមានលក្ខខណ្ឌតម្រូវថា របួសនោះត្រូវតែមានលក្ខណៈធ្ងន់ធ្ងរល្មមអាចគំរាមកំហែងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកដល់ក្រុមត្រូវការពារទេ ប៉ុន្តែកម្រិតនៃការគំរាមកំហែងបំផ្លិចបំផ្លាញក្រុម អាចចាត់ទុកថាជារង្វាស់ដើម្បីវាស់វែងភាពធ្ងន់ធ្ងរនៃរបួសដែលបានបង្កឡើង[211].

---

[210] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៣។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Seromba* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-2001-66-A) ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៤៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣២០-៣២២។

[211] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៤។ នៅក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Seromba* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-2001-66-A) ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៤៦ និងនៅក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១២ មានការបញ្ជាក់ថា មានអត្ថិភាពលក្ខខណ្ឌតម្រូវបែបនេះ ប៉ុន្តែ នៅក្នុងរឿងក្តីទាំងពីរនេះ ជាក់ស្តែង គ្មានអង្គជំនុំជម្រះណាបានពិនិត្យថាតើភស្តុតាងបានបង្ហាញ ឬមិនបានបង្ហាញថា របួសមានមានលក្ខណៈធ្ងន់ធ្ងរល្មមអាចគំរាមកំហែងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកមកលើក្រុមត្រូវការពារ ដែរឬអត់ទេ ហើយសាលក្រមភាគច្រើនដែលបានធ្វើឡើងមុនពេល និងចាប់តាំងពីពេលមានការបញ្ជាក់ដំបូងនេះនៅក្នុងសាលដីការឿងក្តី *Seromba* បានដកចេញលក្ខខណ្ឌតម្រូវនេះជាបន្តបន្ទាប់ (សូមមើល ឧទា. *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-02-60-T) ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៤៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-99-36-T) ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៩០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-97-24-T) ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៥១៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ntawukulilyayo* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-05-82-T) ថ្ងៃទី ០៣ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ៤៥២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kalimanzira* សាលក្រម

iii. ការប្រព្រឹត្តិដោយអមនុស្សធម៌ ឬដោយបន្ថោក ទារុណកម្មផ្លូវចិត្ត ឬរាងកាយ ការរំលោភផ្លូវភេទ ការបំពារបំពានផ្លូវភេទ ការនិរទេស ការស្ទះចម្លើយ ឬក រួមជាមួយនឹងការវាយដំ និង/ឬការគំរាមសម្លាប់ អំពើហិង្សាលើរាងកាយមិនដល់ស្លាប់ដែលធ្វើឱ្យខូចសុខភាព ឬបណ្តាលឱ្យខូចរូបរាង ឬរបួសធ្ងន់ធ្ងរដល់សមាជិកក្រុមត្រូវការពារ និងការធ្វើទុក្ខបុកម្នេញ គឺស្ថិតនៅក្នុងចំណោម

---

អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-05-88-T) ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៥៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Renzaho* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-31-T) ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ៧៦២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-98-41-T) ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ២១១៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Gacumbtsi* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-2001-64-T) ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤ កថាខណ្ឌ ២៩១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ntagerura និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-99-46-T) ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ៦៦៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣២០-៣២៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ntakirutimana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-10 & ICTR-96-17-T) ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៣ កថាខណ្ឌ ៧៨៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៥៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-13-A) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៥៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-3-T) ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥០២-៥០៤)។ *សូមមើលផងដែរ* ការអនុវត្តអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (រឿងក្តី បូស្នៀ និង *Herzegovina តទល់នឹងស៊ែប៊ី និង Montenegro)* តុលាការ ICJ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ៣១៩ ក្នុងនោះ តុលាការ ICJ មិនបានអនុវត្តលក្ខខណ្ឌតម្រូវបន្ថែមចំពោះសេចក្តីសម្រេចលើអង្គហេតុរបស់ខ្លួនឡើយ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានរំឭកឡើងវិញអំពីពាក្យពេចន៍នៃបទប្បញ្ញត្តិពាក់ព័ន្ធនៃលក្ខន្តិកៈ ICTY ដោយមិនបានបញ្ចូលលក្ខខណ្ឌតម្រូវបែបនេះទេ (*សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* វិធាន ៩៨ស្ទួន សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-5/18-AR98bis.1) ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៣)។

អំពើដែលអាចធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា[212]។ ការប៉ះទង្គិចផ្លូវចិត្ត និងស្នាមរបួសរបស់ជនរងគ្រោះដែលនៅមានជីវិត ក្រោយពីការសម្លាប់រង្គាល គឺជារបួសធ្ងន់ធ្ងរខាងសតិបញ្ញា (និងរាងកាយ)[213]។ ការផ្លាស់ទីលំនៅដោយបង្ខំ មិនមែនជាអំពើប្រល័យពូជសាសន៍ទេ ប៉ុន្តែ អាចជាអំពើមួយដែលធ្វើឲ្យរបួសធ្ងន់ធ្ងរដល់រូបរាងកាយ និងសតិបញ្ញាដល់អ្នកនៅមានជីវិត ជាពិសេសប្រសិនបើកាលៈទេសៈនៃការផ្លាស់ទីលំនៅនោះ នាំឲ្យអ្នកផ្លាស់ទីលំនៅស្លាប់ទាំងអស់ ឬស្លាប់មួយចំនួន[214]។

iv. ទំនាក់ទំនងច្បាស់លាស់រវាងអំពើផ្សេងៗនៃអំពើប្រល័យពូជសាសន៍នៅមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ដែលដូចគ្នានឹងមាត្រា II (ក) និង (ខ) នៃ អនុសញ្ញា

---

[212] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Seromba* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-2001-66-A) ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៤៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTR (ICTR-96-13-A) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៥៦។

[213] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-02-60-T) ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៤៧ និង ៦៤៩ ដោយកថាខណ្ឌ ៦៤៧ សរសេរថា *"ការភ័យខ្លាចត្រូវគេចាប់ខ្លួន និងនៅពេលបែកបាក់គ្នា អារម្មណ៍មិនអាចជួយអ្វីបានទាល់តែសោះ និងការភ័យខ្លាចខ្លាំងពីសុវត្ថិភាពគ្រួសារ និងមិត្តភក្តិ ព្រមទាំងសុវត្ថិភាពផ្ទាល់ខ្លួន គឺជាបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តដែលមិនបានធូរស្រាលលឿនបានឡើយ ប្រសិនបើបានធូរស្រាលមែន។ ជាងនេះទៀត [...] អ្នកទាំងនោះបានទទួលរងរបួសផ្លូវចិត្តដោយគេដកចេញ ឯកសារអត្តសញ្ញាណប័ណ្ណ* ដោយអ្នកទាំងនោះមើលឃើញថា ពួកគេមិនបានត្រូវគេធ្វើការផ្លាស់ប្តូរដូចដែលគេបានប្រាប់ពីមុនឡើយ និងនៅពេលដែលពួកគេបានយល់ពីជោគវាសនាចុងក្រោយរបស់ខ្លួនថាទៅជាយ៉ាងណា"។

[214] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY(IT-02-60-T) ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៥០,៦៥៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៥។

ប្រឆាំងអំពើប្រល័យពូជសាសន៍ មិនទាន់មានការបញ្ជាក់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់នៅក្នុងករណីយុត្តិសាស្ត្រទេ ដូចដែលអាចឃើញហើយ[215] គឺ អាចដោយសារថា ទំនាក់ទំនងនេះត្រូវបានចាត់ទុកថាមានលក្ខណៈច្បាស់លាស់ហើយ។ តាមន័យអង្គហេតុដាច់ខាត ដោយយកតាមគំរូនៃសេណារីយ៉ូជាមូលដ្ឋានអំពីមនុស្សឃាត អំពើសម្លាប់ស្ទើរតែទាំងអស់គឺពាក់ព័ន្ធនឹងការបង្កឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ទោះបីជាក្នុងករណីខ្លះ អំពើនោះកើតឡើងក្នុងរយៈពេលខ្លីក៏ដោយ ដែលជាដំណាក់កាលអន្តរការីចាំបាច់បណ្តាល ឱ្យស្លាប់។ ប្រសិនបើក្រោយមកមានការស្លាប់ ហើយអាចបញ្ជាក់ពីការបង្កហេតុដោយចេតនារបស់ជនជាប់ចោទ នោះ គ្មានតុលាការថ្នាក់ជាតិណាសម្រេចផ្តន្ទាទោសបន្ថែមទៀត ដោយផ្អែកលើអង្គហេតុដូចគ្នាដែលបង្កឱ្យមានរបួសធ្ងន់ធ្ងរទេ[216]។ នៅក្នុងប្រព័ន្ធជាតិនៅ ករណីទាំងនេះជាទូទៅ មានចែងនៅក្នុងគោលការណ៍ច្បាប់ព្រហ្មទណ្ឌអំពីបទល្មើសត្រួតគ្នា(*concursus delictorum*)។ នៅក្នុងសំណុំរឿងនេះ គេប្រហែលជាចង់ពិចារណាទស្សនទានអំពីទំនាក់ទំនងបទល្មើសមិនសូវធ្ងន់រវាង ចំណុច (ក) ជាមួយនឹងចំណុច (ខ)។ ប៉ុន្តែ ការសន្និដ្ឋានអំពីទំនាក់ទំនងនេះមានមន្ទិល៖ រហូតមកដល់ពេលនេះ តុលាការមិនអចិន្ត្រៃយ៍នានា ដូចបានពន្យល់ខាងលើហើយ បានបកស្រាយថា ធាតុផ្សំនៃរបួសធ្ងន់ធ្ងរដល់រាងកាយ នៅចំណុច (ខ) គឺជា *"ការខូចខាតសមត្ថភាពធ្ងន់ធ្ងរ និងរយៈពេលវែងដើម្បីរស់ក្នុងជីវិតធម្មតា និងអាច*

[215] មានករណីយុត្តិសាស្ត្រស្តីពីទំនាក់ទំនងរវាងអំពើប្រល័យពូជសាសន៍ជាមួយនឹងការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដោយការយល់ឃើញលើសលុបបង្ហាញឱ្យឃើញថា ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ មិនគួរប្រើប្រាស់ជាការផ្តន្ទាទោសត្រួតគ្នាទេ សូមមើល Stuckenberg *បទចោទត្រួតគ្នា និងការផ្តន្ទាទោសត្រួតគ្នា* នៅក្នុងស្នាដៃរបស់ Stahn (អ្នកកែសម្រួល) ច្បាប់ និងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សារព័ត៌មានសាកលវិទ្យាល័យអុកស្វ៊ដ ឆ្នាំ ២០១៥ ទំព័រ ៨៥០,៨៥១។

[216] តាមពិត វិធីសាស្ត្របែបនេះនឹងនាំឱ្យមានការបន្ថែមទោសស្រាល។ ចុងក្រោយ ការផ្តន្ទាទោសស្រាលបន្ថែមគឺត្រឹមតែការប្រព្រឹត្តិហិង្សា។

*ប្រកបកិច្ចការបាន*”[217] ហើយសាលក្រមពីមុនៗបានសម្រេចលើបញ្ហានេះតែក្នុងបរិបទនៃរឿស ដែល *អ្នកនៅមានជីវិតបានទទួលរងអ៊ុ*តប៉ុណ្ណោះ[218]។ ហេតុនេះ នេះមិនត្រូវទាំងស្រុងតាមករណីដែលលទ្ធផលដែល *មានចេតនា និងសម្រេចបាន* គឺត្រូវសម្លាប់សមាជិកក្រុមត្រូវការពារឱ្យបានឆាប់រហ័ស ទោះបីជាថា ឧទាហរណ៍ អាចមានរយៈពេលឃុំខ្លួនដែលរួមមានការរំលោភបំពានខាងរាងកាយ និងផ្លូវចិត្ត មុនពេលអំពើសម្លាប់កើតឡើងក៏ដោយ។ម្យ៉ាងវិញទៀត ចំណុច ខ តាមតម្រុយធាតុផ្សំសន្យានុម័តតម្រូវថា បុគ្គលជាជនរងគ្រោះ ត្រូវតែ *នៅមានជីវិត* ហើយបើតាមវិធីសាស្ត្រត្រឹមត្រូវតាមទ្រឹស្តី ករណីនេះមិនអាចអនុវត្តត្រួតលើគ្នាជាមួយនឹងករណី ដែលជនរងគ្រោះត្រូវបានសម្លាប់ឡើយ។ វាមិនមែនជាបទល្មើសមិនសូវធ្ងន់ទេ បើធៀបនឹងចំណុច ក។ ក៏មិនចាំបាច់ពង្រីកការបកស្រាយចំណុច ខ ទៅដល់សេណារីយ៉ូនៃការសម្លាប់ដោយចេតនា ដើម្បីកុំឱ្យមានគម្លាតនិទណ្ឌភាពដែលមិនគួរកើតមាន និងកើតមានដោយអចេតនាដែរ៖ ប្រសិនបើជនរងគ្រោះណាម្នាក់ក្នុងចំណោមជនរងគ្រោះដែលត្រូវសម្លាប់នៅមានជីវិត នោះក្នុងករណីណាក៏ដោយ ធាតុផ្សំអត្តនោម័តិអំពីការសម្លាប់ (សូមមើល កថាខណ្ឌ ៩១ ខាងលើ) គឺគ្រប់គ្រាន់សម្រាប់បទចោទនៅក្រុងចំណុច ខ[219]។

---

[217] Stuckenberg *បទចោទត្រួតគ្នា និងការផ្តន្ទាទោសត្រួតគ្នា* នៅក្នុងស្នាដៃ របស់ Stahn (អ្នកកែសម្រួល) ច្បាប់និងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សារព័ត៌មានសាកលវិទ្យាល័យអុកស្វ៊ដ ឆ្នាំ ២០១៥ ទំព័រ ៨៤០ និងទំព័របន្ទាប់ ដោយមានយោង។ ការអនុវត្តរបស់តុលាការលើបញ្ហានេះនៅតែមិនទាន់ដោះស្រាយបាននៅឡើយតាមន័យទ្រឹស្តី។

[218] *សូមមើល* Tams/Berster/Schiffbauer អនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍–មតិយោបល់ CH Beck/Hart/Nomos ឆ្នាំ២០១៤ មាត្រា២ mn 69។

[219] *សូមមេីល* អំពីបរិបទនៃបញ្ហាចោទថាតើត្រឹមកម្រិតណាដែលអ្នករៀបចំអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍អាចដោះស្រាយ ឬមានបំណងដោះស្រាយផលប៉ះពាល់លើទ្រឹស្តីដែលបណ្តាលមកពីទំនាក់ទំនងទៅវិញទៅមករវាងទម្រង់ផ្សេងៗគ្នានៃអំពើប្រល័យពូជសាសន៍ Kreß *ការជួបប្រទះដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិជាមួយនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍* នៅក្នុង ឯកសាររបស់ Stahn (ដូចខាងលើ ជើងទំព័រ ២២៤) ទំព័រ ៧០០។

v. ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ មិនបានដាក់ជាបទចោទនៅក្នុងសំណុំរឿងនេះទេ ហេតុនេះ មិនចាំបាច់ពិភាក្សាអំពីទំនាក់ទំនងនៃអំពើប្រល័យពូជសាសន៍ប្រភេទនេះ ជាមួយនឹងសេណារីយ៉ូនៃអំពើប្រល័យពូជសាសន៍ប្រភេទខាងលើទេ។

ខ. *ធាតុផ្សំអត្តនោម័តិ៖* អំពើសកម្ម ឬអំពើអកម្ម ត្រូវតែជាអំពើចេតនា ហើយមានបំណងធ្វើឱ្យរបួសធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា[220]។

៩៣. ធាតុផ្សំនៃការ**ធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក** គឺ៖

ក. *ធាតុផ្សំសត្យានុម័តិ៖* វិធីសាស្ត្របំផ្លិចបំផ្លាញ មិនបានសម្លាប់សមាជិកនៃក្រុមត្រូវការពារភ្លាមៗទេ ប៉ុន្តែ ចុងក្រោយ ព្យាយាមបំផ្លិចបំផ្លាញរូបរាងកាយសមាជិកនោះ។ ហេតុនេះ ភស្តុតាងបញ្ជាក់ពីលទ្ធផលមិនតម្រូវឱ្យមានទេ។ ឧទាហរណ៍អំពីវិធីសាស្ត្របំផ្លិចបំផ្លាញ មានដូចជា ការរំលោភផ្លូវភេទ[221] ការបដិសេធមិនផ្តល់សេវាសុខភាព[222] ការផ្តល់របបអាហារ

---

[220] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣២៣។

[221] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥០៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១១៦។

[222] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១១៦។

សម្រាប់តែរស់រាន ការបង្កើតកាលៈទេសៈដែលនាំឱ្យជនរងគ្រោះស្លាប់បន្តិចម្តងៗ ដូចជា កង្វះអាហារ ទឹក កន្លែងស្នាក់នៅ សម្លៀកបំពាក់ អនាម័យ ការដាក់ឱ្យមនុស្សធ្វើការហួសហេតុ ឬប្រើកម្លាំងហួសហេតុ និងការបណ្តេញចេញជាប្រព័ន្ធឱ្យមនុស្សចេញពីផ្ទះរបស់ខ្លួន[223]។ ស្ថានភាពនានាត្រូវបានរៀបចំឡើងដើម្បីបំផ្លិចបំផ្លាញរាងកាយក្រុមនោះទាំងស្រុង ឬមួយផ្នែក មិនមែនរៀបចំឡើង ដើម្បីរំលាយក្រុមនោះទេ[224]។ ប្រសិនបើមិនមានភស្តុតាងផ្ទាល់បញ្ជាក់ថា ស្ថានភាពនានាត្រូវបានរៀបចំឡើងដើម្បីបំផ្លិចបំផ្លាញរាងកាយក្រុមនោះទេ នោះត្រូវផ្តោតលើ *"ករណីយភាពសព្វាគ្រប់"* នៃស្ថានភាពបែបនោះដែលនាំឱ្យបំផ្លិចបំផ្លាញរាងកាយក្រុមនោះ ហើយកត្តាពាក់ព័ន្ធ រួមមាន លក្ខណៈនៃស្ថានភាពបែបនោះ រយៈពេលដែលជនរងគ្រោះទទួលរងស្ថានភាពបែបនោះ និងលក្ខណៈនៃសមាជិកក្រុមគោលដៅនោះ ឧទាហរណ៍ ភាពងាយរងគ្រោះរបស់សមាជិកនោះ[225]។ ស្ថានភាពដែលមិនមានលក្ខណៈគ្រប់គ្រាន់ទោះជាតាមបទដ្ឋានណាក៏ដោយ ប៉ុន្តែនៅតែមានលក្ខណៈគ្រប់គ្រាន់អាចឱ្យក្រុមនោះរស់រានបាន ហើយមិនបានចូលរួម

---

[223] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-96-4-T) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥០៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១១៥-១១៦។

[224] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៧។

[225] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤៨។

01588373



ចំណែកបំផ្លិចបំផ្លាញក្រុមនោះទេ គឺជាស្ថានភាពដែលមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃ*អំពើពិរុទ្ធ* នេះទេ[226]។

ខ. *ធាតុផ្សំអត្តនោម័តិ៖* ការធ្វើ "*ដោយចេតនា*" ឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក[227]។

*ចេតនាអំពើប្រល័យពូជសាសន៍*

៩៤. ក្រៅពីត្រូវមានលក្ខខណ្ឌតម្រូវនៃ*ធាតុផ្សំអត្តនោម័តិ* ទាក់ទិននឹងអំពើពាក់ព័ន្ធដូចបានបង្ហាញខាងលើនេះ ជនល្មើសត្រូវមានចេតនាជាក់លាក់ដើម្បីបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកមកលើក្រុមត្រូវការពារ ដោយមានចេតនាបែបនោះ[228]។

៩៥. "***ដើម្បីបំផ្លិចបំផ្លាញ***"- អំពើប្រល័យពូជសាសន៍ រួមមានតែអំពើដែលបានប្រព្រឹត្តឡើងដើម្បីបំផ្លិចបំផ្លិចផ្នែកជីវសាស្ត្រ ឬរូបរាងកាយទាំងស្រុង ឬមួយផ្នែកមកលើក្រុមត្រូវការពារ[229]។

---

[226] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-00-39-T) ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៦៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤៨។

[227] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨១៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-99-36-T) ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៩២។

[228] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨០៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ២០។

[229] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ២៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា

ហេតុនេះ អំពើដែលគ្រាន់តែវាយប្រហារលើលក្ខណៈសង្គម ឬវប្បធម៌របស់ក្រុមត្រូវការពារ ដើម្បីកុំឱ្យក្រុមនោះមានអត្តសញ្ញាណផ្ទាល់ខ្លួន (ឧទាហរណ៍ ការបំផ្លាញអគារសាសនា ឬផ្ទះរបស់សមាជិកក្រុមនោះ) គឺមិនស្ថិតនៅក្នុងនិយមន័យអំពីអំពើប្រល័យពូជសាសន៍ទេ។ ប៉ុន្តែ អំពើបែបនេះអាចជាភស្តុតាង ដែលអាចទាញសេចក្តីសន្និដ្ឋានបញ្ជាក់ពីចេតនាបំផ្លិចបំផ្លាញផ្នែកជីវសាស្ត្រ និងរូបរាងកាយ[230]។

៩៦. "***ទាំងស្រុង ឬមួយផ្នែក***" - ឃ្លានេះសំដៅលើចេតនាបំផ្លិចបំផ្លាញទាំងស្រុង *ឬមួយផ្នែក*មកលើក្រុមត្រូវការពារ៖ ការបំផ្លិចបំផ្លាញក្រុមមួយផ្នែក មិនចាំបាច់ទាល់តែមានចេតនាបំផ្លិចបំផ្លាញក្រុមទាំងស្រុងទេ[231]។ ដោយសារមិនមានសេចក្តីណែនាំនៅក្នុងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ឬនៅក្នុងលក្ខន្តិកៈរបស់ខ្លួននោះ ទើបសាលាក្តីមិនអចិន្ត្រៃយ៍ បានបង្កើតនិយមន័យថា ចេតនាបំផ្លិចបំផ្លាញក្រុមមួយផ្នែក គឺជាចេតនាបំផ្លិចបំផ្លាញក្រុមយ៉ាងហោចណាស់មួយផ្នែក"*ធំ*"ល្មមអាចមានផលប៉ះពាល់មកលើក្រុមទាំងមូល ដោយគិតពីបរិបទដែលអំពើដែលបានចោទនោះបានប្រព្រឹត្តឡើង[232]។

---

ឆ្នាំ ២០១០ កថាខណ្ឌ ៨២២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៥៣។

[230] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ២៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨២២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៥៣។

[231] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៨៣-៥៨៤។

[232] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៦៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៩០។ ការអនុវត្តអនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (រឿងក្តី បូស្នៀ និង *Herzegovina តទល់នឹងស៊ែប៊ី និង Montenegro* )តុលាការ ICJ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ១៩៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ៨-៩។ *រឿងក្តីរដ្ឋអាជ្ញា*

01588375



៩៧. ក្រុមគោលដៅ អាចរួមមាន បុគ្គលិកយោធា ដរាបណាបុគ្គលិកយោធានោះត្រូវបានចាត់ទុកថាជាគោលដៅ ដោយសារពួកគេជាសមាជិកនៅក្នុងក្រុមត្រូវការពារ[233]។

៩៨. "***ដោយមានចេតនាបែបនោះ***" - អំពើបទល្មើស ត្រូវតែបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លិចបំផ្លាញក្រុមគោលដៅ ដែលជាក្រុមមួយដាច់ដោយឡែក និងខុសគេរបស់បុគ្គលជាជនរងគ្រោះ៖ ជនរងគ្រោះចុងក្រោយបំផុត ដោយសារឧក្រិដ្ឋកម្មនេះគឺជាក្រុម[234]។ ជាប់ពាក់ព័ន្ធគ្នា

---

*តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨៣១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៥៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៦។ ទោះបីជានៅក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ ត្រង់កថាខណ្ឌ ៩៧ ភាសាដែលបានប្រើប្រាស់គឺ *"ចំនួនមនុស្សយ៉ាងច្រើន"* ហើយនៅក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ (ត្រង់កថាខណ្ឌ ៦៤) ដោយដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1-T) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ (ហើយត្រូវបានដកស្រង់វិញនៅក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Semanza* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-97-20-T) ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៦) យ៉ាងណាក៏ដោយ ក៏អង្គជំនុះជម្រះសាលាដំបូង ប្រើប្រាស់ពាក្យ"មួយផ្នែកធំ" ហេតុនេះច្បាស់លាស់គឺថា អង្គជំនុំជម្រះសាលាដំបូងរឿងក្តី *Kayishema* មិនមានបំណងអនុវត្តបទដ្ឋានផ្សេងទេ *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កំណត់សម្គាល់ ១៥ កថាខណ្ឌ ៩។

[233] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨៣៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-33-A) ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ២២៦។

[234] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៨២១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៥១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៦១។

នេះវិញដែរ បុគ្គលជាជនរងគ្រោះត្រូវតែជាគោលដៅ *ដោយសារថា* ពួកគេជាសមាជិកនៅក្នុងក្រុម(ប៉ុន្តែ មិនចាំបាច់ទាល់*តែ*ថា ពួកគេជាសមាជិកបែបនេះទេ) ហេតុនេះ ការគ្រាន់តែដឹងអំពីសមាជិកភាពបែបនេះតែមួយមុខនោះ គឺមិនគ្រប់គ្រាន់អាចបញ្ជាក់ពីចេតនាបំផ្លិចបំផ្លាញក្រុមបែបនេះបានទេ[235]។

## ៤.៣. ទម្រង់នៃការទទួលខុសត្រូវ

### ៤.៣.១. ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ

៩៩. អនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក បុគ្គលម្នាក់អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈទម្រង់នៃការទទួលខុសត្រូវតាមរយៈការប្រព្រឹត្តិ (រួមទាំងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម) ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះ គឺសុទ្ធតែជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលដែលស្ថិតក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[236]។

---

[235] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-98-33-T) ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadzic* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-95-5/18-T) ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៥១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Bagilishema* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-95-1A-T) ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៦១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Niyitegeka* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-14-A) ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ៥៣។

[236] <u>ការប្រព្រឹត្តិ៖</u> **សំណុំរឿងលេខ ០០១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៣៨-៤៧៩។ <u>ការរៀបចំផែនការ៖</u> **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៧។ <u>ការញុះញង់៖</u> **សំណុំរឿង ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៩។ <u>ការបញ្ជា៖</u> **សំណុំរឿង ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០១។ <u>ការជួយ និងការជំរុញ៖</u> **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៣។ <u>ការទទួលខុសត្រូវរបស់ថ្នាក់លើ៖</u> **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៤។

01588377



១០០. ***ការប្រព្រឹត្តិ៖*** ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ រួមមានការប្រព្រឹត្តិផ្ទាល់ ឬអំពើអកម្ម ដែលមានពិរុទ្ធនៃអំពើសកម្មមួយ[237]។ ចារីត្រូវតែបានប្រព្រឹត្តអំពើ ដោយមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងអំពីលទ្ធភាពខ្ពស់ដែលថា ឧក្រិដ្ឋកម្មអាចនឹងកើតមានឡើង ដោយសារតែអំពើដែលត្រូវបានចោទប្រកាន់នោះ[238]។ ការប្រព្រឹត្តិក៏រួមមានការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម[239] ដែលនឹងត្រូវពិភាក្សាបន្ថែមនៅផ្នែកខាងក្រោម។

១០១. ***ការរៀបចំផែនការ៖*** ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះកើតឡើង នៅពេលដែលមនុស្សម្នាក់ ឬច្រើននាក់រៀបចំអំពើព្រហ្មទណ្ឌ ដែលបង្កើតបានជាឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងនៅពេលបន្ទាប់[240]។ ការរៀបចំផែនការចាំបាច់ត្រូវតែកើតឡើងមុន និងចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[241]។ ចារីចាំបាច់ត្រូវតែមានចេតនាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីលទ្ធភាពខ្ពស់ដែលថា ឧក្រិដ្ឋកម្មអាចនឹងត្រូវកើតឡើង នៅពេលបំពេញ ឬអនុវត្តផែនការ[242]។

១០២. ***ការញុះញង់៖*** ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះកើតឡើង នៅពេលដែលបុគ្គលម្នាក់ តាមរយៈអំពើសកម្ម ឬអកម្ម បណ្តាលឱ្យមនុស្សម្នាក់ទៀតប្រព្រឹត្តឧក្រិដ្ឋកម្ម[243]។ ការញុះញង់អាចកំណត់បាន តាមរយៈការណែនាំជាលាយលក្ខណ៍អក្សរ ការណែនាំដោយប្រយោល ឬ

---

[237] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧៩។

[238] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៨១។

[239] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧៩។

[240] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៨។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-14/2-A) ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ២៦។

[241] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៨។

[242] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៨។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៩។

[243] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២២។

ការណែនាំមិនផ្ទាល់មាត់ផ្សេងទៀត ហើយមិនចាំបាច់កំណត់ពីអំណាចណាមួយរវាងអ្នកញុះញង់ដែលរងការចោទប្រកាន់ជាមួយនឹងជនល្មើសឡើយ[244]។ ការញុះញង់ចាំបាច់ត្រូវតែកើតឡើងមុន និងរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[245]។ អ្នកញុះញង់ចាំបាច់ត្រូវតែមានចេតនាបង្កឡើង ឬនាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីលទ្ធភាពខ្ពស់ដែលថាឧក្រិដ្ឋកម្មមួយអាចនឹងត្រូវប្រព្រឹត្តឡើង នៅពេលដែលញុះញង់[246]។

១០៣. ***ការបញ្ជា៖*** ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះកើតឡើង នៅពេលដែលបុគ្គលម្នាក់ នៅក្នុងតួនាទីមាន*សិទ្ធិអំណាចជាក់ស្តែង* ឬ*តាមផ្លូវច្បាប់* បង្គាប់មនុស្សផ្សេងទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[247]។ មិនតម្រូវឱ្យមានទំនាក់ទំនងថ្នាក់លើថ្នាក់ក្រោមផ្លូវការណាមួយឡើយរវាងអ្នកចេញបង្គាប់ និងអ្នកទទួលបង្គាប់[248]។ ការបង្គាប់បញ្ជានេះ ដែលមិនតម្រូវថាត្រូវតែមានក្នុងទម្រង់ណាមួយនោះទេ ចាំបាច់ត្រូវតែរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[249]។ ការទទួលខុសត្រូវលើការបញ្ជាអាចកើតឡើងផងដែរ នៅពេលដែលបុគ្គលម្នាក់បានប្រគល់

---

[244] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២២។

[245] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ **សំណុំរឿងលេខ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២២។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Kordić និង Čerkez* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-14/2-A) ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ២៧។

[246] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ **សំណុំរឿងលេខ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៤។

[247] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[248] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[249] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

បញ្ជា ឬផ្ទេរបញ្ជា រួមមានតាមរយៈអន្តរការី[250]។ អ្នកចេញបញ្ជាចាំបាច់ត្រូវតែមានចេតនាឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីលទ្ធភាពខ្ពស់ដែលថា ឧក្រិដ្ឋកម្មអាចនឹងត្រូវប្រព្រឹត្តដោយសារការធ្វើតាមបញ្ជា ឬអនុវត្តតាមបញ្ជា[251]។

១០៤. ***ការទទួលខុសត្រូវរបស់ថ្នាក់លើ៖*** ការទទួលខុសត្រូវរបស់ថ្នាក់លើ (ឬបញ្ជា) គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈអំពើអកម្មដែលមានពិរុទ្ធភាព ហើយតាមរយៈអំពើនេះ ថ្នាក់លើស៊ីវិល ឬយោធា អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសារមិនបានរារាំង និង/ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្ម ដែលអ្នកនៅក្រោមបង្គាប់បានប្រព្រឹត្ត។

១០៥. លក្ខខណ្ឌតម្រូវទីមួយគឺអត្ថិភាពនៃទំនាក់ទំនងរវាងថ្នាក់លើ ជាមួយនឹងអ្នកនៅក្រោមបង្គាប់[252] ដែលអាចជាលក្ខណៈជាក់ស្តែង ឬផ្លូវច្បាប់[253]។ បន្ថែមលើនេះ ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តចំពោះថ្នាក់លើទាំងស៊ីវិល ទាំងយោធា[254]។ ថ្នាក់លើទោះបីជាស៊ីវិល ឬយោធា ចាំបាច់ត្រូវតែមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដែលជាសមត្ថភាពជាក់ស្តែងដើម្បីរារាំង និង/ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មរបស់ចារីជាអ្នកនៅក្រោមបង្គាប់[255]។ ចុងក្រោយ

---

[250] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[251] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៨។

[252] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣៨។

[253] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤០។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត("រឿងក្តី Čelebići")* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-96-21-A) ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ១៩១-១៩២ និង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-88-T) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ១០៣៨។

[254] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៤។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧៦-៤៧៧។

[255] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤០ ដល់ ៥៤២។

ថ្នាក់លើចាំបាច់ត្រូវតែមិនបានចាត់វិធានការដែលចាំបាច់ និងសមហេតុផលដើម្បីរារាំងការប្រព្រឹត្តិឧក្រិដ្ឋកម្មបែបនេះ ឬដាក់ទណ្ឌកម្មចារី[256]។ យោងតាមយុត្តិសាស្ត្ររបស់សាលាក្តីមិនអចិន្ត្រៃយ៍ គឺមិនចាំបាច់ត្រូវបង្ហាញភស្តុតាងបញ្ជាក់ពីទំនាក់ទំនងហេតុនិងផលរវាងការដែលថ្នាក់លើមិនបានរារាំងឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ ជាមួយនឹងការកើតឡើងនូវឧក្រិដ្ឋកម្មទាំងអស់នេះទេ[257]។

១០៦. បន្ថែមពីលើនេះ ដើម្បីទទួលខុសត្រូវព្រហ្មទណ្ឌ ថ្នាក់លើចាំបាច់ត្រូវតែបានដឹង ឬមានហេតុផលត្រូវដឹងថា ឧក្រិដ្ឋកម្មមួយរៀបនឹងកើតឡើង ឬបានប្រព្រឹត្ត ដោយអ្នកនៅក្រោមបង្គាប់របស់គាត់ម្នាក់ ឬក៏ច្រើននាក់ ពោលគឺការដឹងតាមរយៈការមានព័ត៌មានដែលសមល្មមនឹងធ្វើឱ្យជ្រួតជ្រាបសម្រាប់ជាយុត្តិកម្មឱ្យសួរដេញដោលបន្ថែមទៀត[258]។ ថ្នាក់លើមិនចាំបាច់ត្រូវដឹងអត្តសញ្ញាណច្បាស់លាស់របស់ចារីជាអ្នកនៅក្រោមបង្គាប់ទេ ប៉ុន្តែ អត្ថិភាពនៃអត្តសញ្ញាណនេះត្រូវតែមានការបញ្ជាក់[259]។

១០៧. ការមិនបានរារាំង និងការមិនបានដាក់ទណ្ឌកម្ម គឺជាទម្រង់នៃការទទួលខុសត្រូវដាច់ពីគ្នាទាំងអង្គហេតុ ទាំងអង្គច្បាប់ ដែលមានកាតព្វកិច្ចផ្លូវច្បាប់ពីរខុសដាច់ពីគ្នា។ ថ្នាក់លើអាចត្រូវទទួលខុសត្រូវចំពោះការមិនបានអនុវត្តចំណុចទាំងពីរ[260]។

---

[256] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៦។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៥ ដល់ ៥៤៧។

[257] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hadžihasanović និង Kubura* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-01-47-A) ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ៤០។

[258] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៣ ដល់ ៥៤៤។

[259] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-02-60-A) ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ២៨៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Orić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-03-68-A) ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ៣៥។

[260] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៥ ដល់ ៥៤៧។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hadžihasanović និង Kubura* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-01-47-A) ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ២៥៩-២៦០។

១០៨. ថ្នាក់លើអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោមដែលមិនបានស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួនជាផ្លូវការទេ ដរាបណា លក្ខខណ្ឌតម្រូវផ្សេងទៀតនៃការទទួលខុសត្រូវថ្នាក់លើត្រូវបានបំពេញ[261]។

១០៩. ***ធាតុផ្សំអត្តនោម័តិ៖*** ដែលតម្រូវឱ្យថ្នាក់លើទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ *គឺ* ថ្នាក់លើបានដឹង ឬមានហេតុផលត្រូវដឹងថា ថ្នាក់ក្រោមរបស់ខ្លួន (១) ហៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និង (២) មានចេតនាច្បាស់លាស់តាមលក្ខខណ្ឌតម្រូវនេះ[262]។

១១០. ***សហឧក្រិដ្ឋកម្មរួម៖*** ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម មានន័យស្មើនឹងការប្រព្រឹត្ត អនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[263]។ សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃសហចារីដែលមនុស្សជាច្រើននាក់មានគោលបំណង ឬគោលដៅរួមគ្នាដែលស្មើនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន[264]។

---

[261] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧២១។ **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤២ ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង BlaÈkić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-14-A) ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៧ និង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត ("រឿងក្តីCelebići")* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-96-21-A) ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២៥២។

[262] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević & Jokić សាលក្រម* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60) ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៨២, ៦៨៦។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Brđanin* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ (IT-99-36-T) ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ៧១៥-៧២១។

[263] **សំណុំរឿងលេខ ០០២- ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាន នូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២២។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩០។

[264] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩២។

១១១. តុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនានាបានកំណត់ទម្រង់ចំនួនបីនៃសហឧក្រិដ្ឋកម្មរួម[265]។ ទម្រង់ទីមួយ និងទីពីរនៃសហឧក្រិដ្ឋកម្មរួម មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយអាចអនុវត្តបាននៅ អ.វ.ត.ក[266]។ ទម្រង់ទីពីរនៃសហឧក្រិដ្ឋកម្មរួម ដែលជាគោលការណ៍មានធាតុផ្សំដូចគ្នាជាមួយនឹងទម្រង់ទីមួយ មិនបានដាក់ជាបទចោទលើ **អោ អាន** ឡើយ។ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលវេលានោះឡើយ ដូច្នេះ ទម្រង់នេះមិនអាចអនុវត្តបានទេនៅ អ.វ.ត.ក[267]។ ហេតុដូច្នេះ មានតែធាតុផ្សំនៃទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះ ដែលនឹងត្រូវសង្ខេបនៅក្នុងផ្នែកនេះ។

១១២. *គោលបំណងរួម៖* គោលបំណង ឬគោលដៅរួម អាចជាអំពើឧក្រិដ្ឋតែម្តង (ហេតុនេះ គោលបំណងរួមនេះ*ស្មើនឹង*ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន) ឬអាចជាគោលដៅមិនមែនឧក្រិដ្ឋកម្មដែលមនុស្សជាច្រើនមានចេតនាសម្រេច តាមរយៈមធ្យោបាយឧក្រិដ្ឋកម្ម (ហេតុនេះ គោលបំណងរួមនេះ*ពាក់ព័ន្ធនឹង*ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន) [268]។

---

[265]**សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadic* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-94-1-A) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩៦-២០៤។

[266] **សំណុំរឿងលេខ ០០២- ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២២។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩១។ **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៩១។

[267] **សំណុំរឿងលេខ ០០២- ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៣៥, ៣៨។ **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៩១។ **សំណុំរឿងលេខ ០០២- ឯកសារ D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៧៧, ៨៣ ដល់ ៨៨។

[268] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨១៤។ **សំណុំរឿងលេខ ០០២- ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៧។ **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brdanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-

១១៣. ជាឧទាហរណ៍នៅក្នុងសំណុំរឿង 00២/0១ អង្គជំនុំជម្រះសាលាដំបូង និង អ.ជ.ត.ក បាន សម្រេចថា សមាជិកនៃសហឧក្រិដ្ឋកម្មរួម មានគោលបំណងរួមមួយ ដើម្បីអនុវត្តបដិវត្ត សង្គមនិយម នៅក្នុងប្រទេសកម្ពុជា ដែលគោលបំណងរួមនេះមិនមែនជាគោលបំណងឧក្រិដ្ឋឡើយ ប៉ុន្តែពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដើម្បីធ្វើឱ្យគោលបំណងរួមនោះសម្រេចបានជាផ្លែផ្កា[269]។

១១៤. មិនមានលក្ខខណ្ឌតម្រូវថា អ្នកចូលរួមសហឧក្រិដ្ឋកម្មរួមត្រូវតែមានផែនការដែលបានរៀបចំ ឬបង្កើតឡើងពីមុនរួចហើយទេ។ គោលបំណង ឬគោលដៅរួម អាចលេចចេញជារូបរាង ដោយឥតព្រៀងទុក ហើយអាចទាញចេញសេចក្ដីសន្និដ្ឋានបានពីអង្គហេតុដែលថា មនុស្សជាច្រើននាក់បានធ្វើសកម្មភាពរួមគ្នា ដើម្បីអនុវត្តសហឧក្រិដ្ឋកម្មរួម[270]។

---

36-A) ថ្ងៃទី 0៣ ខែ មេសា ឆ្នាំ ២00៧ កថាខណ្ឌ ៤១៨។ រឿងក្ដី *ព្រះរាជអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL (SCSL-04-16-A) ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២00៨ កថាខណ្ឌ ៨0។*សូមមើលផងដែរ រឿងក្ដីព្រះរាជអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-30/1-A) ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២00៥ កថាខណ្ឌ ៩៦។

[269] **សំណុំរឿងលេខ 00២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២0១៤ កថាខណ្ឌ ៧៧៨, ៨0៤ និង ៨៣៤។ **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២0១៦ កថាខណ្ឌ ៨១៦។ ប្រហែលគ្នានេះដែរនៅក្នុង*រឿងក្ដីព្រះរាជអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-04-74-T) វ៉ុលទី ៤ នៃវ៉ុលទី ៦ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២0១៣ កថាខណ្ឌ ២៤, ៤១ ដល់ ៤៣, ៦៥ ដល់៦៨ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សមាជិកសហឧក្រិដ្ឋកម្មរួម មានគោលបំណងរួមដើម្បីបង្កើតរដ្ឋឯករាជ្យ ដែលដាច់ចេញពី Bosnia និង Herzegovina។ ទោះបីជាគោលដៅនេះមិនមានលក្ខណៈឧក្រិដ្ឋក៏ដោយ តែសមាជិកសហឧក្រិដ្ឋកម្មរួម មានបំណងសម្រេចគោលដៅនេះតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយចំនួនប្រឆាំងប្រជាជនមូស្លីម។

[270] *រឿងក្ដីព្រះរាជអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-94-1-A) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧ (ii)។ *រឿងក្ដីព្រះរាជអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី 0៣ ខែ មេសា ឆ្នាំ ២00៧ កថាខណ្ឌ ៤១៨។ *រឿងក្ដីព្រះរាជអាជ្ញា តទល់នឹង Mpambara* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-01-65-T) ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២00៦ កថាខណ្ឌ ១៣ “*ខុសពីការសមគំនិត គឺមិនចាំបាច់បង្ហាញពីការព្រមព្រៀងជាក់លាក់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មឡើយ៖ គោលបំណងរួមអាចកើតឡើងភ្លាមៗ និងមិនផ្លូវការទេ ហើយអ្នកចូលរួមពាក់ព័ន្ធ មិនចាំបាច់ពាក់ព័ន្ធគ្នាតាមរយៈអង្គការចាត់តាំងផ្លូវការឡើយ*”។

១១៥. *មនុស្សច្រើននាក់៖* សហឧក្រិដ្ឋកម្មរួមតម្រូវឱ្យមានការចូលរួមពីមនុស្សច្រើននាក់ ដើម្បីគោលបំណងឧក្រិដ្ឋកម្មរួម[271]។ មិនចាំបាច់បង្ហាញឈ្មោះអ្នកចូលរួមទាំងអស់នៅក្នុងសហឧក្រិដ្ឋកម្មរួមឡើយ ហើយវាអាចគ្រប់គ្រាន់ហើយត្រឹមលើកឡើងឱ្យបានច្បាស់លាស់អំពីប្រភេទមនុស្ស ឬក្រុមមនុស្ស[272]។ មនុស្សច្រើននាក់មិនចាំបាច់ត្រូវរៀបចំជារចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាលឡើយ[273]។

១១៦. *ការចូលរួមគោលបំណងរួម៖* ការចូលរួមគោលបំណងរួម មិនចាំបាច់ពាក់ព័ន្ធនឹងការអនុវត្តផ្នែកណាមួយនៃធាតុផ្សំសត្យានុម័តរបស់ឧក្រិដ្ឋកម្ម ដែលជាផ្នែកមួយនៃគោលបំណងរួមនោះទេ[274]។ វាគ្រប់គ្រាន់ហើយត្រឹមថា អំពើរបស់អ្នកចូលរួមនោះក្នុងរបៀបណាម្យ៉ាងមានគោល

---

[271] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩២។ សាលដីកា *Kvocka* កថាខណ្ឌ ៨១។

[272] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩២។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣០។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Đorđević* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-87/1-T) ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៨៦១៖ *មិនចាំបាច់ត្រូវបង្ហាញឈ្មោះអ្នកចូលរួមទាំងអស់ឡើយ។ អាស្រ័យតាមកាលៈទេសៈនៃរឿងក្ដី គឺអាចគ្រប់គ្រាន់ហើយត្រឹមសំដៅលើប្រភេទមនុស្ស ឬក្រុមមនុស្ស។ ទោះជាយ៉ាងនេះក្ដី ប្រភេទ ឬក្រុមមនុស្សបែបនេះ ចាំបាច់ត្រូវតែកំណត់អត្តសញ្ញាណឱ្យបានគ្រប់គ្រាន់ដើម្បីជៀសវាងភាពមិនច្បាស់លាស់ ឬមិនប្រាកដប្រជា*"។ ឧទាហរណ៍អំពីការកំណត់ចរិតលក្ខណៈមិនបានច្បាស់លាស់អំពីសមាជិកសហឧក្រិដ្ឋកម្មរួម *សូមមើល រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-00-39-A) ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៥៦ ដល់ ១៥៧។

[273] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-94-1-A) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧(i)។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Đorđević* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-05-87/1-T) ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៨៦១។

[274] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤២៧។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-94-1-A) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧ (iii)។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-00-39-A) ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ២១៥។

ដៅជំរុញគោលបំណងឧក្រិដ្ឋរួម[275]។ អំពើរបស់អ្នកចូលរួមសហឧក្រិដ្ឋកម្មរួម អាចជាអំពើសកម្ម ឬអំពើអកម្មដែលមានពិរុទ្ធភាព[276]។ ការរួមចំណែករបស់អ្នកចូលរួមសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ត្រូវទាល់តែជាការរួមចំណែកដែលចាំបាច់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទេ ដែលការរួមចំណែកដែលចាំបាច់នេះមានន័យថា ប្រសិនបើគ្មានការចូលរួមបែបនេះទេ នោះឧក្រិដ្ឋកម្មដែលជាផ្នែកមួយនៃគោលបំណងរួម អាចមិនបានប្រព្រឹត្ត ឬមិនត្រូវបានប្រព្រឹត្ត

---

[275] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-94-1-A) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩១, ២២៧ (iii), ២២៩(iii)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-30/1-A) ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ១៨៧។ សាលក្រម *Krajišnik* បានផ្តល់ជាឧទាហរណ៍ល្អមួយអំពីការប្រព្រឹត្តិដែលមិនមានលក្ខណៈឧក្រិដ្ឋទេ ប៉ុន្តែនៅក្នុងកាលៈទេសៈនៃរឿងក្តីនេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ នៅក្នុងកថាខណ្ឌ ១១២០ និង ១១២១ នៃ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលក្រម អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY(IT-00-39-T) ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ អង្គជំនុំជម្រះសម្រេចថា ការរួមចំណែកជារួមរបស់ Krajišnik នៅក្នុងសហឧក្រិដ្ឋកម្មរួម គឺដើម្បីជួយបង្កើត និងរក្សានិរន្តរភាពបក្ស SDS និងរចនាសម្ព័ន្ធរដ្ឋ "*ដែលចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម*"។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានបញ្ជាក់ថា "*ការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មឡើយ អ្វីដែលសំខាន់គឺថា ការចូលរួមនេះគឺដើម្បីជំរុញការអនុវត្តគោលដៅ ឬគោលបំណងរួមដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម*" *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-00-39-A) ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ២១៥, ២១៨។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣០។

[276] **សំណុំរឿងលេខ ០០២- ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-30/1-A) ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ១៨៧, ៤២១ និង ៥៥៦។ ជាគោលការណ៍ទូទៅ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និង ICTR បានសម្រេចស្របគ្នាថា ឧក្រិដ្ឋកម្មអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលមានពិរុទ្ធភាព ក្នុងករណីដែលមានភារកិច្ចត្រូវអនុវត្តសកម្មភាព ហើយជនជាប់ចោទអាចត្រូវទទួលខុសត្រូវផ្ទាល់ចំពោះចូលរួមចំណែកដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មតាមរយៈអំពើអកម្ម ក្នុងករណីដែលជនជាប់ចោទមានភារកិច្ចអនុវត្តសកម្មភាព *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blaškić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-95-14-A) ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៦៣ និង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Galić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-29-A) ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៧៥។

01588386



ឡើយ[277] ប៉ុន្តែ ការរួមចំណែកនោះយ៉ាងហោចណាស់ចាំបាច់ត្រូវតែជាការរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[278]។

១១៧. សូម្បីតែសកម្មភាពដែលតាមការមើលឃើញ គឺមិនមានភាពពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ ក៏សកម្មភាពទាំងនោះអាចត្រូវយកមកពិចារណាផងដែរ នៅពេលសម្រេចថាតើអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមនោះបានចូលរួមចំណែកយ៉ាងសំខាន់ដែរ ឬអត់[279]។ ទោះជាយ៉ាងនេះក្តី សកម្មភាពបែបនេះអាចជំរុញ និងគាំទ្រដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម បើទោះបីជាដោយប្រយោលក្តី[280]។ នៅក្នុងការវាយតម្លៃនេះ សកម្មភាពទាំងអស់គួរយកមកពិចារណា ហើយការចូលរួមចំណែកណាមួយមិនគួរត្រូវវាយតម្លៃឱ្យដាច់ដោយឡែកពីគ្នានោះឡើយ[281]។ ភាពសំខាន់នៃការចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម គួរត្រូវសម្រេចតាមករណីនីមួយៗ ដោយគិតពីកត្តាផ្សេងៗគ្នា រួមទាំងតួនាទីរបស់ជនត្រូវចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ព្រមទាំងការខិតខំណាមួយដើម្បីរារាំងឧក្រិដ្ឋកម្ម[282]។

១១៨. *ធាតុផ្សំអត្តនោម័តិ៖* សមាជិកនៅក្នុងសហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗ ដែលជាផ្នែកមួយនៃគោលបំណងរួម គឺថា ចេតនានេះចាំបាច់ត្រូវតែមានទាំងគោលបំណងរួម ទាំងឧក្រិដ្ឋកម្មដែលមាននៅក្នុងចេតនានោះ[283]។ ចេតនានេះចាំបាច់

---

[277] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-30/1-A) ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៩៨ និង ១៩៣។

[278] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-00-39-A) ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ២១៥ និង ៦៩៦។

[279] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨៤។

[280] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨៤។

[281] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨០។

[282] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨០។

[283] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ១០៥៣។

ត្រូវតែចូលរួម និងជាចេតនារួមរបស់សមាជិកសហឧក្រិដ្ឋកម្មរួមទាំងអស់[284]។ នៅក្នុងករណី ដែលឧក្រិដ្ឋកម្មនោះពាក់ព័ន្ធជាមួយនឹងការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍ សមាជិកសហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវតែចូលរួមចេតនាពិសេស ដែលជាលក្ខខណ្ឌតម្រូវ សម្រាប់ឧក្រិដ្ឋកម្មទាំងអស់នោះ[285]។

១១៩. អ.ជ.ត.ក បានបញ្ជាក់បំភ្លឺថា នៅក្នុងករណីដែលគោលបំណងរួម*ពាក់ព័ន្ធជាមួយនឹង*ការ ប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើននោះ មិនចាំបាច់ថា អ្នកដែលឯកភាពលើគោលបំណងរួម

---

[284] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-00-39-A) ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ២០០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-97-24-A) ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៥។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadić* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-94-1-A) ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩៦៖"ប្រភេទបែបនេះលើកដំបូងមាននៅក្នុងរឿងក្តី ដែលសហជនជាប់ចោទទាំងអស់ធ្វើសកម្មភាពផ្អែកតាមការរៀបចំរួម ដោយមានចេតនាឧក្រិដ្ឋកម្មដូចគ្នាតែមួយ។ ឧទាហរណ៍ ការបង្កើតផែនការក្នុងចំណោមសហចារីដើម្បីសម្លាប់ ក្នុងករណីដែលអនុវត្តការរៀបចំរួម *(និងបើទោះបីជាសហចារីនីមួយៗអនុវត្តតួនាទីផ្សេងៗគ្នានៅក្នុងផែនការនោះក៏ដោយ) ក៏ពួកគេទាំងអស់សុទ្ធតែមានចេតនាសម្លាប់។ លក្ខខណ្ឌតម្រូវសត្យានុម័ត និងអត្តនោម័តសម្រាប់ដាក់បន្ទុកការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើអ្នកចូលរួមដែលមិនមាន ឬមិនអាចមានភ័ស្តុតាងបញ្ជាក់ពីការនាំឱ្យមានការសម្លាប់នោះ គឺមានដូចតទៅ៖ (១) ជនជាប់ចោទត្រូវតែចូលរួមដោយស្ម័គ្រចិត្តនៅក្នុងផ្នែកមួយនៃការរៀបចំរួម (ឧទាហរណ៍ តាមរយៈការជំរុញអំពើហិង្សាមិនដល់ស្លាប់មកលើជនរងគ្រោះ ឬតាមរយៈការផ្តល់ជំនួយជាក់ស្តែង ឬសម្របសម្រួលសកម្មភាពរបស់សហចារី) និង (២) ជនជាប់ចោទបើទោះបីជាមិនបាននាំឱ្យមានការសម្លាប់ក៏ដោយ ប៉ុន្តែមានចេតនាចង់បានលទ្ធផលបែបនេះ"* និង កថាខណ្ឌ ២២៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Ntakirutimana និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-10-A និង ICTR-96-17-A) ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤៦៣៖ "*ប្រភេទទីមួយគឺជាទម្រង់"មូលដ្ឋាន"នៃសហឧក្រិដ្ឋកម្មរួម។ ទម្រង់នេះមាននៅក្នុងរឿងក្តីដែលសហចារីទាំងអស់* ធ្វើសកម្មភាពផ្អែកតាមការរៀបចំរួម ដោយមានចេតនាឧក្រិដ្ឋកម្មដូចគ្នាតែមួយ"។ **សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៤។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Vasiljević* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-32-A) ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៣ កថាខណ្ឌ ១០១។

[285] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-98-30/1-A) ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ១០៩-១១០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krnojelac* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-97-25-A) ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ កថាខណ្ឌ ១១១ -១១២។

ពិតជា *ចង់ឱ្យ* ប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលបំណងចុងក្រោយនោះ[286]។ អ.ជ.ត.ក បានបន្ថែមថា ករណីនេះអាចរួមបញ្ចូលឧក្រិដ្ឋកម្ម ដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយដើម្បីសម្រេចគោលបំណងរួមណាមួយ បើទោះបីជាការប្រព្រឹត្តិពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ[287]។ អ.ជ.ត.ក បានពន្យល់ថា ប្រសិនបើគោលដៅនៃគោលបំណងរួមនឹងសម្រេចបាន លុះត្រាតែអាចមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ហើយមានការព្រមព្រៀងគ្នាថា ត្រូវបន្តសម្រេចគោលដៅនេះ ដោយពុំគិតថាអាចមានការប្រព្រឹត្តិឧក្រិដ្ឋកម្មយ៉ាងណាក៏ដោយ នោះគោលបំណងរួម មានបញ្ចូលឧក្រិដ្ឋកម្មទាំងនេះ ពីព្រោះថា បើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏ឧក្រិដ្ឋកម្មទាំងនេះត្រូវបានគ្រោងទុកដោយគោលបំណងរួមរួចហើយ។[288] ដោយផ្អែកផងដែរលើការប្រើពាក្យ "*ចង់ឱ្យ*" យើង Michael Bohlander សូមបកស្រាយថា សេចក្ដីសម្រេចនេះរបស់ អ.ជ.ត.ក គឺការបញ្ជាក់បំភ្លឺថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនចាំបាច់ទាល់តែជាគោលដៅចម្បងរបស់សមាជិកសហឧក្រិដ្ឋកម្មរួមឡើយ។ ទោះជាយ៉ាងនេះក្ដី នៅតែចាំបាច់ត្រូវតែបង្ហាញពីចេតនារបស់សមាជិកសហឧក្រិដ្ឋកម្មរួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលជាលក្ខខណ្ឌតម្រូវជាមូលដ្ឋានសម្រាប់សហឧក្រិដ្ឋកម្មរួមប្រភេទទីមួយ។

១២០. *ចារីផ្ទាល់៖* សមាជិកសហឧក្រិដ្ឋកម្មរួមអាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ប្រសិនបើឧក្រិដ្ឋកម្មនោះគឺជាផ្នែកមួយនៃគោលបំណងរួម ហើយត្រូវបានប្រព្រឹត្តឡើងដើម្បីជំរុញគោលបំណងរួមនោះ[289]។ ដើម្បីឱ្យសមាជិកសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយអ្នកដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមនោះ ចាំបាច់ត្រូវតែបង្ហាញថា ឧក្រិដ្ឋកម្មនោះអាចកើតឡើងដោយសារសមាជិកសហឧក្រិដ្ឋកម្មរួម យ៉ាងហោចណាស់ក៏ម្នាក់ដែរ ហើយ

[286] **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨០៨។

[287] **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨០៨។

[288] **សំណុំរឿងលេខ 00២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨០៨។

[289] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Brdanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី 0៣ ខែ មេសា ឆ្នាំ ២00៧ កថាខណ្ឌ ៤១០-៤១៣។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-00-39-A) ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២00៩ កថាខណ្ឌ ២២៥។

សមាជិកនោះ នៅពេលប្រើប្រាស់ចារីផ្ទាល់ ដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម បានធ្វើសកម្មភាពដើម្បីជំរុញគោលបំណងរួម[290]។ អត្ថិភាពនៃទំនាក់ទំនងនេះ គឺជាបញ្ហាដែលត្រូវវាយតម្លៃតាមករណីនីមួយៗ[291]។

## ៤.៣.២. ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ (ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦)

១២១. ស.ច.ស ក្នុងសំណុំរឿង ០០២ បានសម្រេចថា ការប្រព្រឹត្តិតាមរយៈការចូលរួមសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ អនុវត្តចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះ[292]។ អ.ប.ជ មិនបានដោះស្រាយជាក់លាក់អំពីភាពអាចអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ចំពោះឧក្រិដ្ឋកម្មជាតិឡើយ ប៉ុន្តែ បានច្រានចោល

---

[290]**សំណុំរឿងលេខ ០០២- ឯកសារ** E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤១៣។

[291]*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-99-36-A) ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤១៣ និង ៤១៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY(IT-00-39-A) ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ២២៥-២២៦។យោងតាម សាលដីកា *Krajišnik* កថាខណ្ឌ ២២៦៖ "*កត្តាដែលបង្ហាញពីចំណងទាក់ទងបែបនេះ រួមមានភ័ស្តុតាងបង្ហាញថា សមាជិករបស់សហឧក្រិដ្ឋកម្មរួម បានស្នើសុំដោយត្រង់ ឬដោយប្រយោលទៅអ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ឬបានញុះញង់ បញ្ជា ជំរុញ ឬលើកទឹកចិត្ត ឬជួយដល់អ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម*"។ យោងតាម សាលដីកា *Brđanin* កថាខណ្ឌ ៤១០៖ "ក្នុងករណីដែលមេឃ្លោងចារីនៃឧក្រិដ្ឋកម្មណាមួយមួយមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមទេ នោះ លក្ខខណ្ឌតម្រូវដ៏សំខាន់នេះអាចទាញសេចក្តីសន្និដ្ឋានចេញពីកាលៈទេសៈផ្សេងៗ រួមមាន ការពិតដែលថា ជនជាប់ចោទ ឬសមាជិកណាម្នាក់ទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួម បានសហការយ៉ាងជិតស្និទ្ធជាមួយមេចារីដើម្បីជំរុញគោលបំណងឧក្រិដ្ឋកម្មរួម"។

[292] **សំណុំរឿងលេខ ០០២- ឯកសារ** D427 *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣០៧។ **សំណុំរឿងលេខ ០០២- ឯកសារ** D427/1/30 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ២៩០។ **សំណុំរឿងលេខ ០០២- ឯកសារ** D97/13 *ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ២២។

ទម្លាក់ករណីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលថា សហឧក្រិដ្ឋកម្មរួមអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ។ តាមទស្សនៈរបស់ អ.ប.ជ ការចូលរួមសហឧក្រិដ្ឋកម្មរួម រួមមានស្ថានភាពដែលជនត្រូវចោទអាច "*មានលក្ខណៈដាច់ឆ្ងាយចេញពីការរួមប្រព្រឹត្តជាក់ស្ដែងនៃអំពើពិរុទ្ធនៃបទឧក្រិដ្ឋ ជាជាងស្ថានភាពទាំងឡាយដែលត្រូវបានដឹងមុន តាមរយៈការចូលរួមផ្ទាល់ ដែលត្រូវបានកំណត់លក្ខខណ្ឌ យោងតាមច្បាប់នៅថ្នាក់ជាតិ*"[293]។ អ.ប.ជ ក៏បានបង្ហាញទស្សនៈផងដែរថា ទម្រង់ថ្នាក់ជាតិនៃសហចារី ដែលមានចែងនៅក្នុងមាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺដូចសហឧក្រិដ្ឋកម្មរួមដែរ ជាទម្រង់មួយនៃការប្រព្រឹត្តិ ដែលស្ថិតនៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[294]។

១២២. ហេតុដូច្នេះ ស្របតាមដីកាដំណោះស្រាយសំណុំរឿង ០០៤/១ ដោយអនុវត្តតាមរូបមន្តរបស់ អ.ប.ជ អំពីទម្រង់នៃការទទួលខុសត្រូវនៅថ្នាក់ជាតិ និងដោយពិចារណាលើវិធីសាស្ត្ររបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០២ នោះ ទម្រង់នៃការទទួលខុសត្រូវតាមរយៈការប្រព្រឹត្តិ (ជាសហចារី) ការរៀបចំផែនការ និងការបញ្ជា នឹងត្រូវយកមកពិចារណាពាក់ព័ន្ធនឹងការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

## ៥. ការពិចារណាអំពីតំណក្ដាង

### ៥.១. ចម្លើយដែលមិនមែនជាកំណត់ហេតុស្ដាប់ចម្លើយរបស់ ក.ស.ច.ស

១២៣. ភាគច្រើនលើសលប់នៃភស្ដុតាងដែលត្រូវបានពឹងផ្អែកក្នុងសំណុំរឿង ០០៤/០២ គឺរួមមានកំណត់ហេតុស្ដាប់ចម្លើយដែល ក.ស.ច.ស បានធ្វើឡើងនៅក្នុងពេលស៊ើបអង្កេត ហើយត្រូវបានរៀបចំឡើងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងត្រូវការពារនីតិវិធីផ្លូវច្បាប់ច្បាស់

---

[293] **សំណុំរឿងលេខ ០០២- ឯកសារ D97/15/9** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១០១។

[294] មាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងជាភាសាបារាំងថា៖ "*Toute personne participant volontairement, soit directement, soit indirectement, à la perpétration d'un crime ou d'un délit, est passible des peines applicables à l'auteur principal. La participation directe constitue la coaction, la participation indirecte constitue la complicité.*"។ **សំណុំរឿងលេខ ០០២- ឯកសារ D97/15/9** *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១០២។

លាស់ ដូច្នេះហើយត្រូវទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[295]។ យើង Michael Bohlander យល់ឃើញថា ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការមកពីសំណុំរឿងផ្សេងទៀតរបស់ អ.វ.ត.ក ហើយបានដាក់ចូលក្នុងសំណុំរឿង ០០៤/០២ ដោយសារប្រតិចារឹកទាំងនោះពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់នានា ក៏ទទួលបានសច្ចធារណ៍ដូចគ្នានេះផងដែរ។

១២៤. ចម្លើយ ឬភ័ស្តុតាងដទៃទៀតដែលប្រមូលបានដោយមិនមានការត្រួតពិនិត្យតាមផ្លូវតុលាការពីសំណាក់ស្ថាប័នដែលមិនស្ថិតនៅក្នុង អ.វ.ត.ក រួមមាន មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានធ្វើឡើងដោយគ្មានការធានា និងបែបបទនីតិវិធីតុលាការ ដែលជាលក្ខខណ្ឌនៃកំណត់ហេតុស្តាប់ចម្លើយទេ ហេតុនេះ មិនទទួលបានសច្ចធារណ៍បែបនេះឡើយ[296]។ ទោះជាយ៉ាងនេះក្តី ករណីនេះមិនរាប់បញ្ចូលឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពដើមពីមជ្ឈមណ្ឌលឯកសារកម្ពុជា ពោលគឺជាឯកសារដែលអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថាទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធជាបឋម និងភាពអាចជឿជាក់បាន[297]។

---

[295] **សំណុំរឿងលេខ ០០២- ឯកសារ E96/7** *សេចក្តីសម្រេចលើសំណើសុំ របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨២ ពាក់ព័ន្ធនឹងការទទួលយក កំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង,* ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៦ ដល់ ២៧, ២៩។ **សំណុំរឿងលេខ ០០២- ឯកសារ E162,** *ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះផ្នែកនៃ ឯកសារ E114, E114/1, E131/1/9. E131/6, E136 និង E158* ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៣។ **សំណុំរឿងលេខ ០០២- ឯកសារ E185** *សេចក្តីសម្រេចលើការជំទាស់ ទៅនឹងឯកសារដែលបានស្នើសុំដាក់ នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ក១ ដល់ ក៥ របស់សហព្រះរាជអាជ្ញា និង ចំពោះ ឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីដំណាក់កាលដំបូង នៃសំណុំរឿង០០២/០១* ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២០។

[296] **សំណុំរឿងលេខ ០០២- ឯកសារ E96/7** *សេចក្តីសម្រេចលើសំណើសុំ របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨២ ពាក់ព័ន្ធនឹងការទទួលយក កំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៩។

[297] **សំណុំរឿងលេខ ០០២- ឯកសារ E185** *សេចក្តីសម្រេចលើការជំទាស់ ទៅនឹង ឯកសារដែលបានស្នើសុំដាក់ នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ក ១ ដល់ ក ៥ របស់សហព្រះរាជអាជ្ញា និងចំពោះ ឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីដំណាក់កាលដំបូង នៃសំណុំរឿង០០២/០១* ចុះថ្ងៃទី ៩

01588392



១២៥. ការស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញា បើទោះបីជាត្រូវបានរៀបចំឡើងជាពិសេសសម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការស្តាប់ចម្លើយទាំងនេះមិនត្រូវបានធ្វើឡើងដោយមានការស្បថដែរ ហើយត្រូវបានរៀបចំឡើងដោយភាគីមួយ ដែលមានផលប្រយោជន៍ជាក់ស្តែងនៅក្នុងលទ្ធផលនៃសំណុំរឿង។ ទោះជាយ៉ាងនេះក្តី ចម្លើយបែបនេះត្រូវបានប្រមូលឡើងក្នុងគោលបំណងសម្រាប់សវនាការព្រហ្មទណ្ឌ ដូច្នេះហើយ ជាគោលការណ៍ ត្រូវទទួលបានតម្លៃជាភស្តុតាងខ្ពស់ជាងភស្តុតាងដែលមិនបានរៀបចំឡើងក្នុងគោលបំណងបែបនេះ (រួមទាំងចម្លើយដែលប្រមូលបានដោយមជ្ឈមណ្ឌលឯកសារកម្ពុជា)[298]។

១២៦. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានទេ ហើយទទួលបានតម្លៃជាភស្តុតាងទាបប៉ុណ្ណោះ ប្រសិនបើមិនដឹងអំពីកាលៈទេសៈដែលបានកត់ត្រាពាក្យសុំនោះទេ[299]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះដែលគ្រាន់តែបង្ហាញពីសេចក្តីសន្និដ្ឋានទូទៅ ហេតុនេះគ្រាន់តែជា"*ការរៀបរាប់ទូទៅ*"ដែលមិនមែនជាបទពិសោធផ្ទាល់ខ្លួនទេ ត្រូវចាត់ទុកថាមិនមានព័ត៌មានគ្រប់គ្រាន់អាចបញ្ជាក់ពីអង្គហេតុពាក់ព័ន្ធបានទេ[300]។ ចម្លើយដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នៅក្រៅនីតិវិធីតុលាការ ដែលមិនមែនជាការស្តាប់ចម្លើយដែលធ្វើឡើងដោយ ក.ស.ច.ស ត្រូវទទួលបានតម្លៃជាភស្តុតាងទាប[301] ចំណែកឯសក្ខីកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីផ្តល់មកតាមនីតិវិធីតុលាការ ត្រូវបានវាយតម្លៃដោយប្រុងប្រយ័ត្ន[302]។

---

**ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៨។ សំណុំរឿងលេខ ០០២- ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣៧៣។**

[298] **សំណុំរឿងលេខ ០០២- ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ២៩៦។**

[299] **សំណុំរឿងលេខ ០០២- ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ២៩៦។**

[300] **សំណុំរឿងលេខ ០០២- ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៤៥៧។**

[301] **សំណុំរឿងលេខ ០០២- ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៥០។**

[302] **សំណុំរឿងលេខ ០០២- ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣១៥។**

១២៧. ជាការសន្និដ្ឋាន និងថ្លឹងថ្លែងលើការពិចារណាទាំងអស់នេះ កំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ច.ស និងប្រតិចារិកសវនាការ ត្រូវទទួលបានសច្ចាធារណ៍នៃភាពអាចជឿជាក់បានខ្ពស់ជាង ហើយត្រូវទទួលបានតម្លៃជាភស្តុតាងខ្ពស់ជាងការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នដទៃផ្សេងទៀត។ ចំពោះការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នផ្សេងទៀត គឺមានការអនុវត្តវិធីសាស្ត្រប្រុងប្រយ័ត្នខ្លាំងជាងក្នុងការវាយតម្លៃលើឯកសារទាំងនោះ ហើយព័ត៌មានដែលមាននៅក្នុងនោះត្រូវបានពឹងផ្អែកតែក្នុងករណី ដែលមានការបញ្ជាក់ពីប្រភពផ្សេងទៀតប៉ុណ្ណោះ។

១២៨. ក៏មានការអនុវត្តវិធីសាស្ត្រប្រុងប្រយ័ត្នផងដែរ ចំពោះការវាយតម្លៃលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ **អោ អាន** ដែលបានធ្វើឡើងនៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១[303]។ មេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍ថា ស.ច.ស មិនគួរពិចារណាលើកិច្ចសម្ភាសន៍នេះទេ ដោយពិនិត្យលើអង្គហេតុដែលថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើកិច្ចសម្ភាសន៍នេះ ដោយគ្មាននីតិវិធីត្រឹមត្រូវគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ **អោ អាន** ទេ ហើយបានធ្វើឡើងក្នុងពេលដែល **អោ អាន** មិនបានដឹងទាល់តែសោះ ឬមិនបានដឹងច្បាស់ថា គាត់គឺជាជនសង្ស័យម្នាក់ស្ថិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការឡើយ[304]។ ដូចដែល ស.ច.ស បានកត់សម្គាល់នៅក្នុង*ដីកាដំណោះស្រាយ(សំអាងហេតុ)*សំណុំរឿង ០០៤/១ រួចហើយ នៅក្នុងវិធានផ្ទៃក្នុង មិនមានបទប្បញ្ញត្តិដែលចែងអំពីការប្រើប្រាស់ចម្លើយដែលជនសង្ស័យ និងជនត្រូវចោទបានផ្តល់ជូនទៅស្ថាប័ន ឬអង្គការផ្សេង ទោះបីជាថាបានដឹង ឬមិនបានដឹងថា ខ្លួនឯងជាជនសង្ស័យ ឬជាជនត្រូវចោទស្ថិតនៅក្រោមការស៊ើបអង្កេតរបស់ អ.វ.ត.ក នោះទេ ប៉ុន្តែ ចម្លើយបែបនេះត្រូវបាន អតីត ស.ច.ស និងអង្គជំនុំជម្រះសាលាដំបូង ប្រើប្រាស់ជាមូលដ្ឋានតាមកម្រិតផ្សេងៗតាមការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន និងស្របតាម

---

[303] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌល ឯកសារកម្ពុជា ដាក់ចូលក្នុងសំណុំរឿង ០០៤/២ ដោយមានលេខ ឯកសារ D191.2 ប៉ុន្តែ ក.ស.ច.ស ពឹងផ្អែកលើប្រតិចារិកផ្លូវការរបស់តុលាការពីកិច្ចសម្ភាសន៍នោះដែលមានលេខ ឯកសារ D219/847.1។

[304] **ឯកសារ D351/6** *ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦* ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៧ កថាខណ្ឌ ២០៩, ២១១។

01588394



បទដ្ឋានទូទៅនៃការវាយតម្លៃភស្តុតាង[305]។ ស្របតាមវិធីសាស្ត្របែបនោះ និងគោលការណ៍វាយតម្លៃភស្តុតាងដែលបានពន្យល់នៅក្នុងផ្នែកនេះ យើង Michael Bohlander ឱ្យតម្លៃទៅលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ **អោ អាន** ទាបជាងការស្តាប់ចម្លើយដែលធ្វើឡើងដោយ ក.ស.ច.ស។ ភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃចម្លើយនៅក្នុងកិច្ចសម្ភាសន៍បែបនេះ ត្រូវបានវាយតម្លៃតាមករណីនីមួយៗ ដោយគិតពីភស្តុតាងផ្សេងទៀតទាំងអស់នៅក្នុងសំណុំរឿង។

## ៥.២. ភស្តុតាងពាក្យចចាមអារ៉ាម និងការពឹងផ្អែកលើភស្តុតាងដែលមិនមានការបញ្ជាក់

១២៩. យោងតាមវិធានផ្ទៃក្នុង ៨៧ រាល់ភស្តុតាងទាំងអស់អាចទទួលយកបាននៅក្នុងសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក រួមទាំង ពាក្យចចាមអារ៉ាមផងដែរ។ ទាំងអង្គជំនុំជម្រះសាលាដំបូង ទាំង អ.ជ.ត.ក យល់ឃើញថា ភស្តុតាងពាក្យចចាមអារ៉ាម អាចយកជាមូលដ្ឋានបានក្នុងករណីដែលមានភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាងគ្រប់គ្រាន់[306]។ តុលាការអន្តរជាតិផ្សេងទៀតក៏បានទទួលស្គាល់ថា ចៅក្រមអាចពឹងផ្អែកដោយប្រុងប្រយ័ត្នលើពាក្យចចាមអារ៉ាម ដោយកំណត់លើភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃពាក្យចចាមអារ៉ាមនោះតាមករណីនីមួយៗ[307]។ នេះគឺជាវិធីសាស្ត្រដែលអនុវត្តតាមនៅក្នុងដីកាដំណោះស្រាយនេះ។

---

[305] **សំណុំរឿងលេខ 00៤/១- ឯកសារ** D308/3 *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី ១0 ខែ កក្កដា ឆ្នាំ ២0១៧ កថាខណ្ឌ ១៣៨-១៣៩។

[306] **សំណុំរឿងលេខ 00១- ឯកសារ** E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២0១0 កថាខណ្ឌ ៥៣។**សំណុំរឿងលេខ 00២- ឯកសារ** F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២0១៦ កថាខណ្ឌ ៣0២។

[307] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ndindabahizi* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-01-71-A) ថ្ងៃទី១៦ ខែមករា ឆ្នាំ២00៧ កថាខណ្ឌ ១១៥។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Gacumbitsi* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-2001-64-A) ថ្ងៃទី៧ ខែ កក្កដា ឆ្នាំ២00៦ កថាខណ្ឌ១១៥។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Rutaganda* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-96-3-A) ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២00៣ កថាខណ្ឌ ៣៤,២0៧, ៣១១។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹងKarera* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-01-74-A) ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២00៩ កថាខណ្ឌ៣៩, ១៧៨។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Kordić និង Cerkez* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-95-14/2-A) ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២00៤ កថាខណ្ឌ ២៨១-២៨៤។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Gatete* សាលដីកា អង្គជំនុំជម្រះតុលាការ

១៣០. សក្ខីកម្មរបស់សាក្សីណាម្នាក់អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីអង្គហេតុណាមួយ ក្នុងករណីដែលអាចជឿជាក់បាន និងមានតម្លៃជាភស្តុតាងគ្រប់គ្រាន់(ទោះបីជាវិធីសាស្ត្រនេះ ដូចបានកត់សម្គាល់ខាងលើ បានយកមកអនុវត្តតែក្នុងករណីកំណត់ហេតុស្តាប់ចម្លើយធ្វើឡើង ដោយ ក.ស.ច.ស និងប្រតិចារឹកសវនាការរបស់ អ.វ.ត.ក ក៏ដោយ)[308]។ ជាគោលការណ៍ ភស្តុតាងពាក្យចចាមអារ៉ាមដែលមិនមានការបញ្ជាក់ ក៏អាចយកជាមូលដ្ឋានបានដែរ[309]។ ប៉ុន្តែ កត្តានានា ដូចជា ប្រភពនៃពាក្យចចាមអារ៉ាមនោះ កាលៈទេសៈដែលសាក្សីបានដឹងអំពីពាក្យ ចចាមអារ៉ាមនោះ ភាពស៊ីចង្វាក់រវាងភស្តុតាងនោះជាមួយនឹងភស្តុតាងពាក់ព័ន្ធផ្សេងទៀតនៅ ក្នុងសំណុំរឿង និងកាលៈទេសៈពាក់ព័ន្ធទាំងអស់ផ្សេងទៀត ចាំបាច់ត្រូវវាយតម្លៃដោយប្រុង ប្រយ័ត្នក្នុងករណីពាក្យចចាមអារ៉ាមមិនមានការបញ្ជាក់ ជាពិសេសក្នុងករណីភស្តុតាងប្រភេទ នេះពាក់ព័ន្ធនឹងធាតុផ្សំជាក់លាក់នៃបទឧក្រិដ្ឋ ឬការប្រព្រឹត្តិរបស់ជនត្រូវចោទ។

១៣១. ដោយខុសពីចម្លើយដែលប្រមូលបានក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ឯកសារសម័យ កម្ពុជាប្រជាធិបតេយ្យដែលមានប្រភពដើមផ្ទាល់ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានធ្វើ ឡើងនៅក្នុងអំឡុងពេល ឬនៅជិតអំឡុងពេលនៃហេតុការណ៍ដែលបានរៀបរាប់នៅក្នុងឯកសារ នោះ ហេតុនេះគឺជាភស្តុតាងផ្ទាល់។ ឯកសារប្រភេទនេះមិនប៉ះពាល់ការចងចាំរបស់សាក្សី ឡើយចំពោះចម្លើយរបស់សាក្សី ហើយមិនបានធ្វើឡើងដោយភាគីណាមួយដែលមាន ប្រយោជន៍រួចជាស្រេចពីលទ្ធផលនៃសំណុំរឿងឡើយ នៅពេលដែលបង្កើតឯកសារនោះ។ ដូច បានកត់សម្គាល់ខាងលើ ឯកសារប្រភេទនេះក៏ទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាព អាចជឿជាក់បានដែរ។ ហេតុនេះ ខណៈដែលត្រូវអនុវត្តវិធីសាស្ត្រមួយដ៏ប្រុងប្រយ័ត្ន ភស្តុ

---

កំពូលនៃតុលាការ ICTR (ICTR-00-61-A) ថ្ងៃទី៨ ខែតុលាក ឆ្នាំ២០១២ កថាខណ្ឌ ៩៩។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង* *Đorđević* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-05-87/1-A) ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ៣៩៧។

[308] **សំណុំរឿងលេខ ០០១- ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៣។

[309] **សំណុំរឿងលេខ ០០២- ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០២។ រឿងក្តី*រដ្ឋអាជ្ញាតទល់នឹង Gacumbitsi* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-2001-64-A) ថ្ងៃទី៧ ខែ កក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១៣៣។

តាង ដែលមិនមានការបញ្ជាក់ប្រភេទនេះ ត្រូវបានប្រើប្រាស់នាពេលកន្លងមកក្នុងករណីសមស្រប។

## ៥.៣. ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម

១៣២. អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម មានការហាមឃាត់ដាច់ខាតមិនឱ្យប្រើប្រាស់ជាភស្តុតាងទេ នូវព័ត៌មាននៅក្នុងចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម[310] និងមិនឱ្យប្រើប្រាស់ចម្លើយបែបនេះ នៅក្នុងការសួរដេញដោលសាក្សីទេ[311] ក្រៅពីប្រើប្រាស់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទជាអ្នកធ្វើទារុណកម្ម ដើម្បីបញ្ជាក់ថាមានការផ្តល់ចម្លើយដោយសារការធ្វើទារុណកម្ម។

១៣៣. ចម្លើយសារភាពរបស់អ្នកទោស ដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានសន្មតថាធ្វើឡើងដោយទារុណកម្ម។ នេះគឺជាសច្ចធារណ៍[312]។

១៣៤. ព័ត៌មាននៅក្នុង"*ប្រវត្តិរូបអ្នកទោស*"[313]មន្ទីរ ស-២១ ក្រៅពីឈ្មោះអ្នកទោស ភេទ ថ្ងៃខែឆ្នាំចាប់ខ្លួន ឬសម្លាប់ គឺស្ថិតនៅក្នុងការហាមឃាត់នេះ[314]។ ប៉ុន្តែ ព័ត៌មាននៅក្នុងចម្លើយ

---

[310] **សំណុំរឿងលេខ ០០២- ឯកសារ** D130/9/21 *សេចក្តីសម្រេចលើភាពអាចទទួលយកបាន នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត លើការប្រើប្រាស់ចម្លើយដែលទទួលបាន ឬអាចទទួលបានតាមរយៈការធ្វើទារុណកម្ម* ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣០។ **សំណុំរឿងលេខ ០០១- ឯកសារ** E1/27.1 *ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ កាំង ហ្គេកអ៊ាវ ហៅឌុច* ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៨ ដល់ ៩។ **សំណុំរឿងលេខ ០០១- ឯកសារ** E176 *សេចក្តីសម្រេចលើសំណើរបស់ភាគីខាងសុំដាក់សម្ភារៈមួយចំនួនទៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២)* ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៨។ **សំណុំរឿងលេខ ០០២- ឯកសារ** E1/129.1 *ប្រតិចារឹកសវនាការលើអង្គសេចក្តីសំណុំរឿង ០០២ [មាស មឿន]* ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០១២ **ERN 00851054** បន្ទាត់ទី ២១-២៣, **ERN 00851055** បន្ទាត់ទី១-៦។

[311] **សំណុំរឿងលេខ ០០២- ឯកសារ** F26/12 *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជី ឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៤៧។ **សំណុំរឿងលេខ ០០២- ឯកសារ** E1/129.1 *ប្រតិចារឹកសវនាការលើអង្គសេចក្តីសំណុំរឿង០០២ [មាស មឿន]* ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០១២ **ERN 00851054** បន្ទាត់ទី ២១-២៣, **ERN 00851055** បន្ទាត់ទី១-៦។

[312] **សំណុំរឿងលេខ ០០២- ឯកសារ** F26/12 *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជី ឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៥៧ ដល់ ៥៨។

សារភាពនៅមន្ទីរសន្តិសុខ ស-២១ ដែលមានប្រភពដើមពីជនដែលមិនមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ឧទាហរណ៍ ចំណាររបស់អ្នកធ្វើទារុណកម្ម គឺមិនស្ថិតនៅក្នុងការហាមឃាត់នេះឡើយ[315]។ មាត្រា ១៥ ក៏មិនបានហាមឃាត់មិនឱ្យប្រើប្រាស់ព័ត៌មាននៅក្នុងចម្លើយដែលធ្វើឡើងដោយទារុណកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកសាក្សី និងអាចឈានទៅស្តាប់ចម្លើយពួកគាត់ដែរ[316]។ ហេតុដូច្នេះ មិនមានការហាមឃាត់មិនឱ្យប្រើ

---

[313] ជាទូទៅ ជា ឯកសារមួយទំព័រដែលបង្ហាញពីឈ្មោះអ្នកទោសនៅ ស ២១ ឈ្មោះក្រៅ ថ្ងៃខែឆ្នាំកំណើត ភេទ ជនជាតិ តួនាទី និងមន្ទីរ/ផ្នែកនៅក្នុងជួរ"បដិវត្តន៍" ទីកន្លែងកំណើត ចំនួនកូន ថ្ងៃខែឆ្នាំចាប់ខ្លួន និងទីកន្លែងចាប់ខ្លួន។ សូមមើល **ឯកសារ D251** *សេចក្តីសម្រេចរួមសំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងការប្រើប្រាស់ជាសក្ខាទុកពលនៃភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម* ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៣១។

[314] **ឯកសារ D251** *សេចក្តីសម្រេចរួមសំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងការប្រើប្រាស់ជាសក្ខាទុកពលនៃភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម* ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៣៥។

[315] **សំណុំរឿងលេខ ០០២- ឯកសារ** F26/12 *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជី ឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៦៦ ដល់ ៦៨។

[316] ហេតុផលមួយក្នុងចំណោមហេតុផលនានានៃគោលការណ៍ដែលមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មគឺដើម្បីដកចេញការលើកទឹកចិត្តមិនឱ្យរដ្ឋចូលរួមក្នុងការធ្វើទារុណកម្ម។ ដើម្បីជៀសវាងកុំឱ្យស្មុគស្មាញអំពីហេតុផលគោលការណ៍នេះ ក្នុងការបញ្ជាក់ពីភាពស្របច្បាប់ក្នុងការប្រើប្រាស់ភស្តុតាងដែលបានរកឃើញតាមរយៈព័ត៌មានដែលទទួលដោយសារការធ្វើទារុណកម្ម គឺចាំបាច់ត្រូវបែកចែងឱ្យដាច់ពីគ្នារវាងសេណារីយ៉ូពីរដូចតទៅ។ សេណារីយ៉ូទីមួយ គឺករណីដែលព័ត៌មានទទួលបានដោយសារការធ្វើទារុណកម្ម ត្រូវអាជ្ញាធរដែលធ្វើទារុណកម្ម ប្រើប្រាស់ដើម្បីស្វែងរកសាក្សី ជនសង្ស័យ អ្នករត់គេចខ្លួន ឬដើម្បីជួយការស៊ើបអង្កេតដែលកំពុងបន្ត។ សេណារីយ៉ូទីពីរ គឺករណីដែលស្ថាប័នតុលាការដែលស៊ើបអង្កេតលើអ្នកធ្វើទារុណកម្ម ព្យាយាមប្រើប្រាស់ព័ត៌មានដែលទទួលបានពីអ្នកធ្វើទារុណកម្មនោះ ដើម្បីកំណត់អត្តសញ្ញាណប្រភពភស្តុតាងដែលអាចមានប្រឆាំងអ្នកធ្វើទារុណកម្មនោះ។ ការអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានទទួលបានតាមរយៈការធ្វើទារុណកម្ម ធ្វើជាតម្រុយស៊ើបអង្កេតនៅក្នុងសេណារីយ៉ូទីមួយ អាចជាការលើកទឹកចិត្តឱ្យប្រើប្រាស់ទារុណកម្ម។ ឧទាហរណ៍ ប្រសិនបើអង្គភាពស៊ើបអង្កេតមួយទទួលបានចម្លើយតាមរយៈការធ្វើទារុណកម្ម បន្ទាប់មកប្រើប្រាស់ឈ្មោះដែលមាននៅក្នុងចម្លើយនោះ ដើម្បីស្វែងរកបណ្តុំ ឯកសារ ឬជនដែលមានព័ត៌មានពាក់ព័ន្ធជាមួយការស៊ើបអង្កេតនោះ ឯកសារ ឬសក្ខីកម្មពីរបស់ជននោះមិនត្រូវទទួលយកធ្វើជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ។ ប៉ុន្តែ នៅក្នុងសេណារីយ៉ូទីពីរ ស្ថាប័នតុលាការមិនបានពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងអាជ្ញាធរដែលធ្វើទារុណកម្មទេ ហើយប្រើប្រាស់តម្រុយដែលអាចមានដើម្បីស្វែងរកភស្តុតាងប្រឆាំងអ្នកធ្វើទារុណកម្មនោះ។ តាមទស្សនៈរបស់យើង ភស្តុតាងពីសាក្សីដែលបានរកឃើញដោយផ្អែកលើចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្មអាចប្រើប្រាស់បានតែក្នុងសេណារីយ៉ូទីពីរប៉ុណ្ណោះ។ អង្គបុរេជំនុំជម្រះ ក៏បានបញ្ជាក់ផងដែរថា ការប្រើប្រាស់ជាតម្រុយ

01588398



ប្រាស់ភស្តុតាងពីសាក្សី ដែលមានអត្តសញ្ញាណនៅក្នុងចម្លើយដែលទទួលបានដោយការធ្វើទារុណកម្មទេ ដូចជា ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ហើយក្រោយមកសាក្សីនោះត្រូវបាន ក.ស.ច. ស ស្តាប់ចម្លើយ[317]។

## ៥.៤. របាយការណ៍រៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

១៣៥. ពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ១៩៩៩ ជាផ្នែកមួយនៃគម្រោងរៀបចំផែនទីរបស់ខ្លួនដើម្បីកំណត់អត្តសញ្ញាណ និងរៀបចំផែនទីរណ្តៅសាកសពរួមនៅទូទាំងប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំរបាយការណ៍ចំនួនប្រាំ ដែលមានព័ត៌មានអាចពាក់ព័ន្ធនឹងកិច្ចស៊ើបសួរលើការចោទប្រកាន់លើ **អោ អាន** ("របាយការណ៍រៀបចំផែនទី")។ របាយការណ៍ចំនួនពីរក្នុងចំណោមរបាយការណ៍រៀបចំផែនទី គឺពាក់ព័ន្ធនឹងបេសកកម្មដែលក្រុមការងាររៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះទៅខេត្តកំពង់ចាម នៅខែ មីនា និងខែ មេសា ឆ្នាំ ១៩៩៧ និងនៅខែ កក្កដា ឆ្នាំ ១៩៩៨[318]។ របាយការណ៍រៀបចំផែនទីចំនួន ៣ ផ្សេងទៀត គឺពាក់ព័ន្ធនឹងការចុះបេសកកម្មដែលបានធ្វើឡើងនៅឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៩ នៅខេត្តកំពង់ធំ និងនៅវត្តបារាយជាន់ដែក[319] ពាក់ព័ន្ធនឹងទីតាំងដែលបានដកចេញពីកិច្ចស៊ើបសួរយោងតាម

---

ស៊ើបសួរនូវព័ត៌មានពី ឯកសារដែលទទួលបានដោយសារការធ្វើទារុណកម្ម មិនមានន័យថា ព័ត៌មាននោះត្រូវបានប្រើប្រាស់ជា"ភស្តុតាង"ទេ(**សំណុំរឿងលេខ ០០៣- ឯកសារ D257/1/8** *សេចក្តីសម្រេចលើពាក្យសុំរបស់[មេធាវីការពារក្តី]សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម* កថាខណ្ឌ២៨។ **សំណុំរឿងលេខ ០០៣- ឯកសារ D253/1/8** *សេចក្តីសម្រេចលើសំណើសុំមោឃភាព ឯកសារ D114/164, D114/167, D114/170 និង D114/171* ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៧ កថាខណ្ឌ ៣០ និង ៣២)។

[317] **សំណុំរឿងលេខ ០០២- ឯកសារ E350/8** *សេចក្តីសម្រេចលើភស្តុតាងដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម* ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ៦៣, ៧០។

[318] **ឯកសារ D1.3.10.8** របាយការណ៍មជ្ឈមណ្ឌល ឯកសារកម្ពុជា ការកំណត់ផែនទីវាលពិឃាតក្នុងប្រទេសកម្ពុជា ឆ្នាំ ១៩៩៧៖ ខេត្តកំពង់ចាម។ **ឯកសារ D1.3.10.12** របាយការណ៍មជ្ឈមណ្ឌល ឯកសារកម្ពុជា ខេត្តកំពង់ចាម ឆ្នាំ១៩៩៨។

[319] **ឯកសារ D1.3.10.9** របាយការណ៍មជ្ឈមណ្ឌល ឯកសារកម្ពុជា ការកំណត់ផែនទីវាលពិឃាតក្នុងប្រទេសកម្ពុជា ឆ្នាំ ១៩៩៧៖ ខេត្តកំពង់ធំ។ **ឯកសារ D1.3.27.8** របាយការណ៍មជ្ឈមណ្ឌល ឯកសារកម្ពុជា គម្រោងរៀបចំផែនទីស្រុកបារាយ វត្តបារាយជាន់ដែក ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៩។ **ឯកសារ D1.3.10.16** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងរៀបចំផែនទី ឆ្នាំ ១៩៩៩៖ ខេត្តកំពង់ធំ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៩។

វិធានផ្ទៃក្នុង៦៦*ស្ទួន*[320]។ របាយការណ៍ទាំងនោះផ្តល់ព័ត៌មានផ្សេងៗ ដូចជា ចំនួនរណ្តៅសាកសព និងចំនួនជនរងគ្រោះពាក់ព័ន្ធនឹងទីតាំងដែលជាផ្នែកមួយនៃការចោទប្រកាន់នៅក្នុងសំណុំរឿង 004/0២។

១៣៦. ការយល់ឃើញរបស់យើង Michael Bohlander អំពីតម្លៃជាភស្តុតាងនៃរបាយការណ៍រៀបចំផែនទី គឺដូចគ្នានឹងការយល់ឃើញដែល ស.ច.ស បានបង្ហាញនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)សំណុំរឿង 004/២ អំពីរបាយការណ៍ដែលមានព័ត៌មានអាចពាក់ព័ន្ធនឹងការចោទប្រកាន់លើ អ៊ឹម ចែម[321]។ ជាពិសេស របាយការណ៍រៀបចំផែនទី ដែលពឹងផ្អែកលើការចុះដល់ទីកន្លែង និងការសម្ភាសន៍ជាមួយនឹងប្រភពនានា មិនបានផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីប្រភពដែលសាក្សីបានដឹងអំពីចំនួនជនរងគ្រោះ ដើម្បីអាចវាយតម្លៃឱ្យបានគ្រប់គ្រាន់អំពីភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាននៃភស្តុតាងទេ។ កាលបរិច្ឆេទ និងមូលហេតុនៃការស្លាប់ជនរងគ្រោះក៏មិនបានដឹង ឬមានភាពច្បាស់លាស់ដែរ ហេតុនេះមិនអាចកំណត់ថាតើការស្លាប់នោះបានកើតឡើង នៅក្នុងដែនកំណត់យុត្តាធិការពេលវេលាពាក់ព័ន្ធដែរឬអត់។ ហេតុនេះ យើង Michael Bohlander យល់ឃើញថា ចំនួនជនរងគ្រោះដែលបានរាយការណ៍នៅក្នុងរបាយការណ៍រៀបចំផែនទី មិនអាចជឿជាក់បានទេ ហេតុនេះ យើងមិនបានពឹងផ្អែកលើរបាយការណ៍ទាំងនេះទេ។ ស្របតាមការសម្រេចពីមុនរបស់យើងនៅក្នុងសំណុំរឿងនេះ[322] ក្នុងការគណនាចំនួនជនរងគ្រោះដែលអាចបង្កឡើងដោយសារ **អោ អាន** យើង Michael Bohlander ពឹងផ្អែកលើសាក្សីដែលអាចផ្តល់ភស្តុតាងជូន ក.ស.ច.ស អំពីចំនួនមនុស្សស្លាប់ និងមូលហេតុស្លាប់នៅទីតាំងឧក្រិដ្ឋកម្មនីមួយៗ។

---

[320] **ឯកសារ** D337 *ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ៤(ក) និងកថាខណ្ឌ១៣ (អំពីមន្ទីរសន្តិសុខវត្តបារាយជាន់ដែក មន្ទីរសន្តិសុខវត្តស្រដៃ)។

[321] **សំណុំរឿងលេខ 004/១- ឯកសារ** D308/3 *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ១៣១-១៣៥។

[322] **ឯកសារ D188/1/1** *ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២ របស់ អោ អាន* ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ៤៨។ **ឯកសារ D189/2** *ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៣ របស់ អោ អាន* ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ២០។

01588400



## ៥.៥. ចំនួនជនរងគ្រោះ

១៣៧. ផ្នែកនីមួយៗនៃការរកឃើញអង្គហេតុអំពីឧក្រិដ្ឋកម្មនៅក្នុងដីកាដំណោះស្រាយនេះ រួមមានការប៉ាន់ស្មានអំពីចំនួនមនុស្សស្លាប់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ ឬសេណារីយ៉ូឧក្រិដ្ឋកម្មនីមួយៗតាមករណីដែលពាក់ព័ន្ធ។ ត្រូវមានការពន្យល់មួយចំនួនអំពីគោលការណ៍ និងវិធីសាស្ត្រដែលយើង Michael Bohlander ប្រើប្រាស់ដើម្បីធ្វើការប៉ាន់ស្មានទាំងនេះ។

១៣៨. ចំពោះទីតាំង ឬសេណារីយ៉ូឧក្រិដ្ឋកម្មទាំងអស់ យើង Michael Bohlander ប្រកាន់យកតួលេខអភិរក្សនិយម គឺចំនួនជនរងគ្រោះជាអប្បបរមាដែលអាចធ្វើការប៉ាន់ស្មានបានតាមរយៈភស្តុតាង ដោយអនុវត្តគោលការណ៍ដូចខាងក្រោម។ គោលការណ៍ខ្លះបញ្ជាក់ពីវិធីសាស្ត្រអភិរក្សនិយមចំពោះការវាយតម្លៃភស្តុតាង ជាងលក្ខខណ្ឌតម្រូវសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ប៉ុន្តែ យើងប្រកាន់យកវិធីសាស្ត្របែបនេះដើម្បីចៀសវាងកុំឱ្យមានហានិភ័យរាប់ចំនួនជនរងគ្រោះស្ទួនគ្នាពីរដង។ ហេតុនេះ ការរាប់ចំនួនជាច្រើនពីសាក្សីដែលរៀបរាប់អំពីជនរងគ្រោះ ត្រូវបានដកចេញពីការគណនាចំនួនសរុប ក្នុងករណីដែលមានហានិភ័យអាចរាប់ចំនួនជនរងគ្រោះស្ទួនគ្នាពីរដង ឬក៏ការស្លាប់ជនរងគ្រោះមិនអាចធ្វើការបញ្ជាក់ឱ្យបានសមហេតុផលទេ ពាក់ព័ន្ធនឹងវិសាលភាពពេលវេលានៃកិច្ចស៊ើបសួរ។ ការដកចេញការរាប់ចំនួនក្នុងរបៀបអភិរក្សនិយមបែបនេះ គឺមានចំណងដើម្បីធានាថាការប៉ាន់ស្មានចំនួនជនរងគ្រោះនៅតែស្ថិតនៅក្នុងចំនួនអប្បបរមា ប៉ុន្តែ ក៏មានន័យថាចំនួនជនរងគ្រោះជាក់ស្តែង អាចមានលទ្ធភាពខ្ពស់មានចំនួនច្រើនជាងឆ្ងាយពីចំនួនប៉ាន់ស្មាននៅក្នុងដីកាដំណោះស្រាយនេះ។

*ការគណនាចំនួនជនរងគ្រោះផ្អែកលើភស្តុតាងដែលទទួលបានពីសាក្សីម្នាក់*

១៣៩. ក្នុងករណីដែលសាក្សីម្នាក់ប្រាប់ពីចំនួនជនរងគ្រោះស្ថិតនៅក្នុងរង្វង់ចំនួនណាមួយ (ឧទា. នៅចន្លោះពី ១០០ នាក់ ទៅ ២០០ នាក់) នោះ យើង Michael Bohlander យកចំនួនទាបបំផុតក្នុងរង្វង់ចំនួននោះ (គឺយកចំនួន ១០០ នាក់) ខុសពីការគណនាចំនួនមធ្យមភាគ។

១៤០. ក្នុងករណីខ្លះ សាក្សីរៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងដដែលៗ ជាផ្នែកមួយនៃការអនុវត្តជាទៀងទាត់ ឬជាផ្នែកមួយនៃដំណើរការណាមួយ ប៉ុន្តែ មិនបានបញ្ជាក់ពីចំនួនហេតុ

ការណ៍ពិតប្រាកដដែលសាក្សីបានដឹងទេ។ ប្រសិនបើតាមរយៈភស្តុតាង បង្ហាញឲ្យឃើញ ច្បាស់ថា ហេតុការណ៍ទាំងនោះបានកើតឡើងជាទៀងទាត់ និង/ឬក្នុងរយៈពេលយូរអង្វែង ហេតុនេះច្បាស់លាស់គឺថា បានកើតឡើងលើសពីពីរដងនោះ យើង Michael Bohlander សន្និដ្ឋានថាហេតុការណ៍នេះបានកើតឡើងបីដង ប៉ុន្តែ បើខុសពីនេះ ចំនួនដែលបានសន្និដ្ឋានគឺចំនួនពីរដងប៉ុណ្ណោះ។

១៤១. ក្នុងករណីដែលសាក្សីសំដៅលើចំនួន *"លើសពាក់កណ្តាល"* ក្នុងចំណោមចំនួនមនុស្សនៅក្នុងក្រុមណាមួយ យើង Michael Bohlander ធ្វើការគណនាចំនួននេះត្រឹមចំនួនពាក់កណ្តាលបូកមួយ។

១៤២. ចំពោះចំនួនប្រហាក់ប្រហែល យើងយកចំនួនដែលមើលទៅឃើញជាក់ស្តែង ដរាបណាយើងជឿជាក់លើមូលដ្ឋានដែលសាក្សីដឹងពីចំនួននោះ ពីព្រោះថា មិនមានវិធីសមហេតុផលណាដែលត្រូវកាត់បន្ថយចំនួននេះឲ្យតិចទៀតទេ។ ឧទាហរណ៍ ក្នុងករណីដែលសាក្សីបញ្ជាក់ថា *"ប្រហែល ១០ នាក់"* ឬ *"ប្រមាណ ១០ នាក់"* ឬ *"ប្រហាក់ប្រហែល ១០ នាក់"* នោះចំនួននេះត្រូវគណនាថាមានចំនួន "១០ នាក់"។

១៤៣. ចំពោះការលើកឡើងមិនច្បាស់ថា *"រាប់រយនាក់"* នោះ ត្រូវគណនាថាមានចំនួន ២00 នាក់ ហើយបើលើកឡើងថាមានចំនួន *"រាប់ពាន់នាក់"* វិញ នោះ ត្រូវគណនាថាមានចំនួន ២000 នាក់។

១៤៤. ក្នុងករណីដែលជនរងគ្រោះណាម្នាក់ត្រូវបានគេរៀបរាប់ថា *"បានបាត់ខ្លួន"* នោះ ជនរងគ្រោះនោះត្រូវបញ្ចូលក្នុងចំនួនមនុស្សស្លាប់ ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ពីការសន្និដ្ឋានថាជននោះត្រូវបានគេសម្លាប់ (ឧទា. ក្នុងករណីដែលការបាត់ខ្លួននេះបានកើតឡើងនៅក្នុងបរិបទហេតុការណ៍សម្លាប់រួម និងក្នុងករណីដែលមិនដែលឃើញជននោះម្តងទៀតទេ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ)។

*ការគណនាចំនួនជនរងគ្រោះផ្អែកតាមភស្តុតាងពីសាក្សីច្រើននាក់*

១៤៥. ចំពោះការគណនាចំនួនជនរងគ្រោះសរុបផ្អែកតាមភស្តុតាងរួមបញ្ចូលគ្នាពីសាក្សីច្រើននាក់ គឺត្រូវបូកចូលគ្នាតែចំនួនអប្បបរមា ដែលទទួលបានពីសាក្សីម្នាក់ៗតែប៉ុណ្ណោះ។

១៤៦. ក្នុងករណីដែលអាចថា សាក្សីច្រើននាក់រៀបរាប់អំពីហេតុការណ៍ដូចគ្នា នោះ យើង Michael Bohlander មិនបូកចូលគ្នានូវចំនួន ដែលទទួលបានពីសាក្សីទាំងនោះឡើយ។ ប៉ុន្តែ ប្រសិនបើមានភស្តុតាងបង្ហាញថា ក្រុមជនរងគ្រោះទាំងនោះគឺជាក្រុមជនរងគ្រោះផ្សេងខុសគ្នា បើតាមសាក្សីម្នាក់ៗ នោះចំនួនជនរងគ្រោះទាំងនោះត្រូវបូកបញ្ចូលគ្នា។

១៤៧. ក្នុងករណីដែលសាក្សីច្រើននាក់នៅក្នុងហេតុការណ៍ណាមួយ ផ្តល់ព័ត៌មានផ្ទុយគ្នាអំពីចំនួនជនរងគ្រោះ នោះត្រូវយកចំនួនទាបបំផុត ប្រសិនបើតួលេខពីសាក្សីម្នាក់ទៀតមិនអាចជឿជាក់បានជាងទេ ឧទាហរណ៍ ដោយសារតាមរយៈភាពអាចជឿជាក់បាន ការបញ្ជាក់ ឬមូលដ្ឋានដែលបានដឹង។ ឧទាហរណ៍ ប្រសិនបើសាក្សីពីរនាក់បញ្ជាក់ថា ពួកគាត់ឃើញមនុស្ស ២០ នាក់ត្រូវបានគេសម្លាប់នៅក្នុងហេតុការណ៍មួយ ប៉ុន្តែ សាក្សីម្នាក់ទៀតគ្រាន់តែឮថា មនុស្សជិត ១០ នាក់ត្រូវបានគេសម្លាប់នៅក្នុងហេតុការណ៍នោះ(ភស្តុតាងឮគេថា) នោះការគណនាចំនួនត្រូវយកចំនួន ២០ នាក់ ជាចំនួនដែលទទួលបានពីសាក្សីផ្ទាល់ភ្នែកទាំងពីរនោះ។

១៤៨. ប្រសិនបើមានការសន្និដ្ឋានផ្អែកលើការវាយតម្លៃជាក់ស្តែងអំពីភស្តុតាង ដែលបង្ហាញថា ជនរងគ្រោះណាម្នាក់បានស្លាប់ នៅក្រៅក្របខណ្ឌពេលវេលានៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤/២ ជនរងគ្រោះនោះត្រូវដកចេញពីការគណនាចំនួនមនុស្សស្លាប់។

១៤៩. ក្នុងករណី ដែលសាក្សីណាម្នាក់មិនអាចបញ្ជាក់ឈ្មោះទីតាំងឧក្រិដ្ឋជាក់ស្តែងឱ្យបានច្បាស់លាស់ដែលជនរងគ្រោះណាម្នាក់បានស្លាប់ទេ ប៉ុន្តែ តាមរយៈភស្តុតាង មានការបង្ហាញឱ្យឃើញច្បាស់ថា ជនរងគ្រោះនោះបានស្លាប់នៅទីតាំងដែលបានដាក់ជាបទចោទ ឬក៏ពុំមានសម្មតិកម្មសមហេតុផលណាផ្សេង ដែលកាត់ផ្តាច់ភាពពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទចំពោះជនរងគ្រោះនោះទេ ជនរងគ្រោះនោះមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនមនុស្សស្លាប់សរុបសម្រាប់ទីតាំងឧក្រិដ្ឋកម្មណាមួយឡើយ ប៉ុន្តែ ត្រូវរាប់បញ្ចូលក្នុងចំនួនមនុស្សស្លាប់សរុបសម្រាប់តំបន់ ដែលជនរងគ្រោះនោះត្រូវគេអះអាងថា បានជាប់ឃុំឃាំង ឬបានស្លាប់នៅទីនោះ ហេតុនេះ ជនរងគ្រោះនោះត្រូវរាប់បញ្ចូលក្នុងចំនួនមនុស្សសរុបសម្រាប់សំណុំរឿង។

*ការរាប់ចំនួនសមាជិកគ្រួសារ*

១៥០. សាក្សីជាច្រើននាក់ ជាពិសេសសាក្សីដែលផ្តល់ភស្តុតាងអំពីការប្រព្រឹត្តិមកលើជនជាតិចាម គឺបានរៀបរាប់អំពីចំនួនជនរងគ្រោះគិតជាចំនួនគ្រួសារ មិនមែនរាប់ចំនួនមនុស្សម្នាក់ៗទេ។ ក្នុងន័យដាច់ខាត ចំនួនមនុស្សអប្បបរមាដែលត្រូវការដើម្បីបង្កើតបានជាគ្រួសារមួយអាចត្រូវគិតថាមានចំនួនពីរនាក់ ប៉ុន្តែ កត្តាដែលយើង Michael Bohlander បង្ហាញនៅខាងក្រោមនេះ នៅពេលដែលពិចារណាកត្តាទាំងនោះរួមបញ្ចូលគ្នា ស្តែងឱ្យឃើញថា ការប៉ាន់ស្មានចំនួនអប្បរមាដែលសមហេតុផល និងសមស្របសម្រាប់គ្រួសារមួយគឺមានចំនួនបួននាក់។

១៥១. តាមសក្ខីកម្មសំណុំរឿង ០០២ របស់ លោក អ៊ីសា ឧស្មាន ជាអ្នកជំនាញជនជាតិចាម និងជាអតីតអ្នកវិភាគនៅ ក.ស.ច.ស បានឱ្យដឹងថា គ្រួសារជនជាតិចាមជាមធ្យមមានសមាជិកចំនួនប្រាំនាក់ ទៅប្រាំមួយនាក់។ គ្រួសារជាច្រើនក្នុងចំណោមគ្រួសារទាំងនេះ គឺជាគ្រួសារមានសមាជិកលាយជំនាន់ចម្រុះរស់នៅជាមួយគ្នា រួមមាន ទាំងចៅ ផងដែរ ហើយជួនកាលមានទាំងចៅទួតផង[323]។ តាមពិត លោក អ៊ីសា យល់ឃើញថា សមាជិកចំនួនប្រាំនាក់នៅក្នុងគ្រួសារមួយអាចចាត់ទុកថាជាចំនួននៅក្រោមមធ្យមភាគ[324]។

១៥២. តាមរយៈភស្តុតាង បង្ហាញឱ្យឃើញច្បាស់ថា នៅក្នុងប្រទេសកម្ពុជា គ្រួសារដែលមានកូនតែម្នាក់គឺជាករណីកម្រ។ សាក្សីភាគច្រើនមកពីគ្រួសារដែលមានកូន/បងប្អូនចំនួនច្រើននាក់។ ប្រសិនបើប៉ាន់ស្មានថា គ្រួសារនីមួយៗមានសមាជិកតែពីរនាក់ នោះធ្វើឱ្យខូចភស្តុតាងរបស់សាក្សីជាច្រើននាក់ដែលបានប្រាប់ថា មានសមាជិកលើសពីរនាក់នៅក្នុងក្រុមគ្រួសារ។

១៥៣. ចុងក្រោយ ប្រសិនបើថា មានតែប៉ុន្មានគ្រួសារតែប៉ុណ្ណោះដែលជាជនរងគ្រោះ នោះអាចថាគ្រួសារទាំងនោះសុទ្ធតែអាចមានចំនួនសមាជិកតិចជាងចំនួនសមាជិកជាមធ្យមនៅក្នុងគ្រួសារ។ ប៉ុន្តែ ដោយពិនិត្យពីចំនួនគ្រួសារយ៉ាងច្រើន ដែលសាក្សីនានាបានប្រាប់ថាជាជនរងគ្រោះនោះ

---

[323] **ឯកសារ** D219/702.1.80 *ប្រតិចារិកសវនាការលើអង្គសេចក្តីសំណុំរឿង ០០២ [អ៊ីសា ឧស្មាន]* ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ERN 01393109 បន្ទាត់ទី ១២-១៧។

[324] **ឯកសារ** D219/702.1.80 *ប្រតិចារិកសវនាការលើអង្គសេចក្តីសំណុំរឿង ០០២ [អ៊ីសា ឧស្មាន]* ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ERN 01393109 បន្ទាត់ទី ២៣-២៥។

តាមលក្ខណៈភរវនីយភាពជាក់ស្តែង មិនអាចថា គ្រួសារទាំងនោះជាគ្រួសារមានសមាជិកតិច ខុសពីធម្មតាឡើយ។

១៥៤. ការពិចារណាទាំងអស់នេះនាំឱ្យយើង Michael Bohlander ធ្វើការសន្និដ្ឋានថា ប្រសិនបើ សាក្សីមិនបានបញ្ជាក់ពីចំនួនសមាជិកនៅក្នុងគ្រួសារទេ នោះការប៉ាន់ស្មានអប្បបរមាទាប បំផុតដែលសមហេតុផលគឺមានចំនួនបួននាក់នៅក្នុងគ្រួសារមួយ។

## ៥.៦. បញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស

១៥៥. បញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស [325](“បញ្ជីឈ្មោះ ស ២១ របស់ ក.ស.ច.ស”) ត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៅក្នុងសំណុំរឿងនេះដើម្បីបញ្ជាក់ពីកាលបរិច្ឆេទ ដែលអ្នក ទោសចូលមន្ទីរ ស ២១ ហើយក្នុងករណីដែលមានការបញ្ជាក់បែបនេះ ក៏បញ្ជាក់ពីកាល បរិច្ឆេទសម្លាប់អ្នកជាប់ឃុំនៅ ស ២១ និងចំនួនមនុស្សដែលបានបញ្ជូនទៅ ស ២១ និង/ឬត្រូវ បានសម្លាប់នៅ ស ២១ បន្ទាប់ពីជាប់ឃុំនៅ ស ២១។ ការប្រើប្រាស់ជាមូលដ្ឋានបែបនេះគឺ ជាការសមស្រប ដោយសារថា អ្នកវិភាគនៅ ក.ស.ច.ស បានធ្វើការវិភាគគ្រប់ជ្រុងជ្រោយ និងចំណាយពេលច្រើន ហើយបានប្រើប្រាស់វិធីសាស្ត្ររឹងមាំដើម្បីរៀបចំបញ្ជីឈ្មោះ ស ២១ របស់ ក.ស.ច.ស[326]។

## ៥.៧. លិខិតធានា

១៥៦. លិខិតធានាត្រូវបានផ្តល់ជូនសាក្សីដែលស្នើសុំ អនុលោមតាមវិធាន ២៨។ បទពិសោធបាន បង្ហាញថា ការផ្តល់ការធានាបែបនេះមិនមែនសុទ្ធតែធ្វើឱ្យសាក្សីចង់ពិភាក្សាអំពីហេតុការណ៍ នោះទេ ជាពិសេស ក្នុងករណីបង្ហាញថា សាក្សីអាចចូលរួមក្នុងសកម្មភាពឧក្រិដ្ឋ។ ប្រការនេះ ទំនងជាដោយសារតែពួកគេចង់រក្សា “មុខមាត់” និងចៀសវាងកុំឱ្យមានការសង្ស័យពីការពាក់ព័ន្ធ

---

[325] **ឯកសារ D219/825.1.2** បញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ EN ERN 01222328-01222936។

[326] **ឯកសារ D322/8** *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ ឯកសារ ប.ក.ក ទៅក្នុងសំណុំរឿង 004* ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ៤៧។ **ឯកសារ D219/825.1.1** *របាយការណ៍នៃសកម្មភាពស៊ើបអង្កេត* ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ ERN 01399603-01399605។

នឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មលើជនរួមជាតិ។ ដូច្នេះ ភាពអាចជឿជាក់បានរបស់សាក្សីមួយចំនួនត្រូវបានកំណត់ ដោយផ្អែកលើខ្លឹមសារនៃសក្ខីកម្មរបស់ពួកគេ និងស្របតាមការចូលរួមរបស់ពួកគេក្នុងអំពើឧក្រិដ្ឋដូចបានចោទប្រកាន់ ទោះបីជាលិខិតធានាត្រូវបានផ្តល់ជូនក៏ដោយ។

## ៦. ការវិភាគអង្គហេតុ និងការរកឃើញ

### ៦.១. រចនាសម្ព័ន្ធរដ្ឋបាល

#### ៦.១.១. ថ្នាក់ជាតិ

១៥៧. កម្ពុជាប្រជាធិបតេយ្យត្រូវបានគ្រប់គ្រង តាមរយៈរចនាសម្ព័ន្ធរដ្ឋបាលតាមឋានានុក្រម ដោយមានគណៈមជ្ឈិមជា *"អង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុត សម្រាប់ទូទាំងប្រទេស"*[327]។ គណៈមជ្ឈិមមានសមាសភាពសមាជិកគណៈអចិន្ត្រៃយ៍ និងលេខាភូមិភាគជាសមាជិកមិនអចិន្ត្រៃយ៍[328]។ ទោះបីជាយោងតាមលក្ខន្តិកៈ ប.ក.ក គណៈមជ្ឈិមអនុវត្តសិទ្ធិអំណាចប្រតិបត្តិការលើកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ការគ្រប់គ្រងជាក់ស្តែងត្រូវបានអនុវត្តដោយអង្គភាពក្រៅលក្ខន្តិកៈមួយមានឈ្មោះថាគណៈអចិន្ត្រៃយ៍ ដែលកើតចេញពីគណៈមជ្ឈិម[329]។

---

[327] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053025 មាត្រា ៧(ខ)។ ឯកសារ **D1.3.20.2** ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ ERN 00089845 មាត្រា ១។

[328] ឯកសារ **D179/1.2.11** ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០២ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794078, 00794087-00794088។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794521 បន្ទាត់ ២០-២៥។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00340575-00340576។ *សូមមើល* ឯកសារ **D219/702.1.137** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីក្នុងការជំនុំជម្រះក្តី "ឌុច" ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ [កាំង ហ្គេកអ៊ាវ ហៅ ឌុច], ERN 00339538-00339539។

[329] ឯកសារ **D179/1.2.34** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ [ដេវីដ ឆេនដ័ល័រ] ERN 00826703 (បន្ទាត់ ២៤-២៥)។ ឯកសារ **D179/1.2.11** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794078-00794079។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794527 បន្ទាត់ ៩។ ឯកសារ **D219/702.1.137** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីក្នុងការជំនុំជម្រះក្តី

១៥៨. គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ទទួលបន្ទុកតាក់តែងគោលនយោបាយ និងសេចក្តីណែនាំ រួចផ្សព្វផ្សាយដល់លេខាភូមិភាគ និងតំបន់ស្វយ័ត ដែលផ្សព្វផ្សាយបន្តដល់លេខាតំបន់ និងស្រុកដើម្បីអនុវត្ត[330]។ បន្ទាប់មក ការអនុវត្តសេចក្តីណែនាំត្រូវគេរាយការណ៍ឡើងទៅគណៈទាំងពីរ (មជ្ឈិម) តាមខ្សែចង្វាក់បញ្ជា[331]។

---

"ឌុច" ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ERN 00339538-00339539។ ឯកសារ **D1.3.36.1** កំណត់ហេតុសួរចម្លើយ (ខៀវ សំផន) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ERN 00156619។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00340575-00340576។ ឯកសារ **D6.1.1051** កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ ERN 00154927។ ឯកសារ **D6.1.91** កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រម ស៊ើបអង្កេត ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00239832។ ឯកសារ **D118/103.3** សារណាស្តាពរជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404803 កថាខណ្ឌ ៥៦។

[330] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053024 មាត្រា ៦(៤)-៦(៥), 00053028 មាត្រា ១២(២), 00053030 មាត្រា ១៥(២), 00053031 មាត្រា ១៨(២), 00053033-00053034 មាត្រា ២៣(១)-១៣(៣)។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ERN 00794527-00794530។ ឯកសារ **D179/1.2.24** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ [សៅ សារុន] ERN 00814446 បន្ទាត់ **៣-៧**។ *សូមមើលផងដែរ* ឯកសារ **D267.1.80** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣ [ពេជ្រ ជឹម] ERN 00934801-00934802។ ឯកសារ **D6.1.989** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ ERN 00486471-00486472 ឆ.១៤-ឆ១៥។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373497-00373498។ ឯកសារ **D219/442** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥ ERN 01125503 ឆ.២, 01125506 ឆ.២៩។

[331] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053024 មាត្រា ៦(៥), 00053027 មាត្រា ៦១០(២)(ខ), 00053029 មាត្រា ១៣(៤), 00053031 មាត្រា ១៦(៤), 00053032 មាត្រា ១៩(៤)។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ERN 00794524-00794530, 00794526។ ឯកសារ **D179/1.2.24** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ [សៅ សារុន] ERN 00814408 បន្ទាត់ **២០-២៥**, 00814406 បន្ទាត់ **១៤-២១**។

១៥៩. នៅឆ្នាំ ១៩៧៥ ប.ក.ក បានបែងចែកប្រទេសកម្ពុជាទៅជាភូមិភាគរដ្ឋបាលចំនួន ៦ ដែលត្រូវរាយការណ៍ផ្ទាល់ទៅមជ្ឈិម គឺភូមិភាគឧត្តរ ភូមិភាគពាយព្យ ភូមិភាគឦសាន ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា[332]។ នៅចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ ភូមិភាគឧត្តរត្រូវបានរំលាយ ហើយភូមិភាគកណ្ដាល និងភូមិភាគឧត្តរថ្មី ត្រូវបានបង្កើតឡើង[333]។

១៦០. បន្ថែមពីលើភូមិភាគ ប.ក.ក បានបង្កើត *"តំបន់ស្វយ័ត"* មួយចំនួន ដែលរាយការណ៍ផ្ទាល់ទៅមជ្ឈិម ដោយមិនឆ្លងកាត់ថ្នាក់ភូមិភាគ គឺតំបន់ស្វយ័ត ១០៣ (ព្រះវិហារ) តំបន់ស្វយ័ត

---

[332] ឯកសារ **D6.1.975** សៀវភៅភូមិសាស្ត្រនៃក្រសួងអប់រំកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៧ ERN 00065948-00065951។ ឯកសារ **D6.1.82** ផែនទីគូលីវ ឆ្នាំ១៩៧៦ នៃកម្ពុជាប្រជាធិបតេយ្យបង្ហាញពីភូមិភាគដែលមាននៅពេលនោះ ឆ្នាំ១៩៧៦ ERN 00193066។ ឯកសារ **D1.3.27.1** ផែនទីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ ERN P 00000003។

[333] ឯកសារ **D219/847.1** ឯកសារភ្ជាប់ ១៖ កិច្ចសម្ភាសន៍ជាមួយ អោ អាន ថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ERN 01337371-01337372។ ឯកសារ **D6.1.724** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ ស៊ូ ERN 00407776 ឆ.៦, 00407778 ឆ.១៥។ ឯកសារ **D118/103.3** សារណាស្ដាពរជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404800។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373494-00373495។ ឯកសារ **D6.1.736** កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00403910-00403911។ ឯកសារ **D6.1.729** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង គឹមអឿន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ERN 00418568-00418569 ឆ.១។ ឯកសារ **D219/486.1.1** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ [សួន កានិល] ERN 00871106-00871107។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ERN 00794520 បន្ទាត់ ១៣-១៥។ *សូមមើលផងដែរ* ឯកសារ **D1.3.16.1** ជីវប្រវត្តិ កែ ពក មានចំណងជើង "កែ ពក បានការពារខ្លួន មុនស្លាប់" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00164132-00164135 (*"មានខ្ញុំជាលេខា កងចាប អនុលេខា តាអាន ជាសមាជិក។ ចាប់ពីពេលនោះមកក៏រៀបចំបំបែកភូមិភាគឧត្តរថ្មីជាពីរវិញគឺ កងចាបទទួលតំបន់សៀមរាប ឧត្តរមានជ័យ ឡើងត្រង់ទៅមជ្ឈិម។ ឯខ្ញុំនៅភូមិភាគកណ្ដាលវិញដដែល។"*)។ ឯកសារ **D179/1.2.38** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ [ឌុង សុផង់] ERN 00844456 បន្ទាត់ ៤-៦ (*"ខ្ញុំចាំថាទិសនេះជាភូមិភាគមួយដែលរៀបចំថ្មីបាទ។ គឺក្រោយពីខាងតំបន់ស្វយ័ត សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ បានលុបចេញ ហើយក៏បង្កើតភូមិភាគមួយថ្មីហៅថា "ភូមិភាគ ៨០១" បាទ។ អ៊ីចឹងទិសនេះគឺក្រុមខ្ញុំ និងគ្រូខ្ញុំគាត់ធ្លាប់បានបកប្រែបាទ"។*)

១០៥ (មណ្ឌលគិរី) តំបន់ស្វយ័ត ១០៦ (សៀមរាប) តំបន់ស្វយ័ត ៥០៥ (ក្រចេះ) និង ទីក្រុងស្វយ័តកំពង់សោម[334]។

១៦១. ភូមិភាគត្រូវបានបែងចែកជា ៣២ តំបន់ ដែលចែកចេញជាស្រុក និងឃុំ។ អង្គភាពរដ្ឋបាលថ្នាក់ទាបបំផុត គឺភូមិ និងសហករណ៍[335]។ ថ្នាក់រដ្ឋបាលនីមួយៗចាប់ពីឃុំឡើងទៅ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការមួយ ដែលមានសមាសភាពលេខា អនុលេខា និងសមាជិកយ៉ាងតិចម្នាក់[336]។ លេខាគណៈកម្មាធិការគឺជាកម្មាភិបាលជាន់ខ្ពស់បំផុត ក្នុងថ្នាក់

---

[334] ឯកសារ **D6.1.975** សៀវភៅភូមិសាស្ត្រនៃក្រសួងអប់រំកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៧ ERN 00065950-00065951។ ឯកសារ **D6.1.82** ផែនទីគូលែរ ឆ្នាំ១៩៧៦ នៃកម្ពុជាប្រជាធិបតេយ្យបង្ហាញពីភូមិភាគដែលមាននៅពេលនោះ ឆ្នាំ១៩៧៦ ERN 00193066។ ឯកសារ **D1.3.27.1** ផែនទីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ ERN P 00000003។ ឯកសារ **D179/1.2.39** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ [នួន សុផន់] ERN 00845294 បន្ទាត់ ១៣-១៧, 00845294 បន្ទាត់ ១៧-១៨។

[335] ឯកសារ **D6.1.975** សៀវភៅភូមិសាស្ត្រនៃក្រសួងអប់រំកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៧ ERN 00065948-00065951, 00066007-00066008។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794522 បន្ទាត់ ៤-៦, 00794522 បន្ទាត់ ២៤-២៥។ ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053025 មាត្រា ៧។

[336] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053025 មាត្រា ៧។ ឯកសារ **D6.1.975** សៀវភៅភូមិសាស្ត្រនៃក្រសួងអប់រំកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៧ ERN 00065951-00065952, 00066014-00066015។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794521 បន្ទាត់ ៧-១១, បន្ទាត់ ១៧-១៩, 00794522 បន្ទាត់ ៨-៩, 00794522 បន្ទាត់ ១៩-២២, 00794522 បន្ទាត់ ២៤-២៥, 00794523 បន្ទាត់ ៥-៦, បន្ទាត់ ១៨-២១។ ឯកសារ **D179/1.2.10** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00793477 បន្ទាត់ ២-១១។ ឯកសារ **D179/1.2.24** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ [សៅ សារុន] ERN 00814408 បន្ទាត់ ៤-១២, 00814408 បន្ទាត់ ១៣-១៥, 00814434 បន្ទាត់ ៤-៨, 00814446 បន្ទាត់ ១-២។ ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" 00053025 មាត្រា ៧។ *សូមមើលផងដែរ* ឯកសារ **D6.1.707** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ERN 00373509។ ឯកសារ **D6.1.989** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ ERN 00486473 ឆ.២២។ ឯកសារ

រដ្ឋបាលនីមួយៗ ហើយជាទូទៅ ជាសមាជិកគណៈកម្មាធិការនៃថ្នាក់រដ្ឋបាលខាងលើបន្ទាប់[337]។

១៦២. កងទ័ព ប.ក.ក ត្រូវបានបែងចែកជាទ័ពស្រួច ទ័ពតំបន់ និងឈ្លប[338]។ គណៈភូមិភាគនីមួយៗមានទ័ពយ៉ាងហោចណាស់មួយកងពល ក្រោមបង្គាប់ផ្ទាល់ ហើយកងពលនេះទទួលខុសត្រូវចំពោះការការពារ និងសន្តិសុខ ក្នុងភូមិភាគ[339]។ កងពលនីមួយៗមានបីកងវរសេនាធំ ហើយ

---

D6.1.651 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ERN 00373386-00373387។

[337] ឯកសារ **D6.1.651** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ERN 00373386-003733387។ ឯកសារ **D179/1.2.24.** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ [សៅ សារុន] ERN 00814407 បន្ទាត់ ៧-២០, 00814407 បន្ទាត់ ២២-២៥។ ឯកសារ **D6.1.980** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាវ៉ាយ ប៊ាន ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ ERN 00486494 ឆ.១, 00486495 ឆ.៥។

[338] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053035 មាត្រា ២៧។ ឯកសារ **D1.3.20.2** ឯកសាររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ ERN 00089850 មាត្រា ១៩។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794532 បន្ទាត់ ២៣ ដល់ ERN 00794533 បន្ទាត់ ២។

[339] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053013 មាត្រា ១, 00053025 មាត្រា ៧(២), 00053032 មាត្រា ១៩(១)-១៩(២), មាត្រា ១៩(៤)។ ឯកសារ **D6.1.873** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០១ "ឌុច" [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00406932 បន្ទាត់ ១០-១១។ ឯកសារ **D219/702.1.148** កំណត់ហេតុស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨ ERN 00204701-00204703។ ឯកសារ **D6.1.751** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" ចេញផ្សាយថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៧៦ (ពេញ) ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ ERN 00062839-00062842។ ឯកសារ **D6.1.734** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឈឿន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ERN 00373481។

កងវរសេនាធំនីមួយៗមានបីកងវរសេនាតូច ដែលចែកចេញជាកងអនុសេនាធំ កងអនុសេនាតូច និងក្រុម[340]។

## ៦.១.២. ភូមិភាគកណ្ដាល

១៦៣. ភូមិភាគកណ្ដាល ជាអង្គភាពរដ្ឋបាលមានទីតាំងភូមិសាស្ត្រនៅកណ្ដាលកម្ពុជាប្រជាធិបតេយ្យ ដែលរួមបញ្ចូលផ្នែកខ្លះនៃខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តក្រចេះ[341]។ ភូមិភាគកណ្ដាល មានព្រំប្រទល់ជាប់ភូមិភាគឧត្តរថ្មី ភូមិភាគបូព៌ា ភូមិភាគបស្ចិម ភូមិភាគពាយព្យ និងតំបន់ស្វយ័ត ១០៦ និង ៥០៥។ ព្រំប្រទល់ខាងត្បូង និងខាងកើត ត្រូវបានខណ្ឌដោយទន្លេមេគង្គ។ ភូមិភាគកណ្ដាលមានព្រំប្រទល់ជាប់ទីក្រុងភ្នំពេញ រដ្ឋធានីកម្ពុជាប្រជាធិបតេយ្យ ត្រង់ចំណុចប្រសព្វទន្លេមេគង្គ និងទន្លេសាប[342]។

១៦៤. ភូមិភាគកណ្ដាលត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ និងកាត់យកភូមិភាគឧត្តរចាស់មួយផ្នែកធំ ដែលរួមបញ្ចូលខេត្តភាគខាងជើង ដូចជាសៀមរាប ឧត្តរ

---

[340] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053013 មាត្រា ១។ ឯកសារ **D219/702.1.112** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០១ "ឌុច" ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ERN 00364520 [ប៊ូ ធុន] បន្ទាត់ ៤-៥។ ឯកសារ **D179/1.2.43** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ [មាស វឿន] ERN 00853066 បន្ទាត់ ២៣-២៥ ដល់ ERN 00853067 បន្ទាត់ ១-៣, បន្ទាត់ ១២, 00853067 បន្ទាត់ ១៦-១៩។ ឯកសារ **D219/461** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ែន ឌុល ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១៥ ERN 01130690 ឆ.៤។ ឯកសារ **D219/876** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាន ប៉ាង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01357590 ឆ.១៥។ ឯកសារ **D219/847.1** ឯកសារភ្ជាប់ ១៖ កិច្ចសម្ភាសន៍ជាមួយ អោ អាន ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ERN 01337346-01337348។

[341] ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [ឌុច] ERN 00794520 បន្ទាត់ ១៤-១៥។ ឯកសារ **D6.1.637** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ERN 00398223-00398224។

[342] ឯកសារ **D6.1.82** ផែនទីគូល័រ ឆ្នាំ១៩៧៦ នៃកម្ពុជាប្រជាធិបតេយ្យបង្ហាញពីភូមិភាគដែលមាននៅពេលនោះ ឆ្នាំ១៩៧៦ ERN 00193066។ ឯកសារ **D1.3.27.1** ផែនទីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ ERN P 00000003។ ឯកសារ **D1.3.20.2** ឯកសាររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ ERN 00089849 មាត្រា ១៥។

មានជ័យ និងព្រះវិហារ[343]។ តំបន់ស្វយ័ត ១០៦ (សៀមរាប) និងតំបន់ស្វយ័ត ១០៣ (ព្រះវិហារ) ត្រូវបានច្របាច់បញ្ចូលគ្នាបង្កើតជាភូមិភាគឧត្តរថ្មី[344]។ ភូមិភាគកណ្តាលមានបីតំបន់៖ តំបន់ ៤១ តំបន់ ៤២ និងតំបន់ ៤៣[345]។ មន្ទីរភូមិភាគ ដែលជាទីបញ្ជាការភូមិភាគជាផ្លូវការ ស្ថិតនៅកណ្តាលក្រុងកំពង់ចាម[346]។

---

[343] ឯកសារ **D219/847.1** ឯកសារភ្ជាប់ ១៖ ប្រតិចារឹករបស់ អេា អាន ថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ERN 01337371-01337372។ ឯកសារ **D6.1.724** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ស៊ូ ERN 00407776 ឆ.៦, 00407778 ឆ.១៥។ ឯកសារ **D118/103.3** សារណាស្តាពរជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404800។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373494-00373495។ ឯកសារ **D6.1.736** កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00403910-00403911។ ឯកសារ **D6.1.729** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង គឹមអឿន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ERN 00418568-00418569 ឆ.១។ *សូមមើលផងដែរ* ឯកសារ **D1.3.16.1** ជីវប្រវត្តិ កែ ពក មានចំណងជើង "កែ ពក បានការពារខ្លួន មុនស្លាប់" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00164132-00164135 (*"មានខ្ញុំជាលេខា កងចាប អនុលេខា តាអាន ជាសមាជិក។ ចាប់ពីពេលនោះមក ក៏រៀបចំបំបែកភូមិភាគឧត្តរថ្មីជាពីរវិញគឺ កងចាបទទួលតំបន់សៀមរាប ឧត្តរមានជ័យ ឡើងត្រង់ទៅមង្គលបុរី ឡើងត្រង់ទៅមង្គលបុរី*

*ភូមិភាគកណ្តាលវិញដដែល។*")។

[344] ឯកសារ **D179/1.2.39** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ [ឌង សុផង់] ERN 00845294 បន្ទាត់ ១៣-១៧, 00845294 បន្ទាត់ ១៧-១៨។ ឯកសារ **D6.1.724** កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ ស៊ូ ERN 00407776 ឆ.៦, 00407778 ឆ.១៥។ ឯកសារ **D6.1.736** កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00403910-00403911។ ឯកសារ **D6.1.729** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង គឹមអឿន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ERN 00418568-00418569 ឆ.១។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794520 បន្ទាត់ ១៣-១៥, បន្ទាត់ ២៤-២៥។ *សូមមើលផងដែរ* ឯកសារ **D1.3.16.1** ជីវប្រវត្តិ កែ ពក មានចំណងជើង " កែ ពក បានការពារខ្លួន មុនស្លាប់" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00164132-00164135។ ឯកសារ **D179/1.2.38** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ [ឌង សុផង់] ERN 00844456 បន្ទាត់ ៤-៦ (*"ខ្ញុំចាំថាទិសនេះជាភូមិភាគមួយដែលរៀបចំថ្មីបាទ។ គឺក្រោយពីខាងតំបន់ស្វយ័ត សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ បានលុបចេញ ហើយក៏បង្កើតភូមិភាគមួយថ្មីហៅថា "ភូមិភាគ ៨០១" បាទ។*")។

[345] ឯកសារ **D117/35** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ ERN 00980365 ឆ.១៣។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា

១៦៥. អង្គភាពទូរលេខ និងមន្ទីរពាណិជ្ជកម្ម ស្ថិតនៅជិតមន្ទីរភូមិភាគ។ មន្ទីរពាណិជ្ជកម្មស្តុក និងចែកចាយគ្រឿងឧបភោគ-បរិភោគដល់តំបន់[347]។ សម្រាប់ជាផ្នែកភ័ស្តុភារ ភូមិភាគកណ្តាលក៏មានរថយន្តដឹកគ្រឿងឧបភោគ-បរិភោគ និងអ្នកទោស ទៅមន្ទីរសន្តិសុខ និងការដ្ឋាននានានៅទូទាំងភូមិភាគ[348]។

---

ឆ្នាំ២០០៩ ERN 00373495-00373496។ ឯកសារ **D219/249** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៥ ERN 01083736 ឆ.១។ ឯកសារ **D6.1.675** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ឆាំ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00402447 ឆ.៦៣។ ឯកសារ **D117/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សេង ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ ERN 00893180 ឆ.៣។ ឯកសារ **D219/178** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុច រ៉ា ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01066300 ឆ.៥។

[346] ឯកសារ **D6.1.384** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ុច ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៩ ERN 00348842។ ឯកសារ **D107/15** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១២ ERN 00800953-00800954។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373494-00373495។ ឯកសារ **D219/249** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៥ ERN 01083736 ឆ.៥។ ឯកសារ **D6.1.385** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៩ ERN 00348836-00348837។ ឯកសារ **D107/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784981-00784982។ ឯកសារ **D117/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សេង ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ ERN 00893180 ឆ.២។ ឯកសារ **D6.1.707** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ERN 00373508។

[347] ឯកសារ **D6.1.707** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ERN 00373508-00373509, 00373512-00373514។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373494-00373495។ ឯកសារ **D219/249** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៥ ERN 01083736 ឆ.៥-៦។ ឯកសារ **D117/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សេង ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ ERN 00893179 ឆ.១, 00893183 ឆ.១៩។ ឯកសារ **D219/606** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ខេងថៃ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01175103 ឆ.៣៨-ឆ.៤១, 011751103-01175104 ឆ.៤៣-ឆ.៤៥។

[348] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ថេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344690 ឆ.៤៧, 01344691 ឆ.៥៤។ ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01146380 ឆ.៧២, 01146381 ឆ.៧៦, 01146382 ឆ.៧៨, 01146395 ឆ.១៤៣។ ឯកសារ **D219/582** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូយ មៀច ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ERN 01166935

១៦៦. កងទ័ពភូមិភាគស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពីគណៈភូមិភាគ[349]។ កងយោធាភូមិភាគឈរជើងនៅតាមមូលដ្ឋាននានា ទូទាំងភូមិភាគ រួមទាំងនៅវត្តភ្នំប្រុសភ្នំស្រី ក្នុងឃុំគាស់ក្រឡ និងឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម[350]។ ភូមិភាគកណ្ដាលដំណើរការមន្ទីរសន្តិសុខមួយ ជិតសាលាខេត្តកំពង់ចាម[351]។ ស.ច.ស មិនទទួលបានបណ្ដឹងអំពីមន្ទីរសន្តិសុខនេះទេ។

---

ទំ.៥៤-ទំ.៥៥។ ឯកសារ **D219/855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344701 ទំ.១៤៦។ ឯកសារ **D219/816** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យ៉ា ម៉ាត់លី ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ERN 01322152-01322153 ទំ.២១, 01322157 ទំ.៤៥។ ឯកសារ **D219/702.1.109** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២/០២ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ [នោ សាខុះ] ERN 01418410 បន្ទាត់ ៩-១១។

[349] ឯកសារ **D117/66** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01023132 ទំ.២។ ឯកសារ D1.3.30.16 ទូរលេខរបស់យោធាកម្ពុជាប្រជាធិបតេយ្យដោយ ពក មានចំណងជើង "ទូរលេខ ១០ ប៉ុស្តិ៍វិទ្យុ ៣៩៣ សូមជំរាបមកគណៈ៨៧០ ជាទីស្នេហា និងរលឹក" ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៨ ERN 00052886។ ឯកសារ **D219/702.1.26** ទូរលេខ ១១ កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៨ ERN 00052887។ ឯកសារ **D6.1.974** ទូរលេខ ០៣ សុំជំរាបមកគណៈ ៨៧០ ជាទីស្នេហា និងរលឹក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ ERN 00001108។ ឯកសារ **D6.1.437** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែ អ៊ុន ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ERN 00271379។ ឯកសារ **D219/178** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គុច វ៉ា ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01066299 ទំ.១-៥។ ឯកសារ **D6.1.636** កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ERN 00398198-00398200។

[350] ឯកសារ **D107/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784991 ទំ.២។ ឯកសារ **D219/602** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទឹប គឹមហេង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01172149 ទំ.១៨។ ឯកសារ **D219/138** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ERN 01056061 ទំ.៩៧។ *សូមមើលផ្នែកការដ្ឋានឧក្រិដ្ឋកម្មវត្តភ្នំប្រុសភ្នំស្រី។ សូមមើលផងដែរ* ឯកសារ **D219/178** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គុច វ៉ា ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01066301 ទំ.១៣ (*"ភ្នំប្រុស ជាភ្នំមួយនៅជិតទីរួមខេត្តកំពង់ចាម ហើយធ្លាប់ជាទីតាំងយោធាឈរជើងនៅទីនោះ។ មុនឆ្នាំ១៩៧៧ ពួកខ្ញុំធ្លាប់ដើរល្បាតឆៅភាឧហ្នឹងដែរ"*)។

[351] ឯកសារ **D6.1.697** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373503។ ឯកសារ **D117/20** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម សេង ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ ERN 00893182 ទំ.១៨។

## ៦.១.៣. តំបន់ ៤១

១៦៧. តំបន់ ៤១ ស្ថិតនៅប៉ែកខាងត្បូងនៃភូមិភាគ ហើយមានព្រំប្រទល់ខាងត្បូងជាប់ទន្លេមេគង្គ។ តំបន់នេះគ្របដណ្តប់លើខេត្តកំពង់ចាមភាគខាងលិច ដែលនៅខាងលិចទន្លេមេគង្គ[352]។ តំបន់ ៤១ មានស្រុកកំពង់សៀម ស្រុកព្រៃឈរ ស្រុកបាធាយ ស្រុកកងមាស និងស្រុកជើងព្រៃ[353]។

១៦៨. មន្ទីរតំបន់ ៤១ ជាទីបញ្ជាការរបស់តំបន់ ជាផ្ទះ និងមន្ទីររបស់លេខាតំបន់។ មន្ទីរតំបន់ស្ថិតនៅភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម[354]។

១៦៩. បរិវេណមន្ទីរតំបន់រួមបញ្ចូលទាំងអគារផ្សេងទៀតជាច្រើន[355] ដូចជាផ្ទះមួយខ្នងសម្រាប់លេខាតំបន់ និងផ្ទះមួយខ្នងសម្រាប់ប្រធានមន្ទីរតំបន់ ៤១ ដែលមានមុខងារសំខាន់ជាអ្នកគ្រប់គ្រង

---

[352] ឯកសារ **D6.1.82** ផែនទីតួល័រ ឆ្នាំ១៩៧៦ នៃកម្ពុជាប្រជាធិបតេយ្យបង្ហាញពីភូមិភាគដែលមាននៅពេលនោះ ឆ្នាំ១៩៧៦ ERN 00193066។ ឯកសារ **D1.3.27.1** ផែនទីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ ERN P 00000003។

[353] ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373495-00373496។ ឯកសារ **D6.1.373** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុន អុល ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៩ ERN 00326637។ ឯកសារ **D117/56** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 00997284 ឃ.៣០។

[354] ឯកសារ **D117/70** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 01046794 ឃ.២៥។ ឯកសារ **D117/71** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ERN 01046804 ឃ.២៣។ ឯកសារ **D107/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម គុល ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784981-00784982។ ឯកសារ **D219/284** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ ERN 01091374 ឃ.១១។ ឯកសារ **D117/39** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គូ សេម ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៤ ERN 00993584 ឃ.៨។ ឯកសារ **D219/702.1.87** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ [យូ វ៉ាន់] ERN 01451941 បន្ទាត់ ១៧-១៩។ *សូមមើលផងដែរ* ឯកសារ D74 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ័ត្ត ពៅ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ERN 00729729 ឃ.៩។ ឯកសារ **D219/802** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុង ហេង ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ERN 01308075 ឃ.១៥។ ឯកសារ **D219/761** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ិល ខន ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ERN 01242612 ឃ.៦-៨។ ឯកសារ **D219/870** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រី ញ៉ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01348886 ឃ.៣០, ឃ.៣៣។

បុគ្គលិកឱ្យលេខាតំបន់[356]។ ប្រធានយោធាតំបន់ស្នាក់នៅក្រោមផ្ទះរបស់លេខាតំបន់ ជាមួយសមាជិកកងការពារលេខាតំបន់[357]។ អ្នកបើកបររបស់តំបន់ ៤១ ក៏ដេកនៅក្រោមផ្ទះរបស់លេខាតំបន់ដែរ[358]។ កងការពារមួយទៀតដេកនៅក្រោមផ្ទះរបស់ប្រធានមន្ទីរតំបន់[359]។

---

[355] ឯកសារ **D219/800** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ERN 01308045 ទ.១០០។

[356] ឯកសារ **D219/800** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ERN 01308046 ទ.១០១។ ឯកសារ **D117/56** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វឿង ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 00997281-00997282 **ទ.១៨-១៩**, 00997283 **ទ.២៥**។ ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01146373 ទ.១៩។ ឯកសារ **D219/788** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុត សារ៉េត ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ERN 01301756 ទ.៤៩-ទ.៥០។ ឯកសារ **D219/315** កំណត់ហេតុស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ERN 01097732 ទ.១២, ទ.១៦, 01097742 ទ.៨៩, 01097748 ទ.១៣០, ទ.១៣២។ ឯកសារ **D219/321** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុត ឃី ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៥ ERN 01099645-01099646 ទ.៧-ទ.៩។ ឯកសារ **D219/686** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុត ឃី ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203981 ទ.២១, 01203984 ទ.៣៧, ទ.៣៩។ ឯកសារ **D219/541** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីម គឿន ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៥ ERN 01157492 **ទ.៤៤-ទ.៤៥, ទ.៥២**។ ឯកសារ **D219/442** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វឿង ERN 01125512 ទ.៧៣-ទ.៧៤។ ឯកសារ **D219/331** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផន សុផល ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ERN 01101255 ទ.២៥-ទ.២៨, 01101257 ទ.៣៨។ ឯកសារ **D219/704** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីម គឿន ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ERN 01210604 ទ.២៨, 01210605 ទ.៣២។ ឯកសារ **D219/855** កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344693 ទ.៧។ ឯកសារ **D219/331** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផន សុផល ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ERN 01101254 ទ.៨-ទ.១០។

[357] ឯកសារ **D219/800** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ERN 01308046 ទ.១០៨។

[358] ឯកសារ **D219/800** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ERN 01308046 ទ.១១១។

[359] ឯកសារ **D219/800** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ERN 01308046 ទ.១០៧។

១៧០. មន្ទីរពាណិជ្ជកម្មតំបន់ ភស្តុភារតំបន់ រោងឡានតំបន់ ឃ្លាំងតំបន់ រោងបាយតំបន់ មន្ទីរជនពិការតំបន់ និងមន្ទីរឃោសនាការតំបន់ មានទីតាំងស្ថិតនៅក្នុង ឬជិតមន្ទីរតំបន់ ៤១[360]។

១៧១. មន្ទីរសន្តិសុខធំ (មិត្តសុប) របស់តំបន់ ៤១ មានទីតាំងស្ថិតនៅឃុំគរ ស្រុកព្រៃឈរ ហើយត្រូវបានគ្រប់គ្រងដោយប្រធានសន្តិសុខតំបន់ ដែលរាយការណ៍ទៅលេខាតំបន់ និងពេលខ្លះ ទៅប្រធានមន្ទីរតំបន់[361]។ មន្ទីរសន្តិសុខមួយទៀតនៃតំបន់ ៤១ មានទីតាំងស្ថិតនៅវត្តតាមាក់ ចម្ងាយប្រហែលមួយគីឡូម៉ែត្រ ពីមន្ទីរតំបន់ ៤១[362]។

១៧២. យោធាតំបន់ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈតំបន់[363]។ ប្រធានយោធាតំបន់រាយការណ៍ផ្ទាល់ទៅលេខាតំបន់[364]។ យោធាតំបន់មានទាហានមួយកងវរសេនាធំ ប្រហែល ៣០០ នាក់ នៅវត្តតាមាក់ និងនៅទីតាំងផ្សេងទៀត ក្នុងតំបន់ ៤១[365]។

---

[360] ឯកសារ **D219/498** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01141576 ឆ.១៣។ ឯកសារ **D219/541** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ធឿន ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៥ ERN 01157491 ឆ.៣៣-ឆ.៣៥។ ឯកសារ **D219/460** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01130682 ឆ.២។ ឯកសារ **D219/582** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តួយ មៀច ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ERN 01166932 ឆ.២០, ឆ.២៥។ ឯកសារ **D219/686** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុត ឃី ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ERN 01203988 ឆ.៦៧។

[361] មើលផ្នែក ៦.៤.១.៣ មន្ទីរសន្តិសុខមិត្តសុប កថាខណ្ឌ ៣៨៥-៤១១។

[362] មើលផ្នែក ៦.៤.១.៨ វត្តតាមាក់ កថាខណ្ឌ ៥៥៦-៥៨៩។

[363] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053030 មាត្រា ១៦(១)។ ឯកសារ **D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ធឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ERN 00997038 ឆ.១១២។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ERN 01056061 ឆ.៩៨។ ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344698 ឆ.១១៧-១២២។ *សូមមើលផងដែរ* ឯកសារ **D117/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃឹម ជឿង ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ERN 00872762 ឆ.២៤ (បញ្ជាក់ថា បញ្ជាឲ្យចាប់ខ្លួនមកពីគណៈស្រុក ឬគណៈតំបន់។)។

[364] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344696 ឆ.១០០, 01344714 ឆ.២៥០។ ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01146376 ឆ.៤១, 01146377 ឆ.៥៣។

## ៦.១.៤. ស្រុកនៅតំបន់ ៤១

១៧៣. មន្ទីរស្រុកកំពង់សៀមស្ថិតនៅក្នុងវត្តក្រឡា ភូមិអង្គញដី ជិតវត្តអង្គញដី[366]។ ស្រុកកំពង់សៀម មានមន្ទីរសន្តិសុខពីរ នៅវត្តអង្គញដី និងទួលបេង[367]។

---

[365] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344695 **ទ.៩៣**, 01344697 **ទ.១១៥**។ ឯកសារ **D219/315** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ERN 01097751 **ទ.១៥១**។ ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01146379 **ទ.៦៦**។ ឯកសារ **D219/541** កំណត់ហេតុស្តាប់ចម្លើយសាក្សី គីម ធឿន ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៥ ERN 01157496 **ទ.៩៣**។ ឯកសារ **D219/543** កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាំ ម៉ុន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ ERN 0117516 **ទ.៥៥-ទ.៥៦**។ ឯកសារ **D219/459** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ អឿន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ERN 01130674 **ទ.១០**។ ឯកសារ **D219/544** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុន ហេងង ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ ERN 01157528 **ទ.៣៩**។ ឯកសារ **D219/582** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូយ មៀច ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ERN 01166938 **ទ.៧៦**។ ឯកសារ ឯកសារ **D219/800** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ERN 01308055 **ទ.២០១**។ ឯកសារ **D219/837** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ERN 01335581 **ទ.៤២**, 0135582 **ទ.៤៩**, 01335583 **ទ.៥៨**។ ឯកសារ **D219/442** កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ វណ្ឌ ERN 01125520 **ទ.១២៨**, **ទ.១៣០**។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នា២០១៥ ERN 01056061 **ទ.៩៤-៩៥** *សោយយោង* ឯកសារ **D219/460** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01130683 **ទ.១០** *("អ្នកយាមនៅទីនោះគឺសុទ្ធតែជាទាហានមកពីភូមិភាគ។ ពួកគេមានឡានចំនួន ៣ ហើយបើតាមខ្ញុំស្មានគឺពួកគេមានគ្នាពី ៥០ ទៅ៦០នាក់។")*។

[366] ឯកសារ **D107/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម កុល ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784981-00784982។ ឯកសារ **D219/461** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន ធុល ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១៥ ERN 01130690 **ទ.៥**។ ឯកសារ **D117/31** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ERN 00964454 **ទ.១៣**។ ឯកសារ **D117/24** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ERN 00947235 **ទ.១២**, **ទ.១៦**។ ឯកសារ **D219/284** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ ERN 01091384 **ទ.៩១**។ ឯកសារ **D117/70** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 01046795 **ទ.៣០**។ ឯកសារ **D117/44** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ហឿន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៤ ERN 00987149 **ទ.៦**។

[367] *សូមមើលផ្នែក* ៦.៤.១.៤ ទួលបេង និងវត្តអង្គញដី កថាខណ្ឌ ៤១២-៤៥៥។

១៧៤. មន្ទីរស្រុកព្រៃឈរស្ថិតនៅជាប់មន្ទីរតំបន់ នៅជិតផ្លូវបំបែកទៅព្រៃទទឹង ក្នុងឃុំជ្រៃវៀន ស្រុកព្រៃឈរ[368]។

១៧៥. មន្ទីរស្រុកកងមាសស្ថិតនៅទីតាំងសាលាស្រុកបច្ចុប្បន្ន កែងផ្លូវពីផ្សារពាមជីកង ទៅព្រៃទទឹង និងផ្លូវពីពាមជីកង ទៅរការកោង[369]។ មន្ទីរសន្តិសុខស្រុកកងមាសស្ថិតនៅវត្តអូរត្រកួន[370]។

១៧៦. គ្មានអ្នកណាដឹងថា មន្ទីរស្រុកបាធាយស្ថិតនៅកន្លែងណាទេ។ មន្ទីរសន្តិសុខស្រុកបាធាយស្ថិតនៅវត្តបាធាយ[371]។

១៧៧. គ្មានអ្នកណាដឹងថា មន្ទីរស្រុកជើងព្រៃ ឬមន្ទីរសន្តិសុខស្រុកជើងព្រៃ ស្ថិតនៅកន្លែងណាទេ។

១៧៨. គណៈស្រុកនីមួយៗគ្រប់គ្រង *"កងឈ្លប"*[372] ហើយប្រធានយោធាស្រុករាយការណ៍ផ្ទាល់ទៅលេខាស្រុក[373]។

---

[368] ឯកសារ **D219/315** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ERN 01097731 ឆ.១១។ ឯកសារ **D219/460.1** ផែនទីស្រុកព្រៃឈរ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01130679។ ឯកសារ **D219/460** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01130682 ឆ.២។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ERN 01056054 ឆ.៧១។

[369] ឯកសារ **D117/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ យឿន ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ERN 01007900។ ឯកសារ **D117/63** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាយ ឌឿន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៤ ERN 01007908 ឆ.៣៣។ ឯកសារ **D117/64** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុង គីមឃុន ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ERN 01007913 ឆ.៤។

[370] *សូមមើល*ផ្នែក ៦.៤.១.៥ មន្ទីរសន្តិសុខវត្តអូរត្រកួន កថាខណ្ឌ ៤៥៦-៤៩១។

[371] *សូមមើល*ផ្នែក ៦.៤.១.៦ មន្ទីរសន្តិសុខវត្តបាធាយ កថាខណ្ឌ ៤៩២-៥៣៦។

[372] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ERN 00053013 មាត្រា ១, 00053029 មាត្រា ១៣(១)-១៣(៤)។ ឯកសារ **D219/442** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ERN 01125522 ឆ.១៤៤។ ឯកសារ **D219/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ នី ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ERN 01031431-01031432 ឆ.៤១។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ERN 01056041-001056042 ឆ.១១-១២។ ឯកសារ **D219/463** កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ែន ជុល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ERN 01130702 ឆ.១។

## ៦.១.៥. អំណាចតាមផ្លូវច្បាប់របស់ភូមិភាគ និងតំបន់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

១៧៩. ក្របខ័ណ្ឌរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ដែលបានកំណត់ក្នុងលក្ខន្តិកៈ ប.ក.ក បាន បញ្ជាក់អំពីតួនាទី អំណាច និងបុព្វសិទ្ធិរបស់អង្គការនយោបាយ និងថ្នាក់រដ្ឋបាលរបស់កម្ពុជា ប្រជាធិបតេយ្យ[374]។

១៨០. ភូមិភាគជាថ្នាក់រដ្ឋបាលក្រោមថ្នាក់មជ្ឈិម[375] ហើយត្រូវបានគ្រប់គ្រងដោយគណៈភូមិភាគ[376]។ សមាជិកគណៈភូមិភាគមានភារកិច្ចតាមផ្លូវច្បាប់ *"ចុះជាប់តំបន់ ស្រុក សាខា... និងកងទ័ព*

---

[373] ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមសេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784993 ឆ.២២។ ឯកសារ **D219/323** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត សុធុន ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ ERN 01099667 ឆ.២៣។ ឯកសារ **D219/26** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ នី ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ERN 01031431-01031432 ឆ.៤១។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ERN 01056042 ឆ.១៦, 01056049 ឆ.៤៧, 01056061 ឆ.៩០។ *មើល* ឯកសារ **D117/70** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 01046797 ឆ.៤១។ ឯកសារ **D219/463** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន ធុល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ERN 01130702 ឆ.៤។ ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344715 ឆ.២៥៧។ ឯកសារ **D6.1.413** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុក ហឿន ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00243082-00243083។ ឯកសារ **D36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ម៉ាលី ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ERN 00716479-00716479។ *សូមមើលផងដែរ* ឯកសារ **D6.1.386** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០ ERN 00348795។ ឯកសារ **D117/70** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ERN 01046795 ឆ.២៨។

[374] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ ១៩៧៦។

[375] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053025 មាត្រា ៧(១)-(២), 00053031 មាត្រា ១៨(៣), 00053032 មាត្រា ១៩(៤)។

[376] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053032 មាត្រា ១៩។

*បរិវត្តន៍ ដើម្បីដឹកនាំអនុវត្តភារកិច្ច" "ក្ដាប់មហាជនឱ្យជាប់ និងឱ្យណែនជានិច្ច"* តាមរយៈការ *"អប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង"*[377]។

១៨១. គណៈភូមិភាគទទួលខុសត្រូវកាន់កាប់ទ្រព្យសម្បត្តិរបស់ភូមិភាគ រួមទាំងការដ្ឋាន និងផ្លូវ[378]។ ដូច្នេះ គណៈភូមិភាគទទួលខុសត្រូវចុះមើលតាមការដ្ឋានក្នុងភូមិភាគ[379] ហើយត្រួតពិនិត្យ និងអនុញ្ញាតឱ្យផ្ទេរ និងចល័តប្រជាជន និងសម្ភារ ក្នុងភូមិភាគរៀងៗខ្លួន[380]។

---

[377] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053032 មាត្រា ១៩(១)-(៣)។ "សាខា" សំដៅលើអង្គភាពថ្នាក់ក្រោមគេក្នុងបក្សកុម្មុយនីស្តកម្ពុជា៖ *សូមមើល* ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053026-00053028 មាត្រា ៩-១១។

[378] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053032 មាត្រា ១៩(៤)។ ឯកសារ **D179/1.2.11** ប្រតិចារឹកសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ERN 007940663 បន្ទាត់ ៧-១៩។

[379] ឯកសារ **D6.1.437** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែ អ៊ុន ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ERN 00271382-00271383។ ឯកសារ **D6.1.427** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិវ ពៅ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ERN 00267761-00267762។

[380] ឯកសារ **D219/193** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព៉ត ផាត ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01070060-01070061 **ឆ.៤២-ឆ.៤៣**, 01070061-01070062 **ឆ.៤៨, ឆ.៥៣**។ **ឯកសារ D6.1.364** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿន សែម ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ERN 00316513-00316514។ ឯកសារ **D219/702.1.5** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ [ឡៅ នៅ] ERN 00811945 បន្ទាត់ ២១-២៥, 00819246 បន្ទាត់៤-៥។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00373499។ ឯកសារ **D219/551** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ហេង ឃ្លី ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ERN 01157600 ឆ.៨៤។ ឯកសារ **D118/92** កំណត់ហេតុស្ដាប់ចម្លើយសាក្សី ណុប ណាន ERN 00947253 ឆ.១១ *ស្ដីពីរបៀបដែលចលនាត្រូវកម្រិតជាទូទៅសម្រាប់បុគ្គលទាំងអស់ និងតម្រូវឱ្យមានការយល់ព្រមពីថ្នាក់លើ៖* **D219/395** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៀវ ហេង ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៥ ERN 01114701 ឆ.៨។ ឯកសារ **D219/427** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ERN 01121728 **ឆ.៥៧**។ ឯកសារ **D219/666** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យ៉ង់ សារៀប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ERN 01200327 **ឆ.៨៣**។ ឯកសារ **D219/22** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អោក គីម ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ERN 01029633 **ឆ.៥៤**។ **ឯកសារ**

១៨២. គណៈភូមិភាគក៏ទទួលខុសត្រូវគ្រប់គ្រងវិន័យនៅក្នុងភូមិភាគផងដែរ[381]។ ថ្វីត្បិតតែលក្ខន្តិកៈ ប.ក.ក មិនបានកំណត់និយមន័យនៃវិន័យក៏ដោយ ក៏ក្នុងការអនុវត្ត *"វិន័យ"* មានន័យស្មើនឹង *"ទណ្ឌកម្ម"* ហើយដូច្នេះ *"ការគ្រប់គ្រងវិន័យ"* គឺពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម[382]។

---

**D219/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហូ ហឿន ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១៥ ERN 01096502 ឆ.២។ ឯកសារ **D219/125** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ERN 01047411 ឆ.២៩៩។ ឯកសារ **D219/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ ERN 01032615 ឆ.៣០។ ឯកសារ **D6.1.156** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គាន់ សារឿន ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៨ ERN 00196824។ ឯកសារ **D219/702.1.45** ស្នើសុំផ្ញើសំបុត្រមួយ ដោយលោក ខៀវ សំផន ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៧ ERN 00157633។ ឯកសារ **D219/702.1.38** ខៀវ សំផន "លិខិតចំហជូនបងប្អូនជនរួមជាតិទាំងអស់" បោះផ្សាយនៅក្នុងកាសែត ខេមបូឌាដេលី ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ ERN 00002796។ ឯកសារ **D219/702.1.70** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ERN 00818649-00818650។ ឯកសារ **D219/370.1.4** សារផ្ញើតាមហិបឲូត មានចំណងជើង "ជីវិតនៅក្នុងប្រទេសកម្ពុជា" ERN 00709588។ ឯកសារ **D179/1.2.18** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ERN 00799245; *លិខិតអនុញ្ញាតឱ្យធ្វើដំណើរត្រូវបានពិនិត្យនិងអនុវត្តដោយឈ្លបនៅគោលដៅផែកនេះ ហើយអ្នកដែលគ្មានលិខិតនឹងត្រូវចាប់ខ្លួន សូមមើលឧទាហរណ៍* ឯកសារ **D118/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ប្រិល ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ERN 00905870 ឆ.៨។ ឯកសារ **D219/63** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សៅ សុខ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01037162 ឆ.៧៩។ ឯកសារ **D119/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ERN 00933133-00933134 ឆ.៣០។ ឯកសារ **D219/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លើម សេន ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ERN 01047179 ឆ.១៦។ ឯកសារ **D6.1.1059** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ឌុច ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ ERN 00177625។ ឯកសារ **D179/1.2.17** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២ ERN 00797576; *គណៈភូមិភាគទទួលខុសត្រូវពិនិត្យការជម្លៀសប្រជាជនពីភូមិភាគផ្សេងៗក្នុងតំបន់របស់ពួកគេ សូមមើលឧទាហរណ៍* ឯកសារ **D6.1.991** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សឿម ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ ERN 00485645-00485646 ឆ.៥។

[381] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053032 មាត្រា ១៩(៤)។

[382] ឯកសារ **D6.1.1073** ចម្លើយតបរបស់ ឌុច ទៅនឹង ១៣សំណួរដាណាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ ERN 00234072។

១៨៣. លើសពីនេះទៀត គណៈភូមិភាគត្រូវ *"មានប្រព័ន្ធរាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ភូមិភាគ ជូនគណៈមជ្ឈិម"*[383]។ ក្នុងការអនុវត្ត ករណីនេះតម្រូវឱ្យមានភារកិច្ចមួយចំនួន រួមមានការផ្ញើ និងទទួលរបាយការណ៍ពីមជ្ឈិម[384] ការចូលរួមវគ្គរៀនសូត្រជាមួយ *"អង្គការ"*[385] នៅភ្នំពេញ[386] និងការទទួលសមាជិកមជ្ឈិម ក្នុងភូមិភាគរៀងៗខ្លួន[387]។

---

[383] ឯកសារ D1.3.20.1 ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ ១៩៧៦ ERN 00053032 មាត្រា ១៩(៤)។

[384] ឯកសារ **D6.1.514** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ERN 00345912។ ឯកសារ **D118/249** កំណត់ហេតុនៃការស្តាប់ចម្លើយពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សុខ ឯម ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៤ ERN 00990859 **ឆ.៩, ឆ.១២,** 00990860 **ឆ.១៦**។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00340570-00340571; *ទូរលេខបញ្ជូនពីភូមិភាគទៅមជ្ឈិម សូមមើលឧទាហរណ៍* ឯកសារ **D6.1.499** ទូរលេខកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង "ទូរលេខ ៣២៤" ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ ERN 00296228-00296231។ ឯកសារ **D1.3.34.2** របាយការណ៍ពីមន្ទីរភូមិភាគនិរតីជូនអង្គការ ស្តីពីសភាពការការពារនិងសភាពការសេដ្ឋកិច្ចក្នុងភូមិភាគ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ ERN 00000708-00000709។ ឯកសារ **D6.1.1230** គោរពជូនអង្គការ៖ អំពីការការពារខ្មាំង ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៨ ERN 00076286-000762888។ ឯកសារ **D1.3.27.3** របាយការណ៍រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់ ម៥៦០ ស្តីពីសភាពការណ៍ក្នុងភូមិភាគពាយ័ព្យ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ ERN 00008497-00008501។ ឯកសារ **D219/702.1.65** ទូរលេខ ៥៣៖ គោរពជូនគណៈ ៨៧០ ជាទីគោរពស្នេហានិងនឹករលឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៧ ERN 00020852-00020854។ ឯកសារ **D219/370.1.14** គោរពជូនអង្គការពី ម៤០១ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ ERN 00143575-00143580។ ឯកសារ **D219/370.1.13** គោរពជូនអង្គការ ពី ម៤០១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨ ERN 00143603-00143617។ ឯកសារ **D6.1.966** របាយការណ៍ ម៥៦០ស្តីពីភូមិភាគពាយ័ព្យ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៧ ERN 00214271-00214273។ ឯកសារ **D1.3.30.19** របាយការណ៍របស់ញឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ ERN 00021043-00021045។ ឯកសារ **D1.3.27.4** របាយការណ៍របស់ ញឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ ERN 00021046-00021048។ ឯកសារ **D219/702.1.62** ទូរលេខ ៦០៖ គោរពជូនគណៈ៨៧០ ជាទីស្នេហា និងនឹករលឹក អំពីសភាពការណ៍គ្រប់ផ្នែកមួយចំនួន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៧៧ ERN 00069447-00069449។ ឯកសារ **D1.3.27.3** របាយការណ៍រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយមន្ទីរ ៥៦០ អំពីសភាពការណ៍ក្នុងភូមិភាគពាយ័ព្យ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ ERN 00008497-00008501។ ឯកសារ **D6.1.60** ទូរលេខ ៣២ គោរពជូន ម.៨៧០ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ERN 00020851។ ឯកសារ **D219/702.1.3** ជូនម.៨៧០ ជាទីស្នេហា និងនឹករលឹក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ERN 00000879; *គណៈភូមិភាគនឹងទទួលការទាក់ទងផ្ទាល់ពីគណៈមជ្ឈិម សូមមើលឧទាហរណ៍*

---

ឯកសារ **D6.1.1085** កំណត់ហេតុស្តាប់ចម្លើយសាក្សី ឋា សុត ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ERN 00204743-00204744។

[385] "អង្គការ" ជាពាក្យត្រូវបានប្រើសម្រាប់សម្គាល់ថ្នាក់កំពូលនៃបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែត្រូវប្រជាជនទូទៅប្រើក្នុងន័យទូលាយសំដៅលើបក្សកុម្មុយនីស្តកម្ពុជា៖ ឯកសារ **D6.1.1070** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ នួន ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៨ ERN 00195565។ ឯកសារ **D6.1.863** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី នួន - ការប្រជុំរៀបចំសវនាការ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ [នួន] ERN 00328660 បន្ទាត់ ៧, បន្ទាត់ ៨-១០។ ឯកសារ **D6.1.1067** កំណត់ហេតុនៃការសួរចម្លើយ នួន ដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ ERN 00146659-00146660។ ឯកសារ **D179/1.2.13** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ [នួន] ERN 00795487 បន្ទាត់ ២៤-២៥, 00795488 បន្ទាត់ ១-១៣។

[386] ឯកសារ **D6.1.677** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុក សួរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00402478 ធ.៥៨។ ឯកសារ **D6.1.389** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ នៅ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ERN 00355441។ ឯកសារ **D6.1.141** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន (១) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ERN 00251438-00251440។ ឯកសារ **D6.1.501** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន សុវណ្ណហាន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ ERN 00287712-00287714។ ឯកសារ **D6.1.637** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ នួន ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ERN 00398222-00398223។ ឯកសារ **D6.1.736** កំណត់ហេតុនៃការសួរចម្លើយ នួន ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00403907-00403908។ ឯកសារ **D6.1.1051** កំណត់ហេតុនៃការសួរចម្លើយ នួន ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ ERN 00154927។ ឯកសារ **D6.1.1070** កំណត់ហេតុនៃការសួរចម្លើយ នួន ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៨ ERN 00195567។ ឯកសារ **D6.1.661** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ERN 00398480-00398481។ ឯកសារ **D6.1.1076** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ ERN 00204089; *ឧទាហរណ៍ជាក់លាក់នៃទំនាក់ទំនងរវាងរដ្ឋបាលស៊ីវិល និងយោធា៖ លេខាភូមិភាគ តម្រូវឱ្យចូលរួមប្រជុំជាមួយក្រុមយោធានៅទីក្រុងភ្នំពេញដើម្បីពិភាក្សាពីបញ្ហាយោធា សូមមើលឧទាហរណ៍* ឯកសារ **D6.1.674** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គោម សែ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00401315-00401316 ឆ.៣។

[387] ឯកសារ **D34.1.11** កម្រងនៃការផ្សព្វផ្សាយព័ត៌មានទៅបរទេស (ហ្វ៊ីប៊ីស) ខែធ្នូ ឆ្នាំ១៩៧៧ សេវាព័ត៌មានក្នុងប្រទេសរបស់ក្រុងភ្នំពេញ ERN (EN) 00168335។ ឯកសារ **D6.1.1070** កំណត់ហេតុនៃការសួរចម្លើយ នួន ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៨ ERN 00195567។ ឯកសារ **D6.1.438** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌី យើ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ERN 00271356-00271357។ ឯកសារ **D6.1.1081** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង លីផេង ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ ERN 00204025។ ឯកសារ **D6.1.385** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៩ ERN 00348833-00348835។

១៨៤. គណៈភូមិភាគត្រូវទទួលរបាយការណ៍ស្តីពីសភាពការណ៍ និងការងាររបស់តំបន់[388]។ គណៈភូមិភាគត្រូវរៀបចំសន្និបាតភូមិភាគមួយឆ្នាំម្តង[389] និងកិច្ចប្រជុំសាមញ្ញរៀងរាល់បីខែម្តង[390]។

១៨៥. លេខាភូមិភាគមានសិទ្ធិអំណាចតែងតាំង និងដកសមាជិកគណៈភូមិភាគដទៃទៀត ដោយមានការឯកភាពពីគណៈមជ្ឈិម[391]។ លើសពីនេះទៀត គណៈភូមិភាគទទួលខុសត្រូវក្នុងការអនុម័ត និងអនុញ្ញាតឱ្យលេខាតំបន់តែងតាំង និងដកសមាជិកគណៈតំបន់[392]។

១៨៦. ថ្វីត្បិតតែលក្ខន្តិកៈ ប.ក.ក មិនបានបញ្ជាក់បន្ថែមអំពីសមាសភាពគណៈភូមិភាគក៏ដោយ ក៏អតីតប្រធាន ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ("ឌុច") បានពន្យល់ថា ភូមិភាគត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការមួយដែលមានគ្នាបីនាក់ រួមមានលេខា អនុលេខាដែលជាទូទៅទទួលខុសត្រូវខាងសន្តិសុខ និងសមាជិកម្នាក់ដែលជាទូទៅទទួលខុសត្រូវខាងសេដ្ឋកិច្ច[393]។

---

[388] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053030 មាត្រា ១៦(៤)។

[389] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053031 មាត្រា ១៨។

[390] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053032 មាត្រា ២០។

[391] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053031 មាត្រា ១៨(៣)។ ឯកសារ **D6.1.533** របាយការណ៍អ្នកជំនាញ ក្រេក អេធេសាន់ អ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ERN 00314795។

[392] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053030 មាត្រា ១៥(៣)។ ឯកសារ **D6.1.863** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ឌុច - ការប្រជុំរៀបចំសវនាការ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ [ក្រេក អេតធេសាន់] ERN 00328701 បន្ទាត់ ៤-៦, បន្ទាត់ ១២-១៤។ ឯកសារ **D6.1.533** របាយការណ៍អ្នកជំនាញ ក្រេក អេធេសាន់ អ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ERN 00314801-00314803។

[393] ឯកសារ **D6.1.863** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ឌុច - ការប្រជុំរៀបចំសវនាការ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ [កាំង ហ្កេកអ៊ាវ ហៅ ឌុច] ERN 00328700 បន្ទាត់ ១០-១១, បន្ទាត់ ១១-១២។ *សូមមើលផងដែរ* ឯកសារ **D6.1.533** របាយការណ៍អ្នកជំនាញ ក្រេក អេធេសាន់ អ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ERN 00314779-00314780។ ឯកសារ **D219/847.1** ឯកសារភ្ជាប់ ១៖

១៨៧. យោងតាមលក្ខន្តិកៈ ប.ក.ក កងទ័ពបដិវត្តន៍កម្ពុជា ស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់គណៈមជ្ឈិម[394]។ ទោះជាយ៉ាងណា គណៈតំបន់ទទួលខុសត្រូវ *"ដឹកនាំអនុវត្តភារកិច្ច"* របស់អង្គភាពនានានៃកងពលរបស់កងទ័ពបដិវត្តន៍កម្ពុជា[395] ហើយក្នុងការអនុវត្ត កងពលនៃកងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានបញ្ចូលទៅក្នុងរដ្ឋបាលភូមិភាគ[396]។

១៨៨. តាមសេចក្តីណែនាំរបស់គណៈមជ្ឈិម ប.ក.ក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ លេខាភូមិភាគរួមទាំង កែ ពក ផងដែរ មានសិទ្ធិអំណាចសម្រេចឲ្យចាប់[397] និងសម្លាប់[398]។

---

កិច្ចសម្ភាសន៍ជាមួយ អោ អាន ថ្ងៃទី១ ខែសីហា ឆ្នាំ២០១១ ERN 01337344-01337345, 01337345-01337346, 01337353-01337355។

[394] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053035 មាត្រា ២៧-មាត្រា ២៨។

[395] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053032 មាត្រា ១៩(១)។

[396] ឯកសារ **D6.1.734** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឈឿន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ERN 00373481។ ឯកសារ **D219/702.1.148** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨ ERN 00204701-00204703។ ឯកសារ **D1.3.29.7** បទសម្ភាសន៍របស់ UNHCHR ជាមួយជនសង្ស័យ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ ERN 00002496-00002497។ *សូមមើលផងដែរ* ឯកសារ **D219/702.1.9** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ធីនិត ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ ERN 00423556 ធ. ៨។ ឯកសារ **D219/702.1.149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទា ទិត ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ ERN 00277277។

[397] ឯកសារ **D1.3.19.1** សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ERN 00003136។ ឯកសារ **D6.1.94** កំណត់ហេតុនៃស្តួរចម្លើយ ជនត្រូវចោទ ឌុច ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ERN 00242926។ ឯកសារ **D6.1.736** កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00403907-00403908។ ឯកសារ **D6.1.871** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច" ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00377790 បន្ទាត់ ២។ ឯកសារ **D118/103.3** សារណាស្តាពរជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404797។ ឯកសារ **D6.1.863** ប្រតិចារឹក នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ឌុច - ការប្រជុំរៀបចំសវនាការ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ [កាំង ហ្គេកអ៊ាវ ហៅឌុច] ERN 00328660 បន្ទាត់ ១០-២១។ ឯកសារ **D6.1.1056** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ឌុច ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៨ ERN 00178025-

ក្នុងករណីខ្លះ ឌុច បានបញ្ជាក់ថា អនុលេខាភូមិភាគក៏ប្រើអំណាចសម្រេចឱ្យចាប់ ឬ *"កម្ទេច"* ផងដែរ[399]។ លើសពីនេះទៀត ការសម្រេចទាក់ទងនឹងការចាប់បក្ខជន និងកម្មាភិបាលថ្នាក់មធ្យមខ្លះ ត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍នៃភូមិភាគនីមួយៗ[400]។ ដូច្នេះ សមាជិក

---

00178026។ ឯកសារ **D1.3.29.5** កំណត់ហេតុនៃការស្តាប់ចម្លើយ ជនត្រូវចោទ ឌុច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ ERN 0019887483។ ឯកសារ **D179/1.2.12** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00794528 បន្ទាត់ ១៤-១៦, បន្ទាត់ ១៨-២៥។ ឯកសារ **D6.1.873** ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០១ "ឌុច" [កាំង ហ្គេកអ៊ាវ ហៅឌុច] ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00406932 បន្ទាត់ ៥-១៥។ ឯកសារ **D6.1.636** កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ERN 00398199-00398200។

[398] ឯកសារ **D6.1.796** កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៩ ERN 00410186។ ឯកសារ **D219/702.1.40** លិខិតគោរពជូនអង្គការជាទីស្នេហា និងទីករលើក ជាភាសាខ្មែរ ដោយប៉ាល់ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៨ ERN 00406602។ ឯកសារ **D118/103.3** សារណាស្តាពរផាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404791-00404792។

[399] ឯកសារ **D6.1.862** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច" ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00327860 បន្ទាត់ ១៨-១៩, ERN 00327860 បន្ទាត់ ២៥ ដល់ 00327861 បន្ទាត់ ១-៥។ ឯកសារ **D179/1.2.19** ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00799648 បន្ទាត់ ១០-១៥។ ឯកសារ **D118/103.3** សារណាស្តាពរផាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404793-00404794។ *សូមមើលផងដែរ* ឯកសារ **D6.1.873** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច" [កាំង ហ្គេកអ៊ាវ ហៅឌុច] ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00406931 បន្ទាត់ ៤-៥ (*"ប្រធានមន្ទីរនគរបាលគ្មានសិទ្ធិសម្រេចចាប់មនុស្សទេ បក្សជាអ្នកសម្រេច។ បញ្ជាក់ដែលខ្ញុំហៅថា បក្សនៅពេលនោះ គឺសំដៅលេខា និងអនុលេខាភូមិភាគ។"*)។ ឯកសារ **D6.1.1063** កំណត់ហេតុនៃការស្តាប់ចម្លើយជនត្រូវចោទ ឌុច ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ ERN 00187667 (*"ពាក្យកម្ទេច" សំដៅ ការចាប់ ការឃុំខ្លួន (ដើម្បីសួរចម្លើយ) និងចុងបញ្ចប់សម្លាប់។"*)។ ឯកសារ **D1.3.29.3** កំណត់ហេតុនៃការស្តាប់ចម្លើយជនត្រូវចោទ ឌុច ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ ERN 00158841 (*"ពាក្យថា "ដោះស្រាយ" និង "កម្ទេច" មានន័យដូចគ្នាគឺ "សម្លាប់" គឺយកជនរងគ្រោះទៅសម្លាប់ ប៉ុន្តែពាក្យ "ដោះស្រាយ" ត្រូវបានគេប្រើនាសម័យ វ៉ន វេត ហើយសម័យ សុន សេន គេប្រើពាក្យ "កំទេច"... ប៉ុន្តែក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥... ខ្មែរក្រហមប្រើពាក្យ "សំរិតសំរាំង" ដែលពាក្យនេះមានន័យថា ចាប់ជនរងគ្រោះជាឈុត (ចំនួនច្រើន)"*)។

[400] ឯកសារ **D6.1.1056** កំណត់ហេតុនៃការស្តាប់ចម្លើយជនត្រូវចោទ ឌុច ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៨ ERN 00178025-00178026។

គណៈមជ្ឈិមនៃគណៈអចិន្ត្រៃយ៍មានសិទ្ធិអំណាចខ្លាំងលើការសម្រេចដែលទាក់ទងនឹងការចាប់ និងសម្លាប់ នៅភូមិភាគកណ្តាល។

១៨៩. តំបន់ជាថ្នាក់រដ្ឋបាលនៅក្រោមភូមិភាគ[401]។ គណៈតំបន់ជា *"អង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុត"* សម្រាប់តំបន់ និងថ្នាក់រដ្ឋបាលក្រោមបង្គាប់[402]។ យោងតាមលក្ខន្តិកៈ ប.ក.ក គណៈតំបន់ទទួលខុសត្រូវកាន់កាប់ទ្រព្យសម្បត្តិរបស់តំបន់ គ្រប់គ្រងវិន័យក្នុងតំបន់ និងមានប្រព័ន្ធរាយការណ៍ជូនថ្នាក់លើអំពីស្ថានការណ៍ និងការងារនៅក្នុងតំបន់[403]។ គណៈតំបន់ក៏ទទួល

[401] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053025 មាត្រា ៧(២)-(៣), 00053030 មាត្រា ១៥(៣), 00053031 មាត្រា ១៦(៤)។

[402] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ ១៩៧៦ ERN 00053025 មាត្រា ៧(៣), 00053028 មាត្រា ១២(៣), 00053030 មាត្រា ១៦(១)។

[403] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053030 មាត្រា ១៦។ *សម្រាប់ការពន្យល់បន្ថែមនៃប្រព័ន្ធរាយការណ៍ សូមមើលផងដែរ* ឯកសារ **D6.1.1073** ចម្លើយតបរបស់ ឌុច ទៅនឹង ១៣សំណួរជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ ERN 00234072។ ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប អ៊ីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008704 ឆ.៤៤។ ឯកសារ **D118/249** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សុខ ឯម ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៤ ERN 00990859 ឆ.៩។ ឯកសារ **D6.1.652** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ERN 00373469-00373470។ ឯកសារ **D118/152** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុក ទូច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00968027 ឆ.៨៤។ ឯកសារ **D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ហៅ តាអាន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095245-01095247 ឆ.៦៩-ឆ.៧៤។ ឯកសារ **D219/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040093-01040094 ឆ.៣។ ឯកសារ **D118/149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហម សោម ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00967988 ឆ.៥៣។ ឯកសារ **D219/117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប សឹង ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046467 ឆ.៧២។ ឯកសារ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ រ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01075658-01075659 ឆ.១៤។ ឯកសារ **D119/136** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ERN 01003844 ឆ.១៩-ឆ.២០។ ឯកសារ **D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉ុំ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ERN 00979404 ឆ.៤២។ ឯកសារ **D219/762** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សារ៉ាយ ហៀន ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ERN 01242622 ឆ.១៦។

ខុសត្រូវផងដែរលើការគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវសហជីព សហករណ៍ សាខា និងកងទ័ពបដិវត្តន៍កម្ពុជាក្នុងក្របខ័ណ្ឌតំបន់[404]។ គណៈតំបន់មានភារកិច្ចតាមផ្លូវច្បាប់ក្នុងការផ្សព្វផ្សាយ និងអនុវត្តផែនការការងាររបស់គណៈភូមិភាគកណ្ដាល នៅទូទាំងតំបន់ តាមរយៈការណែនាំ *"ជាប្រចាំ និងជាប់ជានិច្ច"* នូវគោលជំហរនយោបាយ និងសតិអារម្មណ៍របស់ថ្នាក់ក្រោម និងប្រជាជន[405]។

១៩០. គណៈតំបន់ត្រូវទទួលរបាយការណ៍ស្ដីពីស្ថានការណ៍ និងការងាររបស់ស្រុក[406]។ គណៈតំបន់ក៏ត្រូវរៀបចំសន្និបាតតំបន់ រៀងរាល់ប្រាំមួយខែម្ដង[407] និងកិច្ចប្រជុំសាមញ្ញប្រចាំខែ[408]។

---

[404] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053030 មាត្រា ១៦(១)-(២), 00053031 មាត្រា ១៦(៣)។

[405] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053030 មាត្រា ១៦(២)។ *ទូទាំងបក្សកុម្មុយនីស្តកម្ពុជា លេខាតំបន់ទទួលខុសត្រូវផ្សព្វផ្សាយ និងអនុវត្តផែនការពីគណៈភូមិភាគរបស់ពួកគេ សូមមើលឧទាហរណ៍* ឯកសារ **D6.1.652** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ERN 00373470-00373471។ ឯកសារ **D118/96** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ERN 00947292 ឆ.៣២-ឆ.៣៣។ ឯកសារ **D118/245** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ERN 00990645 **ឆ.១៦-ឆ.១៧**។ ឯកសារ **D118/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ERN 00945430 ឆ.២៨។ ឯកសារ **D219/117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប សឹង ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046469 **ឆ.៩៨**។ ឯកសារ ឯកសារ **D118/149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាម សោម ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ERN 00967985 ឆ.២១-ឆ.២៣។ ឯកសារ **D6.1.786** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ឌុច (២) ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៧ ERN 00163532។ ឯកសារ **D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ERN 00368608-00368609។

[406] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053029 មាត្រា ១៣(៤)។ *សូមមើលឧទាហរណ៍* ឯកសារ **D6.1.653** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ERN 00373475។ ឯកសារ **D6.1.1200** សេចក្ដីរាយការណ៍ជូនបក្សអំពីចម្លើយអ្នកទោស ពីមន្ទីរអប់រំស្រុក១០៥ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៧ ERN 00082724-00082728។ ឯកសារ **D6.1.229** សេចក្ដីរាយការណ៍ជូនបក្សអំពីអ្នកទោស ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦ ERN 00271030-00271031។

១៩១. លេខាតំបន់មានសិទ្ធិអំណាចតាមផ្លូវច្បាប់លើកម្មាភិបាលថ្នាក់ស្រុក និងឃុំ ក្នុងតំបន់របស់ខ្លួន រួមទាំងការតែងតាំងសមាជិកគណៈតំបន់ និងស្រុក ដោយមានការយល់ព្រមពីលេខាភូមិភាគ និងគណៈអចិន្ត្រៃយ៍[409]។ លេខាតំបន់ ក្រោមឱវាទ ប.ក.ក ក៏អាចតែងតាំង និងដកកម្មាភិបាល ផ្សេងទៀត នៅថ្នាក់តំបន់ ស្រុក និងឃុំ[410]។ លេខាតំបន់ក៏ទទួលខុសត្រូវក្នុងការអនុម័ត និងអនុញ្ញាតឱ្យលេខាស្រុកតែងតាំង និងដកកម្មាភិបាល នៅថ្នាក់ស្រុក និងឃុំ[411]។

---

[407] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ ១៩៧៦ ERN 00053030 មាត្រា ១៥។

[408] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053031 មាត្រា ១៧។

[409] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053030 មាត្រា ១៥(៣)។ ឯកសារ **D6.1.863** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តី ឌុច - ការប្រជុំរៀបចំសវនាការ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២00៩ [ក្រេក អេធេសាន់] ERN 00328701 បន្ទាត់ ៤-៦, បន្ទាត់ ១២-១៤។ ឯកសារ **D6.1.533** របាយការណ៍អ្នកជំនាញ ក្រេក អេធេសាន់ អ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២00៧ ERN 00314801-00314803។

[410] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053028 មាត្រា ១២(៣)។ ឯកសារ **D6.1.863** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តី ឌុច - ការប្រជុំរៀបចំសវនាការ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២00៩ [ក្រេក អេធេសាន់] ERN 00328701 បន្ទាត់ ១២-១៤; *ឧទាហរណ៍នៃការតែងតាំងលេខាតំបន់ (ឬដក) តំណែងថ្នាក់តំបន់៖* **D119/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ERN 00895159 **ឆ.៦**។ ឯកសារ **D118/274** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ ERN 00999990 **ឆ.២១**។ ឯកសារ **D118/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម ផល ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ERN 00891160 **ឆ.១១**។ ឯកសារ **D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ERN 00997028 **ឆ.៤៤**។ *ឧទាហរណ៍លេខាតំបន់តែងតាំង (ឬដក) តួនាទីគណៈស្រុកនិងឃុំ៖* ឯកសារ **D118/242** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ឿន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ERN 00998732 **ឆ.៧០**, 00998760 **ឆ.២៧៥**។ ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ERN 00953027 **ឆ.៦៣**។ ឯកសារ **D6.1.988** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ ណាន់ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ ERN 00498372 **ឆ.១៩-ឆ.២០**។ ឯកសារ **D134/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ ណាន់ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៣ ERN 00947322 **ឆ.៨**។ ឯកសារ **D6.1.985** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ វេន ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ERN 00492979-00492979 **ឆ.១**, **ឆ.២**។ ឯកសារ **D219/702.1.142** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន

១៩២. យោងតាមលក្ខន្តិកៈ ប.ក.ក គណៈតំបន់ក៏ទទួលខុសត្រូវផងដែរក្នុងការគ្រប់គ្រង និងអនុវត្តភារកិច្ចដែលកងទ័ពបដិវត្តន៍កម្ពុជាបានបំពេញ[412]។ ដូច្នេះ នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ តំបន់នីមួយៗមានអង្គភាពយោធាមួយដែលរាយការណ៍ផ្ទាល់ទៅលេខាតំបន់[413]។

១៩៣. ស្របតាមគោលការណ៍គ្រឹះរបស់ ប.ក.ក ស្ដីពី *"ការប្រយ័ត្នចំពោះសកម្មភាពខ្មាំងទាំងអស់"* លេខាតំបន់ក៏ទទួលខុសត្រូវផងដែរក្នុងការណែនាំដល់ថ្នាក់ក្រោម និងប្រជាជន ឲ្យតាមរកខ្មាំង

---

ផ្លឹងចូយ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨ ERN 00197861-00197862។ ឯកសារ **D179/1.2.23** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២ [សៅ សារុន] ERN 00813310 បន្ទាត់ ២៣-២៥។ ឯកសារ **D6.1.141** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ សារុន (១) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ERN 00251438-00251439។ *ឧទាហរណ៍នៃការតែងតាំងលេខាតំបន់ (ឬការមក) សមាជិកគណៈឃុំ និងភូមិ៖* ឯកសារ **D118/77** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណាង នី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ERN 00934388 ឆ.២៣។ ឯកសារ **D118/87** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព សឿន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ERN 00945430 ឆ.២៨។ ឯកសារ **D119/156** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង ឿន ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤ ERN 01024774។

[411] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្ដកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053028 មាត្រា ១២(៣)។ ឯកសារ **D6.1.533** របាយការណ៍អ្នកជំនាញ ក្រេក អេធេសាន់ អ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ERN 000314812-00314813។

[412] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្ដកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053030 មាត្រា ១៦(១)។

[413] ឯកសារ **D118/259** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ERN 00997038 ឆ.១១២។ ឯកសារ **D219/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ហៅ តាអាន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ERN 01095263 ឆ.១៨២, 01095264 ឆ.១៩០-១៩១។ ឯកសារ **D219/263** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆាំ លុយ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ ERN 01086091 ឆ.៣។ ឯកសារ **D118/244** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផរ ប៉ែត ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ERN 00990637-00990638 ឆ.៥-ឆ.៦។ ឯកសារ **D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008705 ឆ.៥០។

ដើម្បីកសាង ឬ *"កម្ទេច"* [414]។ នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ លេខាតំបន់មានសិទ្ធិបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់បុគ្គលជាក់លាក់ ហើយក្នុងករណីខ្លះទៀត បញ្ជាឱ្យដោះលែងនៅក្នុងតំបន់រៀងៗខ្លួន[415]។

១៥៤. លើសពីនេះទៀត មន្ទីរសន្តិសុខតំបន់ស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់របស់លេខាតំបន់[416]។

---

[414] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053009-00053010, "លក្ខការណ៍ និងគោលជំហរនយោបាយជាមូលដ្ឋានរបស់បក្ស", 00053021 មាត្រា ៥(៣), 00053023 មាត្រា ៥(៩)។ ឯកសារ **D6.1.740** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស តុលា-វិច្ឆិកា ១៩៧៧ ERN 00064759-000647760។ ឯកសារ **D1.3.22.5** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស ធ្នូ ១៩៧៨-មករា ១៩៧៨ (ពេញ) ERN 00064537-00064538; *ទូទាំងបក្សកុម្មុយនីស្តកម្ពុជា លេខាតំបន់បានណែនាំថ្នាក់ក្រោមឱ្យត្រួតពិនិត្យនិងតាមដានខ្មាំងក្នុងជួរ សូមមើលឧទាហរណ៍* ឯកសារ **D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ឥម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ERN 01008706 ឆ.៥៦។ ឯកសារ **D219/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01040094 ឆ.៥។ ឯកសារ **D219/117** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប សឹង ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ERN 01046469 ឆ.១០០, 01046472 ឆ.១២៥, 01046475 ឆ.១៤៧។ ឯកសារ **D118/96** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ERN 00947292 ឆ.៣៥។ ឯកសារ **D118/77** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ERN 00934389 ឆ.៣០។ ឯកសារ **D118/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទីម ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ ERN 00951929 ឆ.២២។ ឯកសារ **D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ERN 00368610-00368612។

[415] ឯកសារ **D6.1.1063** កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ឌុច ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ ERN 00187650។ ឯកសារ **D6.1.653** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ERN 00373475។ ឯកសារ **D6.1.695** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន់ នេន ERN 00414444-00414445 ឆ.១៩-ឆ.២៣។ ឯកសារ **D6.1.1200** សេចក្តីរាយការណ៍ជូនបក្ស អំពីចម្លើយអ្នកទោស ពីមន្ទីរអប់រំស្រុក១០៥ ERN 00082724-00082725។ ឯកសារ **D6.1.229** សេចក្តីរាយការណ៍ជូនបក្ស អំពីអ្នកទោស ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦ ERN 00271030។

[416] ឯកសារ **D118/103.3** សារណាស្តាពរជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00404707-00404808។ ឯកសារ **D6.1.652** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ERN 00373466-00373467។

## ៦.២. ការរកឃើញខាងអង្គហេតុ និងសហឧក្រិដ្ឋកម្មរួម

១៥៥. ប្រហែលជាចាប់ពីចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ និងយ៉ាងហោចណាស់ រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ កែ ពក **អោ អាន** និងកម្មាភិបាល ប.ក.ក ដទៃទៀត បានដឹងអំពីគោលបំណងរួមនៃការអនុវត្តគោលនយោបាយ ប.ក.ក ដូចខាងក្រោម នៅភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ៖

ក. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន

ខ. ការកសាង "សមាសភាពមិនល្អ" និងការសម្លាប់ខ្មាំង ទាំងក្នុង និងក្រៅជួរ ប.ក.ក

គ. ការកំណត់គោលដៅលើក្រុមជាក់លាក់ រួមទាំងកម្មាភិបាល ប.ក.ក នៅភូមិភាគកណ្តាល អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ *"ប្រជាជន ១៧ មេសា"* ប្រជាជនមកពីភូមិភាគបូព៌ា ជនជាតិចាម និងក្រុមគ្រួសារ

ឃ. ការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ តាមរយៈការបង្ខំឱ្យប្រជាជនភូមិភាគកណ្តាលរៀបការ។

### ៦.២.១. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន

១៥៦. ប.ក.ក ចង់ផ្លាស់ប្តូរប្រទេសកម្ពុជា ពីសេដ្ឋកិច្ចទីផ្សារ ទៅជារដ្ឋសង្គមនិយមខ្លួនទីពឹងខ្លួន ផ្អែកលើសេដ្ឋកិច្ចកសិកម្ម[417]។ គោលដៅនេះត្រូវសម្រេច តាមរយៈវិធានការមួយចំនួន រួមទាំង

[417] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ចុះខែមករា ឆ្នាំ១៩៧៦ ERN 00053009-00053012។ ឯកសារ **D1.3.20.2** ឯកសាររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦ ERN 00089844។ ឯកសារ **D6.1.746** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស តុលា-វិច្ឆិកា ១៩៧៥ (ពេញ) ERN 00063245-00063246។ ឯកសារ **D1.3.22.1** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ១០ តុលា ១៩៧៥ (ពេញ) ERN 00063399-00063400។ ឯកសារ **D6.1.532** ខៀវ សំផន "ពិចារណាអំពីប្រវត្តិសាស្ត្រពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ" ភាហ៊ុ ខែតុលា ឆ្នាំ២០០៧ ERN (ERN) 00498303។ **ឯកសារ D6.1.1139** អង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១ របស់សភាតំណាងប្រជាជនកម្ពុជា ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ERN 00053626-00053627។ **ឯកសារ D6.1.774** បទឧទ្ទេសនាមរបស់សមមិត្តលេខាក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦ ERN 00072753-00072754។

01588433



ការបង្កើតសហករណ៍ និងការដ្ឋាន នៅទូទាំងប្រទេសកម្ពុជា និងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដើម្បីឱ្យពួកគេទៅធ្វើការនៅតាមទីតាំងទាំងនោះ[418]។

១៩៧. ក្នុងគោលដៅនេះ ប.ក.ក បានតាក់តែង និងដាក់ឱ្យអនុវត្តគោលនយោបាយជាបន្តបន្ទាប់ តាំងពីមុនពេលបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ។ ចាប់ផ្ដើមពីខែ ឧសភា ឆ្នាំ ១៩៧២ ប.ក.ក បានបង្កើតសហករណ៍ និងការដ្ឋាន នៅក្នុងដែនដីក្រោមការត្រួតត្រារបស់ ប.ក.ក[419]។ ក្រោយការបង្កើតកម្ពុជាប្រជាធិបតេយ្យ ការដ្ឋាន និងសហករណ៍ ត្រូវបានបង្កើត និងពង្រីក នៅទូទាំងប្រទេសកម្ពុជា[420]។

១៩៨. ការផ្លាស់ប្ដូរទីលំនៅដោយបង្ខំ និងការប្រមូលកម្លាំងពលកម្មឱ្យទៅធ្វើការនៅតាមការដ្ឋាន និងសហករណ៍ មានគោលបំណងសម្រេចទិសដៅជាច្រើនរបស់ ប.ក.ក រួមទាំងការផ្លាស់ប្ដូរឱ្យបានឆាប់រហ័សពីប្រព័ន្ធកសិកម្មអន់ថយរបស់កម្ពុជាទៅជាប្រព័ន្ធកសិកម្មទំនើប

---

[418] ឯកសារ **D1.3.22.1** ទស្សនាវដ្ដីបក្សកុម្មុយនីស្ដកម្ពុជា មានចំណងជើង "យុវជន យុវនារីបដិវត្ត" លេខ ១០ តុលា ១៩៧៥ (ពេញ) ERN 00063399-00063402។ ឯកសារ **D322/8.1.13** យុវជន យុវនារីបដិវត្ត លេខ ១២ ធ្នូ ១៩៧៥ ERN 00063717-00063718។ ឯកសារ **D322/8.1.11** ទស្សនាវដ្ដីបក្សកុម្មុយនីស្ដកម្ពុជា មានចំណងជើង "យុវជន យុវនារីបដិវត្ត" លេខ ៨ សីហា ១៩៧៥ ERN 00399132-00399135។

[419] ឯកសារ **D179/1.2.8** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00791938 បន្ទាត់ ១៦-១៧, 00791969 បន្ទាត់ ៧-១០។ ឯកសារ **D117/36.1.21** ខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ERN 00442208-00442209។ ឯកសារ **D6.1.745** ទស្សនាវដ្ដីបក្សកុម្មុយនីស្ដកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៩ កញ្ញា ១៩៧៨ (ពេញ) ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៧៨ ERN 00064606-00064607។

[420] ឯកសារ **D179/1.2.8** ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ [កាំង ហ្គេកអ៊ាវ ហៅ ឌុច] ERN 00791938 បន្ទាត់ ២១-២៣។ ឯកសារ **D6.1.755** ទស្សនាវដ្ដីបក្សកុម្មុយនីស្ដកម្ពុជា មានចំណងជើង "យុវជន យុវនារីបដិវត្ត" លេខពិសេស ធ្នូ-មករា ១៩៧៦-៧៧ (ពេញ) ERN 00063039-00063042។ ឯកសារ **D1.3.22.1** ទស្សនាវដ្ដីបក្សកុម្មុយនីស្ដកម្ពុជា មានចំណងជើង "យុវជន យុវនារីបដិវត្ត" លេខ ១០ តុលា ១៩៧៥ (ពេញ) ERN 00063399-00063400។ **ឯកសារ D6.1.737** ទស្សនាវដ្ដីបក្សកុម្មុយនីស្ដកម្ពុជា ចំណងជើង "ទង់បដិវត្ត" លេខ ៨ សីហា ១៩៧៥ (ពេញ) ERN 00063347-00063348។

ក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ[421] ដើម្បីទ្រទ្រង់ប្រជាជន ២០ លាននាក់ តាមការគ្រោងទុក[422]។ ករណីនេះរួមបញ្ចូលទាំងគោលដៅប្រចាំឆ្នាំក្នុងការបង្កបង្កើនផលស្រូវឲ្យបានពី ៣ ទៅ ៧ តោនក្នុងមួយហិកតា ដើម្បីចិញ្ចឹមប្រជាជន និងឈានទៅសម្រេចបាននូវស្វ័យឧបត្ថម្ភ[423]។ លើសពីនេះទៅទៀត ប.ក.ក បានចាប់ផ្តើមគម្រោងសាងសង់ហេដ្ឋារចនា

---

[421] ឯកសារ **D6.1.746** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស តុលា-វិច្ឆិកា ១៩៧៥ (ពេញ) ERN 00063245-00063246។ ឯកសារ **D1.3.22.1** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "យុវជនយុវនារីបដិវត្ត" លេខ ១០ តុលា ១៩៧៥ (ពេញ) ERN 00063399-00063402។ ឯកសារ **D6.1.752** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៨ សីហា ១៩៧៦ (ពេញ) ERN 00063277-00063279, 00063297-00063298។ ឯកសារ **D6.1.745** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា ចំណងជើង "ទង់បដិវត្ត" លេខ ៩ កញ្ញា ១៩៧៨ (ពេញ) ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៧៨ ERN 00064611-00064612, 00064613-00064614, 00064614-00064615។ ឯកសារ **D6.1.1257** សេចក្តីថ្លែងការណ៍របស់ជនសង្ស័យ អៀង សារី ហៅ វ៉ាន់ មានចំណងជើង "អគ្គលេខាធិការអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៣២ ប្រជុំពេញអង្គថ្ងៃទី២៨ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ ERN 00291026-00291027។ ឯកសារ **D6.1.837** ឯកសារបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេស គ្រប់ផ្នែក ( ឯកសារទី៣) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ ERN 00072367-00072368។

[422] ឯកសារ **D6.1.1257** សេចក្តីថ្លែងការណ៍របស់ជនសង្ស័យ អៀង សារី ហៅ វ៉ាន់ មានចំណងជើង "អគ្គលេខាធិការអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៣២ ប្រជុំពេញអង្គថ្ងៃទី២៨ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ ERN (EN) 00079815។ ឯកសារ **D6.1.816** *កម្រងនៃការផ្សព្វផ្សាយព័ត៌មានទៅបរទេស របាយការណ៍សម្រាប់ខែតុលា ឆ្នាំ១៩៧៧,* ខែតុលា ឆ្នាំ១៩៧៧ ERN (EN) 00168651, 00168718។

[423] ឯកសារ **D6.1.746** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស តុលា-វិច្ឆិកា ១៩៧៥ (ពេញ) ERN 00063252-00063253, 00063254-00063255។ ឯកសារ **D6.1.752** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៨ សីហា ១៩៧៦ (ពេញ) ERN 00063283-00063284។ ឯកសារ **D6.1.745** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៩ កញ្ញា ១៩៧៨ (ពេញ) ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៧៨ ERN 00064611-00064612។ ឯកសារ **D6.1.837** ឯកសារបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេស គ្រប់ផ្នែក ( ឯកសារទី៣) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ ERN 00072397-00072398។ ឯកសារ **D6.1.1145** កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី២ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ ERN 00000793-00000794។ ឯកសារ **D6.1.740** ទស្សនាវដ្ដីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត លេខពិសេស តុលា-វិច្ឆិកា ១៩៧៧" ERN 00064765-00064766។ ឯកសារ **D117/52**

សម្ព័ន្ធទូទាំងប្រទេស រួមទាំងការពង្រីកសហករណ៍[424] ការសាងសង់ប្រព័ន្ធស្រោចស្រព ទំនប់[425] ផ្លូវ ផ្លូវដែក ស្ពាន កំពង់ផែអាកាសយានដ្ឋាន[426] និងការទាញយកធនធានរ៉ែ[427]។ យន្តការជានិមិត្តរូប និងជាក់ស្តែងនៃគោលនយោបាយនេះ គឺការបង្កើតកងចល័តដែលមាន

---

កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុំ រ៉ែស ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ERN 00990835 ឆ.២៣។

[424] ឯកសារ **D6.1.737** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៨ សីហា ១៩៧៥ (ពេញ) ERN 00063347-00063348។ ឯកសារ **D6.1.745** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៩ កញ្ញា ១៩៧៨ (ពេញ) ERN 00064603-00064604, 00064611-00064613។

[425] ឯកសារ **D6.1.746** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស តុលា-វិច្ឆិកា ១៩៧៥ (ពេញ) ERN 00063241-00063242។ ឯកសារ **D6.1.745** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៩ កញ្ញា ១៩៧៨ (ពេញ) ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៧៨ ERN 00064610-00064611។ ឯកសារ **D6.1.536** កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ ERN 00143495-00143496, 00143496-00143497។ ឯកសារ **D6.1.1257** សេចក្តីថ្លែងការណ៍របស់ជនសង្ស័យ អៀង សារី ហៅ វ៉ាន់ មានចំណងជើង "អគ្គលេខាធិការអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៣២ ប្រជុំពេញអង្គថ្ងៃទី២៨ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ ERN 00291026-00291027។ ឯកសារ **D6.1.837** ឯកសារបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេស គ្រប់ផ្នែក ( ឯកសារទី៣) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ ERN 00072371-00072373។ ឯកសារ **D322/8.1.13** យុវជន យុវនារីបដិវត្ត លេខ ១២ ធ្នូ ១៩៧៥ ERN 00063721-00063723។ ឯកសារ **D1.3.30.2** ទូរលេខ ០៤ ពី កែ ពក លេខាភូមិភាគកណ្តាល សូមគោរពជូនបង ប៉ុល ជាទីគោរព ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ EN 00000766។

[426] ឯកសារ **D322/8.1.13** យុវជន យុវនារីបដិវត្ត លេខ ១២ ធ្នូ ១៩៧៥ ERN 00063721-00063723, 00063749-00063750។ ឯកសារ **D1.3.24.2** កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍" ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ERN 00019118, 00019125-00019126។

[427] ឯកសារ **D215/1.1.5** D61152 ទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង កម្ពុជា មិថុនា ១៩៧៦ ERN 01000785-01000787។ ឯកសារ **D6.1.745** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៩ កញ្ញា ១៩៧៨ (ពេញ) ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៧៨ ERN 00064612-00064613។ ឯកសារ **D215/1.1.10** D61157 ទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង កម្ពុជា ចេញផ្សាយលេខ ២៤ មករា ១៩៧៨ ERN 01000948-01000949។ ឯកសារ **D215/1.1.3** D61150 ទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង កម្ពុជា ចេញផ្សាយលេខ ៣ មីនា ១៩៧៦ ERN (EN) 01149042។ ឯកសារ **D322/8.1.13** យុវជន យុវនារីបដិវត្ត លេខ ១២ ធ្នូ ១៩៧៥ ERN 00063723។ ឯកសារ **D322/8.1.23** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស មេសា ១៩៧៧ (ពេញ) ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ ERN 00062978-00062989។

01588436



កម្មករវហូតដល់រាប់ពាន់នាក់ ដែលត្រូវគេដាក់ពង្រាយនៅតាមការដ្ឋាន និងសហករណ៍ ឱ្យធ្វើស្រែ និងកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ស្របតាមផែនការរបស់ ប.ក.ក[428]។

១៩៩. ការបង្កើតសហករណ៍ និងការដ្ឋាន ក៏អនុញ្ញាតឱ្យ ប.ក.ក តាមដាន និងគ្រប់គ្រងចលនា និងជីវិតប្រចាំថ្ងៃរបស់ប្រជាជនឱ្យកាន់តែប្រសើរ[429] និងបំពាក់បំប៉នមនោគមន៍វិជ្ជារបស់ ប.ក.ក ដល់ប្រជាជន[430]។ សហករណ៍ក៏ជួយសម្រួលដល់គោលបំណងរបស់ ប.ក.ក ក្នុងការ

---

[428] ឯកសារ **D1.3.22.1** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "យុវជន យុវនារីបដិវត្ត" លេខ ១០ តុលា ១៩៧៥ (ពេញ) ERN 00063428-00063429។ ឯកសារ **D6.1.752** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៨ សីហា ១៩៧៦ (ពេញ) ERN 00063277-00063278។ ឯកសារ **D6.1.745** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៩ កញ្ញា ១៩៧៨ (ពេញ) ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៧៨ ERN 00064613-00064614។ ឯកសារ **D6.1.837** ឯកសារបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយ ស្ដារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេស គ្រប់ផ្នែក ( ឯកសារទី៣) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ ERN 00072380-00072383, 00072395-00072397។ ឯកសារ **D6.1.755** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស ធ្នូ-មករា ១៩៧៦-៧៧ (ពេញ) ERN 00063007-00063009។ ឯកសារ **D322/8.1.23** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស មេសា ១៩៧៧ (ពេញ) ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ ERN 00062978-00062989។ ឯកសារ **D322/8.1.35** យុវជន យុវនារីបដិវត្ត លេខ ១១ វិច្ឆិកា ១៩៧៨ ERN 00376514-00376515។

[429] ឯកសារ **D1.3.24.1** កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥ ERN 00008485-00008486, 00008487-00008490, 00008492-00008493។ ឯកសារ **D6.1.1127** អំពីការក្ដាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស ( ឯកសារទី៦) ២២ កញ្ញា ១៩៧៥ ERN 00072403-00072405។ ឯកសារ **D219/370.1.14** គោរពជូនអង្គការពី ម៤០១ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ ERN 00143578។ ឯកសារ **D6.1.743** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខ ៧ កក្កដា ១៩៧៨ (ពេញ) ERN 00064487-00064489, 00064497, 00064499-00064500។ ឯកសារ **D6.1.1267** ទូរលេខ ២៥៤៖ គោរពជូនគណៈ ៨៧០ ជាទីស្នេហា អំពីសភាពការណ៍ខ្មាំងនៅតាមព្រំដែន ព្រះវិហារ និងឧត្តរមានជ័យ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ ERN 00001060-00001061។

[430] ឯកសារ **D6.1.746** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "ទង់បដិវត្ត" លេខពិសេស តុលា-វិច្ឆិកា ១៩៧៥ (ពេញ) ERN 00063248-00063250, 00063264-00063265។ ឯកសារ **D1.3.22.1** ទស្សនាវដ្តីបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើង "យុវជន យុវនារីបដិវត្ត" លេខ ១០ តុលា ១៩៧៥ (ពេញ) ERN 00063402-00063403, 00063427-00063428។ ឯកសារ **D6.1.1127** អំពីការក្ដាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិប

សម្រេចបាននូវសង្គមគ្មានវណ្ណៈ ដែលក្នុងនោះ មនុស្សគ្រប់គ្នាធ្វើការជាសមូហភាព[431] ដោយគ្មានប្រាក់កម្រៃ[432]។

២០០. ទន្ទឹមនឹងនេះ ប.ក.ក ចង់គ្រប់គ្រងទាំងស្រុងលើសេដ្ឋកិច្ច តាមរយៈការវាយកម្ទេច និងលុបបំបាត់ *"ពួកសក្តិភូមិ" "ម្ចាស់ដី"* និង *"នាយទុន"*[433] ដើម្បីអនុវត្ត *"បដិវត្តន៍ប្រជាធិបតេយ្យ*

---

[1763] ឯកសារ **D219/116** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពិន ពៅ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ ERN 01046450 ទំ.២៤។ ឯកសារ **D219/871** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពិន ពៅ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01352080 ទំ.៣៨។

ថា គាត់មិនអាចបែងចែកក្នុងចំណោមអ្នកទោសបានទេរវាងជនជាតិចាម និងជាតិដទៃទៀត[1764]។ ការអះអាងនេះមិនអាចទុកចិត្តបានទេ បើពិចារណាពីចេតនារបស់គាត់ក្នុងការបន្ថយការទទួលខុសត្រូវរបស់គាត់ និងភស្តុតាងផ្ទុយ ដែលអតីតអ្នកទោសម្នាក់បានបញ្ជាក់យ៉ាងច្បាស់ពីវត្តមានជនជាតិចាមក្នុងចំណោមជនរងគ្រោះ ខណៈដែល ពិន ពៅ គ្រប់គ្រងនៅទីនោះ។ លើសពីនេះទៀត ការទទួលស្គាល់ថា ជនជាតិចាមក្នុងចំនួនយ៉ាងច្រើនត្រូវបាននាំមកដាក់នៅមន្ទីរសន្តិសុខ និងត្រូវបានសម្លាប់ គឺមានលក្ខណៈផ្ទុយគ្នាផងដែរទៅនឹងការពណ៌នារបស់គាត់ ដែលចាត់ទុកអ្នកទោសថាជា *"ខោរវៀត និងខោរ"*[1765]។

៥៣0. ផ្ទុយមកវិញ ការពណ៌នារបស់អតីតអ្នកទោសម្នាក់ អំពីប្រជាជនចាមនៅមន្ទីរសន្តិសុខនោះ គឺមានលក្ខណៈយកជាសំអាង និងទុកចិត្ត ដោយសារគាត់គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកទោសតែពីរបីនាក់ដែលត្រូវបានអនុញ្ញាតឱ្យដើរចុះឡើងក្នុងបរិវេណមន្ទីរសន្តិសុខ ហើយដូច្នេះគឺស្ថិតនៅក្នុងទីតាំងមួយ ដែលអាចសង្កេតឃើញព្រឹត្តិការណ៍ទាំងឡាយនៅទីនោះ។ ភស្តុតាងជាទូទៅរបស់គាត់មានលក្ខណៈស៊ីចង្វាក់ទៅនឹងអ្វីដែលសាក្សីផ្សេងៗទៀតបានបញ្ជាក់ ហើយគាត់មិនមានហេតុផលណាច្បាស់លាស់ត្រូវនិយាយមិនស្មោះត្រង់នោះឡើយ។ គាត់បានពណ៌នាយ៉ាងច្បាស់លាស់អំពីលក្ខណៈដែលគាត់កំណត់ថា ជនរងគ្រោះគឺជាជនជាតិចាម ដោយសារប្រធានមន្ទីរសន្តិសុខប្រាប់គាត់អំពីជាតិពន្ធុរបស់អ្នកទាំងនោះ ហើយថែមទាំងបានឮជនជាតិចាមនិយាយភាសាចាមថែមទៀត។[1766] ភស្តុតាងដែលគាត់បានផ្តល់ឱ្យអំពីការសម្លាប់ជនជាតិចាមនៅទីតាំងនោះ ក៏មានលក្ខណៈស៊ីចង្វាក់ផងដែរទៅនឹងការប្រតិបត្តិការ ដែលបានលើកឡើងនៅក្នុងផ្នែក ៦.៤.២ ស្តីអំពីការប្រល័យពូជសាសន៍ទៅលើជនជាតិចាម ដែលបានលើកឡើងពីការដឹកជញ្ជូនជនជាតិចាមក្នុងចំនួនយ៉ាងច្រើន និងប្រជាជនដទៃទៀតមកពីភូមិភាគបូព៌ាទៅដាក់នៅកន្លែងផ្សេងនៅក្នុងខេត្តកំពង់ចាម ដើម្បីយកទៅសម្លាប់។ អាស្រ័យហេតុនេះ ការ

---

[1764] ឯកសារ D219/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន ពៅ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២0១៤ ERN 01046455 ឆ.៥៤។

[1765] ឯកសារ D219/871 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន ពៅ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២0១៦ ERN 01352079-01352080 ឆ.៣៣-ឆ.៣៤។

[1766] ឯកសារ D219/875 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី៣0 ខែវិច្ឆិកា ឆ្នាំ២0១៦ ERN 01355372-01355373 ឆ.៣៨-ឆ.៣៩។

ពណ៌នារបស់អតីតអ្នកទោសនេះពាក់ព័ន្ធទៅនឹងការសម្លាប់ជាទ្រង់ទ្រាយធំទៅលើជនជាតិចាមនៅវត្តបាធាយ គឺមានលក្ខណៈពិតយ៉ាងច្រើនជាងការអះអាងផ្ទុយរបស់ ពិន ពៅ។ ប៉ុន្តែទោះជា ពិន ពៅ មិនអាចចាត់ទុកថា ជឿជាក់បានពាក់ព័ន្ធនឹងប្រភេទជនរងគ្រោះ និងចំនួននៃការសម្លាប់មនុស្សនៅវត្តបាធាយ ខណៈដែលគាត់បានគ្រប់គ្រងនៅមន្ទីរសន្តិសុខនោះក៏ដោយ ភ័ស្តុតាងដែលគាត់បានផ្តល់ស្តីអំពីទិដ្ឋភាពផ្សេងៗនៃការប្រតិបត្តិការមន្ទីរសន្តិសុខ ត្រូវចាត់ទុកថា អាចទុកចិត្តបានជាទូទៅ ហើយជាពិសេសនៅពេលដែលមានភ័ស្តុតាងផ្សេងៗទៀតស៊ីចង្វាក់គ្នា។

៥៣១. យោងទៅតាមអតីតអ្នកទោសខ្លះ ការសម្លាប់មនុស្សនៅវត្តបាធាយ បានបញ្ឈប់នៅក្នុងពេលណាមួយក្នុងឆ្នាំ ១៩៧៨ ក្រោយពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រកាសនូវការលើកលែងទោស[1767] ហើយសាក្សីម្នាក់បានរៀបរាប់អំពីការផ្សាយវិទ្យុ អំពីចំណុចដូចគ្នានេះដែរនៅក្នុងចុងឆ្នាំ ១៩៧៨[1768]។ ទោះជាយ៉ាងណាក៏ដោយ គិតមកត្រឹមពេលនោះ មានតែអ្នកទោសពី៦ ទៅ៧នាក់ប៉ុណ្ណោះដែលនៅរស់នៅទីនោះ[1769]។ សាក្សីម្នាក់ទៀតបំភ្លឺថា ការសម្លាប់មនុស្សបន្តរហូតដល់ពេលអ្នកទោសត្រូវបានរំដោះដោយវៀតណាម[1770]។

[1767] ឯកសារ **D1.3.10.22** របាយការណ៍ "បេសកម្មរបស់ការិយាល័យសហព្រះរាជអាជ្ញាចុះទៅស្រុកបាធាយ ខេត្តកំពង់ចាម" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ERN 00800716 កថាខណ្ឌ ៣៧, *យោងតាមការបញ្ជាក់ដោយ* ឯកសារ **D3/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ រស់ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ERN 00619854-00619855 ឆ.១-ឆ.២។ ឯកសារ **D89** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា គី ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ERN 00743569-00743570។ ឯកសារ **D91** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆយ ឡឹង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ERN 00743576។

[1768] ឯកសារ **D219/80** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ ណាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01039230 ឆ.៣៣។

[1769] ឯកសារ **D1.3.10.22** របាយការណ៍ "បេសកម្មរបស់ការិយាល័យសហព្រះរាជអាជ្ញាចុះទៅស្រុកបាធាយ ខេត្តកំពង់ចាម" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ERN 00800716 កថាខណ្ឌ ៣៧, *យោងតាមការបញ្ជាក់ដោយ* ឯកសារ **D3/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ រស់ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ERN 00619854-00619855 ឆ.១-ឆ.២។

[1770] ឯកសារ **D97** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង រុន ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ ERN 00743599។

៥៣២. តួលេខច្បាស់លាស់នៃចំនួនមនុស្សស្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយមិនអាចកំណត់បានទេ ប៉ុន្តែសាក្សីទាំងឡាយសង្កេតឃើញនូវការស៊ីចង្វាក់គ្នាថា ជនរងគ្រោះមានចំនួនរាប់ពាន់នាក់[1771]។ ទោះបីជាផ្អែកទៅលើភ័ស្តុតាង ទំនងថា មន្ទីរសន្តិសុខនោះបានចាប់ផ្តើមតាំងពីមុនកម្ពុជាភិបាលនិរតីមកដល់ក៏ដោយ និងទំនងថា ចំនួនមនុស្សដែលត្រូវបានសម្លាប់មានលក្ខណៈតិចជាង បានកើតឡើងមុនកម្ពុជាភិបាលនិរតីមកដល់ក៏ដោយ មានលក្ខណៈច្បាស់លាស់ណាស់ថា ការសម្លាប់មនុស្សយ៉ាងច្រើនលើសលុបបានកើតឡើងក្រោយពេលកម្ពុជាភិបាលនិរតីមកដល់។ ហេតុការណ៍នេះ មានលក្ខណៈស៊ីចង្វាក់ទៅនឹងការសម្លាប់មនុស្សនៅទូទាំងតំបន់៤១។ ជាពិសេសប្រតិបត្តិការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ហើយប្រព្រឹតទៅរយៈពេលយូរបំផុតនៅមន្ទីរសន្តិសុខនោះ-ពោលគឺការបោសសម្អាតប្រជាជនមូលដ្ឋាន ដែលជាប់សង្ស័យឱ្យចេញពីតំបន់នោះ ហើយក្រោយមកការសម្លាប់ជាទ្រង់ទ្រាយធំទៅលើប្រជាជន ដែលមកពីភូមិភាគបូព៌ារួមមានទាំងជនជាតិចាម-សុទ្ធតែបានកើតឡើងនៅក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយកម្ពុជាភិបាលភូមិភាគនិរតី។

៥៣៣. ផ្អែកទៅលើការថ្លឹងថ្លែងដូចខាងលើនេះ ការប៉ាន់ស្មានតួលេខទាបបំផុតគឺមានចំនួន **៥០០០** ឬច្រើនជាងនេះ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយ គឺត្រូវបានសម្លាប់ក្រោយពីកម្ពុជាភិបាលនិរតីបានមកដល់ និងមុនពេលវៀតណាមមកដល់ក្នុងខែមករា ឆ្នាំ១៩៧៩។ ការប៉ាន់ស្មាននេះគឺផ្អែកទៅលើការបំភ្លឺរបស់សាក្សីដូចខាងក្រោម៖ អតីតអ្នកទោសម្នាក់ ដែលបានសង្កេត និងពណ៌នាឡើងវិញយ៉ាងពិស្តារអំពីការប្រតិបត្តិការរបស់មន្ទីរសន្តិសុខ បានប៉ាន់ស្មានថា នៅទីនោះមានប្រជាជនប្រហែល ១០០០០ ឬ១១០០០នាក់ត្រូវបានសម្លាប់[1772] ទោះបីជា

---

[1771] ឯកសារ **D219/80** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01039228 ឆ.២១, 01039232 ឆ.៤០។ ឯកសារ **D3/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ រស់ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ERN 00619857 ឆ.១២។ ឯកសារ **D91** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆយ ឡឹង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ERN 00743576។ ឯកសារ **D219/116** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន ពៅ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ ERN 01046451 ឆ.៣០។ ឯកសារ **D3/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជី សេងហួត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ERN 00619819 ឆ.៦។

[1772] ឯកសារ **D219/80** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01039228 ឆ.២១, 01039232 ឆ.៤០។

គាត់មិនបានបញ្ជាក់ច្បាស់ថាតើមនុស្សប៉ុន្មាននាក់ត្រូវបានសម្លាប់មុន ឬក្រោយកម្មាភិបាលនិរតីមកដល់ក៏ដោយ។ ដោយសារតែចំនួននៃការសម្លាប់មនុស្សបានកើនឡើងក្រោយកម្មាភិបាលនិរតីមកដល់ ការប៉ាន់ប្រមាណអាចកំណត់ដោយសមហេតុផលថា យ៉ាងហោចណាស់មានពាក់កណ្ដាលនៃចំនួនមនុស្ស ១០០០០នាក់នេះត្រូវបានសម្លាប់ ក្រោយពេលកម្មាភិបាលនិរតីមកដល់ គឺប្រហែលនឹងចំនួន **៥០០០**នាក់។ ដូចគ្នានេះដែរ អ្នកទោសម្នាក់ទៀតបានឮអ្នកយាមមន្ទីរសន្តិសុខនៅទីនោះនិយាយថា មានមនុស្សជាង **៥០០០**នាក់មកពីភូមិភាគបូព៌ាត្រូវបានសម្លាប់[1773]។ តួលេខនេះគឺមានលក្ខណៈស៊ីចង្វាក់ទៅនឹងចំនួនអ្នកទោសមកពីភូមិភាគបូព៌ាដែលបានសម្គាល់ឃើញថា យកមកដាក់មន្ទីរសន្តិសុខនេះដើម្បីសម្លាប់ចោល។ សាក្សីនានាបានពណ៌នាអំពីឡានអាមេរិកាំងប្រភេទ ៤x៤ ចំនួនពីរគ្រឿង[1774] បានដឹកអ្នកទោសមកពីភូមិភាគបូព៌ាមកមន្ទីរសន្តិសុខ ពីពីរ ទៅបួនដង រាល់ថ្ងៃ[1775] នៅក្នុងរយៈពេលពីមួយ ទៅពីរខែ[1776]។ ឡាននីមួយៗដឹកពេញ ហើយមានអ្នកទោសចន្លោះពី២០ ទៅ៣០នាក់[1777]។ អ្នកទោសទាំងនេះមកពីភាគបូព៌ា រួមមានទាំងទាហាន ប្រពន្ធរបស់ទាហាន នគរបាល *"អ្នកខាងតុលាការ"* (ប្រហែលជា តែអាចមិនពិតដែរ គឺជាអ្នកដែលពីមុនធ្វើការក្នុងប្រព័ន្ធតុលាការនៅ

[1773] ឯកសារ **D91** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆយ ឡឹង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ERN 00743576។

[1774] ឯកសារ **D219/875** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01355369 ឆ.១៧។

[1775] ឯកសារ **D91** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆយ ឡឹង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ERN 00743575។ ឯកសារ **D97** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង រុន ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ ERN 00743597-00743598។ ឯកសារ **D219/875** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01355370 ឆ.១៩។

[1776] ឯកសារ **D219/875** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01355369 ឆ.១៧, 01355371 ឆ.២៩។

[1777] ឯកសារ **D91** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆយ ឡឹង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ERN 00743575។ ឯកសារ **D97** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង រុន ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ ERN 00743597-00743598។ ឯកសារ **D219/875** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01355370 ឆ.២០-ឆ.២១, 01355376 ឆ.៦០។

ក្នុងរបបលន់ នល់) ហើយនិងកងអារុធបាត្ត ដែល *"មិនស្មោះត្រង់"*[1778]។ ការពណ៌នានេះបានផ្តល់នូវរង្វង់នៃចំនួនចន្លោះពី ២៤០០ (ឡាន ២ x ពីរដងក្នុងមួយថ្ងៃ x មួយខែ (៣០ថ្ងៃ) x អ្នកទោស២០នាក់) និង ៣៣៦០០ (ឡាន២ x ៤ដងក្នុងមួយថ្ងៃ x ពីរខែ (៦០ថ្ងៃ) x អ្នកទោស៧០នាក់)។ ការប្រមាណតួលេខថាមាន **៥000**នាក់ គឺនៅក្នុងរង្វង់នៃការប៉ាន់ប្រមាណនេះយ៉ាងច្បាស់ណាស់ ហើយទោះជាគិតយកអប្បបរិមា ក៏ចំនួននេះជាការប៉ាន់ប្រមាណទាបបំផុតមួយ។

៥៣៤. សាក្សីទាំងឡាយពណ៌នាអំពីរណ្តៅសាកសពថាមានចំនួន និងទំហំផ្សេងៗគ្នា៖ រណ្តៅដែលមានទំហំ *"៦x២ ម៉ែត្រ មានជម្រៅ ១.៨ ម៉ែត្រ"* ដែលអាចក្នុងរណ្តៅមួយដាក់បានសាកសព៤០នាក់[1779] រណ្តៅ៧ ឬ៨ ដែលមានទទឹង២០ម៉ែត្រ ហើយអាចដាក់សាកសពរាប់រយនាក់[1780]។ រណ្តៅរាប់រយដែលមានទំហំជាច្រើនម៉ែត្រ[1781] និងរណ្តៅតូចៗ១000 ដែលអាចដាក់សាកសពបានម្នាក់ ឬពីរនាក់[1782]។ អ្នកទោសម្នាក់ដែលបានជីករណ្តៅបំភ្លឺថា ចំនួនរណ្តៅគឺ *"មិនអាចរាប់បានឡើយ"*។ ហើយថា រណ្តៅទាំងនោះស្ថិតនៅក្នុងរង្វង់ពីរហិកតា[1783]។ រណ្តៅទាំងនោះស្ថិតនៅខាងកើតវត្ត[1784] ប្រហែលពី២០ ទៅ៣០ម៉ែត្រពីអគារឃុំឃាំង[1785]

---

[1778] ឯកសារ **D219/875** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01355371 **ឆ.២៧**។

[1779] ឯកសារ **D91** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆយ ឡឹង ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ERN 00743574។

[1780] ឯកសារ **D97** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង រុន ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ ERN 00743597។

[1781] ឯកសារ **D3/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជី សេងហួត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ERN 00619821 **ឆ.៩**។

[1782] ឯកសារ **D219/80** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01039232 **ឆ.៣៩**។

[1783] ឯកសារ **D3/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អុំ រស់ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ERN 00619857 **ឆ.១២**។

[1784] ឯកសារ **D3/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អុំ រស់ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ERN 00619857 **ឆ.១២**។ ឯកសារ **D219/80** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ERN 01039232 **ឆ.៣៩**។

ហើយមាននៅពាសពេញចាប់ពីមន្ទីរសន្តិសុខរហូតទៅដល់ជើងភ្នំនៅខាងត្បូង[1786]។ ក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ឆ្អឹង និងលលាដ៍ក្បាល ត្រូវបានជីករកឃើញដោយប្រជាជនដែលស្វែងរករបស់មានតម្លៃ។ សាក្សីម្នាក់បានប៉ាន់ប្រមាណថា មានក្បាលចំនួនរាប់ពាន់ត្រូវបានប្រមូលទុក[1787]។ ចេតិយមួយដាក់ធាតុទាំងនោះនៅទីតាំងនោះដែរ[1788]។ រណ្តៅ និងសាកសពទាំងនេះ ដែលបានសង្កេតឃើញដោយសាក្សីមានលក្ខណៈស៊ីចង្វាក់ទៅនឹងការសម្លាប់ទ្រង់ទ្រាយធំ ដែលបានកើតឡើងនៅវត្តបាធាយ ប៉ុន្តែមិនបានយកមកគិតដើម្បីឱ្យចេញជាតួលេខនៃចំនួនជនរងគ្រោះនោះទេ ដោយសារវាមិនអាចកំណត់បាន ថាតើរណ្តៅណាបានជីកមុន ឬក្រោយការមកដល់របស់កម្មាភិបាលភូមិភាគនិរតី ហើយក៏មិនមានលទ្ធភាពអាចបែងចែកច្បាស់លាស់នូវជនរងគ្រោះនេះ ថាពិតជាដូចគ្នា ឬខុសគ្នាពីជនរងគ្រោះដែលប៉ាន់ស្មានមានចំនួនប្រហែល១០០០០ ឬ១១០០០ ដែលអតីតអ្នកទោសបានសង្កេតឃើញដូចដែលបានពណ៌នាខាងលើ។

*ការទស្សនកិច្ចដោយ អោ អាន*

៥៣៥. មិនមានភស្តុតាងថា **អោ អាន** បានមកទស្សនកិច្ចមន្ទីរសន្តិសុខវត្តបាធាយទេ។

៥៣៦. កងការពាររបស់ **អោ អាន** បំភ្លឺអំពីព្រឹត្តិការណ៍មួយ ដែល **អោ អាន** មកទស្សនកិច្ចស្រុកបាធាយ ប៉ុន្តែភស្តុតាងរបស់គាត់ មិនមានលក្ខណៈច្បាស់លាស់បញ្ជាក់ថាតើទស្សនកិច្ចនោះមកដល់មន្ទីរស្រុក ឬមន្ទីរសន្តិសុខវត្តបាធាយឬយ៉ាងណានោះទេ។ សាក្សីនោះពីដំបូងបំភ្លឺថា គាត់អមដំណើរ **អោ អាន** បានម្តងទៅកាន់មន្ទីរសន្តិសុខវត្តបាធាយ ដើម្បីទៅចូលរួម *"ប្រជុំ*

---

[1785] ឯកសារ **D3/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ រស់ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០ ERN 00619857 ឆ.១២។ ឯកសារ **D3/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផ្លុង សាន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00628295-00628296 ឆ.១១។

[1786] ឯកសារ **D3/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផ្លុង សាន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00628295-00628296 ឆ.១១។

[1787] ឯកសារ **D3/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជី សេងហួត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ERN 00619819 ឆ.៦។

[1788] ឯកសារ **D3/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជី សេងហួត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ERN 00619819 ឆ.៦។

*ធម្មតា*" ដែលបានលើកឡើងអំពីការកសាង និងការកំណត់របបអាហារ[1789]។ ទោះជាយ៉ាងណាក៏ដោយ កងការពារនោះនៅពេលដែលបានសួរអំពីការប្រជុំទាំងនេះនៅក្នុងកិច្ចសម្ភាសមួយក្រោយមក គាត់ឆ្លើយថា គាត់ និង **អោ អាន** បានចូលរួមប្រជុំនៅបាធាយ និយាយអំពីការបង្កបង្កើនផលនៅមន្ទីរស្រុកជាមួយនឹងប្រធានឃុំ និងភូមិ ហើយខណៈពេលដែលនៅបាធាយ គាត់បានឃើញអ្នកទោសមួយក្រុមកំពុងតែអត់អាហារ ជាប់ឃុំនៅក្នុងផ្ទះមួយចម្ងាយ ១០០ម៉ែត្រពីកន្លែងប្រជុំនោះ[1790]។ នៅក្នុងឱកាសនេះ កងការពារនោះក៏បានឃើញផងដែរ មនុស្សជាងដប់នាក់កំពុងជាប់ចំណង ហើយបណ្ដើរទៅក្នុងព្រៃ[1791]។

## ៦.៤.១.៧ ទីតាំងសម្លាប់មនុស្សទួលភ្នំប្រុស

*ទីតាំង និងការបង្កើត*

៥៣៧. ភ្នំប្រុសនិងភ្នំស្រី គឺជាភ្នំតូចពីរនៅទន្ទឹមគ្នា មានទីតាំងស្ថិតនៅឃុំក្រឡា និងអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម នៅក្នុងភូមិសាស្ត្រដែលធ្លាប់ជាតំបន់៤១ នៃភូមិភាគកណ្ដាល[1792]។ ភ្នំទាំងពីរនេះស្ថិតនៅជាប់ខាងជើងផ្លូវជាតិលេខ៧ ចម្ងាយប្រហែល៧គីឡូម៉ែត្រភាគពាយ័ព្យនៃ

---

[1789] ឯកសារ **D219/731** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ERN 01218076 ឆ.៦៩-ឆ.៧០។ ឯកសារ **D219/732** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ERN 01218088 ឆ.៥២-ឆ.៥៣។

[1790] ឯកសារ **D219/855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344713 ឆ.២៣៧-ឆ.២៣៩។

[1791] ឯកសារ **D219/855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01344715 ឆ.២៥៥, ឆ.២៥៨។

[1792] ឯកសារ **D3/23** របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ ERN 00712698-00712699។

ទីក្រុងកំពង់ចាម[1793]។ មន្ទីរស្រុកកំពង់សៀម ស្ថិតនៅចម្ងាយ៥គីឡូម៉ែត្រភាគឦសាននៃភ្នំប្រុសភ្នំស្រីតាមបណ្ដោយផ្លូវជាតិលេខ៧[1794]។

៥៣៨. មុនរបបកម្ពុជាប្រជាធិបតេយ្យមានវត្តមួយដំណើរការនៅភ្នំប្រុសភ្នំស្រី[1795] ហើយក៏មានមូលដ្ឋានកងទ័ពលន់ នល់ ស្ថិតនៅទីតាំងច្រកចូលទៅវត្ត[1796]។

៥៣៩. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភ្នំប្រុសភ្នំស្រី គឺជាមូលដ្ឋានយោធាភូមិភាគកណ្ដាល[1797]។ មានបន្ទាយយោធាមួយស្ថិតនៅជើងភ្នំប្រុសនៅជិតផ្លូវជាតិលេខ៧ ហៅថា ហ្វូតហាម ឬ

---

[1793] ឯកសារ D3/23 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ ERN 00712698-00712699។

[1794] ឯកសារ D219/138 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃ៨ ខែមករា ឆ្នាំ២០១៥ ERN 01056042 ឆ.១៣។ ឯកសារ D179/1.2.5 ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២/០២ [ប្រាក់ យុត] ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ ERN 00773570។ ឯកសារ D179/1.2.6 ប្រតិចារឹកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២/០២ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ [ប្រាក់ យុត] ERN 00773656។

[1795] ឯកសារ D219/377 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01112254 ឆ.៨។

[1796] ឯកសារ D219/377 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01112254 ឆ.៨។ *សូមមើលផងដែរ* ឯកសារ D219/138 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃ៨ ខែមករា ឆ្នាំ២០១៥ ERN 01056061 ឆ.៩៩ [*"មូលដ្ឋានយោធានោះស្ថិតនៅទីនោះតាំងពីមុនសម័យខ្មែរក្រហមទៅទៀត"*]។

[1797] ឯកសារ D117/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01023133 ឆ.៨។ ឯកសារ D219/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ERN 01046842 ឆ.៧៨។ ឯកសារ D3/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00629960 ឆ.៧។ ឯកសារ D219/377 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01112254 ឆ.៨។ ឯកសារ D219/178 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុច វ៉ា ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ERN 01066301 ឆ.១៣។

បន្ទាយសេ[1798]។ ទាហានត្រូវបានដាក់ឱ្យឈរជើងផងដែរនៅកំពូលភ្នំប្រុស[1799] ក្នុងនោះរួមមានទាំងប្រធាននៃទីតាំងនោះដែលរស់នៅកំពូលភ្នំប្រុសជាមួយនឹងកងការពាររបស់គាត់[1800]។

៥៤០. ប្រជាជននៅមូលដ្ឋាននោះត្រូវហាមឃាត់មិនឱ្យចូលបរិវេណភ្នំប្រុសភ្នំស្រី[1801] ប៉ុន្តែមានប្រជាជនខ្លះធ្វើកសិកម្មនៅជុំវិញបរិវេណនោះ[1802]។

៥៤១. គិតមកត្រឹមខែមីនា ឬមេសា ឆ្នាំ១៩៧៧ មានទីតាំងសម្លាប់មួយបានដំណើរការនៅភ្នំប្រុសភ្នំស្រី[1803] ហើយបន្តដំណើរការយ៉ាងហោចណាស់រហូតដល់មានការបោសសម្អាតភូមិភាគ

---

[1798] ឯកសារ **D117/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01023132 ឆ.៦។ ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784990 ឆ.២។

[1799] ឯកសារ **D117/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01023132 ឆ.៣។ ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784990 ឆ.២។

[1800] ឯកសារ **D107/19.1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00785003 ឆ.២០។ ឯកសារ **D3/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00629960 ឆ.៧។

[1801] ឯកសារ **D219/472** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ ចាន់ថុល ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ERN 01133444 ឆ.៩០។ ឯកសារ **D219/119.1.2** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផ្លុង ហាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ERN 00797016។ ឯកសារ **D3/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00629959 ឆ.៤។ ឯកសារ **D219/502** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មួក សេងលី ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01142493 ឆ.២៤។ ឯកសារ **D219/859** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡេង វ៉ា ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01346213 ឆ.៤៤។ ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00784992 ឆ.១៦។

[1802] ឯកសារ **D219/159** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឌី ហួន ERN 01059370 ឆ.១៦៧។ ឯកសារ **D219/859** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡេង វ៉ា ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01346212 ឆ.៣៩។

[1803] ឯកសារ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088622 ឆ.៦។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន

01588763



បូព៌ា នៅពាក់កណ្ដាលឆ្នាំ១៩៧៨[1804]។ ភាគច្រើននៃការសម្លាប់មនុស្សបានកើតឡើងនៅក្នុងចន្លោះទីតាំងភ្នំទាំងពីរនោះ[1805] ប៉ុន្តែក៏មានការសម្លាប់មនុស្សបានកើតឡើងផង ដែរនៅទីតាំងផ្សេងៗទៀតនៅលើ និងនៅជុំវិញភ្នំទាំងពីរនោះ[1806]។

*បុគ្គលិក ការប្រតិបត្តិការ និងរចនាសម្ព័ន្ធនៃការបញ្ជា*

៥៤២. ភ្នំប្រុសភ្នំស្រី ស្ថិតនៅក្រោមការគ្រប់គ្រងរបស់លេខាភូមិភាគកណ្ដាល កែ ពក[1807]។

៥៤៣. គិតមកត្រឹមខែមិថុនា ឆ្នាំ១៩៧៧[1808] កែ ពក បានតែងតាំង ឈិត ជឿន (មិនមានទំនាក់ទំនងទៅនឹង ឈិត ជឿន ហៅថាម៉ុក) ឱ្យគ្រប់គ្រងភ្នំប្រុសភ្នំស្រី[1809]។ សាក្សីម្នាក់បំភ្លឺថា ជឿន គឺ

---

កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00384434។ ឯកសារ **D117/66** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01040460 ឆ.៣។

[1804] ឯកសារ **D219/855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374648-01374649 ឆ.៦៣, 01374660-01374661 ឆ.១៩៩។ សាក្សីនិយាយថា ការសម្លាប់ពួកកម្មាភិបាលបូព៌ាទ្រង់ទ្រាយធំនៅវត្តភ្នំប្រុសកើតឡើងក្នុងខែមិថុនា ឆ្នាំ១៩៧៧ ប៉ុន្តែមិនច្បាស់ចំពោះកាលបរិច្ឆេទ។ ទោះជាយ៉ាងនេះក្ដី ផ្អែកលើភស្តុតាងផ្សេងទៀត ហេតុការណ៍នេះទំនងកើតឡើងក្នុងអំឡុងពេលបោសសម្អាតភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨។

[1805] ឯកសារ **D3/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630445 ឆ.៧។ ឯកសារ **D3/23** របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស៖ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ ERN 00644191។

[1806] ឯកសារ **D95** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សឹង លឹម ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ ERN 00746991-00746992។ ឯកសារ **D219/119.1.2** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម បណ្ដឹងរដ្ឋប្បវេណី ផ្លុង ហាន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ERN 00797011។ ឯកសារ **D3/20** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្រី កានឿន ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00631100 ឆ.៣។ ឯកសារ **D219/377** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01132626 ឆ.៩។ **D191.1.112** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ណាត ហឿន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ERN 00797022 (ហើយអ្នកដែលគេដឹកទៅនោះ ត្រូវបានសម្លាប់ទាំងអស់នៅលើកំពូលភ្នំ)។

[1807] ឯកសារ **D117/66** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01040459 ឆ.១-ឆ.២, 01040461 ឆ.៨-ឆ.៩។ ឯកសារ **D107/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គីម អេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787224-00787225 ឆ.៣-ឆ.៤។ ឯកសារ **D219/377** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01132625 ឆ.៨, 01132626 ឆ. ១៣។ ឯកសារ **D3/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630446 ឆ.១៣។

ជាកូនប្រុសធម៌របស់ កែ ពក[1810]។ ជឿន បានទទួលខុសត្រូវ កិច្ចការសន្តិសុខ និងគ្រប់គ្រងភ្នំប្រុសភ្នំស្រី[1811] ហើយមានអំណាចធ្វើការសួរចម្លើយ និងផ្អាកការសម្លាប់មនុស្សជាបណ្ដោះអាសន្ននៅទីតាំងនោះ[1812]។ ជឿន ខ្លួនគាត់ផ្ទាល់អះអាងថាខ្លួនជាសាក្សីម្នាក់ក្នុងការបញ្ជាក់ថាគាត់ *"មានសិទ្ធិ និងអំណាច"* ទៅលើតំបន់ភ្នំប្រុស[1813] ហើយក៏បានការពារផងដែរចំពោះមនុស្សមួយចំនួន ដែលបានគេចខ្លួនពីការចាប់[1814]។ នៅចុងឆ្នាំ ១៩៧៧ កែ ពក បានទស្សនកិច្ចភ្នំប្រុស ភ្នំស្រី ហើយបញ្ជា ជឿន ឱ្យ *"ដុតចោលទាំងអស់នូវឯកសារដែលសេសសល់ពីអ្នកដែលត្រូវបានសម្លាប់"* ហើយ *"កប់សាកសពដែលមិនទាន់បានកប់ចប់សព្វ*

---

[1808] ឯកសារ **D3/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630444 ទ.៤។

[1809] ឯកសារ **D107/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787225 ទ.៧។ ឯកសារ **D107/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ឹម កុល ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787219។ ឯកសារ **D219/323** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុត សុផុន ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ ERN 01113697 ទ.១១។ ឯកសារ **D3/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630444 ទ.៤។ ឯកសារ **D191.1.112** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ណាត ហឿន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ERN 00797022។ សូមមើលផងដែរ។ <u>អត់មានទំនាក់ទំនងអ្វីនឹង ឈិត ជឿន ហៅ តាម៉ុក ទេ</u> *សូមមើល* ឯកសារ **D219/422.4** ប្រតិចារិកនៃបទសម្ភាសន៍ជាមួយ ញ៉ឹម កុល ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ERN 01136792 ["កុំច្រឡំ ឈិត ជឿន ថាជា តាម៉ុក។ ឈិត ជឿន ម្នាក់នេះមិនមែនតាម៉ុកទេ។ នេះ គឺជឿន ម្នាក់ផ្សេងទៀត"]។

[1810] ឯកសារ **D107/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787219។

[1811] ឯកសារ **D3/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630445 ទ.៧។

[1812] ឯកសារ **D219/323** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុត សុផុន ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ ERN 01113697 ទ.១២។

[1813] ឯកសារ **D3/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630444 ទ.៤។

[1814] ឯកសារ **D107/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787226 ទ. ១៥។ ឯកសារ **D3/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630444-00630445 ទ.៦-ទ.៨។

*គ្រប់"*[1815]។ ជឿន នៅបន្តគ្រប់គ្រងភ្នំប្រុសភ្នំស្រីរហូតដល់វៀតណាមមកដល់ក្នុងឆ្នាំ ១៩៧៩។ មិនមានភស្តុតាងបញ្ជាក់ថា ការគ្រប់គ្រងនោះបានផ្ទេរទៅឱ្យអ្នកណាផ្សេងឡើយ ហើយគាត់ត្រូវបានឃើញនៅតំបន់នោះរហូតដល់ពេលនោះដែរ[1816]។

៥៤៤. មានក្រុមផ្សេងៗបានជួយនៅក្នុងការដំណើរការសម្លាប់មនុស្សនៅភ្នំប្រុសភ្នំស្រី នៅក្នុងអំឡុងពេលដែល កែ ពក និង ជឿន នៅគ្រប់គ្រងទៅនោះ។ យោងតាមយោធាម្នាក់ដែលឈរជើងនៅទីតាំងនោះ យោធាទាំងឡាយដែលឈរជើងនៅទីតាំងនោះ គឺមិនមែនដើម្បីសម្លាប់មនុស្សនោះឡើយ ហើយនៅក្នុងខែ កក្កដា ឬសីហា ឆ្នាំ ១៩៧៧ *"ក្រុមសន្តិសុខ"* ឬ *"ក្រុមយោធា"* បានត្រូវនាំមកពីសៀមរាប ហើយសម្លាប់មនុស្សនៅទីតាំងនោះ[1817]។ ការសម្លាប់មនុស្សបានផ្អាកនៅក្នុងខែ វិច្ឆិកា ឬធ្នូ ឆ្នាំ ១៩៧៧ នៅពេលដែល កែ ពក *"បានចាប់ខ្លួន និងយកក្រុមសន្តិសុខដែលមកពីសៀមរាបនោះចេញ"*[1818]។ បន្ទាប់មកក្រុមនេះត្រូវបានជំនួសដាក់ក្រុមមួយមកពីភ្នំពេញ ក្រោមការដឹកនាំរបស់មនុស្សម្នាក់ឈ្មោះ តាហោ[1819]។

៥៤៥. **អោ អាន** បានធ្វើផែនការជាមួយគ្នានឹងគណៈកម្មាធិការភូមិភាគកណ្តាល ក្នុងការបញ្ជូនមនុស្សទៅភ្នំប្រុសភ្នំស្រី ដើម្បីសម្លាប់ចោល ហើយគាត់ចាត់ចែងការប្រតិបត្តិការបញ្ជូនអ្នក

---

[1815] ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787225 ត.៦-ត.៧។

[1816] ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787227 ត.២៥។ **D219/323** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត សុផុន ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ ERN 01113697 ត.១៤។

[1817] ឯកសារ **D117/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01040460 ត.៦។ ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787224 ត.៣, 00787226 ត.១៦។

[1818] ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787225 ត.៦។

[1819] ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787226, ត.១៩។ ឯកសារ **D117/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01040460 ត.៦, ត.៧។

ទោសពីតំបន់៤១ ទៅកាន់ទីនោះដើម្បីសម្លាប់ចោល[1820]។ មិនមានភស្តុតាងបន្ថែមបញ្ជាក់អំពីអំណាចរបស់គាត់ ឬតួនាទីរបស់គាត់ពាក់ពន្ធនឹងទីតាំងនេះទេ។

*ការចាប់ខ្លួន និងការបញ្ជូនទៅភ្នំប្រុសភ្នំស្រី*

៥៤៦. មុននឹងបញ្ជូនមកភ្នំប្រុសភ្នំស្រី អ្នកទោសនៅតំបន់៤១ បានត្រូវប្រមូលផ្តុំនៅព្រៃទទឹងជិតមន្ទីរតំបន់៤១ ឬមន្ទីរសន្តិសុខវត្តតាមាក់។ អ្នកទោសខ្លះត្រូវបានប្រមូលផ្តុំក្រោមការយកលេសថាឱ្យពួកគេទៅរៀនសូត្រ ឬទៅប្រជុំហើយមិនទាន់ចាប់ខ្លួនឡើយ រហូតដល់ពេលពួកគេបានឡើងឡានមកភ្នំប្រុសភ្នំស្រី ប៉ុន្តែអ្នកទោសផ្សេងទៀត បានត្រូវឃុំខ្លួនជាមុនសិននៅមន្ទីរសន្តិសុខវត្តតាមាក់ មុនពេលបញ្ជូនមកភ្នំប្រុសភ្នំស្រី[1821]។ ការសម្រេចត្រូវបញ្ជូនអ្នកទោសទៅទីតាំងណា គឺធ្វើឡើងដោយប្រធានមន្ទីររបស់ **អោ អាន** ឈ្មោះ អួន តាមបញ្ជារបស់ **អោ អាន**[1822]។ អ្នកទោសដែលមានហានិភ័យខ្ពស់ ឬដែលជាអាទិភាព បន្ទាប់មកត្រូវបញ្ជូនទៅទិស *"ខាងកើត"* តម្រង់មកភ្នំប្រុសភ្នំស្រី[1823] ប៉ុន្តែអ្នកទោសដែលមានអាទិភាពទាប ត្រូវបញ្ជូនទៅទីតាំងសម្លាប់មួយផ្សេងទៀត[1824]។ ការកំណត់ប្រភេទអ្នកទោសនេះ និងការប្រតិបត្តិការបញ្ជូនអ្នកទោសត្រូវបានអនុវត្តស្របតាមផែនការ ដែលធ្វើឡើងដោយ**អោ អាន** និងគណៈកម្មាធិការភូមិភាគកណ្តាលក្នុងពេលប្រជុំ ដូចដែលបានលើកឡើងក្នុងកថាខណ្ឌ២៧៩។

---

[1820] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374646 ឆ.៤២។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00346157។ *សូមមើល* ជំពូក៦.៣.៤.២ – ៦.៣.៤.៣។

[1821] *សូមមើល*ជំពូក ៦.៣.៤.៣ ការកំណត់ក្រុមគោលដៅជាក់លាក់ កថាខណ្ឌ២៩៤។

[1822] ឯកសារ **D219/543** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាំ ម៉ុន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ ERN 01174540 ឆ.២១។ ឯកសារ **D219/315** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ERN 01111982 **ឆ.១៥២**, **ឯកសារ D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ERN 01374647, ឆ.៤៦, ឆ.៤៨, 01374648 ឆ.៥៦, 01374649 ឆ.៦៤។

[1823] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374646 ឆ.៣៨, 01374656 ឆ.១៦០។

[1824] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374646 ឆ.៣៨, 01374647 ឆ.៤៥។

៥៤៧. អ្នកទោសត្រូវបានបញ្ជូនមកភ្នំប្រុសភ្នំស្រីតាមឡាន[1825] ដែលកាន់កាប់ដោយភូមិភាគកណ្តាល[1826] ហើយមានឡានខ្លះអមដំណើរការពារដោយកងការពារប្រដាប់ដោយអាវុធ[1827]។ ឡានខ្លះអាច ជារបស់តំបន់៤១[1828]។ យ៉ាងហោចណាស់មានអ្នកបើកបរពីរនាក់នៃអង្គភាពដឹកជញ្ជូនរបស់មន្ទីរពាណិជ្ជកម្មតំបន់៤១ បានបើកឡានដឹកអ្នកទោសពីព្រៃទទឹងទៅកាន់ភ្នំប្រុសភ្នំ

---

[1825] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374647 ឆ.៤៧។ ឯកសារ **D107/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787226 ឆ.១៥។ ឯកសារ **D117/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ERN 01040460 ឆ.៧។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ERN 01059295 ឆ.៩៣។ ឯកសារ **D219/543** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាំ ម៉ុន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ ERN 01174539 ឆ.៧, ឆ.១០។ ឯកសារ **D219/502** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មួក សេតលី ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01152374 ឆ.២៤។ ឯកសារ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088622 ឆ.៦។ ឯកសារ **D3/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630445 ឆ.៧។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ERN 01059295 ឆ.៩៣។ ឯកសារ **D219/377** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01132625 ឆ. ៧។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨ ERN 00346157។

[1826] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374647 ឆ.៤៧។ ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01167896 ឆ.៧២។ ឯកសារ **D117/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ERN 01040460 ឆ.៧។

[1827] ឯកសារ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088622-01088623 ឆ.៦-ឆ.៧។ *មេីល* ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ERN 01059295 ឆ. ៩៣ [*"ហើយក៏គ្មានអ្នកយាមដែរ"*]។

[1828] ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01167897 ឆ.៧៥-ឆ.៧៦។ ឯកសារ **D219/460** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01131219 ឆ.១១។

ស្រី[1829]។ ជាដំបូងឡានទាំងនោះ ដែលប្រើប្រាស់សម្រាប់ដឹកអ្នកទោសគឺជាឡាន GMC អាមេរិកាំង ហើយក្រោយមកគឺជាឡាន *"ហ្សីល"* របស់ចិន ត្រូវបានប្រើប្រាស់[1830]។ អ្នកទោសដែលបានបញ្ជូនមកទីតាំងនោះ រួមមានគ្រួសារទាំងមូល មានទាំងមនុស្សចាស់ និងកុមារ។[1831]

៥៤៨. សាក្សីនានាបានបំភ្លឺអំពីការប្រតិបត្តិការជាច្រើន ដែលដឹកមនុស្សយ៉ាងច្រើនទៅកាន់ភ្នំប្រុសភ្នំស្រី។ សាក្សីទាំងនេះបានឃើញអ្នកទោសពេលចេញដំណើរតាមឡាន និងបានដឹងមកពីអ្នកបើកបរនិងអ្នកផ្សេងៗទៀតពាក់ព័ន្ធនៅក្នុងប្រតិបត្តិការនោះថា ភ្នំប្រុសភ្នំស្រី គឺជាគោលដៅដែលត្រូវទៅ។ ចាប់ពីខែ មីនា ឬមេសា ឆ្នាំ ១៩៧៧ សមាជិកម្នាក់នៃអង្គភាពកាត់ដេរតំបន់៤១ បានចាប់ផ្ដើមកត់សម្គាល់ឃើញថា មានឡាន GMC ចំនួនពីរគ្រឿង ដែលអាចដឹកបាន៥០នាក់ ដឹកមនុស្សពីព្រៃទទឹង *"អស់រយៈពេលពេញមួយសប្ដាហ៍"* ហើយក្រោយមក *"ក្រោយពីបានស្ងប់ស្ងាត់អស់មួយរយៈ ឡានទាំងនោះត្រឡប់មកម្ដងទៀត ហើយយកមនុស្ស*

---

[1829] ឯកសារ **D219/315** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ERN 01111982 ទ.១៤៦-ទ.១៤៧។ ឯកសារ **D219/460** កំណត់ហេតុនៃ ការស្ដាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01151219 ទ.១១។ *យោង* ឯកសារ **D219/226** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពេញ វ៉ី ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088623 ទ.៨ [ថ្លែងថា "ផ្នែកដឹកជញ្ជូនរបស់តំបន់" ពុំបានចូលរួមដឹកមនុស្សទៅភ្នំប្រុស ភ្នំស្រីទេ]។

[1830] ឯកសារ **D107/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិន គីមអេង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787226 ទ. ១៩។ ឯកសារ **D219/855** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374647 ទ.៥៤។ ឯកសារ **D219/502** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ម្លូក សេងលី ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01152374 ទ.២៤។ ឯកសារ **D219/226** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088622 ទ.៦។

[1831] ឯកសារ **D219/138** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ERN 01059295 ទ.៩៣។ ឯកសារ **D117/38** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គ្រួច គីម ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ERN 01056735 ទ.៥។ ឯកសារ **D3/10** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នីវ ស៊ិន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ERN 00623579 ទ.១១។ ឯកសារ **D219/159** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នី ហួន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01067872-01067873 ទ.១៦៧-ទ.១៧១។

*បន្ថែមចេញទៅទៀត។... ព្រឹត្តិការណ៍នេះបន្តកើតមានរហូតដល់ខែ តុលា ឆ្នាំ ១៩៧៧"* នៅពេលដែលសាក្សីឈប់ធ្វើការនៅទីនោះ[1832]។ ទោះបីជាសាក្សីមិនបានបញ្ជាក់ថា មនុស្សមានចំនួនប៉ុន្មាននាក់ដែលដាក់ស្លែងដាក់នៅលើឡានទាំងនោះក៏ដោយ ការទាញសន្និដ្ឋានសមហេតុផលមួយគឺថា ឡានទាំងនោះមានដាក់មនុស្សពេញ ដោយសារធ្វើរបៀបនេះ គឺជាមធ្យោបាយមានប្រសិទ្ធភាពបំផុតក្នុងការដឹកជញ្ជូនមនុស្សច្រើន ច្រើនជើង។ សាក្សីផ្សេងទៀត ក៏បានពណ៌នាស៊ីចង្វាក់គ្នាដែរអំពីឡានដែលបានដាក់មនុស្សពេញៗឆ្ពោះទៅកាន់ទីតាំងនោះ[1833]។ អាស្រ័យហេតុនេះ ចំនួនអប្បបរមាមួយអាចកំណត់បានដោយសមហេតុផលផ្អែកទៅលើចំនួនឡានពីរគ្រឿងដែលដឹកមនុស្ស៥០នាក់ជាច្រើនជើង (ឡាននានាមកអស់រយៈពេល *"ពេញមួយសប្តាហ៍"* គិតស្មើនឹង៥ជើង បូកនឹង *"ឡានទាំងនោះត្រឡប់មកវិញ"* មកយកមនុស្សថែមទៀតជាច្រើនជើង គិតស្មើនឹង ២ជើង) ដែលសរុបទៅមានចំនួន **៧០០**នាក់។ នៅក្នុងការប្រតិបត្តិការមួយដាច់ដោយឡែក កងការពាររបស់ **អោ អាន** បានពណ៌នាអំពីឡាន *"ហ្ស៊ីល"* របស់ចិន ដែលដឹកបានចំនួន៣០នាក់ ដឹកប្រជាជនភាគបូព៌ាមកពីព្រៃទទឹង ក្នុងអំឡុងពេលពីរខែកន្លះ ដែលគិតទៅមានចំនួន *"យ៉ាងហោចណាស់ **៥០០** នាក់"* ហើយដែលបង្ហាញថា តួលេខគឺខ្ពស់ជាងនេះ ពីព្រោះការប្រតិបត្តិការបានដំណើរការរហូតដល់ក្រោយពេលគាត់ត្រឡប់ទៅធ្វើការនៅកន្លែងផ្សេងទៀត[1834]។ កម្មាភិបាលភ័ស្តុភាតំបន់៤១ ម្នាក់ បានពណ៌នាអំពីការប្រតិបត្តិការមួយទៀតនៅចុងឆ្នាំ១៩៧៧ នៅពេលដែល

---

[1832] ឯកសារ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088622 ឆ.៦។

[1833] ឯកសារ **D219/323** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត សុផុន ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ ERN 01113697 ឆ.១១។ ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ERN 01059295 **ឆ.៩៣**។ ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00346157។ ឯកសារ **D219/159** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នី ហួន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01067873 ឆ.១៦៩-ឆ.១៧១។

[1834] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374647 **ឆ.៥៣**, 01374648 **ឆ.៦២**, 01374651 **ឆ.៩៧**, 01374656 **ឆ.១៦៥**។ ឯកសារ **D219/731** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ERN 01224112 ឆ.៩៦។

*"ប្រជាជនទាំងគ្រួសារទាំងមូល"*[1835] ត្រូវស្នាក់នៅវត្តតាមាក់បួន ឬប្រាំថ្ងៃ ហើយនៅពេលណាដែលមាន *"គ្រប់ចំនួន"* ភ្លាម នោះមនុស្សទាំងនោះនឹងត្រូវដឹកបញ្ជូនទៅភ្នំប្រុសភ្នំស្រី ហើយបានប៉ាន់ប្រមាណថា ហេតុការណ៍នេះបានកើតឡើងចំពោះ *"យ៉ាងហោចណាស់មនុស្ស ៣០០នាក់"*[1836]។ ការសរុបតួលេខប៉ាន់ប្រមាណជាអប្បបរមាសម្រាប់តែការប្រតិបត្តិការនៅស្រុកចំនួនបីនេះ មានចំនួនទាំងអស់យ៉ាងតិចមនុស្ស ***១៥០០នាក់*** ត្រូវបានបញ្ជូនមកភ្នំប្រុសភ្នំស្រីខណៈដែល **សេរ អាន** គ្រប់គ្រងតំបន់៤១។ ដោយសារសាក្សីចំនួនពីរនាក់ក្នុងចំណោមសាក្សីទាំងនេះ បានឃើញតែហេតុការណ៍ដោយឡែកៗនៃផ្នែកមួយរបស់ប្រតិបត្តិការដែលធំតែប៉ុណ្ណោះ ដូច្នេះតួលេខជាក់ស្ដែងនឹងត្រូវខ្ពស់ច្រើនជាងនេះទៅទៀត។

៩៤៩. សាក្សីផ្សេងៗទៀតដែលកំពុងរកស្ទូងជិតភ្នំប្រុសភ្នំស្រី បានឃើញឡានដឹកអ្នកទោសតម្រង់ទៅទីតាំងនោះ។[1837] សាក្សីម្នាក់បានឃើញ *"ឡានពី២០ ទៅ៣០គ្រឿងក្នុងមួយថ្ងៃ...*

---

[1835] ឯកសារ **D219/504** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01167895 ឆ.៦៧, 01167913 ឆ.១៤៣។

[1836] ឯកសារ **D219/504** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01167895 ឆ.៦៧, 01167913 ឆ.១៤៣។ *សូមមើលផងដែរ* ឯកសារ **D219/460** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01151219 ឆ.១១ [*"តែកុងឡានពីរនាក់ មានឈ្មោះ សែ និង ផេត ដែលធ្វើការនៅក្នុងកងដឹកជញ្ជូនតំបន់ ក៏ត្រូវបានគេចាត់តាំងឱ្យដឹកមនុស្សពីវត្តតាមៈទៅភ្នំប្រុស ភ្នំស្រី"*]. 01151220 ឆ.១៥ [*"មុននឹងគ្រប់ចំនួន ដឹកចេញទៅម្ដងៗ"*]។ ឯកសារ **D3/10** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នីវ ស៊ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ERN 00623579 ឆ.១១ [*"ក្រោយឆ្នាំ១៩៧៥ នៅពេលដែលពួកនិរតីបានមកគ្រប់គ្រងតំបន់នេះ ហើយពេលនោះ មានឡានធំបានមកភូមិនេះដឹកប្រជាជនថ្មីចំនួន១៥គ្រួសារ [...] ក្នុងឆ្នាំ១៩៨៣ ខ្ញុំបានទៅលេងភ្នំប្រុស ភ្នំស្រី ហើយខ្ញុំបានឃើញអដ្ឋធាតុ និងលលាដ៍ជាច្រើន។ ដូច្នេះ ខ្ញុំគិតថា ប្រជាជនជាច្រើនត្រូវបានគេយកទៅសម្លាប់នៅទីនោះ"*]។ ឯកសារ **D219/876** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាន ប៉ាង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01362677-01362678 ឆ.៤៨ [*"បានច្រើនមួយសារមក គេយកចេញទៅសម្លាប់បាត់ទៅ"*] ឆ.៥០-ឆ.៥១, ឆ.៦១។

[1837] ឯកសារ **D219/159** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នី ហួន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ERN 01067873 ឆ.១៦៩-ឆ.១៧១។ ឯកសារ **D219/138** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ERN 01059295 ឆ.៩៣។

*មានដាក់មនុស្សពេញៗ"* បើកតម្រង់ទៅភ្នំប្រុសភ្នំស្រី[1838] ដោយមិនបានបញ្ជាក់ថាចំនួនប៉ុន្មានថ្ងៃ ហើយសាក្សីម្នាក់ទៀតបានឃើញឡានទាហានដប់គ្រឿងដឹកអ្នកទោសមកទម្លាក់នៅភ្នំប្រុសភ្នំស្រី[1839]។ ដោយសារមិនមានលទ្ធភាពអាចកំណត់ផ្អែកទៅលើភ័ស្តុតាងបច្ចុប្បន្នថាតើឡានទាំងនេះគឺជាឡានដែលដឹកអ្នកទោសដដែលដូចគ្នា ដែលបានឃើញបើកទៅកាន់ទីតាំងនោះ ចេញមកពីវត្តតាមាក់ ឬមន្ទីរតំបន់៤១ ចំនួនជនរងគ្រោះទាំងនេះមិនត្រូវបានបូកបញ្ចូលនៅក្នុងតួលេខសរុបអប្បបរមាដែលបានប៉ាន់ស្មានសម្រាប់ទីតាំងនេះឡើយ។

*ការសម្លាប់មនុស្ស*

៥៥០. អស់មួយរយៈពេលកន្លងទៅមានការយល់ដឹងជាទូទៅមួយនៅក្នុងតំបន់៤១ ថាមនុស្សដែលត្រូវយកមកភ្នំប្រុសភ្នំស្រី គឺត្រូវបានចុងក្រោយមកសម្លាប់ចោល[1840]។ សាក្សីនានាបានបញ្ជាក់ថាប្រជាជនដែលបានដាក់ឡាន ហើយដែលបានមកទីតាំងនោះមិនបានត្រឡប់ទៅវិញឡើយ[1841] ហើយសាក្សីខ្លះក្រោយមកបានដឹងមកពីអ្នកបើកបរឡានថា ប្រជាជនទាំងនេះត្រូវបាន

---

[1838] ឯកសារ **D219/323** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត សុផុន ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ ERN 01113697 ទ.១១។

[1839] ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00346157។

[1840] ឯកសារ **D219/543** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាំ ម៉ុន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ ERN 01174539 ទ.៧។ ឯកសារ **D191.1.112** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ណាត ហឿន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ERN 00797022។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កាឱល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00384434។ ឯកសារ ឯកសារ **D117/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សេង ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ ERN 00900990 ទ.១៥។ ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01167895 ទ.៦៧, 01167913 ទ.១៤៣។

[1841] ឯកសារ **D3/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នីវ ស៊ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ERN 00623579 ទ.១១។ ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374646 ទ.៤២។

សម្លាប់[1842]។ សាក្សីនានាបានបំភ្លឺថា មានតែខោអាវ និងរបស់របររបស់ប្រជាជនប៉ុណ្ណោះ ដែលបានយកត្រឡប់មកវិញ បែងចែក ឬទុកមួយកន្លែង[1843] ដែលមានលក្ខណៈស៊ីចង្វាក់ជាមួយភស្តុតាងដែលថា អ្នកទោសនៅភ្នំប្រុសភ្នំស្រីត្រូវបានឃើញថា បានដោះអាវចេញមុននឹងត្រូវសម្លាប់[1844]។

៥៥១. សាក្សីផ្សេងៗទៀតបានឃើញ ឬបានឮនូវការសម្លាប់មនុស្ស ខណៈដែលការសម្លាប់នោះកំពុងតែប្រព្រឹត្តទៅ។ មនុស្សជាច្រើនត្រូវបានគេឃើញថា ត្រូវបានដុតទាំងរស់នៅក្នុងឡធំៗនៅវត្តភ្នំប្រុសភ្នំស្រីនៅក្នុងហេតុការណ៍ចំនួនពីរ ខណៈដែលមានកម្មាភិបាលដែលមិនអាចកំណត់បានថាជានរណាច្បាស់លាស់កំពុងមានវត្តមាននៅទីនោះ[1845]។ អ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ត្រូវបានចាត់តាំងឱ្យប្រមូលធាតុដែលនៅសល់ពីការដុតនោះយកមកធ្វើជី ហើយបានឃើញឆ្អឹងមនុស្សនៅក្នុងគំនរធាតុដែលស្ថិតនៅជិតឡនោះ។ គំនរធាតុទាំងនោះមានទំហំ

---

[1842] ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01167895 ឆ.៦៧, 01167913 ឆ.១៤៣។ ឯកសារ **D219/543** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណៅ ម៉ុន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ ERN 01174539 ឆ.៧, ឆ.១០។ ឯកសារ **D3/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នីវ ស៊ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ERN 00623579 ឆ.១១។ ឯកសារ **D219/502** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មួក សេងលី ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ ERN 01152374 ឆ.២៤។ ឯកសារ **D219/226** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088622 ឆ.៦។

[1843] ឯកសារ **D219/855** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ERN 01374646 ឆ.៤២។ ឯកសារ ឯកសារ **D3/17** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នីវ ស៊ុន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ERN 00631097 *ដូចដែលបានបញ្ជាក់ក្នុង* ឯកសារ **D3/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នីវ ស៊ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ERN 00623579 ឆ.១១។

[1844] ឯកសារ **D6.1.379** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ERN 00346157។ ឯកសារ **D219/472** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹ ចាន់ថុល ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ERN 01178455 ឆ.៦៥។

[1845] ឯកសារ **D219/859** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡេង វ៉ា ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01373607-01373608 ឆ.២៧, ឆ.៣០-ឆ.៣៧, 01373610 ឆ.៥៧-ឆ.៦២។ ឯកសារ **D117/37** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡេង វ៉ា ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ERN 01072509 ឆ.១៨។

01588773



*"ដំបូចផ្ទះមួយ"* គំនរនីមួយៗមានទំហំប្រហែល១០ម៉ែត្រ ហើយ *"ខ្ពស់"* ហើយមើលទៅហាក់ដូចជាបានគរឡើងដោយប្រើត្រាក់ទ័រកាយ[1846]។

៥៥២. យូ វ៉ាន់ អ្នកនាំសាររបស់លេខាស្រុកកំពង់សៀម ប្រាក់ យុត បានរំឮកថា ខ្លួនបានឃើញឡាន GMC ផ្ទុកដោយបុរស ស្ត្រី និងកុមារនៅភ្នំប្រុស ហើយក្រោយមកដឹងថាមនុស្សទាំងនោះត្រូវបានសម្លាប់នៅពេល ដែលនាងបានឮសូរសំឡេងកាំភ្លើង និងសំឡេងស្រែកចេញមកពីទីតាំងនោះមួយម៉ោងក្រោយមក[1847]។ សាក្សីម្នាក់ទៀតដែលបានរស់នៅភ្នំប្រុសក្រោមការការពាររបស់ ឈិត ជឿន *"បានឮប្រជាជនស្រែកថ្ងូរដោយការឈឺចាប់"* ហើយ ជឿន បានប្រាប់គាត់ថា នោះគឺជាអ្នកទោសកំពុងត្រូវបានសម្លាប់[1848]។ សំឡេងស្រែក និងទ្រហោយំក៏ត្រូវបានឮសូរផងដែរនៅពេលយប់ចេញមកពីអណ្តូងមួយ ដែលមានចម្ងាយប្រហែលកន្លះគីឡូម៉ែត្រពីភ្នំប្រុសភ្នំស្រី[1849]។

៥៥៣. ក្រោយពីវៀតណាមបានមកដល់នៅក្នុងខែ មករា ឆ្នាំ ១៩៧៩ សាក្សីនានាបានបំភ្លឺថា បានឃើញ *"រណ្តៅជាច្រើន"* ដែលមានទំហំមិនអាចបញ្ជាក់បាន ផ្ទុកទៅដោយឆ្អឹងមនុស្ស[1850]

---

[1846] ឯកសារ **D219/859** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡេង វ៉ា ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01373610-01373611 ឆ.៦៤-ឆ.៦៨។ ឯកសារ **D117/37** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡេង វ៉ា ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ERN 01072509 ឆ.២០។

[1847] ឯកសារ **D219/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ERN 01059295 ឆ.៩៣។

[1848] ឯកសារ **D3/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00630445 ឆ.៦-ឆ.៧។

[1849] ឯកសារ **D219/772** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ស៊ីម ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៦ ERN 01309839-01309842 ឆ.៥៨-ឆ.៧៩។

[1850] ឯកសារ **D3/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី កានឿន ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១០ ERN 00631100 ឆ.៣។ ឯកសារ **D219/377** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01132626 ឆ.៩។

រួមមាន *"ឆ្អឹង និងលលាដ៍ក្បាលចំនួនរាប់មិនអស់"*[1851] និងសាច់រលួយ[1852] នៅក្នុងទីតាំងចន្លោះពីភ្នំប្រុសភ្នំស្រីរហូតដល់អាកាសយានដ្ឋានខាងកើតភូមិស្រឡៅ។ តំបន់នោះមានធុំក្លិនស្អុយមិនអាចទ្រាំបានដោយសារក្លិនសាកសពស្អុយរលួយនៅក្នុងរណ្ដៅទាំងនោះ[1853] បញ្ជាក់ថារណ្ដៅទាំងនោះគឺនៅថ្មីៗនៅឡើយ។ មានរណ្ដៅដែលមានជម្រៅពីរម៉ែត្រ មាន៤ ឬ ៥ជួរនៅភាគខាងជើងភ្នំប្រុស[1854]។ នៅភូមិជិតនោះ គឺភូមិស្រឡៅ ឃុំអំពិល ស្រុកកំពង់សៀម *"មានរណ្ដៅយ៉ាងច្រើនដែលបានកប់សាកសពរាប់ពាន់នាក់"* ហើយមានរណ្ដៅពីរដែលមានទំហំបីម៉ែត្រ និងជម្រៅ១០ម៉ែត្រសុទ្ធតែដាក់សាកសពពេញរហូតដល់មាត់រណ្ដៅ[1855]។

៥៥៤. របាយការណ៍ផែនទីរបស់មជ្ឈមណ្ឌលឯកសារមួយ[1856] បង្ហាញថា មានមនុស្សចំនួន ១0000 នាក់ត្រូវបានសម្លាប់នៅភ្នំប្រុសភ្នំស្រី ហើយសាក្សីម្នាក់ឮថា មនុស្សដែលបានរាប់ឃើញច្រើន

---

[1851] ឯកសារ **D219/226** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពេញ វ៉ាំ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088623 ឆ.៩។ ឯកសារ **D3/20** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្រីការឿន ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១០ ERN 00631100 ឆ.៣។ ឯកសារ **D219/232** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វ៉ាន់ ឈុនសេង ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ERN 01090003 ឆ.៤៨។ ឯកសារ **D219/293** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជាម ពៅ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ERN 01111817 ឆ.១០។ ឯកសារ **D95** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ឹង លឹម ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ ERN 00746991។ ឯកសារ **D6.1.697** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ERN 00384434។ ឯកសារ **D3/10** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នីវ ស៊ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ERN 00623579។

[1852] ឯកសារ **D219/377** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មន ម៉ុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ERN 01132626 ឆ.១០។

[1853] ឯកសារ **D219/378** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តែម ឈាង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01132630 ឆ.១១។

[1854] ឯកសារ **D219/119.1.2** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ផ្លុង ហន ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ERN 00797011។

[1855] ឯកសារ **D219/378** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តែម ឈាង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ERN 01132628, 01132630 ឆ.១១។

[1856] ឯកសារ **D1.3.10.5** របាយការណ៍ស្ដីអំពីដំណើរទស្សនកិច្ចរបស់ក្រុមគូសផែនទី CGP ទៅកាន់ខេត្តកំពង់ចាម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៥ ERN 00208309។ *សូមមើលផងដែរ* ឯកសារ **D219/363** កំណត់ហេតុនៃការស្ដាប់

ជាងនោះទៀត *"មានលលាដ៍ក្បាលច្រើនជាងមួយម៉ឺន"* នៅក្នុងពេលដែលមានការកាយរណ្តៅនៅក្នុងឆ្នាំ ១៩៨០ ឬឆ្នាំ ១៩៨១[1857]។ ដោយផ្អែកលើហេតុផលដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១៣៦ តួលេខនេះមិនអាចយកមកធ្វើជាសំអាងបានឡើយ។

*ការទស្សនកិច្ចដោយ អោ អាន*

៥៥៥. មិនមានភស្តុតាងណាអាចយកមកសំអាងបានថា **អោ អាន** បានមកទស្សនកិច្ចនៅទីតាំងនេះឡើយ។ សាក្សីម្នាក់ដែលបានរស់នៅភ្នំប្រុសក្រោមការការពាររបស់ ធឿន អស់រយៈពេលមួយខែកន្លះបានបង្ហាញឱ្យមើលរូបថត **អោ អាន** ហើយបានបញ្ជាក់ថា នាងបានឃើញបុគ្គលនោះពីរដងនៅភ្នំប្រុសភ្នំស្រី[1858]។ ផ្ទុយមកវិញ អ្នកបើកបរឡានរបស់ **អោ អាន** និងអ្នកការពាររបស់ **អោ អាន** ទាំងពីរនាក់បដិសេធថា មិនដែលបានមកភ្នំប្រុសជាមួយ **អោ អាន** ឡើយ[1859]។

## ៦.៤.១.៨ មន្ទីរសន្តិសុខឧត្តរតាមាក់

*ទីតាំង និងការបង្កើត*

---

ចម្លើយសាក្សី ហាក់ សុផល ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ERN 01128233 ឆ.១០-ឆ.១១ [*ពន្យល់ថា ចំនួនតួលេខគឺផ្អែកលើ ឯកសារ ដែលរដ្ឋាភិបាលបានគាស់កកាយ ប្រមូលឆ្អឹងសាកសព នៅឆ្នាំ១៩៨២ និងការសាកសួរផ្ទាល់មាត់ជាមួយប្រធាន និងអនុប្រធានមន្ទីរវប្បធម៌ និងសាសនាខេត្ត*]។ ឯកសារ D219/366 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ERN 01128240 ឆ.២៨ (*"ស. ក្នុង ឯកសារ (CGP) របាយការណ៍បានបញ្ជាក់ថា មានមនុស្ស១០.០០០នាក់ត្រូវបានសម្លាប់នៅវត្តភ្នំប្រុស... តើតួលេខនេះផ្អែកលើអ្វី? ឆ. ខ្ញុំពុំបានទៅកាន់ទីតាំងនោះទេ។ របាយការណ៍នេះត្រូវបានធ្វើឡើងនៅមុនពេលខ្ញុំចូលធ្វើការជាមួយក្រុមការងារនេះ"*)។

[1857] ឯកសារ **D3/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី កានឿន ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ ERN 00631100 **ឆ.៤**។

[1858] ឯកសារ **D107/19.1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង សុគន្ធ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787239 **ឆ.២៦**។

[1859] ឯកសារ **D117/50** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ប៊ុន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ERN 01059870 **ឆ.៥០**។ ឯកសារ **D219/731** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ERN 01224109 **ឆ.៦៣**។

៥៥៦. វត្តតាមាក់ គឺជាមន្ទីរសន្តិសុខថ្នាក់តំបន់[1860] ឈាតសន្ទឹងលើផ្ទៃដីប្រហែលបីហិកតា[1861] ហើយមានទីតាំងស្ថិតនៅក្នុងភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម[1862]។ សាក្សី

---

[1860] ឯកសារ **D219/460** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ ERN 01151219 ទំ. ៩។ ឯកសារ **D219/504** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01167887 ទំ.១៦, 01167891 ទំ.៤២-ទំ.៤៣, 01167913 ទំ.១៤២។ ឯកសារ **D219/498** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វាំ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ERN 01156188 ទំ.៩។ ឯកសារ **D219/501** កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ERN 01141623។ ឯកសារ **D219/541** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ធឿន ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៥ ERN 01174523 ទំ.៣៨, 01174530 ទំ.៨៩។ ឯកសារ **D219/544** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុន ហេង ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ ERN 01174558 ទំ.១២។ ឯកសារ **D219/800** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ERN 01331739 ទំ.១៩៣។ ឯកសារ **D219/870** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រី ញ៉ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ERN 01373691 ទំ.៨៥, ទំ.៨៩។ ឯកសារ **D107/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម គុណ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787219។ សូមមើលផងដែរ ឯកសារ **D219/315** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ERN 01111982 ទំ.១៥២ (*"វត្តតាមាក់ជារបស់ថ្នាក់តំបន់ ប៉ុន្តែវាមិនមែនជាមន្ទីរសន្តិសុខទេ វាដូចជាកន្លែងទុកអ្នកទោសមួយរយៈ ដូចជា គេចាប់អ្នកទោសពីកន្លែងផ្សេងមក គេយកមកដាក់នៅវត្តតាមាក់មួយរយៈ ហើយគេក៏បញ្ជូនចេញទៅវិញ"*)។

[1861] ឯកសារ **D219/584** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01167237។

[1862] ឯកសារ **D36** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ម៉ាលី ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ERN 00722231។ ឯកសារ **D107/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញឹម គុណ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00787219។ ឯកសារ **D219/217** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆេន ហាម ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ERN 01088552 ទំ.១៧៥។ ឯកសារ **D219/288** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឺន ឡៃស៊ីម ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ERN 01111776 ទំ.៣៩។ ឯកសារ **D219/405** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ប៊ុនសេរី ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ERN 01148847 ទំ.៧០។ ឯកសារ **D219/442** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វណ្ណ ហៅ យក់ ង៉ូវ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥ ERN 01434559 ទំ.២៣៩។ ឯកសារ **D219/541** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ធឿន ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៥ ERN 01174522 ទំ.៣០។ ឯកសារ **D219/584** **D219/327** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01167236។ *ប្រៀប* ឯកសារ **D3/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នីវ ស៊ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ERN 00623577 ទំ.១ (*"នៅពេលនោះ ឃុំជ្រៃវៀន មានឈ្មោះថា សង្កាត់ខ្លែងពណ៌"*)។

ទាំងឡាយក៏បានហៅមន្ទីរសន្តិសុខនេះថា *"វត្តព្រៃទទឹង"*[1863] *"វត្តព្រៃឈេរ"*[1864] ឬ *"គុកព្រៃទទឹង"*[1865]។

៥៥៧. ទ្វារចូលធំ (ខាងត្បូង) ទៅកាន់ទីតាំងនោះស្ថិតនៅលើផ្លូវជាតិលេខ៧ នៅជិតសាលាឃុំព្រៃវៀនបច្ចុប្បន្ន[1866] ដែលមានចម្ងាយប្រហែល៥០០ ទៅ៦០០ម៉ែត្រភាគខាងលិចនៃអតីតមន្ទីរតំបន់៤១ របស់ **អោ អាន** និងមន្ទីរជាច្រើននៃបណ្តាមន្ទីរចំណុះឲ្យតំបន់៤១ ស្ថិតនៅជិតចំណុចប្រសព្វនៃផ្លូវជាតិលេខ៧ ផ្លូវ៦២ និងផ្លូវលេខ៧០[1867] នៅក្នុងភូមិព្រៃទទឹង[1868]។

---

សាក្សីសំដៅទៅលើទីតាំងឈ្មោះ ភូមិស្ពេង *យោង៖* ឯកសារ **D219/542** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នុត គីមណាង ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៥ ERN 01173595 ឆ.១។ ឯកសារ **D219/607** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាក់ គីមស្រៀន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01184901 ឆ.១។ ឯកសារ **D219/608** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ឹម ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ERN 01184909 ឆ.១។

ក៏មានភស្តុតាងគ្រប់គ្រាន់អាចសន្និដ្ឋានបានផងដែរថា **អោ អាន** បានកាន់កាប់មុខងាររបស់ កែ ពក ច្រើនឡើងៗ ក្នុងនាមជាលេខាភូមិភាគកណ្តាលស្តីទីនៅក្នុងស្ថានភាពជាក់ស្តែង មួយផ្នែកដោយសារថា កែ ពក នៅជាប់ការងារសឹកសង្គ្រាម។ ប៉ុន្តែ មិនច្បាស់ថាតើនៅពេលណាពិតប្រាកដ និងរយៈពេលយូរប៉ុន្មានដែលតួនាទីជាក់ស្តែងនេះត្រូវបានអនុវត្ត ហើយករណីដែលគាត់បានប្រើប្រាស់តួនាទីពិសេសនេះ ក៏មិនអាចរកឃើញមានដែរ។

## ៧.២. លក្ខណៈ និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានកើតឡើង

៧០៦. បន្ថែមពីតួនាទីខ្ពស់ជាផ្លូវការរបស់ **អោ អាន** ស្ថានទម្ងន់នៃសកម្មភាពរបស់គាត់ និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដោយសារសកម្មភាពរបស់គាត់ ជាពិសេសមកលើសហគមន៍ជនជាតិចាមដូចបានរៀបរាប់លម្អិតខាងលើ ផ្តល់ជាយុត្តិកម្មសម្រាប់សេចក្តីសន្និដ្ឋានថា គាត់គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។

៧០៧. បទចោទសំខាន់ដែលត្រូវចោទ **អោ អាន** ហើយជាបទចោទតែមួយក៏ច្បាស់ជាឱ្យគាត់ស្ថិតនៅក្នុងដែនយុត្តាធិការបុគ្គលនោះ គឺបទចោទអំពើប្រល័យពូជសាសន៍ជនជាតិចាមនៅតំបន់ភូមិភាគកណ្តាល។

៧០៨. **អោ អាន** មានតួនាទីច្បាស់លាស់ក្នុងការរៀបចំ និងអនុវត្តការបំបាត់ជនជាតិចាមនៅភូមិភាគកណ្តាលនៅទូទាំងតំបន់ ៤១ ជាពិសេស ប៉ុន្តែ ក៏បានផ្តល់ការគាំទ្រភស្តុភារយ៉ាងសំខាន់ដល់ការសម្របសម្រួលផ្លាស់ជនជាតិចាមពីភូមិភាគបូព៌ា ទៅតំបន់ ៤១ ដែលនៅតំបន់នេះជនជាតិចាមត្រូវបានសម្លាប់ ដូចគ្រប់កន្លែងផ្សេងទៀតដែរ គឺត្រូវបានសម្លាប់សុទ្ធសាធ ដោយសារតែថាពាក់ព័ន្ធនឹងបញ្ហាជាតិពន្ធុ និងសាសនារបស់ជនជាតិចាម។ ការសម្លាប់ជនជាតិចាមនៅតំបន់ ៤១ កើតឡើងខ្លាំង និងមានលក្ខណៈជាទូទៅជាងទីកន្លែងផ្សេងទៀតនៅភូមិភាគកណ្តាល។ ការបំបាត់ជនជាតិចាមនៅក្រោមឥទ្ធិពលរបស់ **អោ អាន** ក្រោយពីគាត់កាន់តំណែងនៅភូមិភាគកណ្តាល គឺកើនឡើងមិនឈប់ឈររហូតដល់ចំណុចកំពូល គួរឱ្យតក់ស្លុតប្រណី និងមានលក្ខណៈជាប្រព័ន្ធយ៉ាងសាហាវ។

01588923



៧០៩. តាមការគណនាចំនួនតាមបែបអភិរក្សនិយមខ្លាំង ជនជាតិចាមយ៉ាងតិចបំផុតចំនួន **១៧១១៥** នាក់ ត្រូវបានសម្លាប់នៅភូមិភាគកណ្តាល នៅក្នុងអំឡុងពេលដែល **អោ អាន** កាន់តំណែង ប៉ុន្តែ ចំនួននេះទំនងខ្លាំងអាចច្រើនជាងនេះ។

៧១០. ប៉ុន្តែ **អោ អាន** ក៏ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនផងដែរ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មផ្តាច់ជាតិ ក្រៅពីដាក់មុខសញ្ញាលើជនជាតិចាម ដូចបានបង្ហាញលម្អិតនៅផ្នែកមុនៗ។

៧១១. មនុស្សចំនួន **១២៨៤៤** នាក់ ជាចំនួនប៉ាន់ស្មានយ៉ាងតិចបំផុតតាមបែបអភិរក្សនិយម (រាប់បញ្ចូលទាំងជនជាតិចាមចំនួន ១៧៤៣ នាក់ ហើយចំនួននេះទំនងខ្លាំងអាចច្រើនជាងនេះទៀត) ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សដែល **អោ អាន** ទទួលខុសត្រូវ។ **អោ អាន** ក៏ទទួលខុសត្រូវចំពោះការដ្ឋាន ដែលមនុស្សរាប់ពាន់ត្រូវបានបង្ខំឱ្យធ្វើការក្នុងស្ថានភាពលំបាកយ៉ាងខ្លាំង និងគំរាមសម្លាប់ ប្រសិនបើពួកគេមានកំហុស ឬធ្វើការងារក្នុងរបៀបមួយ ដែលចាត់ទុកថាមិនគួរជាទីពេញចិត្ត។

**៧.៣. សេចក្តីសន្និដ្ឋាន**

៧១២. សរុបមក ទាំងតួនាទី ទាំងការប្រព្រឹត្តិរបស់ **អោ អាន** បង្ហាញឱ្យឃើញច្បាស់ថា គាត់គឺជាអ្នកដើរតួនាទីសំខាន់ម្នាក់នៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ ហើយជាអ្នកចូលរួមដោយមានឆន្ទៈ និងទឹកចិត្តនៅក្នុងការអនុវត្តគោលនយោបាយអមនុស្សធម៌របស់កម្ពុជាប្រជាធិបតេយ្យក្នុងរបៀបព្រៃផ្សៃ និងឧក្រិដ្ឋ។

## ៨. ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីបទឧក្រិដ្ឋ

### ៨.១. ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៧១៣. ចាប់តាំងពីប្រហែលចុងឆ្នាំ ១៩៧៦ រហូតដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ប.ក.ក. បាន អនុវត្តការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល នៅក្នុងភូមិភាគកណ្តាលរបស់កម្ពុជាប្រជាធិបតេយ្យ ដោយរួមទាំងនៅក្នុងតំបន់៤១ ផងដែរ។ ការវាយប្រហារនោះ ត្រូវបានអនុវត្តក្នុងទិដ្ឋភាពចម្បងៗចំនួន៤។

៧១៤. ចំពោះទិដ្ឋភាពទីមួយ ប.ក.ក. អនុវត្តគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋាន នៅពាសពេញប្រទេសកម្ពុជា និងផ្លាស់ទីលំនៅប្រជាជនទាំងអស់ដោយបង្ខំឱ្យទៅធ្វើការនៅតាមសហករណ៍ និងការដ្ឋានទាំងនោះ។ គោលបំណងចម្បង គឺប្រែក្លាយប្រទេសកម្ពុជា ទៅជារដ្ឋសង្គមនិយមឯករាជ្យម្ចាស់ការ ដែលពឹងផ្អែកលើសេដ្ឋកិច្ចកសិកម្ម។ ប.ក.ក. បានបង្ខំប្រជាជនស៊ីវិលឱ្យធ្វើការដោយគ្មានប្រាក់បៀវត្សរ៍ និងនៅក្នុងស្ថានភាពការងារនិងជីវភាពរស់នៅប្រកបដោយគ្រោះថ្នាក់ ដែលធ្វើឱ្យអ្នកធ្វើការទទួលរងទុក្ខវេទនាទាំងផ្លូវកាយនិងផ្លូវចិត្ត។ មនុស្សជាច្រើនបានស្លាប់ ដោយសារការនឿយហត់បាក់កម្លាំង ការបង្អត់អាហារ និងជំងឺ។ មនុស្សផ្សេងទៀតត្រូវបានសម្លាប់ដោយសារកំហុសតូចតាច ឬដោយសារហេតុផលតាមអំពើចិត្តផ្សេងៗទៀត។

៧១៥. ទិដ្ឋភាពទី២ នៃការវាយប្រហាររបស់ ប.ក.ក. ទៅលើប្រជាជនស៊ីវិលនៅក្នុងភូមិភាគកណ្តាល គឺការអប់រំ "*សមាសភាពមិនល្អ*" និងការសម្លាប់ "*ខ្មាំង*" ទាំងនៅក្នុង និងក្រៅ ជួរ ប.ក.ក.។ ប.ក.ក. បានបង្កើតមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស នៅពាសពេញភូមិភាគនោះ ដែលត្រូវបានគេប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណ ត្រួតពិនិត្យ និងអប់រំ ឬសម្លាប់អ្នកដែលត្រូវគេសន្មតថាជាខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ។ អ្នកណាម្នាក់ដែលត្រូវគេសង្ស័យថាបានប្រព្រឹត្តកំហុសតូចតាច ឬមិនស្មោះត្រង់ គឺជាគោលដៅដ៏មានសក្តានុពលសម្រាប់ការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់។

៧១៦. ចំពោះទិដ្ឋភាពទីបី ប.ក.ក. បានកំណត់អត្តសញ្ញាណ ផ្តោតគោលដៅ និងបោសសម្អាតជាប្រព័ន្ធ នូវប្រភេទមនុស្សជាក់លាក់ដែលត្រូវគេសន្មតថាជាគ្រោះគម្រាមកំហែងដ៏មាន

01588925



សក្តានុពល ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ឬមានទស្សនៈផ្ទុយពីទ្រឹស្តីរបស់ ប.ក.ក.។ មនុស្សទាំងអស់នេះ រួមមាន កម្មាភិបាលភូមិភាគកណ្តាល ប្រជាជនដែលត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅចេញពីតំបន់ទីក្រុង អតីតយោធា និងមន្ត្រីផ្សេងៗទៀតរបស់សាធារណរដ្ឋខ្មែរ ប្រជាជនមកពីភូមិភាគបូព៌ា ប្រជាជនចាម និងមនុស្សផ្សេងទៀតដែលមានអត្តសញ្ញាណសាសនា ជាតិពន្ធុ នយោបាយ សេដ្ឋកិច្ច ឬជាតិ ដែលត្រូវគេសន្មតថាជាគ្រោះគម្រាមកំហែងចំពោះគោលដៅរបស់ ប.ក.ក. ក្នុងការផ្លាស់ប្តូរសង្គមកម្ពុជា។ យ៉ាងហោចណាស់ មនុស្សរាប់ម៉ឺននាក់ត្រូវបានគេផ្តោតជាគោលដៅ ក្នុងការបោសសម្អាតភូមិភាគកណ្តាលដែលមានលក្ខណៈជាប្រព័ន្ធ។ មានមនុស្សតិចតួចប៉ុណ្ណោះ នៅរស់រានមានជីវិត។

៧១៧. ទិដ្ឋភាពទី៤ នៃការវាយប្រហាររបស់ ប.ក.ក. ទៅលើប្រជាជនភូមិភាគកណ្តាល គឺការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដើម្បីបង្កើនចំនួនប្រជាជន និងកសាងគ្រួសារដែលមានមនោគមវិជ្ជាបរិសុទ្ធ។ ប.ក.ក. បង្ខំប្រជាជនឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយដៃគូ ដែលត្រូវបានជ្រើសរើសដោយ "*អង្គការ*" ហើយ នៅក្នុងករណីជាច្រើន ប.ក.ក. បានបង្ខំគូស្រករឱ្យរួមភេទ។

៧១៨. លក្ខណៈជាប្រព័ន្ធនៃការវាយប្រហារ ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈ ការរៀបចំផែនការដែលមានលក្ខណៈមជ្ឈការ ការរៀបចំ និងការអនុវត្ត ដែលមានពាក់ព័ន្ធជាមួយនឹងរដ្ឋបាលស៊ីវិលគ្រប់លំដាប់ថ្នាក់ទាំងអស់ និងកងទ័ពបដិវត្តន៍កម្ពុជា។ ជាងនេះទៅទៀត ភាពទូលំទូលាយនៃការវាយប្រហារ ត្រូវបានបង្ហាញតាមរយៈវិសាលភាពពេលវេលា និងភូមិសាស្ត្រដ៏ទូលំទូលាយនៃការវាយប្រហារ ព្រមទាំង ចំនួនជនរងគ្រោះដ៏ច្រើនមហាសាល។ ជាក់ស្តែង ការវាយប្រហារ ត្រូវបានផ្តោតគោលដៅប្រឆាំងនឹងប្រជាជនស៊ីវិលភូមិភាគកណ្តាលទាំងស្រុង។ ការវាយប្រហារត្រូវបានអនុវត្តដោយសារមូលហេតុនយោបាយ ពោលគឺការវាយប្រហារនេះគឺជាការអនុវត្តរបៀបវារៈនយោបាយរបស់ ប.ក.ក.។

៧១៩. ក្នុងឋានៈជាលេខាតំបន់៤១ និងជាអនុលេខា និងជាសមាជិក គណៈភូមិភាគកណ្តាល **អោ អាន** គឺជាអ្នកចូលរួមដ៏សំខាន់ម្នាក់នៅក្នុងការវាយប្រហារជាប្រព័ន្ធនិងទូលំទូលាយប្រឆាំងនឹងប្រជាជនស៊ីវិល។ តាមរយៈការប្រជុំជាទៀងទាត់ ដំណើរទស្សនកិច្ចទៅកាន់

01588926



ការដ្ឋាន និងប្រព័ន្ធវាយការណ៍ដ៏តឹងរ៉ឹងរបស់ ប.ក.ក. **អោ អាន** បានដឹងយ៉ាងពេញលេញអំពីការវាយប្រហារ និងដឹងថាអំពើរបស់គាត់ គឺជាផ្នែកមួយនៃការវាយប្រហារនេះ។

## ៨.២. ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីបទឧក្រិដ្ឋនៅក្នុងតំបន់៤១

### ៨.២.១. ការដ្ឋានពលកម្មដោយបង្ខំ ទំនប់អន្លង់ជ្រៃ

*បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧២០. ការសម្លាប់អ្នកធ្វើការជាក្រុមតូចៗ នៅតាមទីកន្លែងនានាក្បែរការដ្ឋានទំនប់អន្លង់ជ្រៃ ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ចំពោះអ្នកធ្វើការមួយចំនួន ដែលត្រូវបានគេនាំយកចេញទៅនៅពេលយប់ ដោយសារតែកំហុសដែលគេបានសន្មត ហើយមិនឃើញត្រឡប់មកវិញ គេក៏អាចធ្វើការសន្និដ្ឋានផងដែរថាអ្នកទាំងនោះត្រូវបានគេសម្លាប់ក្រោយពេលត្រូវបានគេនាំយកចេញទៅ។

៧២១. បន្ថែមពីលើនេះ ការស្លាប់របស់អ្នកធ្វើការដែលបណ្តាលមកពីអាហារ និងទឹកគ្មានអនាម័យ កង្វះអាហារូបត្ថម្ភ និងការងារធ្ងន់ធ្ងរ មានចរិតលក្ខណៈគ្រប់គ្រាន់ក្លាយជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បុគ្គលិកនៅតាមការដ្ឋាន ពិតជាបានប្រមើលមើលដឹងជាមុននូវលទ្ធផលដ៏ច្បាស់មិនអាចប្រកែកបានថា ការដាក់អ្នកធ្វើការនៅក្នុងស្ថានភាពដ៏លំបាកបែបនោះ អាចនឹងបណ្តាលឱ្យពួកគេស្លាប់។ តែទោះជាយ៉ាងណាក៏ដោយ ពួកគេនៅតែសម្រេចចិត្តអនុវត្តស្ថានភាពការងារ និងរស់នៅដ៏អាក្រក់ទាំងនេះ។

*បទធ្វើឱ្យក្លាយទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧២២. បទធ្វើឱ្យក្លាយទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តនៅការដ្ឋានទំនប់អន្លង់ជ្រៃ។

៧២៣. បុគ្គលិកនៅការដ្ឋានទំនប់អន្លង់ជ្រៃ បានអនុវត្តអំណាចជាម្ចាស់កម្មសិទ្ធលើអ្នកធ្វើការ ដោយកំហិតការធ្វើចលនារបស់ពួកគេ គ្រប់គ្រងពេលវេលា និងទីកន្លែងដែលពួកគេដេក និងអាហារដែលពួកគេហូប និងបង្ខំពួកគេឱ្យធ្វើការងារធ្ងន់ ក្រោមការគម្រាមកំហែងនៃការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ប្រសិនបើពួកគេមិនបំពេញការងារតាមផែនការកំណត់ ឬ មិនធ្វើត្រឹមត្រូវ

តាមបញ្ញាលម្អិត។ តាមរយៈចរិតលក្ខណៈជាប្រព័ន្ធ និងដែលមានការរៀបចំរបស់ការដ្ឋាន គេអាចសន្និដ្ឋានថា ស្ថានភាពទាំងនេះត្រូវបានអនុវត្ត ដោយមានគោលបំណងអនុវត្តអំណាចជាម្ចាស់កម្មសិទ្ធិលើអ្នកទោស។

*បទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧២៤. ការធ្វើបាប និងស្ថានភាពដែលត្រូវបានអនុវត្តលើអ្នកធ្វើការនៅទំនប់អន្លង់ជ្រៃ គឺជាបទអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧២៥. អ្នកធ្វើការនៅទំនប់អន្លង់ជ្រៃ ប្រឈមនឹងស្ថានភាពដ៏អាក្រក់។ ប្រជាជនត្រូវបានគេបង្ខំឱ្យធ្វើការងាររហូតបាក់កម្លាំងធ្ងន់ធ្ងរ។ ពួកគេត្រូវបានដកហូតសិទ្ធិទទួលបានអាហារ និងទឹកគ្រប់គ្រាន់ ហើយជួនកាល ការដកហូតនេះគឺជាទម្រង់នៃការដាក់ទណ្ឌកម្ម ហើយអ្នកធ្វើការដែលមានជំងឺ ត្រូវគេផ្តល់អាហារតិចជាងមុន។ អ្នកធ្វើការរស់នៅក្នុងស្ថានភាពភ័យខ្លាចគ្រប់ពេលវេលាថាពួកគេនឹងត្រូវគេធ្វើបាបផ្នែករាងកាយ ឬត្រូវសម្លាប់។ អ្នកធ្វើការដែលត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តកំហុសតូចតាច ដូចជាធ្វើឱ្យបែកបាក់ឧបករណ៍ ឬលួចអាហារបានបាត់ខ្លួនជារៀងរាល់ថ្ងៃ។ ជាទូទៅ នៅពេលយប់ ប្រជាជនត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ពួកគេ និងត្រូវបាននាំយកចេញទៅជាសម្ងាត់ ដោយផ្អែកលើការចោទប្រកាន់ថា "*ខ្ជិល*" ជា"*ខ្មាំង*" ឬ"*មិនគោរពតាមអង្គការ*"។ មិនមានជម្រើសដំណោះស្រាយតាមផ្លូវច្បាប់ ឬការធានានិតិវិធីនោះឡើយ។ ការអនុវត្តស្ថានភាពបែបនេះចំពោះអ្នកធ្វើការបានរំលោភបំពានសិទ្ធិទទួលបានសេរីភាព និងសន្តិសុខរបស់មនុស្ស សិទ្ធិទទួលបានសេរីភាពនៃការធ្វើដំណើរ និងរស់នៅ សិទ្ធិប្រឆាំងនឹងការធ្វើការដោយបង្ខំ និងសិទ្ធិប្រឆាំងនឹងការប្រព្រឹត្តិឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក។ និយាយដោយឡែក ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ បានរំលោភបំពាន ការការពារប្រឆាំងនឹងការនិរទេសដោយខុសច្បាប់ ឬការផ្លាស់ទីលំនៅដោយខុសច្បាប់។ ជារួម ស្ថានភាពដែលអ្នកធ្វើការបានប្រឈមបានបង្កឱ្យមានព្យសនកម្មរាងកាយនិងផ្លូវចិត្តធ្ងន់ធ្ងរ និងត្រូវបានចាត់ទុកថាជាការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ដែលមានចរិតលក្ខណៈនិងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងបទឧក្រិដ្ឋផ្សេងៗទៀតដែលត្រូវបានចែងនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក.។

៧២៦. ចារីមានចេតនាធ្វើបាបអ្នកធ្វើការនៅទំនប់អន្លង់ជ្រៃដោយដឹងយ៉ាងច្បាស់ថា អំពើនេះពិតជាបង្កឲ្យមានការឈឺចាប់ផ្នែករាងកាយ ឬផ្លូវចិត្ត និងត្រូវចាត់ទុកថាជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

*បទមនុស្សឃាតគិតទុកជាមុន*

៧២៧. ការសម្លាប់នៅការដ្ឋានទំនប់អន្លង់ជ្រៃ ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតគិតទុកជាមុន ដោយអនុលោមតាមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

## ៨.២.២. ទីកន្លែងសម្លាប់មនុស្សគោកព្រីង

*បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧២៨. ការសម្លាប់មនុស្សចំនួន១០៣០នាក់ ដែលត្រូវបានអនុវត្តនៅចន្លោះពីដើមឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅទីកន្លែងសម្លាប់មនុស្សគោកព្រីង ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*បទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧២៩. ការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំនៅទីកន្លែងសម្លាប់មនុស្សគោកព្រីង ក៏បំពេញតាមលក្ខខណ្ឌ *"ទ្រង់ទ្រាយធំ"* ដើម្បីក្លាយជាបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។

៧៣០. ការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ត្រូវបានអនុវត្តយ៉ាងស៊ីចង្វាក់ ចាប់តាំងពីដើមឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេផ្តោតគោលដៅទៅលើក្រុមប្រជាជនផ្សេងៗគ្នា ដោយរួមទាំងកម្មាភិបាលភូមិភាគកណ្តាល និងក្រុម *"ប្រជាជន ១៧ មេសា"* ដែលមានចំនួនច្រើន និងប្រជាជនចាម។ ក្រៅពីករណីលើកលែងក្នុងចំនួនតូច ប្រជាជនទាំងអស់ដែលត្រូវបាននាំយកមកកាន់ទីកន្លែងសម្លាប់មនុស្សនេះ សុទ្ធតែត្រូវបានសម្លាប់ទាំងអស់។ អ្នកសម្លាប់បានប្រើប្រាស់រណ្តៅកប់សាកសពធំៗ ដែលត្រូវបានជីកជាមុននៅនឹងទីកន្លែងសម្លាប់មនុស្ស។ សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថាការសម្លាប់ត្រូវបានអនុវត្ត ដោយមានចេតនាពេញលេញក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ។

*បទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៣១. បទមនុស្សឃាត និងបទសម្លាប់រង្គាល ក៏ត្រូវបានចាត់ទុកថាជាបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។

៧៣២. ទីកន្លែងសម្លាប់មនុស្សគោកព្រីង គឺជាមធ្យោបាយមួយដើម្បីអនុវត្តការសម្លាប់កម្មាភិបាលភូមិភាគកណ្តាល និង *"ប្រជាជន ១៧ មេសា"* ដោយប្រសិទ្ធភាព។ ក្រុមមនុស្សទាំងអស់នេះត្រូវបានចាត់ទុកថាជា *"ជនក្បត់"* *"សមាសភាពមិនល្អ"* និង *"ខ្មាំងផ្ទៃក្នុង"* ដែលការចាត់ចំណាត់ថ្នាក់នេះត្រូវបានប្រើប្រាស់សម្រាប់អ្នក ដែលត្រូវបានសង្ស័យថាជាគិញបរទេស ឬអ្នកដែលមានឥរិយាបថដែលត្រូវគេចាត់ទុកថាផ្ទុយពីគោលនយោបាយរបស់ ប.ក.ក.។ ពួកគេត្រូវបានផ្តោតជាគោលដៅ និងត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំ ដោយសារពួកគស្ថិតនៅក្នុងក្រុមមនុស្សទាំងនេះ។

៧៣៣. មានភស្តុតាងមិនគ្រប់គ្រាន់នោះឡើយ ដើម្បីធ្វើការសន្និដ្ឋានថាអតីតយោធា លន់ នល់ ត្រូវបានសម្លាប់នៅទីកន្លែងសម្លាប់មនុស្សគោកព្រីង ក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយកម្មាភិបាលភូមិភាគនិរតី។

*បទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៣៤. បទមនុស្សឃាត និងបទសម្លាប់រង្គាល ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនចាម ក៏ត្រូវបានចាត់ទុកថាជាបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។ ប្រជាជនចាមត្រូវបានផ្តោតជាគោលដៅ ដោយសារសាសនារបស់ពួកគេ និងត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំ នៅទីកន្លែងសម្លាប់មនុស្សគោកព្រីង។

*បទមនុស្សឃាតគិតទុកជាមុន*

៧៣៥. ការសម្លាប់មនុស្សនៅទីកន្លែងសម្លាប់មនុស្សគោកព្រីង ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតគិតទុកជាមុន ដោយអនុលោមតាមមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

### ៨.២.៣. មន្ទីរសន្តិសុខមិត្តសុខ

*បទដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ*

៧៣៦. ការឃុំខ្លួនមនុស្សនៅមន្ទីរសន្តិសុខមិត្តសុប ចាប់តាំងពីដើមឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់ទុកថាជាបទដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៣៧. អ្នកដែលត្រូវចាប់ខ្លួន ត្រូវបានជ្រើសរើសដោយមូលហេតុតាមអំពើចិត្ត ដោយមូលហេតុទាំងនោះមានដូចជា "*កំហុស*" ជាកម្មាភិបាលភូមិភាគកណ្តាលឬបូព៌ា ឬជា "*ប្រជាជន១៧មេសា*" ឬ មានសមាជិកគ្រួសារ ដែលត្រូវបានបោសសម្អាត។ ភ័ស្តុតាងបានបង្ហាញនូវលំនាំនៃការចាប់ខ្លួន និងការឃុំខ្លួន ដោយពុំមាននិតិវិធីច្បាប់ត្រឹមត្រូវ។ ជាទៀងទាត់ អាជ្ញាធរបានប្រមូលផ្តុំមនុស្សដោយប្រើប្រាស់លេសក្លែងក្លាយ ដើម្បីធ្វើការចាប់ខ្លួន។ នៅពេលត្រូវគេឃុំខ្លួនអ្នកទោសត្រូវបានគេដាក់ខ្នោះជើង ឬត្រូវបានគេបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ នៅក្រោមការត្រួតពិនិត្យដោយអ្នកយាមដែលមានអាវុធ។ នៅចុងបញ្ចប់ មនុស្សដែលត្រូវបានបញ្ជូនទៅកាន់មិត្តសុប ត្រូវបានសម្លាប់នៅទីនោះ តែទោះជាយ៉ាងណាក៏ដោយ មុនពេលត្រូវគេសម្លាប់អ្នកទោសត្រូវបានគេឃុំខ្លួន ក្នុងរយៈពេលមួយវែងសមស្របដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរចាំបាច់សម្រាប់បង្កើតបានជាបទឧក្រិដ្ឋដាក់ក្នុងមន្ទីរឃុំឃាំង។

៧៣៨. ពាក់ព័ន្ធនឹងលក្ខណៈជាប្រព័ន្ធ និងវិសាលភាពនៃការឃុំខ្លួននៅមន្ទីរសន្តិសុខមិត្តសុប សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថាអាជ្ញាធរមានចេតនាដកហូតសេរីភាពរបស់អ្នកជាប់ឃុំតាមអំពើចិត្ត។

*បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៣៩. ការសម្លាប់មនុស្សយ៉ាងហោចណាស់ចំនួន២៨៤នាក់ តាមរយៈការសម្លាប់ ឬតាមរយៈការបង្អត់អាហារ នៅមន្ទីរសន្តិសុខមិត្តសុប ចាប់តាំងពីដើមឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*បទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៤០. ដោយថ្លឹងថ្លែងទៅលើភវនីយភាព មានភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើសេចក្តីសន្និដ្ឋានថា ការធ្វើបាបអ្នកទោសនៅមន្ទីរសន្តិសុខមិត្តសុប គឺជាបទធ្វើទារុណកម្ម។ មន្ត្រីគុកបានប្រព្រឹត្តអំពើ

01588931



បរិង្សាចំពោះអ្នកជាប់ឃុំ ក្នុងអំឡុងពេលសួរចម្លើយ ក្នុងគោលបំណងទទួលបានព័ត៌មាន និងសេចក្តីសារភាព ដែលត្រូវបានហាមឃាត់។ ឌុច ដែលជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខនេះ ក្នុងអំឡុងពេលវេលាពាក់ព័ន្ធនោះ សារភាពថា អ្នកទោសត្រូវបានសួរចម្លើយជាប្រចាំ ប៉ុន្តែគាត់អះអាងថា គាត់មិនបានឃើញវិធីសាស្ត្រដែលអ្នកសួរចម្លើយបានប្រើប្រាស់នោះឡើយ។ សាក្សីមួយរូបបានឮសំឡេងស្រែករបស់អ្នកទោស នៅពេលដែលមន្ទីរសន្តិសុខនេះកំពុងដំណើរការ និងបានឃើញ "*ឧបករណ៍សួរចម្លើយ*" នៅប៉ុន្មានថ្ងៃក្រោយមន្ទីរសន្តិសុខនេះត្រូវបានបោះបង់ចោល។ ដោយផ្អែកលើភ័ស្តុតាងនេះ និងការណ៍ដែលថាទារុណកម្មត្រូវបានប្រើប្រាស់ជាបច្ចេកទេសសួរចម្លើយទូទៅ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេសក្នុងអំឡុងពេលបោសសម្អាតភូមិភាគកណ្តាល គេអាចសន្និដ្ឋានថា អ្នកជាប់ឃុំទទួលរងនូវការឈឺចាប់ ឬទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ ក្នុងអំឡុងពេលសួរចម្លើយ។

*បទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៤១. ការប្រព្រឹត្តិចំពោះអ្នកទោស និងស្ថានភាពនៃការឃុំខ្លួននៅមន្ទីរសន្តិសុខមិត្តសុប ចាប់តាំងពីដើមឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ គឺជាបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៤២. ស្ថានភាពឃុំខ្លួននៅមន្ទីរសន្តិសុខមិត្តសុប បង្កឱ្យមានទុក្ខវេទនា ឬរបួសនកម្មរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ និងជាការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ អ្នកទោសត្រូវបានដាក់ខ្នោះជើងជាក្រុម ហើយអ្នកទោសខ្លះមានស្លាកស្នាមដែលបណ្តាលមកពីការដាក់ខ្នោះនេះ។ របបអាហារមិនគ្រប់គ្រាន់ ហើយអ្នកទោស មានសុខភាពទន់ខ្សោយ និងស្គមស្គាំងយ៉ាងខ្លាំង។ អ្នកទោសខ្លះបានស្លាប់ ដោយសារការបង្អត់អាហារ។ សំឡេងស្រែករបស់អ្នកទោសត្រូវគេស្តាប់ឮពីខាងក្រៅបរិវេណគុក។ ស្ថានភាពអនាម័យ គឺមានសភាពអាក្រក់ដែលមិនអាចពណ៌នាបាន៖ មាន ចៃ និងសង្កើចនៅពាសពេញមន្ទីរសន្តិសុខ។ គ្រូពេទ្យមិនមានឧបករណ៍ និងឱសថទេ។ នៅពេលអ្នកជាប់ឃុំមិនត្រូវបានគេដាក់ខ្នោះ ពួកគេត្រូវបានបង្ខំឱ្យធ្វើការងារធ្ងន់ធ្ងរ។ ចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរ នៃអំពើសកម្មនិងអកម្មទាំងនេះ គឺប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋផ្សេងៗទៀតដែលត្រូវបានចែងនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក.។

៧៤៣. យោធា និងអ្នកយាម នៅមន្ទីរសន្តិសុខមិត្តសុប ត្រូវគពិនិត្យអ្នកទោសជាប់ជាប្រចាំ។ ក្នុងនាមជាចារីផ្ទាល់នៃបទប្រព្រឹត្តអមនុស្សធម៌ចំពោះអ្នកជាប់ឃុំ ពួកគេបានបង្កើតស្ថានភាពឃុំខ្លួននេះដោយចេតនា ដោយដឹងថាវាបង្កព្យសនកម្មធ្ងន់ធ្ងរ និងបង្កឱ្យមានការវាយប្រហារធ្ងន់ធ្ងរប្រឆាំងនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ។

*បទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៤៤. បទដាក់ក្នុងមន្ទីរឃុំឃាំង បទមនុស្សឃាត បទធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងអតីតកម្មាភិបាលភូមិភាគកណ្ដាល និង "*ប្រជាជន១៧មេសា*" ត្រូវបានចាត់ទុកថាជាបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ក្រុមមនុស្សទាំងនេះ ត្រូវបានចាត់ទុកថាជា "*ជនក្បត់*" "*ខ្មាំងផ្ទៃក្នុង*" ឬ "*សមាសភាពមិនល្អ*" និងត្រូវបានផ្ដោតជាគោលដៅ នៅពេញទូទាំងតំបន់៤១ ពីព្រោះពួកគេ ត្រូវបានសន្មតថាមានឥរិយាបថ ឬមានទស្សនៈប្រឆាំង ឬផ្ទុយទៅនឹងទស្សនៈនិងគោលនយោបាយរបស់ ប.ក.ក.។ នៅមន្ទីរសន្តិសុខ មិត្តសុប ពួកគេត្រូវបានដកហូតសេរីភាពរបស់ពួកគេ ដោយពុំមាននិតិវិធីច្បាប់ត្រឹមត្រូវ ពួកគេត្រូវបានធ្វើទារុណកម្ម សម្លាប់ និងទទួលរងស្ថានភាពអមនុស្សធម៌នៃការឃុំខ្លួន ការរំលោភបំពានរូបរាងកាយ និងការធ្វើការងារដោយបង្ខំ។

៧៤៥. មានភស្តុតាងមិនគ្រប់គ្រាន់ដែលបង្ហាញថា អតីតយោធា លន់ នល់ ត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខមិត្តសុប ក្រោយការមកដល់នៃកម្មាភិបាលភូមិភាគនិរតី។

*បទមនុស្សឃាតគិតទុកជាមុន*

៧៤៦. ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខមិត្តសុប ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតគិតទុកជាមុន ដោយអនុលោមតាមមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

### ៨.២.៤. មន្ទីរសន្តិសុខឆ្លូងមេខ និងទក្កអង្គញាដី

*បទដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ*

៧៤៧. ការឃុំខ្លួនមនុស្សនៅទួលបេង និងវត្តអង្គញ្ញជី ត្រូវបានចាត់ទុកថាជាបទដាក់ក្នុងមន្ទីរឃុំឃាំង នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៤៨. ជាផ្នែកមួយនៃការបោសសម្អាតតំបន់៤១ ក្រុមមនុស្សជាក់លាក់ត្រូវបានផ្តោតជាគោលដៅ និងត្រូវបានឃុំខ្លួននៅទួលបេង និងវត្តអង្គញ្ញជី ដែលមានដូចជា *"ប្រជាជន ១៧ មេសា"* កម្មាភិបាលភូមិភាគកណ្តាល ប្រជាជនចាម និងអ្នកដែលមានទំនាក់ទំនងជាមួយរបប លន់ នល់។ សមាជិកក្រុមមនុស្សទាំងនេះ ត្រូវបានដកហូតដោយចេតនា នូវសេរីភាពរបស់ពួកគេ ដោយសារហេតុផលតាមអំពើចិត្ត និងដោយពុំមាននីតិវិធីច្បាប់ទាល់តែសោះ។ ប្រជាជន ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុសតូចតាច ដូចជា លួច ឬ *"កំហុសសីលធម៌"* ក៏ត្រូវបានបញ្ជូនទៅកាន់ទួលបេង និងវត្តអង្គញ្ញជីផងដែរ។ ដោយសារពុំមានមូលដ្ឋានច្បាប់ សមស្រប ដើម្បីផ្តល់ភាពត្រឹមត្រូវដល់ការដកហូតសេរីភាពដោយផ្អែកលើមូលដ្ឋាននៃការ ចោទប្រកាន់តូចតាច ការចោទប្រកាន់ទាំងនេះក៏ត្រូវចាត់ទុកថាមានលក្ខណៈតាមអំពើចិត្ត ផងដែរ ទោះបីជាអ្នកទោសទាំងនេះ ត្រូវបានសង្ស័យថាបានប្រព្រឹត្តកំហុសក៏ដោយ។

៧៤៩. *"អ្នកទោសធ្ងន់"* ឬ *"មនុស្សសំខាន់"* ត្រូវបានគេផ្ទេរចេញ បន្ទាប់ពីត្រូវគេឃុំខ្លួននៅទីនោះ រយៈពេលមួយយប់ ហើយអ្នកទោសខ្លះអាចត្រូវគេសម្លាប់ ក្រោយពេលគេបញ្ជូនទៅដល់ ទួលបេង និងវត្តអង្គញ្ញជីក្នុងមួយរយៈពេលខ្លី ចំណែកអ្នកទោសផ្សេងទៀតត្រូវបានឃុំខ្លួន ក្នុងរយៈពេលមួយវែងគ្រប់គ្រាន់ដែលបំពេញលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដែលចាំបាច់ សម្រាប់បង្កើតបានជាបទល្មើសនៃការដាក់ក្នុងមន្ទីរឃុំឃាំង។

*បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៥០. ការសម្លាប់មនុស្សយ៉ាងហោចណាស់ចំនួន២០០នាក់នៅទួលបេង ចាប់តាំងពីដើមឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ គឺជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ។

*បទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៥១. ការសម្លាប់ទាំងនេះក៏បំពេញលក្ខខណ្ឌ *"ទ្រង់ទ្រាយធំ"* ដើម្បីក្លាយជាបទសម្លាប់រង្គាលនៅក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។

01588934



៧៥២. រណ្តៅធំៗ ដែលជារណ្តៅសាកសពរួមនៅទួលបេង ជាសញ្ញាបង្ហាញនូវប្រតិបត្តិការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំដែលមានការរៀបចំ ដែលនៅក្នុងប្រតិបត្តិការនោះ យ៉ាងហោចណាស់មនុស្សចំនួន២០០នាក់ត្រូវបានសម្លាប់។ កាលៈទេសៈទាំងនេះ គឺជាភ័ស្តុតាងគ្រប់គ្រាន់ដែលបង្ហាញថា ចារីមានចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ។

*បទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៥៣. ស្ថានភាពអមនុស្សធម៌នៃការឃុំខ្លួននៅទួលបេង និងវត្តអង្គញ្ញី គឺជាបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សាក្សីមួយចំនួនដែលបានចូលទៅក្នុង ឬនៅក្បែរមន្ទីរសន្តិសុខទួលបេង បានផ្តល់ភ័ស្តុតាងថា អ្នកទោសត្រូវបានឃុំខ្លួនជាជួរៗទល់មុខគ្នា ដោយជើងរបស់ពួកគេត្រូវបានដាក់ខ្នោះជាប់ទៅនឹងរបារឈើ។ អ្នកទោសខ្លះមានរូបរាងស្គមស្គាំង ដោយសារទទួលបានអាហារមិនគ្រប់គ្រាន់ និងយំស្រែកឱ្យគេជួយ។ មានភ័ស្តុតាងចចាមអារ៉ាមដែលបង្ហាញថា អ្នកទោសខ្លះត្រូវគេវាយដោយដំបងឬស្សី។ ស្ថានភាពនៃការឃុំខ្លួនទាំងនេះ បង្កឱ្យមានទុក្ខវេទនា និងព្យសនកម្មរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ និងជាការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិដែលមានចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋផ្សេងៗទៀត ដែលត្រូវបានចែងនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក.។

៧៥៤. សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថាចារីបានបង្កដោយចេតនានូវភាពលំបាកដែលត្រូវបានពិពណ៌នាខាងលើ ទៅលើអ្នកទោស ដោយមានចេតនាបង្កឱ្យមានព្យសនកម្មរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ និងជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

*បទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៥៥. បទឧក្រិដ្ឋនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងបទអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តដោយចេតនា នៅទួលបេង និងវត្តអង្គញ្ញី ប្រឆាំងនឹង *"ប្រជាជន ១៧ មេសា"* កម្មាភិបាលភូមិភាគកណ្តាល អ្នកដែលមានទំនាក់ទំនងជាមួយរបប លន់ នល់ និងគ្រួសាររបស់ពួកគេ ត្រូវបានចាត់ទុកថាជាបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អ្នកដែលត្រូវបានចាប់ខ្លួនជាច្រើននៅទួលបេង និងវត្តអង្គញ្ញី

ត្រូវបានជ្រើសរើស ដោយអនុលោមទៅតាមគោលនយោបាយកំណត់អត្តសញ្ញាណ និង បោសសម្អាតក្រុមមនុស្សទាំងនេះ ដែលក្រុមមនុស្សទាំងនេះត្រូវបានផ្តោតជាគោលដៅ និងត្រូវបានឃុំខ្លួននៅទួលបេង និងវត្តអង្គញ្ញឹ ពីព្រោះពួកគេត្រូវបានសន្មតថាមានឥរិយាបថ ឬមានទស្សនៈប្រឆាំង ឬផ្ទុយនឹងទស្សនៈ និងគោលនយោបាយរបស់ ប.ក.ក. ហើយ ហេតុដូច្នេះ ពួកគេត្រូវបានចាត់ទុកថាជា "*ជនក្បត់*" "*ខ្មាំងផ្ទៃក្នុង*" និង "*សមាសភាពមិនល្អ*"។ អ្នកដែលត្រូវផ្តោតជាគោលដៅ ត្រូវបានដកហូតសិទ្ធិជាមូលដ្ឋាននានា ដូចជាសិទ្ធិទទួលបាន សេរីភាព និងសន្តិសុខរបស់មនុស្ស និងសិទ្ធិទទួលបានការអនុវត្តនិតិវិធីច្បាប់ត្រឹមត្រូវ។

៧៥៦. មានភស្តុតាងមិនគ្រប់គ្រាន់ស្តីពីប្រភេទមនុស្ស ដែលត្រូវបានសម្លាប់នៅទួលបេង និងវត្ត អង្គញ្ញឹ ដើម្បីធ្វើការសន្និដ្ឋានថា បទមនុស្សឃាត និងបទសម្លាប់រង្គាល គឺជាបទធ្វើទុក្ខ បុកម្នេញដោយសារមូលហេតុនយោបាយ។

*បទធ្វើទុកបុកម្នេញដោយសារមូលហេតុសាសនានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៥៧. បទមនុស្សឃាត និងបទសម្លាប់រង្គាល ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនចាម ត្រូវបាន ចាត់ទុកថាជាបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ។ ប្រជាជនចាមត្រូវបានផ្តោតជាគោលដៅ ដោយអនុលោមទៅតាមគោល នយោបាយលុបបំបាត់ប្រជាជនចាមនៅខេត្តកំពង់ចាម និងត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំ នៅទួលបេង និងវត្តអង្គញ្ញឹ។

៧៥៨. ដោយសារពុំដឹងអំពីរយៈពេលឃុំខ្លួនប្រជាជនចាមនៅទួលបេងនិងវត្តអង្គញ្ញឹ មុនពេល គេយកអ្នកទាំងនោះទៅសម្លាប់ គេមិនអាចសន្និដ្ឋានថាពួកគេត្រូវបានឃុំខ្លួនក្នុងរយៈពេល មួយ ដែលមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីក្លាយជាបទដាក់ក្នុងមន្ទីរឃុំឃាំង។ ហេតុដូច្នេះ បទ ឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា តាមរយៈបទល្មើសនៃការ ដាក់ ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត មិនត្រូវបានរកឃើញនោះឡើយ ហេតុ ដូច្នេះ បទចោទប្រកាន់ពាក់ព័ន្ធត្រូវបដិសេធចោល។

*បទមនុស្សឃាតគិតទុកជាមុន*

៧៥៩. ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខទួលបេង និងវត្តអង្គញជី ដែលត្រូវបានពិពណ៌នាពីមុន ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតគិតទុកជាមុន ដោយអនុលោមតាមមាត្រា៥0១ និង ៥0៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

## ៨.២.៥. មន្ទីរសន្តិសុខវត្តអូរត្រកួន

*បទដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៦0. ការឃុំខ្លួនមនុស្សនៅមន្ទីរសន្តិសុខវត្តអូរត្រកួន ចាប់តាំងពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតី រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់ទុកថាជាបទដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៦១. មនុស្សដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខវត្តអូរត្រកួន ត្រូវបានដកហូតសេរីភាពរបស់ពួកគេក្នុងអំឡុងពេលត្រូវចាប់ខ្លួន ដោយផ្អែកលើមូលហេតុតាមអំពើចិត្ត និងមិនគ្រប់គ្រាន់ដូចដែលត្រូវបានពិពណ៌នាខាងលើ ដែលមានដូចជា ការរអ៊ូរទាំអំពីភាពអត់ឃ្លាន ការផ្តាក់ខ្លួនឈឺ ការលួចអាហារ ឬការដាំដុះអាហារដោយពុំមានការអនុញ្ញាត។ ក្រុមមនុស្សជាក់លាក់ត្រូវបានផ្តោតជាគោលដៅ ជាពិសេស៖ *"ប្រជាជន ១៧ មេសា"* ប្រជាជនចាម កម្មាភិបាល និងអតីតយោធា លន់ នល់។ គ្រួសារទាំងមូល ដោយរួមទាំង កុមារ ត្រូវបានឃុំខ្លួន។ អ្នកដែលត្រូវគេឃុំខ្លួន កម្រត្រូវបានគេប្រាប់ហេតុផលសម្រាប់ការចាប់ខ្លួនរបស់ពួកគេ។ ជាប្រចាំ អ្នកដែលត្រូវបានបង្ហាញឈ្មោះនៅក្នុងសេចក្តីសារភាព ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ត្រូវបានចាប់ខ្លួននាពេលបន្ទាប់មក និងត្រូវបញ្ជូនទៅវត្តអូរត្រកួន។

៧៦២. អ្នកទោសត្រូវបានដាក់ខ្នោះ និងមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីបរិវេណនោះឡើយ។ អ្នកទោសទាំងអស់ត្រូវបានដកហូតសិទ្ធិរបស់ពួកគេ និងត្រូវបានឃុំខ្លួន ដោយពុំមាននីតិវិធីច្បាប់ត្រឹមត្រូវណាមួយនោះឡើយ។ ទោះបីជាអ្នកទោសខ្លះ ត្រូវបានសម្លាប់ភ្លាមៗក្រោយពេលមកដល់ អ្នកទោសមួយចំនួនធំចំណាយរយៈពេលវែងសមស្របនៅក្នុងការឃុំខ្លួន ដែលបំពេញលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដែលចាំបាច់សម្រាប់បង្កើតបានជាបទដាក់ក្នុងមន្ទីរឃុំឃាំង។

៧៦៣. លក្ខណៈទូលំទូលាយនៃប្រព័ន្ធចាប់ខ្លួន និងឃុំខ្លួនតាមអំពើចិត្ត នៅវត្តអូរត្រកួន និងអវត្តមានទាំងស្រុងនៃនីតិវិធីច្បាប់បង្ហាញថា ចារីមានចេតនាដកហូតតាមអំពើចិត្ត នូវសេរីភាពរបស់អ្នកជាប់ឃុំ។

*បទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៦៤. ការសម្លាប់មនុស្សយ៉ាងហោចណាស់ចំនួន ៤៩២៤នាក់ នៅមន្ទីរសន្តិសុខវត្តអូរត្រកួន ចាប់តាំងពីដើមឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការសម្លាប់អ្នកទោស ដោយសាររបួសដែលបង្កឡើងក្នុងអំឡុងពេលសួរចម្លើយ ក៏ត្រូវបានចាត់ទុកថាជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។ ជាច្រើនលើក ចារីមានចេតនាបង្កព្យសនកម្មរាងកាយធ្ងន់ធ្ងរដល់អ្នកទោស ទោះបីជាដឹងថាអំពើនេះនឹងនាំទៅដល់ការស្លាប់របស់ជនរងគ្រោះក៏ដោយ។

*បទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៦៥. ការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំទាំងនេះ ក៏បំពេញលក្ខខណ្ឌ "*ទ្រង់ទ្រាយធំ*" ដើម្បីក្លាយជាបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។

៧៦៦. ការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំជាប្រចាំ ផ្តោតគោលដៅទៅលើក្រុមប្រជាជនជាក់លាក់ដូចជា "*ប្រជាជន ១៧ មេសា*" អតីតកម្មាភិបាលនិងយោធា លន់ នល់។ នៅពេលខ្លះ ការសម្លាប់ឈានដល់ទ្រង់ទ្រាយធំមួយ ដែលអ្នកទោសត្រូវបានគេបញ្ជាឱ្យជួយសម្លាប់ ហើយគេចាក់សំឡេងតន្ត្រីខ្លាំងៗ ដើម្បីកុំឱ្យឮសំឡេងស្រែករបស់ជនរងគ្រោះ។ កាលៈទេសៈទាំងនេះបង្ហាញយ៉ាងច្បាស់ថា ចារីបានអនុវត្តការសម្លាប់ ដោយមានចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ។

*បទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៦៧. ការធ្វើបាបអ្នកទោសនៅមន្ទីរសន្តិសុខវត្តអូរត្រកួន ត្រូវបានចាត់ទុកថាជាបទធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

01588938



៧៦៨. ការសួរចម្លើយញឹកញាប់ដែលត្រូវបានអនុវត្តដោយបុគ្គលិកមន្ទីរសន្តិសុខ មានភាពឃោរឃៅយ៉ាងខ្លាំង រហូតបណ្ដាលឱ្យអ្នកទោសខ្លះស្លាប់។ អ្នកទោសខ្លះត្រូវគេចងជើងព្យួរឡើងលើដោយក្បាលចុះក្រោម។ អ្នកទោសផ្សេងទៀតត្រូវគេឆក់នឹងចរន្តអគ្គិសនី។ ការធ្វើបាបបែបនេះ បណ្ដាលឱ្យមានការឈឺចាប់ធ្ងន់ធ្ងរទាំងផ្លូវកាយ និងផ្លូវចិត្ត។ ការសួរចម្លើយទាំងនេះត្រូវបានអនុវត្តដោយមានចេតនាបង្កការឈឺចាប់ ឬទុក្ខវេទនាធ្ងន់ធ្ងរ និងក្នុងគោលបំណងទទួលបានការសារភាព និងការកំណត់អត្តសញ្ញាណ "*ខ្មាំងផ្ទៃក្នុង*"។

*បទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៦៩. ស្ថានភាពអមនុស្សធម៌នៃការឃុំខ្លួន និងការរំលោភបំពានអ្នកទោសនៅមន្ទីរសន្តិសុខវត្តអូរត្រកួន ត្រូវបានចាត់ទុកថាជាបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៧០. អ្នកទោសត្រូវបានគេចង ឬដាក់ខ្នោះជើងជាក្រុមធំៗ។ ប្រជាជនចាមមួយក្រុម ត្រូវគេវាយដំ និងទាត់ធាក់ នៅពេលពួកគេចូលដល់ក្នុងគុក។ កុមារដែលមិនអាចឡើងជណ្ដើរព្រះវិហារដោយខ្លួនឯង ត្រូវបានគេបោះឬរុញ និងបន្ទាប់មកត្រូវបានគេដាក់ខ្នោះជាមួយនឹងអ្នកទោសផ្សេងទៀត។ អ្នកទោសត្រូវបានគេផ្ដល់អាហារមិនគ្រប់គ្រាន់ និងមិនទទួលបានការព្យាបាលនោះឡើយ។ អ្នកទាំងនោះរស់នៅក្នុងស្ថានភាពក្រោមការគម្រាមកំហែងសម្លាប់គ្រប់ពេលវេលា ពីព្រោះពួកគេឮសំឡេងមនុស្សស្រែករកជំនួយ ដែលបង្កការរំខានយ៉ាងខ្លាំងរហូតដល់អាជ្ញាធរចាក់សំឡេងតន្ត្រីខ្លាំងៗ នៅពេលពួកគេសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ។ នៅពេលខ្លះអ្នកទោសត្រូវបានគេបញ្ជាឱ្យជួយសម្លាប់អ្នកទោសផ្សេងទៀត។ អ្នកទោសម្នាក់បានពិពណ៌នាអំពីការបាត់បង់ឆន្ទៈក្នុងការរស់នៅ។ នៅពេលធ្វើការចោទប្រកាន់ បទចោទប្រកាន់អំពើអមនុស្សធម៌ផ្សេងៗទៀត មួយផ្នែកគឺផ្អែកលើភស្តុតាងនៃការបាត់ខ្លួន ជាងនេះទៅទៀតការស៊ើបអង្កេតបានបង្ហាញថា អ្នកទោសនៅវត្តអូរត្រកួន ត្រូវបានសម្លាប់ មិនមែនត្រូវគេនាំយកចេញទៅ និងបាត់ខ្លួននោះឡើយ។ ជារួម ស្ថានភាពនៅមន្ទីរសន្តិសុខនេះបង្កឱ្យមានព្យសនកម្មរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ និងជាការវាយប្រហារប្រឆាំងនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ។ ការធ្វើបាបអ្នកទោស គឺមានចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែល

ទៅនឹងបទឧក្រិដ្ឋផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក.។

៧៧១. ដោយចេតនា ចារីបង្កភាពលំបាកដែលត្រូវបានពិពណ៌នាដូចខាងលើ ទៅលើអ្នកទោសដោយមានចេតនាបង្កឱ្យមានព្យសនកម្មរាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ និងបង្កឱ្យមានការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

*បទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

៧៧២. បទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ត្រូវបានអនុវត្តនៅវត្តអូរត្រកួន តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

៧៧៣. ចារីនៅមន្ទីរសន្តិសុខនេះ ផ្តោតគោលដៅដាក់លាក់ចំពោះ "*ប្រជាជន ១៧ មេសា*" អតីតយោធា លន់ នល់ កម្មាភិបាលភូមិភាគកណ្តាល និងគ្រួសាររបស់ពួកគេ។ ក្រុមមនុស្សទាំងនេះត្រូវបានសន្មតថាមានឥរិយាបថ ឬទស្សនៈ ប្រឆាំង ឬផ្ទុយនឹង ទស្សនៈនិង គោលនយោបាយរបស់ ប.ក.ក.ក. ហើយហេតុដូច្នេះ ពួកគេត្រូវបានចាត់ទុកថាជា "*ជនក្បត់*" "*ខ្មាំងផ្ទៃក្នុង*" និង "*សមាសភាពមិនល្អ*"។ ដោយសារប្រព័ន្ធនៃការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់នៅវត្តអូរត្រកួនមានលក្ខណៈរើសអើង សមាជិកនៃក្រុមមនុស្សទាំងនេះ ត្រូវបានគេបដិសេធនូវសិទ្ធិមានជីវិត សិទ្ធិទទួលបានសេរីភាព និងសន្តិសុខរបស់មនុស្ស សិទ្ធិទទួលបានការអនុវត្តនីតិវិធីច្បាប់ត្រឹមត្រូវ និងសិទ្ធិរួចផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក។ ចរិតលក្ខណៈ នៃអំពើធ្វើទុក្ខបុកម្នេញដែលមានការរៀបចំ និងក្នុងទ្រង់ទ្រាយធំ ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងក្រុមមនុស្សទាំងនេះបង្ហាញថាចារីបានធ្វើអំពើដោយចេតនា និងមានចេតនារើសអើងដោយសារមូលហេតុនយោបាយ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើទុក្ខបុកម្នេញផ្អែកលើហេតុផលសាសនា*

៧៧៤. ការធ្វើទុក្ខបុកម្នេញក៏ត្រូវបានប្រព្រឹត្តផងដែរទៅលើជនជាតិចាម ដោយសារមូលហេតុសាសនា តាមរយៈបទល្មើស ដូចជា ការចាប់ដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់

វង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ មិនមានភស្តុតាងបញ្ជាក់ថា ជនជាតិចាមត្រូវបានធ្វើទារុណកម្មនៅវត្តអូរត្រកួនទេ។

៧៧៥. ជនជាតិចាមនៅមន្ទីរសន្តិសុខវត្តអូរត្រកួនត្រូវបានដាក់ជាមុខសញ្ញា ដោយសារមូលហេតុសាសនា ហើយត្រូវបានបំបាត់សិទ្ធិជាមូលដ្ឋាន។ ជាពិសេសពួកគេត្រូវបានដកហូតនូវសិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព និងសុវត្ថិភាពនៃមនុស្ស សិទ្ធិទទួលបាននូវនីតិវិធីត្រឹមត្រូវតាមផ្លូវតុលាការ សិទ្ធិសេរីភាពផ្នែកសាសនា និងសេរីភាពចាកផុតពីការប្រព្រឹត្តឃោរឃៅអមនុស្សធម៌ និងធ្វើឱ្យបាត់បង់សេចក្តីថ្លៃថ្នូរ។

*ការធ្វើមនុស្សឃាតដោយគិតទុកជាមុន*

៧៧៦. ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវត្តអូរត្រកួន បង្កើតបានជាអំពើមនុស្សឃាតដែលបានគិតទុកជាមុន យោងមាត្រា៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

### ៨.២.៦. មន្ទីរសន្តិសុខវត្តបាធាយ

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការចាប់ដាក់ពន្ធនាគារ*

៧៧៧. ការឃុំឃាំងមនុស្សនៅមន្ទីរសន្តិសុខវត្តបាធាយក្នុងចន្លោះដើមឆ្នាំ ១៩៧៧ និងចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ បង្កើតបានជាបទល្មើសការដាក់ពន្ធនាគារនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៧៨. មនុស្សដែលបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខវត្តបាធាយត្រូវបានចាប់មក ដោយឈរលើមូលហេតុតាមអំពើចិត្ត ដូចជាគ្រាន់តែបានពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ ដែលជាប់ការសង្ស័យថាបានប្រព្រឹត្តខុស។ ក្រុមគ្រួសារទាំងមូល រួមទាំងកុមារផងដែរ ត្រូវចាប់ឃុំខ្លួន។ អ្នកទោសមិនត្រូវបានអនុញ្ញាតឱ្យចេញពីបរិវេណ ហើយភាគច្រើននៃអ្នកទោសទាំងនោះត្រូវជាប់ខ្នោះជើង។ អ្នកទោសទាំងអស់ត្រូវបានដកហូតសេរីភាព ហើយបានជាប់ឃុំដោយមិនដំណើរការឆ្លងតាមនីតិវិធីច្បាប់ត្រឹមត្រូវ។ អ្នកទោសខ្លះត្រូវបានសម្លាប់ក្នុងរយៈពេលយ៉ាងខ្លី ក្រោយពីបានមកដល់ ប៉ុន្តែអ្នកទោសមួយចំនួនធំត្រូវបានជាប់ឃុំក្នុងរយៈពេលយ៉ាងយូរ ដើម្បីបំពេញឱ្យស្របទៅតាមកម្រិតនៃភាពធ្ងន់ធ្ងរនៃបទល្មើស ដែលត្រូវយកមកដាក់ពន្ធនាគារ។

01588941



៧៧៩. ភ័ស្តុតាង ដែលបានបង្ហាញនូវហេតុផលតាមអំពើចិត្ត ឬការខ្វះហេតុផលក្នុងការចាប់ខ្លួន និងឃុំឃាំងមនុស្ស បានបង្ហាញឱ្យឃើញនូវចេតនារបស់រដ្ឋអំណាចនៅក្នុងការប្រព្រឹត្តិអំពើទាំងនោះ ដោយមិនមាននីតិវិធីផ្នែកព្រហ្មទណ្ឌ ហើយវាគឺជាការសន្និដ្ឋានតែមួយគត់ដែលសមហេតុផល។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើមនុស្សឃាត*

៧៨០. ការសម្លាប់មនុស្សយ៉ាងតិចចំនួន៥០០០នាក់ បានប្រព្រឹត្តទៅក្នុងចន្លោះដើមឆ្នាំ ១៩៧៧ និងចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅមន្ទីរសន្តិសុខវត្តបាធាយ បង្កើតបានជាការធ្វើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៨១. លើសពីនេះទៀតអ្នកទោសត្រូវបានបង្អត់អាហារ និងធ្វើទារុណកម្មលើផ្លូវកាយ ខណៈដែលបង្ខំឱ្យធ្វើពលកម្មដោយប្រើកម្លាំងកាយធ្ងន់ធ្ងរ ហើយអ្នកទោសខ្លះបានស្លាប់ ដោយសារអត់អាហារ និងការងារធ្ងន់។ ជនដែលដល់ទាំងឡាយបានដឹងថា ការដាក់ចេញនូវពលកម្មធ្ងន់ៗទៅឱ្យអ្នកទោសដែលខ្វះអាហារ និងទទួលទារុណកម្មផ្លូវកាយ ឬដែលត្រូវបង្អត់អាហារតែម្តងនោះ អាចនឹងធ្វើឱ្យអ្នកទោសអត់អាហារ និងស្លាប់ ហើយដូច្នេះការសន្និដ្ឋានអាចទាញបានថា ពួកគេមានចេតនា ឬយ៉ាងហោចណាស់ទទួលនូវយកផលវិបាកទាំងនោះ។ ដូច្នេះការសម្លាប់មនុស្សទាំងនោះក៏បង្កើតបានផងដែរ នូវការធ្វើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៨២. ការសម្លាប់មនុស្សជាទ្រង់ទ្រាយធំជាប្រចាំ ដែលបានប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខវត្តបាធាយ បានបំពេញគ្រប់លក្ខខណ្ឌនៃ *"ទ្រង់ទ្រាយធំ"* ដើម្បីបង្កើតបានជាបទល្មើសការសម្លាប់រង្គាលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៨៣. ការសម្លាប់ជាទ្រង់ទ្រាយធំទាំងនេះ បានសំដៅយកជាមុខសញ្ញាទៅលើបណ្តាក្រុមមនុស្សដាច់ដោយឡែកៗផ្សេងៗពីគ្នា រួមមានទាំងកម្មាភិបាលភូមិភាគកណ្តាល ប្រជាជនដែលមានមុខនាទីផ្លូវការការពាររបបមុន *"ប្រជាជន១៧មេសា"* ប្រជាជនមកពីភូមិភាគបូព៌ា ប្រជាជនចាមព្រមទាំងក្រុមគ្រួសាររបស់ពួកគេ។ លើកលែងតែអ្នកទោសមួយក្រុមតូច មនុស្សទាំងអស់ដែលបានយកមកដាក់នៅមន្ទីរសន្តិសុខនោះ ត្រូវបានសម្លាប់ចោល។ បណ្តាអ្នកសម្លាប់

មនុស្សនានាបានប្រាប់អ្នកទោសទាំងឡាយថា អ្នកទោសទាំងនោះគឺជាជនក្បត់ជាតិ មុននឹងសម្លាប់ពួកគេ។ ជាច្រើនលើកក្នុងមួយថ្ងៃ អ្នកទោសទាំងឡាយត្រូវបានបណ្ដើរទៅកាន់រណ្ដៅសម្លាប់មនុស្សឱ្យដើរជាជួរជាប់ចំណងដៃមកក្រោយខ្នង ដែលនៅទីនោះពួកគេត្រូវបានវាយដំ ឬចាក់សម្លាប់ចោលតែម្ដង។ ដូច្នេះ ការសម្លាប់មនុស្សត្រូវបានប្រព្រឹត្ត ដោយមានចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើទារុណកម្ម*

៧៨៤. ការធ្វើបាបទៅលើអ្នកទោសនៅមន្ទីរសន្តិសុខវត្តបាធាយ បង្កើតបានជាបទល្មើសការធ្វើទារុណកម្មនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៨៥. កម្មាភិបាលនៅមន្ទីរសន្តិសុខនេះវាយដំ និងធ្វើឱ្យថប់ដង្ហើមអ្នកទោស ដែលបង្កឱ្យមានការទទួលរងទុក្ខវេទនា និងការឈឺចាប់ធ្ងន់ធ្ងរ ទាំងផ្លូវកាយ និងផ្លូវចិត្ត។ នៅក្នុងអំឡុងពេលនៃការសួរចម្លើយ ការធ្វើទារុណកម្មទាំងនោះបានប្រព្រឹត្តទៅក្នុងបំណងទាញយកព័ត៌មានតាមមធ្យោបាយដែលត្រូវបានហាមឃាត់។ ការវាយដំទៅលើអ្នកទោស ដែលបានបំពេញការងារមិនពេញចិត្តថ្នាក់លើ គឺធ្វើឡើងក្នុងបំណងដាក់ទណ្ឌកម្ម ដែលជាវិធីត្រូវបានបង្ខំ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗទៀត*

៧៨៦. លក្ខខណ្ឌផ្សេងៗនៃការឃុំឃាំងនៅមន្ទីរសន្តិសុខវត្តបាធាយ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗ។

៧៨៧. អ្នកទោសទាំងឡាយត្រូវបានដាក់ឱ្យទទួលរងនូវលក្ខខណ្ឌលំបាកធ្ងន់ធ្ងរ។ ពួកគេត្រូវជាប់ខ្នោះជើង វាយដំ ទទួលអាហារ និងទឹកមិនគ្រប់គ្រាន់ ហើយនៅក្នុងពេលដាក់ច្រវាក់ជាប់ជាមួយគ្នាត្រូវបង្ខំឱ្យធ្វើពលកម្មរហូតដល់អស់កម្លាំង ហើយនៅពេលនោះពួកគេត្រូវសម្លាប់ចោលតែម្ដង។ អ្នកទោសទាំងនេះរស់នៅក្រោមការភ័យខ្លាចជាប្រចាំថា ខ្លួននឹងត្រូវសម្លាប់ ហើយត្រូវមើលឃើញជាប្រចាំនូវទិដ្ឋភាពគួរឱ្យរន្ធត់ នូវអំពើហិង្សា និងអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ និងមិនអាចពណ៌នាបាន។ ការប្រព្រឹត្តិទាំងនេះបណ្ដាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយគឺជាការវាយប្រហារប្រឆាំងទៅនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្សក្នុងលក្ខណៈ

និងភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលមាននៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក។

៧៨៨. ជនដែលរស់ទាំងឡាយបានដាក់ចេញ ដោយចេតនានូវលក្ខខណ្ឌទាំងនេះនៅមន្ទីរសន្តិសុខវត្តបាណាយ ដោយមានចេតនាបង្កព្យសនកម្មធ្ងន់ធ្ងរផ្លូវកាយ ឬផ្លូវចិត្ត ឬបានប្រព្រឹត្តនូវការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ទោះបីជាបានដឹងថា លក្ខខណ្ឌទាំងនោះនឹងបណ្តាលឱ្យមានការឈឺចាប់ធ្ងន់ធ្ងរផ្លូវកាយ ឬផ្លូវចិត្ត ព្រមទាំងបង្កើតបានជាការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើទុក្ខបុកម្នេញផ្អែកលើហេតុផលនយោបាយ*

៧៨៩. ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត និងសម្លាប់រង្គាល ដែលបានប្រព្រឹត្តទៅលើប្រជាជនភូមិភាគបូព៌ា និងឧក្រិដ្ឋកម្មនៃការចាប់ដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលប្រព្រឹត្តមកលើប្រភេទមនុស្សផ្សេងៗទៀតដែលបានរៀបរាប់ខាងក្រោមនេះ ក៏បង្កើតបានផងដែរនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើទុក្ខបុកម្នេញផ្អែកលើហេតុផលនយោបាយ។

៧៩០. មនុស្សជាច្រើននៃមនុស្សដែលបានជាប់ឃុំ និងត្រូវសម្លាប់នៅមន្ទីរសន្តិសុខវត្តបាណាយ គឺជាកម្មាភិបាលភូមិភាគកណ្តាល *"ប្រជាជន១៧មេសា"* ប្រជាជនដែលមានតួនាទីផ្លូវការនៅក្នុងរដ្ឋាភិបាលមុន ប្រជាជនភូមិភាគបូព៌ា និងក្រុមគ្រួសាររបស់ពួកគេ។ ក្រុមមនុស្សទាំងនេះត្រូវបានចោទថា បានប្រព្រឹត្ត ឬប្រកាន់ទស្សនៈប្រឆាំង ឬមិនស្របតាមទស្សនៈ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូច្នេះត្រូវចាត់ទុកថា *"ជនក្បត់ជាតិ"* *"ខ្មាំងផ្ទៃក្នុង"* និង *"សមាសភាពមិនល្អ"*។ ពួកគេត្រូវបានដាក់ថាជាមុខសញ្ញា ហើយត្រូវបានដកហូតនូវសិទ្ធិសេរីភាពជាមូលដ្ឋាន ដូចជាសេរីភាពផ្ទាល់ខ្លួន សុវត្ថិភាពផ្លូវកាយ និងសិទ្ធិរស់រានមានជីវិត ដោយសារពួកគេស្ថិតនៅក្នុងប្រភេទក្រុមទាំងនេះ។ ខុសពីប្រជាជនផ្សេងទៀតនៃបណ្តាក្រុម ដែលបានដាក់ចំណាត់ថ្នាក់ទាំងនេះ ប្រជាជនមកពីភូមិភាគបូព៌ា គឺត្រូវបានសម្លាប់ក្នុងពេលយ៉ាងខ្លី បន្ទាប់ពីបានមកដល់ ដោយមិនមានការសួរចម្លើយ រងទារុណកម្ម ឬដាក់ឃុំអស់រយៈពេលយូរនោះឡើយ។ ដូច្នេះ ការចោទប្រកាន់ទៅលើបទល្មើសនៃការ

ធ្វើទុក្ខបុកម្នេញ ដោយសារហេតុផលនយោបាយ ទៅលើប្រជាជនភូមិភាគបូព៌ាផ្អែកលើ បទល្មើស ដែលមានចែងពីការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗ នោះត្រូវលើកលែង។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើទុក្ខបុកម្នេញផ្អែកលើហេតុផលសាសនា*

៧៩១. ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត និងសម្លាប់រង្គាលទៅលើជនជាតិចាម ក៏បង្កើតបានផងដែរនូវ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការធ្វើទុក្ខបុកម្នេញផ្អែកលើហេតុផលសាសនា។

៧៩២. ជនជាតិចាមដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយ ត្រូវបានដាក់ជាមុខសញ្ញាផ្អែក លើសាសនារបស់ពួកគេ ហើយត្រូវបានដកហូតសិទ្ធិសេរីភាពជាមូលដ្ឋាន ដូចជាសេរីភាព ផ្ទាល់ខ្លួន និងសុវត្ថិភាពខាងផ្លូវកាយ និងសិទ្ធិរស់រានមានជីវិតរបស់ពួកគេ។

៧៩៣. មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា មានឧក្រិដ្ឋកម្មនៃការចាប់ដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និងការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗទៀត ត្រូវបានប្រព្រឹត្តទៅលើជនជាតិចាមនៅវត្តបាធាយទេ។ តាមអង្គហេតុ ទំនងថា ជនជាតិចាមដែលបានដាក់នៅវត្តបាធាយត្រូវបានសម្លាប់ក្នុងពេលដ៏ខ្លី បន្ទាប់ពីបានមកដល់ទីនោះ។ ដូច្នេះការធ្វើទុក្ខបុកម្នេញ ដោយសារហេតុផលសាសនា ផ្អែក លើបទល្មើសដែលមានចែងពីការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និងការប្រព្រឹត្តិអំពើ អមនុស្សធម៌ផ្សេងៗទៀត មិនអាចបង្កើតឡើងបានឡើយ។

*ការធ្វើមនុស្សឃាតដោយបានគិតទុកជាមុន*

៧៩៤. ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវត្តបាធាយ បង្កើតបានជាការធ្វើមនុស្សឃាតដោយបានគិត ទុកជាមុន យោងមាត្រា៥0១ និង៥0៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

## ៨.២.៧. ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើមនុស្សឃាត*

៧៩៥. ការសម្លាប់មនុស្សចំនួនយ៉ាងតិច ១៥00នាក់នៅទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស នៅក្នុងចន្លោះ ដើមឆ្នាំ១៩៧៧ ទៅដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ បង្កើតបានជាការធ្វើមនុស្ស ឃាត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការសម្លាប់រង្គាល*

៧៩៦. ការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ដែលបានប្រព្រឹត្តនៅទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស បានបំពេញគ្រប់លក្ខខណ្ឌនៃ *"ទ្រង់ទ្រាយធំ"* បង្កើតបានជាបទល្មើសការសម្លាប់រង្គាលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៧៩៧. ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស ត្រូវបានប្រើជាកន្លែងសម្លាប់អ្នកទោសក្នុងចំនួនរហូតដល់ជាច្រើនឡាន តាមដែលអាចធ្វើទៅបាន ធ្វើយ៉ាងណាឱ្យមានប្រសិទ្ធភាព និងបានឆាប់រហ័សទៅតាមលទ្ធភាពនៃការរៀបចំភស្តុភាអាចធ្វើទៅបាន។ ដូច្នេះការសម្លាប់មនុស្សបានប្រព្រឹត្តទៅយ៉ាងច្បាស់ថាមានចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ។

*ការធ្វើមនុស្សឃាតដោយគិតទុកជាមុន*

៧៩៨. ការសម្លាប់មនុស្សនៅទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស បង្កើតបានជាអំពើមនុស្សឃាតដោយគិតទុកជាមុន យោងតាមមាត្រា៥0១ និង៥0៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

## ៨.២.៨. មន្ទីរសន្តិសុខវត្តតាមាក់

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការដាក់ពន្ធនាគារ*

៧៩៩. ការឃុំឃាំងមនុស្សនៅវត្តតាមាក់ បង្កើតបានជាបទល្មើសនៃការពន្ធនាគារនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៨00. អ្នកទោសជាច្រើនក្នុងចំណោមអ្នកទោសដែលបានជាប់ឃុំនៅវត្តតាមាក់ ត្រូវបានដាក់ជាមុខសញ្ញាដោយចេតនា ដោយសារត្រូវបានចោទថា ពួកគេមានអត្តសញ្ញាណជា *"ប្រជាជន១៧មេសា"* កម្មាភិបាលភូមិភាគកណ្តាល និងជាអ្នកដែលពាក់ព័ន្ធជាមួយនឹងរបបលន់ នល់។ ជាញឹកញាប់គ្រួសារទាំងមូលត្រូវបានចាប់ខ្លួន។ អ្នកទោសទាំងឡាយជារឿយៗត្រូវបានបញ្ជូនចេញទៅកន្លែងផ្សេង បន្ទាប់ពីបានដាក់មួយរយៈពេលខ្លីនៅវត្តតាមាក់ រីឯអ្នកទោសជាច្រើនត្រូវបានដាក់ឃុំដោយចេតនា និងតាមអំពើចិត្តអស់រយៈពេលជាច្រើនថ្ងៃ សប្តាហ៍ ឬខែ ដោយមិនអនុវត្តតាមនីតិវិធីច្បាប់ត្រឹមត្រូវឡើយ។ ការឃុំឃាំងអ្នកទោសទាំងនោះមានរយៈពេលវែង

គ្រប់គ្រាន់ និងបំពេញលក្ខខណ្ឌនៃភាពធ្ងន់ធ្ងរ ដែលតម្រូវដើម្បីបង្កើតបានជាបទល្មើសនៃការដាក់ពន្ធនាគារ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើមនុស្សឃាត*

៨០១. មានអ្នកទោសយ៉ាងហោចណាស់៦នាក់ ត្រូវបានសម្លាប់ដោយកម្មាភិបាលនៅបរិវេណវត្តតាមាក់ ឬនៅក្បែរនោះ។ ការសម្លាប់ទាំងនោះបង្កើតបានជាការធ្វើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការសម្លាប់រង្គាល*

៨០២. ដោយសារមានចំនួនអ្នកទោសក្នុងកម្រិតទាប ដែលអាចបង្កើតនូវកម្រិតប្រាកដប្រជាគ្រប់គ្រាន់ ការសម្លាប់មនុស្សទាំងឡាយនៅវត្តតាមាក់ មិនបំពេញបានទេនូវលក្ខខណ្ឌនៃការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ។ ការសម្លាប់មនុស្សដែលមានលទ្ធភាពអាចជាចំនួនច្រើនជាងនៅទីតាំងក្បែរនោះ ប៉ុន្តែដាច់ដោយឡែក គឺនៅឯទីតាំងទួលត្រពាំងល្វា គឺស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបសួរ ហើយដោយមូលហេតុនេះមិនត្រូវបានចោទប្រកាន់នោះទេ។ ការចោទប្រកាន់បទល្មើសការសម្លាប់រង្គាលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមូលហេតុនេះត្រូវតែលើកលែង។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើទារុណកម្ម*

៨០៣. ការធ្វើបាបទៅលើអ្នកទោសទាំងឡាយនៅវត្តតាមាក់ បង្កើតបានជាការធ្វើទារុណកម្មនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៨០៤. កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដោយចេតនាបានបង្កឱ្យមាននូវការរងទុក្ខវេទនា និងការឈឺចាប់ផ្លូវកាយធ្ងន់ធ្ងរ នៅក្នុងអំឡុងពេលនៃការសួរចម្លើយអ្នកទោសជាដែលៗ និងរយៈពេលយូរ។ អ្នកទោសទាំងឡាយត្រូវបានវាយដំច្រើនលើកច្រើនសា ជាមួយនឹងដំបង ច្រវាក់ បន្ទះដែក ឬខ្សែតី។ ជារឿយៗ ការវាយដំមានលក្ខណៈធ្ងន់ធ្ងររហូតដល់អ្នកទោស *"បាត់ស្មារតី"* ហើយត្រូវវាយម្តងទៀតនៅពេលដឹងខ្លួន។ ការវាយដំត្រូវបានប្រព្រឹត្តក្នុងបំណង

01588947



ជម្រិតយកព័ត៌មាន និងឱ្យឆ្លើយសារភាព។ ការប្រព្រឹត្តិបែបនេះក៏បណ្តាលឱ្យមានផងដែរនូវការរងទុក្ខ និងការឈឺចាប់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗ*

៨០៥. លក្ខខណ្ឌអមនុស្សធម៌ផ្សេងៗក្នុងការឃុំឃាំង និងការធ្វើទារុណកម្មទៅលើអ្នកទោសនៅវត្តតាមាក់ បង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៨០៦. អ្នកទោសខ្លះត្រូវបានដាក់ទោសទាំងថ្ងៃទាំងយប់ ជួនកាលបណ្តាលឱ្យមានរបួសធ្ងន់ធ្ងរ។ មិនមានអាហារគ្រប់គ្រាន់។ អ្នកទោសត្រូវបានធ្វើទារុណកម្មផ្លូវកាយយ៉ាងធ្ងន់ធ្ងរ ជាពិសេសនៅពេលសួរចម្លើយ។ ការធ្វើទារុណកម្មបែបនេះ រំលោភទៅលើសិទ្ធិសេរីភាព និងសុវត្ថិភាពរបស់មនុស្ស សិទ្ធិជៀសផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តិបែបឃោរឃៅ អមនុស្សធម៌ និងធ្វើឱ្យអាម៉ាស់បាត់បង់ភាពថ្លៃថ្នូរ ព្រមទាំងសិទ្ធិទទួលបាននូវដំណើរការនីតិវិធីត្រឹមត្រូវតាមបែបតុលាការ។ មានភស្តុតាងខ្លះបញ្ជាក់ផងដែរថា មានអ្នកទោសមួយចំនួនតូចត្រូវបានបង្ខំឱ្យធ្វើពលកម្មនៅវត្តតាមាក់។

៨០៧. ដោយសារការធ្វើទារុណកម្មបែបនេះមកលើអ្នកទោស ជនរងគ្រោះទាំងឡាយដោយចេតនាបានបង្កឱ្យមានការឈឺចាប់ ឬរបួសស្នាមផ្លូវចិត្តធ្ងន់ធ្ងរ ដែលបង្កើតបានជាការវាយប្រហារធ្ងន់ធ្ងរមួយទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងមាត្រា៥។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើទុក្ខបុកម្នេញផ្អែកលើហេតុផលនយោបាយ*

៨០៨. ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយត្រូវបានប្រព្រឹត្តនៅវត្តតាមាក់ តាមរយៈបទល្មើសដែលចែងពីការដាក់ពន្ធនាគារ ទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

៨០៩. មិនមានភស្តុតាងគ្រប់គ្រាន់ស្តីអំពីព្រឹត្តិការណ៍ផ្សេងៗនៃការសម្លាប់នៅវត្តតាមាក់ ដែលអាចបង្កើតបានជាបទល្មើស ទាំងធ្វើទុក្ខបុកម្នេញតាមរយៈការធ្វើមនុស្សឃាត ឬការសម្លាប់រង្គាល ហើយអាស្រ័យហេតុនេះ ការចោទប្រកាន់ក្នុងផ្នែកនេះត្រូវលើកលែង។

៨១០. បណ្តាជនដែលរស់នៅមន្ទីរសន្តិសុខនេះ បានកំណត់មុខសញ្ញាជាពិសេសគឺ *"ប្រជាជនថ្មី ១៧មេសា"* ប្រជាជនបូព៌ា និស្សិត និងអ្នករដ្ឋការរបស់របបមុន និងគ្រួសារទាំងឡាយដែលបានចោទថា មាន *"និន្នាការខាងសីហនុ ឬ លន់ នល់"* កម្មាភិបាលភូមិភាគកណ្ដាល និងក្រុមគ្រួសារពួកគេ។ ក្រុមទាំងនេះត្រូវបានចោទថា បានប្រព្រឹត្ត ឬកាន់ទស្សនៈប្រឆាំងនឹង ឬមិនស្របជាមួយទស្សនៈ និងគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយដូច្នេះត្រូវចាត់ទុកថា *"ជនក្បត់ជាតិ"* *"ខ្មាំងផ្ទៃក្នុង"* និង *"សមាសភាពមិនល្អ"*។ ជាផលវិបាកនៃប្រព័ន្ធនៃការចាប់ខ្លួន ការឃុំឃាំង ការដាក់លក្ខខណ្ឌ និងការប្រព្រឹត្តិអមនុស្សធម៌ ដែលប្រព្រឹត្តដោយចេតនា និងដោយលក្ខណៈរើសអើង ព្រមទាំងការធ្វើទារុណកម្មនៅវត្តតាមាក់ សមាជិកទាំងឡាយនៃក្រុមទាំងនេះ ត្រូវបានដកហូតសិទ្ធិសេរីភាព និងសុវត្ថិភាពរបស់មនុស្ស សិទ្ធិទទួលបាននូវដំណើរការនីតិវិធីតាមផ្លូវតុលាការត្រឹមត្រូវ ព្រមទាំងសេរីភាពជៀសផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តិឃោរឃៅអមនុស្សធម៌ ឬធ្វើឱ្យអាម៉ាស់បាត់បង់សេចក្ដីថ្លៃថ្នូរ។

*ការធ្វើមនុស្សឃាតដោយគិតទុកជាមុន*

៨១១. ការសម្លាប់មនុស្សដែលបានលើកឡើងខាងលើនៅមន្ទីរសន្តិសុខវត្តតាមាក់ ក៏បង្កើតបានផងដែរនូវការធ្វើមនុស្សឃាតដោយគិតទុកជាមុន យោងមាត្រា៥0១ និង៥0៦ នៃក្រមព្រហ្មទណ្ឌ។

## ៨.៣. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម

៨១២. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តទៅលើជនជាតិចាមនៅខេត្តកំពង់ចាម ដែលជាផ្នែកដ៏ធំមួយនៃជនជាតិចាមទាំងមូលនៃប្រទេសកម្ពុជា។ ជនជាតិចាមគឺជាក្រុមពន្ធុ និងសាសនាដោយឡែក ដែលត្រូវបានការពារដោយអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

៨១៣. ជនជាតិចាមនៅខេត្តកំពង់ចាម គឺជាផ្នែកធំមួយនៃជនជាតិចាមទាំងមូលរបស់កម្ពុជា។ ការសន្និដ្ឋានបែបនេះគឺផ្អែកទៅលើកត្តាបរិមាណវិស័យ ដូចជាចំណែកដ៏ធំ និងការប្រមូលផ្តុំនៃជនជាតិចាមដែលរស់នៅតំបន់នោះ ក៏ដូចជាកត្តាគុណវិស័យ ពាក់ព័ន្ធទៅនឹងការលេចធ្លោរបស់ពួកគេនៅក្នុងប្រវត្តិសាស្ត្រ។

៨១៤. កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានសម្លាប់ជនជាតិចាមយ៉ាងតិចចំនួន១៧១១៥នាក់ នៅខេត្តកំពង់ចាម ក្នុងចន្លោះនៃការមកដល់របស់កម្មាភិបាលភាគនិរតីឆ្នាំ ១៩៧៧ និងចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។

៨១៥. ក្រៅអំពីការសម្លាប់មនុស្ស កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក៏បានបង្កផងដែរនូវព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរទៅលើជនជាតិចាមទាំងនោះ ដែលបានទទួលរងនូវបទពិសោធទាំងនេះ ប៉ុន្តែនៅតែប្រឹងប្រែងរត់គេចផុត ហើយនៅរស់រានមានជីវិត។ ការដែលជនជាតិចាមទាំងនេះបានឃើញផ្ទាល់ភ្នែកនូវការជម្លៀសទាំងស្រុង និងការបំផ្លិចបំផ្លាញនូវសហគមន៍ទាំងឡាយរបស់ពួកគេ ព្រមទាំងការសម្លាប់ក្រុមគ្រួសារ និងអ្នកជាទីស្រឡាញ់របស់ពួកគេ រួមជាមួយនឹងការតក់ស្លុតបាក់ស្មារតីធ្ងន់ធ្ងរ និងយូរអង្វែង តាមរយៈការរងទុក្ខដោយខ្លួនឯងផ្ទាល់ មានលក្ខណៈគ្រប់គ្រាន់បំពេញលក្ខខណ្ឌនៃការបង្កើតបានជាព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ។

៨១៦. ទោះជាយ៉ាងណាក៏ដោយ ការសន្និដ្ឋានមិនអាចធ្វើបានទេថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កដោយចេតនានូវលក្ខខណ្ឌនៃការរស់នៅទាំងឡាយ ដែលបានគិតថានឹងនាំមកនូវការបំផ្លាញតាមផ្លូវរូបរាងកាយទាំងមូលនៃប្រជាជនចាមទាំងអស់។ ដូចគ្នានឹងភាគច្រើននៃប្រជាជនកម្ពុជាទាំងមូលនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ជនជាតិចាមត្រូវបានដាក់ឱ្យទទួលរងនូវលក្ខខណ្ឌរស់នៅ និងការងារធ្ងន់ធ្ងរ រួមមានទាំងពលកម្មធ្ងន់ធ្ងរដោយបង្ខំ និងការខ្វះខាតអាហារ ការសម្រាក អនាម័យ និងសុខាភិបាល។ លើសពីនេះទៀត ក្រោមការគំរាមកំហែងសម្លាប់ជនជាតិចាមត្រូវបានហាមឃាត់មិនឱ្យប្រណិបត្តិសាសនាឥស្លាម និយាយភាសាចាម ឬស្លៀកពាក់ខោអាវប្រពៃណីរបស់ពួកគេ ព្រមទាំងបង្ខំឱ្យហូបសាច់ជ្រូក។ លក្ខខណ្ឌទាំងនេះជាការច្បាស់ណាស់បានបង្កឱ្យមានការរងទុក្ខដ៏ធ្ងន់ធ្ងរ និងបានព្យាយាមលុបបំបាត់នូវអត្តសញ្ញាណវប្បធម៌របស់ប្រជាជនចាម ក៏ប៉ុន្តែមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់ថាលក្ខខណ្ឌដែលបានបង្កមកលើជនជាតិចាមនេះបានគិតទុក ដើម្បីនាំមកនូវការបំផ្លិចបំផ្លាញខាងរូបរាងនៃប្រជាជនចាមទេ។

៨១៧. អំពើទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្តដោយមានចេតនាបំផ្លិចបំផ្លាញជនជាតិចាមក្នុងខេត្តកំពង់ចាម។ ការកំណត់បាននូវចេតនាពិសេសនេះ គឺផ្អែកទៅលើភស្តុតាងយ៉ាងច្រើនលើសលុប នៃការវិវត្តនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ពីដំណាក់កាលនៃការគាបសង្កត់សាសនា ទៅដល់ដំណាក់កាលនៃការលុបបំបាត់ ព្រមទាំងលក្ខណៈ និងទ្រង់ទ្រាយនៃការសម្លាប់ប្រជាជនចាម ដែលបណ្តាលមកពីគោលនយោបាយ និងអំពើទាំងនោះ។

៨១៨. ជនជាតិចាមត្រូវបានកំណត់ជាមុខសញ្ញាពិសេស ដោយសារអត្តសញ្ញាណពន្ធុ និងសាសនារបស់ពួកគេ។ ការសន្និដ្ឋាននេះមិនអាចជៀសផុតបានឡើយ នៅពេលដែលបានពិចារណាទៅលើការរឹតត្បិតទាំងឡាយ ដែលបានដាក់មកលើជនជាតិចាម ក្នុងបំណងព្យាយាមហាមឃាត់មិនឱ្យពួកគេអនុវត្តនូវលក្ខណៈទាំងឡាយ ដែលត្រូវតែប្រណិបត្តិ ក្នុងការកំណត់នូវអត្តសញ្ញាណក្រុមរបស់ពួកគេ។ កត្តាពាក់ព័ន្ធផងដែរគឺថា សមាជិកទាំងឡាយនៃក្រុម ត្រូវបានយកចេញពីភូមិទាំងឡាយ និងកងការងាររបស់ពួកគេ ហើយបន្ទាប់មកបុរស ស្ត្រី និងកុមារទាំងនោះត្រូវបានសម្លាប់ចោលដោយមិនរើសមុខ ក្នុងរយៈពេលយ៉ាងខ្លី បន្ទាប់ពីបានចាប់ខ្លួន ដោយមិនបានចាត់វិធានការអ្វីទាំងអស់ក្នុងការកំណត់ថាតើនរណាបាន ឬមិនបានទទួលខុសត្រូវចំពោះកំហុសណាមួយ ឬនរណាដែលបានប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ ការសន្និដ្ឋានបែបនេះត្រូវបានគាំទ្រផងដែរ ដោយភស្តុតាងទាំងឡាយនៃកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលបានទទួលស្គាល់យ៉ាងច្បាស់លាស់ថា មានគោលនយោបាយរើសអើងប្រឆាំងនឹងជនជាតិចាម ដែលជាចុងបញ្ចប់កំណត់បាននូវគោលបំណងនៃការលុបបំបាត់ខាងរូបរាងកាយនៃជនជាតិចាម។

៨១៩. ភស្តុតាងទាំងមូល ទ្រង់ទ្រាយធំនៃការវាយប្រហារ លក្ខណៈជាប្រព័ន្ធនៃការចាប់ខ្លួន និងការសម្លាប់ ព្រមទាំងការកំណត់មុខសញ្ញាដោយមិនរើសអើង និងដោយទ្រង់ទ្រាយធំទៅលើប្រជាជនចាមទាំងមូល នៅក្នុងបរិបទនៃរចនាសម្ព័ន្ធរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជា និងគោលបំណងនៃគោលនយោបាយទាំងមូលរបស់បក្សកុម្មុយនីស្តកម្ពុជា បញ្ជាក់ឱ្យឃើញច្បាស់ថានៅក្នុងអំឡុងពេលនៃការគ្រប់គ្រងភូមិភាគកណ្តាល ដោយកម្មាភិបាលភូមិភាគនិរតី ជនជាតិ

ចាមនៃខេត្តកំពង់ចាម ត្រូវបានកំណត់ជាគោលដៅ ក្នុងបំណងជាពិសេសសម្រាប់បំផ្លាញរូបរាងកាយពួកគេ។

## ៨.៤. ការសំអាងអង្គច្បាប់ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការរៀបការដោយបង្ខំ និងការរំលោភ*

៨២០. នៅក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរតំបន់៤១ ក្នុងចន្លោះដើមឆ្នាំ ១៩៧៧ រហូតដល់ពេលវៀតណាមមកដល់ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តនូវការរៀបការដោយបង្ខំ ដែលអំពើនៃការរៀបការនេះផ្ទាល់ ឬក៏ផលវិបាករបស់វា បានបង្កនូវការរងទុក្ខ និងព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរទៅលើជនរងគ្រោះទាំងឡាយ និងបង្កើតបានជាការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស កំណត់បានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអំពើអមនុស្សធម៌ផ្សេងៗទៀត ហើយម្យ៉ាងវិញទៀត ក្នុងករណីជាច្រើន ទោះមិនមែនភាគច្រើនក៏ដោយ ការដាក់កាតព្វកិច្ចជាទូទៅឱ្យគូប្តីប្រពន្ធដែលរៀបការថ្មីៗរួមភេទ ដែលបានបង្ខំតាមរយៈការគំរាមកំហែងផ្ទាល់ និងមិនផ្ទាល់ ព្រមទាំងតាមរយៈការតាមដាននាពេលបន្តបន្ទាប់មកទៀតនៅក្នុងស្រុកទាំងនោះ បានដាក់អំពើរំលោភផ្លូវភេទជាស្ថានទម្ងន់ទោសកាន់តែធ្ងន់ថែមទៀតនៅក្នុងបរិបទនៃការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

៨២១. តាមរយៈការដកហូតចេញពីជនរងគ្រោះនូវសិទ្ធិជាមូលដ្ឋាន នៃការស្វយ័ត និងស្វ័យសម្រេចក្នុងការសម្រេចថាតើត្រូវរៀបការជាមួយនរណា នៅពេលណា និងសិទ្ធិស្វយ័តក្នុងការរួមភេទ និងការកំណត់ផ្នែករូបរាងកាយរបស់ពួកគេ ក្នុងទំនាក់ទំនងនៃការរួមភេទ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក៏បានប្រព្រឹត្តផងដែរនូវការវាយប្រហារមួយទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ អំពើនៃការប្រព្រឹត្ត ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ មានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលមានចែងយោងមាត្រា៥នៃច្បាប់ អ.វ.ត.ក។

៨២២. បណ្តាជនដែលដល់ទាំងនេះបានអនុវត្តនូវអំពើរៀបការដោយបង្ខំ និងរំលោភផ្លូវភេទដោយចេតនាដោយបានដឹងនូវភាពធ្ងន់ធ្ងរនៃអំពើទាំងនេះ និងដោយបានដឹងថា ដោយសារមានប្រពៃណី

01588952



ដូចគ្នាជាខ្មែរទាំងអស់គ្នា គឺអំពើទាំងនេះនឹងបង្កឲ្យមាននូវការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរ ហើយក្នុងករណីជាច្រើនក៏ជាការឈឺចាប់ផ្លូវកាយផងដែរ ព្រមទាំងជាការវាយប្រហារមួយទៅលើសេចក្ដីថ្លៃថ្នូរនៃមនុស្សក្នុងនាមជាជនរងគ្រោះ។

## ៩. ការសំអាងផ្នែកអង្គច្បាប់ពាក់ព័ន្ធនៅនឹងទម្រង់នៃការទទួលខុសត្រូវ

### ៩.១. ឧក្រិដ្ឋកម្មអន្តរជាតិ

#### ៩.១.១. ការប្រព្រឹត្តិក្នុងឋានៈជាជនដៃដល់ផ្ទាល់

៨២៣. **អៀង ធីរិទ្ធ** បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗ (ការរៀបការដោយបង្ខំ) តាមរយៈការធ្វើជាអធិបតីដោយផ្ទាល់នៅការរៀបការដោយបង្ខំចំនួន១០គូនៅមន្ទីរស្រុកកំពង់សៀម (១០គូ) ស្ត្រី៥នាក់ត្រូវបង្ខំឲ្យរៀបការជាមួយនឹងបុរសពិការនៅមន្ទីរភស្តុភាស្រុកព្រៃឈរ ៧គូ និង១១គូ ជាបន្តបន្ទាប់ ពីរលើកនៅមន្ទីរតំបន់៤១ ព្រមទាំងមួយគូនៅវត្តតាមាក់។

#### ៩.១.២. ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម

*ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងការអនុវត្តបំណងរួមនៃសហឧក្រិដ្ឋកម្មរួម*

៨២៤. ភស្តុតាងដែលបានលើកឡើងនៅក្នុងផ្នែក៦.១ រហូតដល់៦.៣ កំណត់បានថា ចាប់តាំងពីចុង ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ និងរហូតដល់យ៉ាងហោចណាស់ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩ កែ ពក **អៀង ធីរិទ្ធ** និងកម្មាភិបាលផ្សេងៗទៀតនៃបក្សកុម្មុយនីស្តកម្ពុជា មានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងភូមិភាគកណ្ដាលនៃកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយទាំងនេះត្រូវបានអនុវត្តតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មដូចខាងក្រោម នៅតាមប្រព័ន្ធនៃទីតាំងឧក្រិដ្ឋកម្ម ដូចដែលបានលើកឡើងនៅក្នុងផ្នែក ៦.៤.១ រហូតដល់ ៦.៤.៣ ដោយសមាជិកនៃសហឧក្រិដ្ឋកម្មរួម និងដោយអ្នកមិនមែនសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានប្រើជាឧបករណ៍៖

i. **ការបង្កើត និងដំណើរការនៃសហករណ៍ និងការដ្ឋាន** ត្រូវបានអនុវត្តតាមរយៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌

ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ និងលក្ខខណ្ឌនៃការឃុំឃាំងដោយអមនុស្សធម៌)។

ii. **ការអប់រំរៀនសូត្រនៃ 'សមាសភាពមិនល្អ' និងការសម្លាប់ 'ខ្មាំង' ទាំងក្នុងនិងក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា** ត្រូវបានអនុវត្តតាមរយៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ ការធ្វើទារុណកម្មលើរាងកាយនៃអ្នកទោស និងលក្ខខណ្ឌនៃការឃុំឃាំងផ្សេងៗទៀតដ៏អមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ព្រមទាំងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនា។

iii. **ការកំណត់មុខសញ្ញាក្រុមពិសេស ដូចជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៃភូមិភាគកណ្តាល អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ *"ប្រជាជន១៧មេសា"* ប្រជាជនមកពីភូមិភាគបូព៌ា ប្រជាជនចាម និងក្រុមគ្រួសាររបស់ពួកគេ** ត្រូវបានអនុវត្តតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទៅលើប្រជាជនចាមនៅខេត្តកំពង់ចាម តាមរយៈការសម្លាប់ ការបង្កឱ្យមានព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ និងតាមរយៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយនៃអ្នកទោស លក្ខខណ្ឌនៃការឃុំឃាំងដ៏អមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ ព្រមទាំងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនា[2421]។

[2421] ក្នុងអំឡុងពេលនៃការចូលខ្លួននៅតុលាការ អោ អាន ត្រូវបានផ្តល់យោបល់តាមរយៈសហមេធាវីការពាររបស់ខ្លួនថា មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាដែលបង្ហាញថា សហឧក្រិដ្ឋកម្មរួមពិតជាបានកើតមាន *ដែលក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀត* ពាក់ព័ន្ធនឹងគោលបំណងរួម ក្នុងការអនុវត្តគោលនយោបាយរបស់គណបក្សកុម្មុយនីស្តកម្ពុជា ដោយកំណត់គោលដៅលើ "ក្រុមជាក់លាក់ រាប់បញ្ចូលទាំងក្រុមកម្មាភិបាលភូមិភាគកណ្តាល អតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ជនជាតិចាម និងក្រុមគ្រួសាររបស់ពួកគេ"។ ទោះបីជាគេមិននិយាយសំដៅដល់ "ប្រជាជន១៧ មេសា" និង "ប្រជាជនភូមិភាគបូព៌ា" ដោយជាក់លាក់ក៏ដោយ ក៏ពាក្យ "រាប់បញ្ចូលទាំង" បង្ហាញច្បាស់ថា បញ្ជីនោះពុំមានចេតនាក្នុងការផាត់ចេញឡើយ។ ដូច្នេះ ក្រុមមេធាវីការពារ អោ អាន បានកត់សម្គាល់ឃើញថា ក្រុមជាក់លាក់ក្រៅ

iv. **ការដាក់កំហិតទៅលើការរៀបការតាមរយៈ** ***មធ្យោបាយនានាដូចជា*** **ការរៀបការដោយបង្ខំនៃប្រជាជនភូមិភាគកណ្ដាល** បានអនុវត្តតាមរយៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ)។

*ការចូលរួមរបស់អោ អាន នៅក្នុងការប្រព្រឹត្តិសហឧក្រិដ្ឋកម្មរួម និងចេតនារបស់គាត់នៅក្នុងការសម្រេចនូវបំណងរួម*

៨២៥. **អោ អាន** បានក្លាយជាសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួមនេះមិនហួសពីពេលដែលគាត់បានចូលរួមប្រជុំមួយនៅភ្នំពេញ ជាមួយនឹងមេដឹកនាំថ្នាក់ខ្ពស់ទាំងឡាយនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងដំណើររបស់គាត់ដែលចេញពីភូមិភាគនិរតី ឆ្លងទៅកាន់ភូមិភាគកណ្ដាល នៅក្នុងចំណុចពេលណាមួយ ចន្លោះពីចុងឆ្នាំ ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ ១៩៧៧ ដែលក្នុងអំឡុងពេលនោះ គាត់ត្រូវបានប៉ុល ពត បញ្ជាឱ្យបោសសម្អាតភូមិភាគកណ្ដាល ហើយគាត់បានបន្តកាន់នាទីជាសមាជិកម្នាក់រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

៨២៦. ក្នុងឋានៈជាលេខាតំបន់៤១ អនុលេខាភូមិភាគកណ្ដាល និងជាសមាជិកនៃគណៈកម្មាធិការភូមិភាគកណ្ដាល **អោ អាន** បានដឹងនូវសកម្មភាពទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងតំបន់ និងភូមិភាគរបស់គាត់។ ការដឹងឮនេះបានទទួលមកពីការប្រជុំនានា និងប្រព័ន្ធទំនាក់ទំនងនិងរាយការណ៍ ដែលគាត់បានរក្សាអនុវត្តជាមួយនឹងថ្នាក់ដឹកនាំ និងថ្នាក់ក្រោមរបស់គាត់។ **អោ អាន** គឺជាបុគ្គលចម្បងទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅក្នុងតំបន់៤១ ដូច្នេះត្រូវដឹងសព្វគ្រប់ថា ការអនុវត្តគោលនយោបាយទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា គឺត្រូវសម្រេចបានតាមរយៈឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់។ ជាមួយនឹងការដឹងឮនោះ គាត់បានបន្តប្រើសិទ្ធិ និងអំណាចរបស់គាត់ក្នុងការចូលរួមយ៉ាងសកម្មអនុវត្តគោលនយោបាយនីមួយៗ។

៨២៧. ដូចដែលបានលើកឡើងនៅក្នុងផ្នែក ៦.៣.៤.១ **អោ អាន** បានចូលរួមយ៉ាងច្រើនគួរឱ្យកត់សម្គាល់នៅក្នុងគោលនយោបាយស្ដីអំពីការដ្ឋាន និងសហករណ៍ តាមរយៈ *រួមមានទាំង តែមិន*

---

ពីក្រុមដែលមាននៅក្នុងបញ្ជីនោះ អាចក្លាយជាផ្នែកមួយនៃលក្ខណៈសម្គាល់ជាក់លាក់នៃសហឧក្រិដ្ឋកម្មរួមនៅក្នុងដីកាដំណោះស្រាយ។

*កំណាត់ត្រឹម* ៖ ការកោះប្រជុំជាមួយនឹងថ្នាក់ក្រោម និងណែនាំពួកគេឱ្យយល់នូវមធ្យោបាយអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជា ចាត់ចែង និងត្រួតពិនិត្យការដ្ឋាន ចាត់ចែង និងត្រួតពិនិត្យការសាងសង់ និងការបង្កបង្កើនផល គ្រប់គ្រង និងចលនាប្រមូលកម្លាំង និងធនធានទាំងឡាយ ដើម្បីយកមកប្រតិបត្តិការការដ្ឋាន និងសហករណ៍ ដោយប្រកាសថា ប្រជាជនដែលខកខានបំពេញភារកិច្ចដល់កម្រិតពេញចិត្ត នោះនឹងត្រូវចោទថាជាខ្មាំង ហើយជាផលវិបាកនឹងត្រូវសម្លាប់ ព្រមទាំងបញ្ជាឱ្យអ្នកក្រោមបង្គាប់របស់គាត់សម្លាប់មនុស្សដែលត្អូញត្អែរអំពីស្ថានភាពរស់នៅ និងការងាររបស់ពួកគេ។ លើសពីនេះទៀតហេតុការណ៍នេះបង្ហាញនូវចេតនារបស់គាត់ ក្នុងការអនុវត្តគោលនយោបាយស្តីអំពីការដ្ឋាន និងសហករណ៍ តាមរយៈការប្រព្រឹត្តនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការធ្វើឱ្យទៅជាទាសករ ការធ្វើមនុស្សឃាត និងការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ និងលក្ខខណ្ឌនៃការឃុំឃាំងដោយអមនុស្សធម៌)។

៨២៨. ដូចដែលបានលើកឡើងនៅក្នុងផ្នែក ៦.៣.៤.២ **អោ អាន** បានចូលរួមជាដុំកំភួន នៅក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ស្តីអំពីការកម្ទេចខ្មាំង តាមរយៈ *អំពើនានាដូចជា* ការចូលរួមនៅក្នុងអង្គប្រជុំទាំងឡាយ នៃគណៈកម្មាធិការភូមិភាគកណ្តាលធ្វើផែនការបោសសម្អាតភូមិភាគកណ្តាល ការកំណត់មុខសញ្ញាខ្មាំងដើម្បីបោសសម្អាត ការបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់មនុស្ស ការកោះប្រជុំជាមួយនឹងថ្នាក់ក្រោមស្តីអំពីប្រតិបត្តិការបោសសម្អាត និងបញ្ជាពួកគេឱ្យប្រុងប្រយ័ត្នជាប្រចាំ ក្នុងការអនុវត្តការចាប់មនុស្ស និងការសម្លាប់មនុស្ស ការត្រួតពិនិត្យលើការអនុវត្តក្នុងការបោសសម្អាត ការផ្តល់នូវការគាំទ្រផ្នែកភស្តុភារដល់ប្រតិបត្តិការនៃការបោសសម្អាត ការប្រើប្រាស់មន្ទីរតំបន់៤១ ជាមជ្ឈមណ្ឌលប្រតិបត្តិការចម្បងសម្រាប់ធ្វើសកម្មភាពបោសសម្អាត រួមមានទាំងការឃុំឃាំង ការសួរចម្លើយ ការធ្វើទារុណកម្ម ការដឹកជញ្ជូន និងការសម្លាប់ និងការសម្របសម្រួលប្រព័ន្ធនៃមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដែលតាមរយៈប្រព័ន្ធនោះ អ្នកទោសទាំងឡាយជាប្រចាំត្រូវបានកំណត់អត្តសញ្ញាណជ្រើសរើសសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ចោល។ ហេតុការណ៍នេះសរុបជាមួយនឹងការប្រកាសរបស់គាត់ជាច្រើនលើក បង្ហាញពីការប្តេជ្ញាចិត្តរបស់គាត់ក្នុងការអនុវត្តផែនការរបស់ *"អង្គការ"* បង្ហាញពីចេតនារបស់គាត់ក្នុងការអនុវត្តគោលនយោបាយ

កម្ទេចខ្មាំង តាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយនៃអ្នកទោស ព្រមទាំងលក្ខខណ្ឌឃុំឃាំងដ៏អមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ ព្រមទាំងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនា។

៨២៩. ដូចដែលបានលើកឡើងនៅក្នុងផ្នែក ៦.៤.៣.៣ **អោ អាន** បានចូលរួមជាដុំកំភួននៅក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលកំណត់មុខសញ្ញាក្រុមពិសេសទាំងឡាយ រួមមានទាំងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅក្នុងភូមិភាគកណ្តាល អតីតមន្ត្រីនៃសាធារណរដ្ឋខ្មែរ *"ប្រជាជនទាហានសា"* ប្រជាជនមកពីភូមិភាគបូព៌ា ប្រជាជនចាម និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈ *រួមមានទាំងតែមិនកំណត់ត្រឹម* ការថ្កោលទោសក្រុមទាំងនេះថាជាជនក្បត់ជាតិ ការបញ្ជាឱ្យរកអត្តសញ្ញាណពួកគេ ចាប់ខ្លួន និងយកទៅសម្លាប់ចោល ព្រមទាំងដឹកនាំការបោសសម្អាតក្រុមពិសេសទាំងនេះនៅក្នុងតំបន់៤១។ លើសពីនេះទៀត ហេតុការណ៍នេះបង្ហាញពីចេតនារបស់គាត់ ក្នុងការអនុវត្តគោលនយោបាយកំណត់មុខសញ្ញាក្រុមទាំងនេះ តាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត *"ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយនៃអ្នកទោស ព្រមទាំងលក្ខខណ្ឌឃុំឃាំងដ៏អមនុស្សធម៌"* ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ ព្រមទាំងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនា។

៨៣០. **អោ អាន** បានចូលរួមមានចេតនាពិសេសផងដែរ ក្នុងការកម្ទេចជនជាតិចាមនៃខេត្តកំពង់ចាម តាមរយៈការប្រព្រឹត្តិអំពើដែលមានចែងក្នុងពីសម្លាប់សមាជិកនៃប្រជាជនចាម និងបង្កនូវព្យសនកម្មរូបរាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរទៅលើពួកគេ។ គាត់បានបញ្ជាលេខាស្រុកនានានៅក្នុងតំបន់៤១ ឱ្យប្រមូលបញ្ជីប្រជាជនចាម និងបញ្ជាជនជាតិចាមទាំងអស់ត្រូវចាប់ខ្លួន និងយកទៅសម្លាប់ចោល។ គាត់ចេញបញ្ជាឱ្យមានការចាប់ខ្លួនជាទ្រង់ទ្រាយធំទៅលើជនជាតិចាមជាច្រើនលើក ហើយបានត្រួតពិនិត្យការវិវត្តនៃប្រតិបត្តិការសម្លាប់មនុស្ស តាមរយៈរបាយការណ៍ដែលបានរាយការណ៍ទៅដល់គាត់។ ហេតុការណ៍ដែលថា គាត់មានចេតនា

កម្ទេចជនជាតិចាមបានបញ្ជាក់បន្ថែម តាមរយៈលក្ខណៈ និងទ្រង់ទ្រាយធំនៃការប្រតិបត្តិការដែលបានអនុវត្តតាមបញ្ជារបស់គាត់។ មកដល់ទីបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានចេញបញ្ជាឱ្យមានការប្រឹងប្រែងទ្វេដងថា ជនជាតិចាមណាដែលនៅសេសសល់ ត្រូវតែរកឱ្យឃើញ កត់បញ្ជី ព្រមទាំងតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់មួយកម្រិតទៀតក្នុងការរៀបចំបញ្ជី ដូច្នេះបានបង្ហាញនូវការប្រឹងប្រែងប្តេជ្ញាចិត្តជាបន្ត ក្នុងការកម្ទេចជនជាតិចាម។ ទោះបីជា **អោ អាន** បានអនុញ្ញាតតាមសំណើរបស់ ប្រាក់ យុត ក្នុងការលើកលែងឱ្យនារីជនជាតិចាមម្នាក់ដែលនៅក្រោមការថែទាំងរបស់ ប្រាក់ យុត អំពើដាច់ដោយឡែកមួយនេះ មិនអាចលុបបំបាំងនូវចេតនារបស់គាត់ក្នុងការកម្ទេចជនជាតិចាម ក្នុងនាមជាក្រុមមួយបានឡើយ។ ផ្ទុយទៅវិញការដែលមានការលើកលែងពិសេស ត្រូវតែមានការអនុញ្ញាតពី **អោ អាន** ក្នុងការទុកជីវិតសូម្បីតែជនជាតិចាមដ៏សាមញ្ញម្នាក់ ម្យ៉ាងវិញនោះ បានបង្ហាញនូវភ័ស្តុតាងបន្ថែមនៃចេតនារបស់គាត់ថា ជនជាតិចាមត្រូវតែយកទៅកម្ទេច ហើយម្យ៉ាងវិញទៀត បានផ្តល់នូវការលើកលែង និងប្រយោជន៍ផ្ទាល់ខ្លួន ពីអ្វីដែលជាទូទៅជាគោលនយោបាយកម្ទេចយ៉ាងម៉ត់ចត់ គឺជាអ្វីដែលកើតឡើងជាទូទៅនៅក្នុងប្រព័ន្ធផ្តាច់ការទាំងឡាយ ដែលមានលក្ខណៈល្បីល្បាញ និងជាប្រវត្តិសាស្ត្រ។

៨៣១. ដូចដែលបានលើកឡើងនៅក្នុងផ្នែក ៦.៣.៤.៤ **អោ អាន** បានចូលរួមជាដុំកំភួននៅក្នុងគោលនយោបាយបក្សកុម្មុនីស្តកម្ពុជា ស្តីអំពីការរៀបការដោយបង្ខំ តាមរយៈ *អំពើនានាដូចជា* ការផ្សព្វផ្សាយគោលនយោបាយស្តីអំពីការរៀបការ និងតម្រូវការឱ្យបង្កើនចំនួនប្រជាជន តាមរយៈសុន្ទរកថារបស់គាត់នៅតាមការប្រជុំនានា ការអនុញ្ញាតឱ្យមាន និងការធ្វើអធិបតីនៅពិធីរៀបការទាំងឡាយ ព្រមទាំងការដាក់ចេញនូវច្បាប់វិន័យ ដែលតម្រូវឱ្យគូប្តីប្រពន្ធត្រូវតែរួមភេទនៅពេលរៀបការ ដោយមិនមានការព្រមព្រៀងរបស់គូស្វាមីភរិយាទាំងនោះ។ ការនេះក៏បង្ហាញផងដែរនូវចេតនារបស់គាត់ ក្នុងការអនុវត្តគោលនយោបាយ តាមរយៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអំពើឃោរឃៅផ្សេងៗទៀត (ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ)។

### ៩.១.៣. ការរៀបចំផែនការ

*ការដ្ឋានទំនប់អន្លង់ជ្រៃ*

៨៣២. **អោ អាន** បានរៀបចំផែនការឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ការធ្វើអំពើជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅទំនប់អន្លង់ជ្រៃ ក្នុងចន្លោះពីចុងឆ្នាំ ១៩៧៧ រហូតដល់ពាក់កណ្ដាល ឬចុងឆ្នាំ ១៩៧៨ តាមរយៈការរៀបចំចាត់ចែង និងរក្សានូវប្រព័ន្ធពលកម្មដោយបង្ខំទៅលើកម្មករ ក្រោមលក្ខខណ្ឌទាំងឡាយប្រកបដោយអមនុស្សធម៌នៅការដ្ឋាន រួមមានទាំងការសម្លាប់កម្មករដែលចោទថាជាខ្មាំង ហើយតាមរយៈ *អំពើទាទាដូចជា* ការចលនាប្រមូលកម្លាំង និងធនធានទាំងឡាយមកពីស្រុកផ្សេងៗនៅក្នុងតំបន់៤១ ធ្វើប្រតិភូកម្មការងារទៅឱ្យកម្មាភិបាលដែលមានឋានៈខ្ពស់ៗនៅក្នុងតំបន់៤១ ឱ្យចាត់ចែងការសាងសង់នៅក្នុងតំបន់នោះ ដោយណែនាំអំពីការកំណត់ផែនការបង្កបង្កើនផល និងព្រមានថា អ្នកណាខកខានបំពេញមិនបាននូវភារកិច្ចរបស់ខ្លួននឹងត្រូវចោទថាខ្មាំង។ តាមរយៈអំពើនេះ **អោ អាន** បានចូលរួមជាដុំកំភួននៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ដោយសារ **អោ អាន** មានអំណាចទាំងស្រុងទៅលើការសាងសង់ទំនប់ និងបានធ្វើទស្សនកិច្ចជាប្រចាំទៅទីតាំងនោះ ការទាញសន្និដ្ឋានដែលសមហេតុផលតែមួយគត់គឺថា **អោ អាន** មានចេតនាធ្វើឱ្យឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើង។

*មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស*

៨៣៣. **អោ អាន** បានរៀបចំផែនការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ និងសាសនា ដែលបានប្រព្រឹត្តនៅទីតាំងផ្សេងៗ នៅទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញ្ញជី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ និងមន្ទីរសន្តិសុខវត្តតាមាក់។ គិតមកត្រឹមដើមឆ្នាំ ១៩៧៧ និងរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ **អោ អាន** បានរៀបចំ ត្រួតពិនិត្យ និងថែរក្សាប្រព័ន្ធនៃមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅក្នុងតំបន់៤១ ដោយបម្រើនូវគោលបំណងនៃការឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់បណ្ដាក្រុមមនុស្សដែលចោទថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយដាក់ពួកគេឱ្យទទួលរងនូវលក្ខខណ្ឌនៃការឃុំឃាំងដោយអមនុស្សធម៌។ **អោ អាន** ចូលរួមការប្រជុំថ្នាក់ភូមិភាគ និងថ្នាក់តំបន់នានា ដើម្បីធ្វើផែនការបោសសម្អាត និងអនុវត្តគោលនយោបាយទាំងឡាយរបស់បក្ស

កុម្មុយនីស្តកម្ពុជា។ **អោ អាន** បានកំណត់អត្តសញ្ញាណដោយផ្ទាល់ *"ខ្មាំង"* ដែលត្រូវបោសសម្អាត រៀបចំវិធីសាស្ត្រដើម្បីបញ្ឆោតមនុស្សយកមកចាប់ខ្លួន បញ្ជាឱ្យថ្នាក់ក្រោមរបស់គាត់ធ្វើការចាប់មនុស្ស និងសម្លាប់មនុស្ស ត្រួតពិនិត្យការបោសសម្អាត ផ្តល់ការគាំទ្រផ្នែកភស្តុភា ព្រមទាំងប្រើប្រាស់មន្ទីរតំបន់៤១ ធ្វើជាមជ្ឈមណ្ឌលប្រតិបត្តិការចម្បងសម្រាប់សកម្មភាពបោសសម្អាតទាំងឡាយ។ អាស្រ័យហេតុនេះ **អោ អាន** បានចូលរួមជាដុំកំភួនប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ សាសនា និងបង្ហាញពីចេតនារបស់គាត់ ក្នុងការរើសអើងផ្អែកលើហេតុផលនយោបាយ និងសាសនា។

*ការរៀបការដោយបង្ខំ*

៨៣៤. **អោ អាន** បានរៀបចំផែនការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗ តាមរយៈការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ នៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ។ ក្នុងឋានៈជាអនុភូមិភាគកណ្តាល និងជាលេខាតំបន់៤១ **អោ អាន** បានចាត់ចែងនូវការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ក្នុងការបង្ខំឱ្យមនុស្សរៀបការគូស្រករ *"ដែលអង្គការ"* ជាអ្នករើសឱ្យ និងក្នុងករណីជាច្រើនបង្ខំគូប្តីប្រពន្ធឱ្យរួមភេទនៅពេលរៀបការនោះ ដោយមិនគិតពីការយល់ព្រមរបស់ពួកគេ។ **អោ អាន** បានផ្សព្វផ្សាយគោលនយោបាយស្តីអំពីការរៀបការ និងតម្រូវការដែលត្រូវបង្កើនចំនួនប្រជាជនតាមរយៈការធ្វើសុន្ទរកថារបស់គាត់នៅតាមការប្រជុំនានា បានអនុញ្ញាតឱ្យមាន និងធ្វើជាអធិបតីនៅក្នុងពិធីរៀបការនានា ព្រមទាំងចេញនូវច្បាប់វិន័យដែលតម្រូវឱ្យគូប្តីប្រពន្ធត្រូវតែរួមភេទនៅពេលដែលពួកគេរៀបការ ដោយមិនគិតពីការយល់ព្រមរបស់ពួកគេ។ **អោ អាន** អាស្រ័យហេតុនេះបានចូលរួមដោយចេតនា និងជាដុំកំភួននៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗ។

*ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*

៨៣៥. **អោ អាន** បានរៀបចំផែនការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាមនៅខេត្តកំពង់ចាម តាមរយៈការចេញបញ្ជាឱ្យបណ្ដាលេខាស្រុកនៅក្នុងតំបន់៤១ ប្រមូលបញ្ជីប្រជាជនចាម និងចេញបញ្ជាឱ្យចាប់ជនជាតិចាមទាំងអស់ ហើយយកទៅសម្លាប់ចោល។ **អោ អាន** ក៏បានត្រួតពិនិត្យនូវការវិវត្តនៃប្រតិបត្តិការសម្លាប់មនុស្ស តាមរយៈរបាយការណ៍នានាដែលផ្ញើមកដល់គាត់។ អាស្រ័យហេតុនេះ **អោ អាន** បានចូលរួមដោយចេតនា និងជាដុំកំភួនក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ **អោ អាន** ក៏បានចូលរួមមានចេតនា ជាពិសេសក្នុងការកម្ទេចជនជាតិចាមនៅខេត្តកំពង់ចាម តាមរយៈការប្រព្រឹត្តិអំពើដែលមានចែងអំពីការសម្លាប់សមាជិកនានានៃប្រជាជនចាម ព្រមទាំងបង្កនូវព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរដល់អ្នកដែលនៅរស់រានមានជីវិត។

### *៩.១.៤. ការបញ្ជា*

*ការដ្ឋាន (ទំនប់អន្លង់ជ្រៃ)*

៨៣៦. សិទ្ធិអំណាចផ្ទាល់ និងទាំងស្រុងដែល **អោ អាន** បានប្រើលើការដ្ឋានទំនប់អន្លង់ជ្រៃ សរុបជាមួយនឹងការទស្សនកិច្ច និងការប្រជុំជាទៀងទាត់របស់គាត់នៅទីតាំងនោះ បញ្ជាក់យ៉ាងច្បាស់ថា **អោ អាន** បានបញ្ជាកម្មាភិបាលថ្នាក់ក្រោមរបស់គាត់នៅទីតាំងនោះ ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការធ្វើឱ្យទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងៗ ដែលបានចូលរួមជាដុំកំភួនក្នុងការប្រព្រឹត្តិបទល្មើសទាំងនោះ។ ការព្រមានរបស់ **អោ អាន** ដែលថា អ្នកណាដែលខកខានមិនបានសម្រេចគោលដៅបង្កបង្កើនផលដែលបានកំណត់ នឹងត្រូវចោទជា *"ខ្មាំង"* ដែលជាការកំណត់មួយ ដែលជាទូទៅតែងតែនាំមកនូវការសម្លាប់មនុស្ស ធ្វើឱ្យមានការសន្និដ្ឋានសមរម្យតែមួយគត់ ដែលអាចធ្វើទៅបាន គឺថា **អោ អាន** បានបញ្ជាកម្មាភិបាលទាំងឡាយដែលកាន់អំណាចនៅទីតាំងនោះ ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការធ្វើមនុស្សឃាត។

*មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស*

៨៣៧. **អោ អាន** បានចេញបញ្ជានូវការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត និង

ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ និងសាសនា ដែលបានប្រព្រឹត្តនៅទីតាំងផ្សេងៗ ដូចជាទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខវត្តឡូលបេង និង អង្គញ្ញងី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ និងមន្ទីរសន្តិសុខវត្តតាមាក់។ នៅក្នុងចន្លោះពីដើមឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ **អោ អាន** បានចេញបញ្ជាឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់គាត់កំណត់មុខសញ្ញា ចាប់ខ្លួន និងសម្លាប់ក្រុមនានាដែលចោទថា ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយបានអនុវត្តតាមរយៈប្រព័ន្ធនៃមន្ទីរសន្តិសុខ និងទីតាំងសម្លាប់នៅក្នុងតំបន់៤១ ដែលខ្មាំងទាំងនោះត្រូវបានដាក់ឃុំនៅក្នុងស្ថានភាពប្រកបដោយហិង្សា និងអមនុស្សធម៌ ត្រូវរងទារុណកម្ម និងសម្លាប់ចោល។ លើសពីនេះទៀត ការគ្រប់គ្រងទាំងស្រុងរបស់ **អោ អាន** ទៅលើរចនាសម្ព័ន្ធមន្ទីរសន្តិសុខនៅក្នុងតំបន់៤១ អាចនាំឱ្យមានការសន្និដ្ឋានសមហេតុផលតែមួយគត់ថា បណ្ដាជនដែលដល់ទាំងនោះបានប្រព្រឹត្តទៅតាមបញ្ជាទាំងឡាយដែលចេញមកពី **អោ អាន** ទោះបីជាក្នុងករណីដែលមិនមានភស្តុតាងផ្ទាល់បញ្ជាក់អំពីបញ្ជាណាមួយជាក់លាក់ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នីមួយៗក៏ដោយ។ តាមរយៈបញ្ជាទាំងឡាយរបស់គាត់ **អោ អាន** បានចូលរួមដោយចេតនា និងជាដុំកំភួនក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មខាងលើនេះ។

*ការរៀបការដោយបង្ខំ*

៨៣៨. **អោ អាន** បានចេញបញ្ជាឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ។ **អោ អាន** បានចេញបញ្ជាឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់គាត់ រៀបចំការរៀបការរវាងអ្នកដែលរស់នៅក្នុងតំបន់៤១។ លើសពីនេះទៀត **អោ អាន** បានចេញបញ្ជាឱ្យមានការរៀបការដោយបង្ខំដោយឡែកផ្សេងៗទៀត ដោយបានចេញការអនុញ្ញាតទៅលើបញ្ជីស្នើចាប់គូ ដែលកម្មាភិបាលរបស់គាត់បានដាក់ជូនគាត់សម្រេច។ ជាចុងបញ្ចប់ **អោ អាន** បានចេញបញ្ជាឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់គាត់ធានាថា គូប្ដីប្រពន្ធដែលបានរៀបការត្រូវតែរួមភេទ នៅពេលរៀបការរួច ដើម្បីបង្កើតកូន ដើម្បីបម្រើការរីកចម្រើនរបស់ជាតិ។ ដូច្នេះ **អោ អាន** បានចូលរួមដោយចេតនា និងជាដុំកំភួនក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអំពើអមនុស្សធម៌ផ្សេងៗទៀត។

*ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*

៨៣៩. **អោ អាន** បានចេញបញ្ជាឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាមនៅក្នុងខេត្តកំពង់ចាម តាមរយៈការចេញបញ្ជាឱ្យបណ្ដាលេខាស្រុកនៅក្នុងតំបន់៤១ ប្រមូលបញ្ជីឈ្មោះប្រជាជនចាម ហើយបន្ទាប់មកបញ្ជាឱ្យចាប់ និងសម្លាប់ចាមទាំងអស់នោះ ហើយដូច្នេះគាត់បានចូលរួមដោយមានចេតនា និងជាដុំកំភួនក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ **អោ អាន** ក៏ចូលរួមមានចេតនាពិសេស ក្នុងការកម្ទេចជនជាតិចាមនៃខេត្តកំពង់ចាម តាមរយៈការសម្លាប់សមាជិកប្រជាជនចាម និងបង្កឲ្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរចំពោះអ្នកដែលបាននៅរស់រានមានជីវិត។

## ៩.១.៥. ការញុះញង់

*ការដ្ឋាន (ទំនប់អន្លង់ជ្រៃ)*

៨៤០. **អោ អាន** បានញុះញង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៅទំនប់អន្លង់ជ្រៃក្នុងចន្លោះពីចុងឆ្នាំ ១៩៧៧ ដល់ពាក់កណ្ដាល ឬចុងឆ្នាំ ១៩៧៨ តាមរយៈការផ្ដល់ការណែនាំទាំងឡាយ ស្ដីពីការកំណត់គោលដៅនៃការបង្កបង្កើនផល និងការព្រមានថា អ្នកដែលខកខានមិនអាចសម្រេចភារកិច្ចរបស់ខ្លួនបាន នឹងត្រូវចោទថាជាខ្មាំង។ នៅក្នុងអំឡុងពេលនៃការទស្សនកិច្ចយ៉ាងញឹកញាប់របស់ **អោ អាន** ទៅកាន់ការដ្ឋានទំនប់អន្លង់ជ្រៃ គាត់មិនបានចាត់ការអ្វីដើម្បីបន្ថយ ឬដោះស្រាយលក្ខខណ្ឌដ៏លំបាកវេទនា ដែលកម្មករបានទទួលរង ដែលជាការលើកទឹកចិត្តដល់អ្នកកាន់អំណាចទាំងឡាយឱ្យបន្តការធ្វើបាបទៅលើកម្មករទាំងឡាយថែមទៀត។ តាមរយៈការប្រព្រឹត្តិអំពើសកម្ម និងអកម្មទាំងនេះ **អោ អាន** បានជំរុញជនដៃដល់ទាំងឡាយឱ្យដាក់កម្មករនានាជាទាសករ បង្ខំពួកគេឱ្យធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌ និងឱ្យសម្លាប់កម្មករជារឿយៗ នៅការដ្ឋានទំនប់អន្លង់ជ្រៃ ហើយដូច្នេះ គឺគាត់បានចូលរួមជាដុំកំភួនក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ដោយសារ **អោ អាន** មានអំណាចទាំងស្រុងទៅលើការកសាងទំនប់ ព្រមទាំង

បានទទួលបានកិច្ចជាញឹកញាប់ទៅការដ្ឋាននោះ ការសន្និដ្ឋានតែមួយគត់ដៀសមិនផុតនោះគឺថា **អោ អាន** មានចេតនាបណ្តាយឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។

*មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស*

៨៤១. **អោ អាន** បានញុះញង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម អំពើឃោរឃៅផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ និងសាសនា ដែលបានប្រព្រឹត្តនៅទីតាំងផ្សេងៗនៅទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញ្ញីឌី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ និងមន្ទីរសន្តិសុខវត្តតាមាក់។ នៅក្នុងការប្រជុំជាប្រចាំ **អោ អាន** បានលើកទឹកចិត្តឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់គាត់ធ្វើការរក្សាការប្រុងប្រយ័ត្នជាប្រចាំចំពោះខ្មាំង និងចាប់ខ្មាំងទាំងអស់។ **អោ អាន** ក៏បានអនុញ្ញាតឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់គាត់ផ្ទាល់ធ្វើការកំណត់ ចាប់ខ្លួន និងសម្លាប់ *"ខ្មាំង"* ដោយខ្លួនឯង។ នៅក្នុងបរិបទនៃប្រព័ន្ធមួយ ដែលមានមន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្សនានានៅក្នុងតំបន់៤១ សំដៅដាក់ឃុំឃាំងធ្វើទារុណកម្ម និងសម្លាប់ចោលក្រុមទាំងឡាយដែលចោទថាជាខ្មាំងនៃបក្សកុម្មុយនីស្តកម្ពុជា និងដាក់ពួកគេឱ្យទទួលរងនូវលក្ខខណ្ឌនៃការឃុំឃាំងដ៏ឃោរឃៅក៏ដូចជាអំណាចទាំងស្រុង និងការដឹងឮរបស់ **អោ អាន** ចំពោះមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានានៅក្នុងតំបន់៤១ ការសន្និដ្ឋានអាចទាញបានថា ជនរងគ្រោះទាំងនោះ ត្រូវបានជំរុញជាដុំកំភួនពីការញុះញង់របស់ **អោ អាន** និងថា **អោ អាន** មានចេតនាប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ដែលបានលើកឡើងខាងលើ។

*ការរៀបការដោយបង្ខំ*

៨៤២. **អោ អាន** បានញុះញង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗ ដែលបានប្រព្រឹត្តតាមរយៈការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ។ **អោ អាន** បានលើកទឹកចិត្តឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់គាត់រៀបចំពិធីរៀបការរវាងអ្នកដែលរស់នៅក្នុងតំបន់៤១ បានអនុម័តលើបញ្ជីចាប់គូដែលថ្នាក់ក្រោមរបស់គាត់បានស្នើមក ហើយបញ្ជាកម្មាភិបាលថ្នាក់ក្រោមរបស់

គាត់ឱ្យធានាថា គូប្ដីប្រពន្ធដែលបានរៀបការត្រូវតែរួមភេទនៅពេលរៀបការរួច ដើម្បីបង្កើតកូនបម្រើផលប្រយោជន៍នៃការរីកចម្រើនរបស់ជាតិ។ តាមរយៈពាក្យពេចន៍ និងសកម្មភាពរបស់គាត់ **អោ អាន** មានចេតនាជំរុញបណ្ដាជនដែលឱ្យបង្ខំប្រជាជនរៀបការនៅក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរ ហើយបង្ខំប្រជាជនឱ្យរួមភេទនៅពេលរៀបការរួច។ ដូច្នេះ **អោ អាន** បានចូលរួមជាដុំកំភួនក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗទៀត។

*ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*

៨៤៣. **អោ អាន** បានញុះញង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាមក្នុងខេត្តកំពង់ចាម តាមរយៈការចេញបញ្ជាឱ្យលេខាស្រុកទាំងឡាយនៅក្នុងតំបន់៤១ ប្រមូលបញ្ជីឈ្មោះជនជាតិចាមទាំងអស់នៅតាមស្រុកនីមួយៗ ហើយបន្ទាប់មកចាប់ និងសម្លាប់ពួកគេ។ តាមរយៈអំពើទាំងនេះ **អោ អាន** បានចូលរួមដោយចេតនា និងជាដុំកំភួនក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ **អោ អាន** ក៏ចូលរួមមានចេតនាពិសេសផងដែរក្នុងការកម្ទេចជនជាតិចាមនៅខេត្តកំពង់ចាម តាមរយៈអំពើដែលមានចែងពីការសម្លាប់សមាជិករបស់ប្រជាជនចាម និងបង្កព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរដល់អ្នកដែលបានរស់រានមានជីវិត។

## ៩.១.៦. ការទទួលខុសត្រូវរបស់ថ្នាក់លើ

*ការដ្ឋាន (ទំនប់អន្លង់ជ្រៃ)*

៨៤៤. **អោ អាន** គឺជាលេខាតំបន់៤១ ហើយអាស្រ័យហេតុនេះគាត់មានអំណាច *ព្រឹត្តន័យ និងនីតិន័យ* ទៅលើកម្មាភិបាលនៅការដ្ឋានទំនប់អន្លង់ជ្រៃ ដែលអំណាចនោះផ្ដល់លទ្ធភាពយ៉ាងធំដល់គាត់ក្នុងការទប់ស្កាត់ និងដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តដោយបណ្ដាជនដែលនៅការដ្ឋាននោះ។ **អោ អាន** ខកខានមិនបានធ្វើដូច្នោះឡើយ។ **អោ អាន** បានមកទស្សនកិច្ចការដ្ឋាននោះជាប្រចាំ ហើយបានដឹងឮពេញលេញនូវលក្ខខណ្ឌអមនុស្សធម៌ដែលកម្មករទាំងឡាយបានទទួលរង គឺជាសភាពការណ៍មួយដែល **អោ អាន** ខ្លួនគាត់ផ្ទាល់មានចេតនាចូលរួមប្រព្រឹត្ត។ អាស្រ័យហេតុនេះ **អោ អាន** បានដឹងថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងឡាយដូចជា ការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ និងអំពើ

អមនុស្សធម៌ផ្សេងៗទៀត បានកំពុងប្រព្រឹត្តជាប់ជាបន្តបន្ទាប់ ដោយកម្មាភិបាលថ្នាក់ក្រោមរបស់គាត់នៅការដ្ឋានទំនប់អន្លង់ជ្រៃ។ ទោះបីជាគាត់បានមកទស្សនកិច្ចជាប្រចាំនៅការដ្ឋាននោះក៏ដោយ **អោ អាន** មិនបានចាត់វិធានការទប់ស្កាត់ការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មទាំងឡាយខាងលើនេះ ដែលបានប្រព្រឹត្តដោយកម្មាភិបាលថ្នាក់ក្រោមរបស់គាត់ឡើយ ហើយក៏មិនមានភស្តុតាងបញ្ជាក់ថា **អោ អាន** បានដាក់ទណ្ឌកម្មដល់កម្មាភិបាល ដែលគាត់មានសិទ្ធិអំណាចគ្រប់គ្រងដោយប្រសិទ្ធភាពដែរ។ ផ្ទុយទៅវិញ **អោ អាន** បានចូលរួមយ៉ាងសកម្មក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយនៅការដ្ឋាននោះ។

*មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស*

៨៤៥. **អោ អាន** ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះបណ្តាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងឡាយ ដូចជា ការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ និងសាសនា ដែលបានប្រព្រឹត្តដោយកម្មាភិបាលថ្នាក់ក្រោមរបស់គាត់នៅទីតាំងផ្សេងៗ ដូចជា ទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខទួលបេង និងអង្គញ្ញី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ និងមន្ទីរសន្តិសុខវត្តតាមាក់។ ទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ សុទ្ធតែស្ថិតនៅក្នុងតំបន់៤១ ដែលមានរចនាសម្ព័ន្ធនៃការបញ្ជារាយការណ៍ឱ្យ **អោ អាន** ដែលមានសិទ្ធិគ្រប់គ្រងទាំងផ្លូវច្បាប់ និងតាមជាក់ស្តែងទៅលើកម្មាភិបាលទាំងនោះ។ **អោ អាន** បានទទួលរបាយការណ៍ជាប្រចាំ ដែលបានរាយការណ៍ជូនគាត់អំពីឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តនៅទីតាំងទាំងនេះ ប៉ុន្តែគាត់បានខកខានក្នុងការដាក់ទណ្ឌកម្មបណ្តាជនដែលដល់ ឬទប់ស្កាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះកុំឱ្យបន្តទៀត។

៨៤៦. មិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការកំណត់ថា **អោ អាន** មានសិទ្ធិអំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើកម្មាភិបាលនៅទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុសទេ។ ដូច្នេះ **អោ អាន** មិនត្រូវទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំចំពោះការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទីតាំងសម្លាប់មនុស្សនេះឡើយ។

01588966



*ការរៀបការដោយបង្ខំ*

៨៤៧. **អោ អាន** ទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាក្រោមការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ **អោ អាន** ទាំងតាមផ្លូវច្បាប់ និងតាមជាក់ស្តែង បានរៀបការមនុស្សដោយបង្ខំនៅក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរ ហើយបង្ខំគូប្តីប្រពន្ធឱ្យរួមភេទ នៅពេលរៀបការរួច។ **អោ អាន** បានដឹងអំពីការអនុវត្តយ៉ាងទូលំទូលាយនូវការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ ដែលប្រព្រឹត្តដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាក្រោមការគ្រប់គ្រងរបស់គាត់ ប៉ុន្តែបានខកខានចាត់វិធានការផ្សេងៗក្នុងការទប់ស្កាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ហើយគាត់ក៏មិនបានដាក់ទណ្ឌកម្មដល់ជនដែលដល់ទាំងនោះ។

*ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*

៨៤៨. **អោ អាន** ទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលកម្មាភិបាលថ្នាក់ក្រោមរបស់**អោ អាន** បានប្រព្រឹត្តនៅក្នុងតំបន់៤។ **អោ អាន** បានខកខានក្នុងការទប់ស្កាត់ការកម្ទេចជនជាតិចាមនៅក្នុងតំបន់៤១ ហើយមិនបានចាត់វិធានការណាមួយក្នុងការដាក់ទណ្ឌកម្មជនដែលដល់ទាំងឡាយ ដែលគាត់មានអំណាចគ្រប់គ្រងទាំងខាង *តាមព្រឹត្តិន័យនិងនីតិន័យ*។ **អោ អាន** បានដឹងថា កម្មាភិបាលក្រោមបង្គាប់របស់គាត់ បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយមានចេតនាពិសេសក្នុងការកម្ទេចជនជាតិចាមនៅខេត្តកំពង់ចាម តាមរយៈអំពើទាំងឡាយដែលសម្លាប់សមាជិកនានារបស់ប្រជាជនចាម និងបង្កព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរដល់អ្នកដែលនៅរស់រានមានជីវិត។

៨៤៩. មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា **អោ អាន** មានអំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើបណ្តាជនដែលដល់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅក្នុងតំបន់៤២ និងតំបន់៤៣។ អាស្រ័យហេតុនេះ **អោ អាន** មិនទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំចំពោះអំពើទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងតំបន់ទាំងនោះឡើយ។

## ៩.២. ឧក្រិដ្ឋកម្មតាមច្បាប់ជាតិ

### ៩.២.១. ការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្ម

៨៥០. **អោ អាន** ទទួលខុសត្រូវក្នុងឋានៈជាសហចារីចំពោះឧក្រិដ្ឋកម្ម ការធ្វើមនុស្សឃាតគិតទុកជាមុនដែលបានប្រព្រឹត្តនៅការដ្ឋានអន្លង់ជ្រៃ ទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញជី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ ទីតាំងសម្លាប់មនុស្សភ្នំប្រុស និងមន្ទីរសន្តិសុខវត្តតាមាក់។ **អោ អាន** ជាមួយនឹងកម្មាភិបាលផ្សេងៗទៀតបានចូលរួមដោយផ្ទាល់ និងដោយចេតនាក្នុងការប្រព្រឹត្តិអំពើមនុស្សឃាតគិតទុកជាមុន តាមរយៈការកំណត់មុខសញ្ញាខ្មាំងដែលត្រូវបោសសម្អាត បញ្ជាកម្មាភិបាលក្រោមបង្គាប់ឱ្យសម្លាប់មនុស្ស ដែលបានតួញត្អែរពីលក្ខខណ្ឌរស់នៅ និងការងារសម្របសម្រួលប្រព័ន្ធមន្ទីរសន្តិសុខទាំងឡាយ ដែលតាមរយៈប្រព័ន្ធនោះ អ្នកទោសនានាត្រូវបានកំណត់អត្តសញ្ញាណ ចាប់ខ្លួន និងសម្លាប់ចោល។

### ៩.២.២. ការរៀបចំផែនការ និងការបញ្ជា

៨៥១. ផ្អែកលើហេតុផលដែលបានលើកឡើងខាងលើក្នុងផ្នែក ៩.១.៣ និង ៩.១.៤ **អោ អាន** ក៏ទទួលខុសត្រូវផងដែរចំពោះការរៀបចំផែនការ និងការចេញបញ្ជាឱ្យប្រព្រឹត្តអំពើមនុស្សឃាតគិតទុកជាមុន ដែលបានប្រព្រឹត្តនៅទួលបេង និងវត្តអង្គញជី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ និងមន្ទីរសន្តិសុខវត្តតាមាក់។

## ១០. ការបន្ថិតបន្ថយ

៨៥២. មានការចោទថា **អោ អាន** បានប្រាប់អតីតអ្នកការពាររបស់គាត់ថា អ្នកការពារនោះនឹងត្រូវសម្លាប់ចោល ប្រសិនបើគាត់មិនអនុវត្តផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីថ្លែងបែបនេះ ដែលលើកឡើងនូវបញ្ហាជាទូទៅនៃលទ្ធភាពនៃការការពារបានតាមស្ថានបន្ទាន់បង្ខំ គឺមិនមានអ្វីក្រៅពីការស៊ីចង្វាក់ជាមួយនឹងបរិយាកាសបង្ខំជាទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅគ្រប់រចនាសម្ព័ន្ធ និងកម្រិតដូចដែលសហចៅក្រមស៊ើប

អង្កេតបានសម្រេចនៅក្នុង *ដីកាដំណោះស្រាយ (សំអាងហេតុ)* នៅក្នុងសំណុំរឿង០០៤/១[2422] ហើយវាមានលក្ខណៈទូទៅពេក រហូតដល់វាមានលក្ខណៈថា ទោះបីជាមានសេចក្តីថ្លែងការណ៍ធ្វើដូច្នេះក៏ដោយ ហើយដោយគ្មានអ្វីពិស្តារបន្ថែម វាមិនអាចឈានឡើងដល់កម្រិតដែលយកការបង្ខិតបង្ខំមកការពារខ្លួនបានឡើយ ដោយមិនគិតដល់អង្គហេតុដែលថា ការការពារនឹងត្រូវទាត់ចោល ទោះជាក្នុងហេតុការណ៍ណាក៏ដោយ ដោយសារតែទំនាក់ទំនងដោយស្ម័គ្រចិត្តរបស់ **អោ អាន** ជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ[2423]។

## ១១. សេចក្តីសម្រេចលើការឃុំខ្លួន មុនសវនាការ

៨៥៣. ទោះបីជាយើងបានសម្រេចថា មានបទចោទគ្រប់គ្រាន់ក្នុងការបញ្ជូន **អោ អាន** ទៅសវនាការក៏ដោយ យើងមិនសម្រេចថា ឱ្យមានការឃុំឃាំង **អោ អាន** រង់ចាំសវនាការថាជាវិធានការចាំបាច់ក្នុងការបញ្ចៀសហានិភ័យណាមួយ យោងវិធានផ្ទៃក្នុង ៦៣ (៣)(b)។ **អោ អាន** បានដឹងឮអស់រយៈពេលជាច្រើនឆ្នាំមកហើយថា គាត់ស្ថិតក្រោមការស៊ើបអង្កេត ហើយបានសហការជាមួយនឹងសហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងពេលទូទាំងការស៊ើបអង្កេតតាមផ្លូវតុលាការទាំងមូល។ វាមិនមានសញ្ញាណាបង្ហាញថា គាត់អាចនឹងគេចវេសពីយុត្តាធិការ ដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះណាមួយ ឬជ្រៀតជ្រែកចូលក្នុងដំណើរការផ្លូវតុលាការដោយវិធីណាមួយនោះឡើយ។ ហើយក៏មិនមានបញ្ហាកង្វល់ផ្នែកសុវត្ថិភាពរបស់ **អោ អាន** ឬ

---

[2422] **សំណុំរឿង ០០៤/១** - ឯកសារ D308/3 *ដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ៤១។

[2423] សម្រាប់នត្រីវិទ្ធកម្ពុជាតិ ការបង្ខិតបង្ខំគឺជាការការពារក្តី យោងតាមមាត្រា ៩៦ ដល់ ៩៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ សម្រាប់នត្រីវិទ្ធកម្មអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូង និង អ.ជ.ត.ក បានសម្រេចថា ការបង្ខិបង្ខិតពាក់ព័ន្ធតែជាមួយនឹងកត្តាស្ថានសម្រាលទោសតែប៉ុណ្ណោះ ហើយបានអនុវត្តកម្រិតលក្ខខណ្ឌសម្រាប់ការបង្ខិតបង្ខំ ដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុងរឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Erdemović*។ *សូមមើល* សំណុំរឿង ០០១ - ឯកសារ E188 *សាលក្រម* ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៦០៨ និងសំណុំរឿង ០០១ - ឯកសារ F28 *សាលដីកា* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣៦៤ ដោយដកស្រង់រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Erdemović* សាលក្រមស្តីពីការប្រកាសទោស អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-96-22-T) ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ កថាខណ្ឌ ១៨។

ការរក្សាសណ្តាប់ធ្នាប់សាធារណៈណាមួយអាចនឹងជាហេតុផលសមរម្យ សម្រាប់តម្រូវឱ្យចេញដីកាឃុំខ្លួនឡើយ។

៨៥៤. ហេតុផលបន្ថែមមួយទៀតក្នុងការមិនចេញដីកាឃុំខ្លួននាពេលនេះ គឺភាពមិនប្រាកដប្រជានៃនីតិវិធី ដែលបណ្តាលមកពីមានដីកាដំណោះស្រាយពីរផ្ទុយគ្នា ដែលជាមូលហេតុធ្វើឱ្យមិនមានភាពច្បាស់លាស់យោងវិធានផ្ទៃក្នុង៧៧(១៣) ថាតើការចោទប្រកាន់នឹងត្រូវដំណើរការទៅមុខក្នុងករណីមិនមានមតិភាគច្រើនលើសលុប នៅក្នុងពេលមានឧទ្ធរណ៍ ទៅដល់អង្គបុរេជំនុំជម្រះ ឬយ៉ាងណា។

## ១២. ដីកាបញ្ចប់ការស៊ើបសួរយោងវិធាន *៦៦ស្ទួន*

យើង**បញ្ចប់**ការស៊ើបសួរតាមផ្លូវតុលាការពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយ ដែលបានដកចេញតាមសេចក្តីសម្រេចយោងវិធាន៦៦*ស្ទួន* ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៥។

## ១៣. ដីកាលើកលែងចោទចំពោះការចោទប្រកាន់មួយចំនួន

ការចោទប្រកាន់ខាងក្រោមនេះត្រូវបាន**លើកលែង**៖

**១. ការបង្អាយចេតនានូវលក្ខខណ្ឌនៃការរស់នៅទាំងឡាយ ដែលគិតថានឹងបណ្តាលឱ្យមានវិនាសកម្មតាមផ្លូវរូបរាងកាយ ថាជាអំពើដែលមានចែងពីឧក្រិដ្ឋកម្មទៅលើជនជាតិចាម។**

**២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖**

**ទីតាំងសម្លាប់មនុស្សគោកព្រីង**

- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយទៅលើអតីតទាហាន លន់ នល់ តាមរយៈបទល្មើសនានា ដែលមានចែងអំពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត។

**មន្ទីរសន្តិសុខមិត្តសុប**

- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយទៅលើអតីតទាហាន លន់ នល់ តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងពីការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

**មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញ្ញីដ៏**

- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត។
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនា តាមរយៈបទល្មើសទាំងឡាយដែលមានចែងពីការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

**មន្ទីរសន្តិសុខវត្តអូរត្រកួន**

- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ តាមរយៈបទល្មើសដែលចែងពីការធ្វើទារុណកម្ម

**មន្ទីរសន្តិសុខវត្តបាលាយ**

- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ ទៅលើប្រជាជនភូមិភាគបូព៌ា តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងពីការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនា តាមរយៈបទល្មើសផ្សេងៗ ដែលមានចែងពីការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

**មន្ទីរសន្តិសុខវត្តតាមាក់**

- ការសម្លាប់រង្គាល
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ តាមរយៈបទល្មើសទាំងឡាយដែលមានចែងពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត។

## ១៤. ជីវការចោទប្រកាន់

### អោ អាន

- ឈ្មោះកំណើតបានកត់ត្រាថា អោម យឿង ឬ អោ យឿង
- កើតនៅឆ្នាំ ១៩៣៣ នៅភូមិតាំងស្វាយ ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
- អាសយដ្ឋានបច្ចុប្បន្ន៖

ភូមិអូរគគី

ឃុំអូរដា

ស្រុកកំរៀង

ខេត្តបាត់ដំបង។

## ត្រូវចោទប្រកាន់ និងបញ្ជូនទៅសវនាការចំពោះបទល្មើសដូចខាងក្រោម

### បទល្មើស ១៖

### ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ទៅលើជនជាតិចាមក្នុងខេត្តកំពង់ចាម តាមរយៈ

- ការសម្លាប់សមាជិកទាំងឡាយនៃក្រុម និង
- ការបង្កនូវព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរទៅលើបណ្ដាសមាជិកទាំងឡាយនៃក្រុម

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ

ដោយសំអាងលើអង្គហេតុទាំងឡាយ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ រហូតដល់ ៣១៩ និង៥៩០ រហូតដល់៦៧៧

ដែលត្រូវដាក់ទណ្ឌកម្មយោងតាមមាត្រា៤ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

### បទល្មើស២៖

### ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

**១. ការដ្ឋានពលកម្មដោយបង្ខំ ទំនប់អន្លង់ជ្រៃ**

- ការធ្វើមនុស្សឃាត
- ការធ្វើឱ្យទៅជាទាសករ
- អំពើអមនុស្សធម៌ផ្សេងៗទៀត

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវរបស់មេដឹកនាំ។

ដោយផ្អែកទៅលើអង្គហេតុទាំងឡាយ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១៥៧ ដល់៣៥៥

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

**២. ទីតាំងសម្លាប់មនុស្សគោកព្រីង**

- ការសម្លាប់រង្គាល
- ការធ្វើមនុស្សឃាត
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ ទៅលើកម្មាភិបាលភូមិភាគកណ្ដាល និង *"ប្រជាជនថ្មី មេសា"* តាមរយៈបទល្មើសដែលមានចែងនៃការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត និង
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនាទៅលើជនជាតិចាម តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងអំពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវក្នុងឋានៈជាអ្នកដឹកនាំ

ផ្អែកលើអង្គហេតុទាំងឡាយ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១៥៧ ដល់ ៣១៩ និង៣៥៦ ដល់៣៨៤។

ត្រូវផ្ដន្ទាទោសយោងមាត្រា៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

**៣. មន្ទីរសន្តិសុខមិតសុខ**

- ការធ្វើមនុស្សឃាត
- ការធ្វើទារុណកម្ម
- ការដាក់ពន្ធនាគារ
- អំពើអមនុស្សធម៌ផ្សេងៗទៀត និង

- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយទៅលើកម្មាភិបាលទាំងឡាយ នៅភូមិភាគកណ្ដាល និង *"ប្រជាជន១៧ មេសា"* តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងអំពីការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម, ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំ

ផ្អែកទៅលើអង្គហេតុទាំងឡាយ ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់៣១៩ និង ៣៨៥ ដល់៤១១

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

### ៤. មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញ្ជី

- ការសម្លាប់រង្គាល
- ការធ្វើមនុស្សឃាត

  ការធ្វើទារុណកម្ម
- ការដាក់ពន្ធនាគារ
- អំពើអមនុស្សធម៌ផ្សេងៗទៀត
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយទៅលើ *"ប្រជាជន១៧ មេសា"* កម្មាភិបាលទាំងឡាយនៅភូមិភាគកណ្ដាល ប្រជាជនដែលមានទំនាក់ទំនងនឹងរបប លន់ នល់ និងគ្រួសាររបស់ពួកគេ តាមរយៈបទល្មើស ដែលមានចែងអំពីការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត និង
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនាទៅលើជនជាតិចាម តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងអំពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំ

01588974



ផ្អែកទៅលើអង្គហេតុទាំងឡាយដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់៣១៩ និង ៤១២ ដល់៤៥៥

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

**៥. មន្ទីរសន្តិសុខវត្តអូរត្រកួន**

- ការសម្លាប់រង្គាល
- ការធ្វើមនុស្សឃាត
- ការធ្វើទារុណកម្ម
- ការដាក់ពន្ធនាគារ
- អំពើអមនុស្សធម៌ផ្សេងៗទៀត
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយទៅលើ *"ប្រជាជន១៧ មេសា"* អតីតទាហាន នល់ នល់ កម្មាភិបាលទាំងឡាយនៅភូមិភាគកណ្ដាល និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈបទល្មើស ដែលមានចែងអំពីការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត និង
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនាទៅលើជនជាតិចាម តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងអំពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំ

ផ្អែកទៅលើអង្គហេតុទាំងឡាយដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់៣១៩ និង៤៥៦ ដល់៤៩១

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

**៦. មន្ទីរសន្តិសុខវត្តបាណាយ**

- ការសម្លាប់រង្គាល
- ការធ្វើមនុស្សឃាត
- ការធ្វើទារុណកម្ម
- ការដាក់ពន្ធនាគារ
- អំពើអមនុស្សធម៌ផ្សេងៗទៀត
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយទៅលើ ប្រជាជនភូមិភាគបូព៌ា តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងអំពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ ទៅលើកម្មាភិបាលភូមិភាគកណ្តាល និង *"ប្រជាជន១៧ មេសា"* ប្រជាជនដែលមានតួនាទីផ្លូវការនៅក្នុងរដ្ឋាភិបាលមុន និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈបទល្មើសដែលមានចែងអំពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ទាំងឡាយផ្សេងៗទៀត និង
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនាទៅលើជនជាតិចាម តាមរយៈបទល្មើសទាំងឡាយ ដែលមានចែងស្តីអំពីការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត

តាមរយៈការប្រព្រឹត្តិដោយសហាឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំ

ផ្អែកទៅលើអង្គហេតុទាំងឡាយដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់៣១៩ និង៤៩២ ដល់៥៣៦

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

## ៧. ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស

- ការសម្លាប់រង្គាល និង
- ការធ្វើមនុស្សឃាត

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម

សំអាងលើអង្គហេតុទាំងឡាយដែលមានចែងក្នុងកថាខណ្ឌ ១៥៧ ដល់៣១៩ និង៥៣៧ ដល់៥៥៥

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

### ៨. មន្ទីរសន្តិសុខវត្តតាមាក់

- ការធ្វើមនុស្សឃាត
- ការធ្វើទារុណកម្ម
- ការដាក់ពន្ធនាគារ
- អំពើអមនុស្សធម៌ផ្សេងៗទៀត និង
- ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយទៅលើ *"ប្រជាជន១៧ មេសា"* កម្មាភិបាលទាំងឡាយនៅក្នុងភូមិភាគកណ្តាល ក្រុមគ្រួសារទាំងឡាយរបស់ពួកគេ ប្រជាជនភូមិភាគបូព៌ា និង បណ្ឌាសិស្ស និងអ្នករដ្ឋការនានារបស់របបមុន និងក្រុមគ្រួសារទាំងឡាយដែលត្រូវចោទថា មាន *"និន្នាការខាងសីហនុ ឬ លន់ នល់"* តាមរយៈបទល្មើសទាំងឡាយដែលមានចែងអំពីការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ អំពើអមនុស្សធម៌ទាំងឡាយផ្សេងៗទៀត

តាមរយៈការប្រព្រឹត្តិដោយសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំ

ដោយសំអាងទៅលើអង្គហេតុទាំងឡាយដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់ ៣១៩ និង៥៥៦ ដល់៥៨៩

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៥ ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

### ៩. ការរៀបការដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ តំបន់៤១

- អំពើអមនុស្សធម៌ផ្សេងៗទៀត

តាមរយៈការប្រព្រឹត្តិក្នុងឋានៈជាចារីផ្ទាល់ និងតាមរយៈសហឧក្រិដ្ឋកម្មរួម ឬតាមរយៈការធ្វើផែនការ ការបញ្ជា ឬការញុះញង់ ឬតាមរយៈការទទួលខុសត្រូវក្នុងឋានៈជាមេដឹកនាំ

ដោយសំអាងលើអង្គហេតុដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់៣១៩ និង៦៧៨ ដល់៦៩៦

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៥, ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក។

## បទល្មើស៣ៈ

## ការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

- ការធ្វើមនុស្សឃាតដោយគិតទុកជាមុន

ត្រូវបានប្រព្រឹត្តនៅបណ្ដាទីតាំងឧក្រិដ្ឋកម្ម ខាងក្រោមតាមប្រភេទនៃការទទួលខុសត្រូវទាំងឡាយដែលមានចែង៖

១. ទីតាំងពលកម្មដោយបង្ខំទំនប់អន្លង់ជ្រៃ តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី)

២. ទីតាំងសម្លាប់មនុស្សគោកព្រីង តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី)

៣. មន្ទីរសន្តិសុខមិត្តសុប (គ) តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី)

៤. ទួលបេង និងវត្តអង្គញដី តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី) ឬតាមរយៈការធ្វើផែនការ ឬការបញ្ជា

៥. មន្ទីរសន្តិសុខវត្តអូរត្រកួន តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី) ឬការធ្វើផែនការ ឬបញ្ជា

៦. មន្ទីរសន្តិសុខវត្តបាធាយ តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី) ឬការធ្វើផែនការ ឬបញ្ជា

៧. ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី)

៨. មន្ទីរសន្តិសុខវត្តតាមាក់ តាមរយៈការប្រព្រឹត្តិ (ការចូលរួមក្នុងការប្រព្រឹត្តិជាសហចារី) ឬការធ្វើផែនការ ឬបញ្ជា

ដោយផ្អែកទៅលើអង្គហេតុទាំងឡាយដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៥៧ ដល់៥៨៩

ត្រូវដាក់ទណ្ឌកម្មយោងមាត្រា ៣(ថ្មី) ២៩ និង៣៩ នៃច្បាប់ អ.វ.ត.ក និងមាត្រា៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ ភ្នំពេញ

ចៅក្រម Michael Bohlander

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

International Co-Investigating Judge

Co-juge D'instruction international